ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការងារប្រចាំត្រីមាសទីបីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
- ថាច់ គីម : រឿងរ៉ាវដែលមិនចេះសាបសូន្យ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨១ ខែកញ្ញា ឆ្នាំ២០០៦

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ការងារប្រចាំត្រីមាសទីបីរបស់មជ្ឈមណ្ឌល ........................១

**ផ្នែកឯកសារ**

◆ ប៊ុត ហេង ៖ ប្រធានក្រុមធ្វើឯកសារនៅមន្ទីរស-២១ ..........................៣

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្មេចនៅមន្ទីរ ស-២១ .......................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ........................................................................១៧

◆ ចំណាងខក្រិដ្ឋកម្ម មន្ទីរសន្តិសុខភូមិភាគនិរតី ..................................១៩

◆ ដំណើរទស្សនកិច្ចលើកទី៧របស់ប្រជាជន ......................................២៨

◆ ខ្មាំងបដិវត្តន៍ ៖ ទោស និង ទណ្ឌកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ .........២៩

◆ ថាច់ គីមៈ រឿងរ៉ាវដែលមិនចេះសាបសូន្យ ....................................៣៩

**ផ្នែកច្បាប់**

◆ សូមគោរពជូនចៅក្រមជាតិ និងអន្តរជាតិ .......................................៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ នយោបាយអភិរក្សបូជនីយដ្ឋានប្រល័យពូជសាសន៍នៅរ៉ាន់ដា .............៤៨

◆ ក្មេងជំនាន់ក្រោយនិងការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជា .......................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទូតឡាវ ៖ ជាមនុស្សដំបូងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ .................៥៥

◆ អ្នកដែលឃ្លាតឆ្ងាយ ..................................................................៥៩



ពៅ ភិរុន និង ថាច់ គីម ឆ្នាំ១៩៧២



ជនរងគ្រោះនៃរបបខ្មែរក្រហមទស្សនាសារមន្ទីខក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង(ស-២១)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ ដេង ពង្សរ៉ាស៊ី, អៀ ម៉េងទ្រី, ប៊ាង ពីរីន, យិន នាន, ឡុង ដានី, អ៊ុង ថន, ស៊ូហ្សាន អ៊ី យុក, រស់ សំពៅ, ភូ គីមមឿ, ពុធ ធាវី **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ** ៖ បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ** ៖ វ័ន្ន តារាពិដោរ

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការងារប្រចាំត្រីមាសទីបីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ២០០៦

បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមក្នុងពិធីសច្ចាប្រណិធានរបស់ចៅក្រមនិងមន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីខែកក្កដាកន្លងទៅនេះ ហើយបានបន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននេះពេញមួយត្រីមាសទីបីទៀត ។ ក្រៅពីការផ្តល់នូវប្រព័ន្ធទិន្នន័យនៃឯកសារឯកសារថតចម្លងចំនួន៥២៨ដុំ និងឯកសារជាក្រដាសចំនួន១៩.០០០ទំព័រទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវគ្គហ្វឹកហ្វឺនរយៈពេលពីរសប្តាហ៍សម្រាប់ជាបទពិសោធន៍ដល់មន្ត្រីនគរបាលយុត្តិធម៌ចំនួន១២រូបដែលត្រូវទៅបំពេញការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វគ្គហ្វឹកហ្វឺននេះបានណែនាំមន្ត្រីនគរបាលទាំង១២រូប អំពីរចនាសម្ព័ន្ធ នីតិវិធី និងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវគោលគំនិតជាមូលដ្ឋាននៃច្បាប់អន្តរជាតិការបំពេញការងារស៊ើបអង្កេតទ្រង់ទ្រាយធំ យុទ្ធសាស្ត្រនិងបច្ចេកទេសសម្ភាសន៍ត្រឹមត្រូវ និងបញ្ហាដែលទាក់ទិននឹងនីតិវិធីភស្តុតាង ការប្រមូលនិងការប្រគល់ភស្តុតាង ។ ជាងនេះទៀតយើងបានរៀបចំគម្រោងរយៈពេលបីខែក្នុងទិសដៅស្វែងយល់អំពីឥរិយាបថរបស់ប្រជាជនក្នុងការចូលរួមធ្វើជាសាក្សីក្នុងអង្គជំនុំជម្រះវិសាមញ្ញដោយវាយតម្លៃទៅលើការគំរាមកំហែង និងគ្រោះថ្នាក់ដែលទាក់ទិននឹងបុគ្គលទាំងនេះ ស្រាយបំភ្លឺសេចក្តីត្រូវការចាំបាច់របស់សាក្សីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនិងបង្កើតមធ្យោបាយដែលអាចធ្វើទៅបានសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការផ្សេងៗទៀតដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សាក្សី ។

ការងាររៀបចំឯកសាររបស់មជ្ឈមណ្ឌលនៅក្នុងត្រីមាសទីបីរួមមាន ការរបញ្ចូលឯកសារចំនួន១៦.០០០ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ការថតចម្លងឯកសារជាង១០.០០០ទំព័រ ការត្រួតពិនិត្យរាល់ឯកសារប្រវត្តិរូបអតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យចំនួន១៧៨ប្រវត្តិរូប និងការចុះទៅសម្ភាសន៍តាមប្រភេទនៃប្រវត្តិរូប (ឬជាមួយសាច់ញាតិរបស់ជនរងគ្រោះនិងម្ចាស់ប្រវត្តិរូប) នៅក្នុងខេត្តចំនួនពីរគឺ ខេត្តបាត់ដំបងនិងខេត្តបន្ទាយមានជ័យ ។

គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆមាសទីបីនេះ បានអញ្ជើញអ្នកស្រុកអ្នកភូមិនិងមន្ត្រីក្នុងតំបន់ចំនួន១.៥៦៥នាក់ មកទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតបឹងជើងឯក (គម្រោងនេះចាប់ផ្តើមនៅក្នុងខែកុម្ភៈ មានប្រជាជនចំនួនជាង៥ពាន់នាក់បានចូលរួមក្នុងដំណើរទស្សនកិច្ចនេះ) ។ ក្រុមដែលបានធ្វើទស្សនកិច្ចនៅក្នុងខែកក្កដា ក៏បានសម្តែងនូវការគោរពចំពោះឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូសូមេលី នៅគេហដ្ឋានរបស់លោក ។ កិច្ចការផ្សព្វផ្សាយជាសាធារណៈផ្សេងទៀត រួមមានការសម្ភាសន៍មេដឹកនាំសាសនាអ៊ីស្លាមចំនួន៦៨នាក់សម្រាប់ចុះផ្សាយនៅក្នុងទស្សនាវដ្តីចាមដែលគ្រោងនឹងបោះពុម្ពផ្សាយក្នុងពេលខាងមុខនេះ និងការចាប់ផ្តើមការងារទៅលើអត្ថបទមួយសរសេរដោយសមាជិកក្រុមប្រឹក្សាដូនជីដែលនឹងមានចែកកូនសៀវភៅផ្សព្វផ្សាយនៅថ្ងៃ បើកសវនាការដើមឆ្នាំ២០០៧ខាងមុខនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានជ្រើសរើសសិស្សនិងនិស្សិតស្ម័គ្រចិត្តចំនួន២៨ក្រុម (១៧៥នាក់) ជួយចែកឯកសារចំនួន១០.២៣២ច្បាប់ តាមសហគមន៍ចំនួន១៦កន្លែងនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងត្រីមាសទីបីនេះ ការិយាល័យព័ត៌មានសារធារណៈបានទទួលភ្ញៀវឲ្យចូលអានឯកសារចំនួន២១៧០នាក់ ។ ក្នុងចំណោមអ្នកដែលមកអានឯកសារមាន លោក ស៊ុម រិទ្ធី ដែលជាអតីតអ្នកទោសខ្មែរក្រហមនៅក្នុងខេត្តសៀមរាបចន្លោះឆ្នាំ១៩៧៦-៧៩ បានប្រគល់រូបគំនូរចំនួន២២សន្លឹកដែលរៀបរាប់ពីជីវិតរបស់គាត់

នៅក្នុងគុកនិងការធ្វើទារុណកម្មអ្នកទោស មកឲ្យការិយាល័យព័ត៌មានសាធារណៈដើម្បីទុកឯកសារ ។ ការិយាល័យព័ត៌មានសាធារណៈក៏បានទទួលសំបុត្រស្វែងរកគ្រួសារជាច្រើននិងបានរកឃើញព័ត៌មានសមាជិកគ្រួសារដែលបានបាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមការងារការិយាល័យព័ត៌មានសាធារណៈបានរៀបចំ «កម្មវិធីចុះបញ្ចាំងខ្សែភាពយន្តឯកសារ» បានចំនួនមួយលើកនៅក្នុងត្រីមាសទីបីនេះនៅក្នុងខេត្តបាត់ដំបង ដែលនៅទីនោះក្រុមការងារបានបញ្ចាំងខ្សែភាពយន្តឯកសារនិងបានរៀបចំឲ្យមានការពិភាក្សាស្តីអំពីដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងការរំលោភផ្លូវភេទនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ កម្មវិធីចុះបញ្ចាំងខ្សែភាពយន្តឯកសារនិងដំណើរទស្សនកិច្ចរបស់ក្រុមសិស្សនិងនិស្សិតស្ម័គ្រចិត្តទៅកាន់ខេត្តក្រចេះត្រូវបានក្រុមថតរបស់មជ្ឈមណ្ឌលយើងថតសកម្មទាំងអស់នោះទុកជាភាពយន្តឯកសារដែរ ។

នៅក្នុងត្រីមាសទីបីនេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅចំនួនពីរលេខបន្ថែមទៀត ៖ ១) «*ការប៉ះបោរជនជាតិចាម ៖ រឿងរ៉ាវរបស់ជនរងគ្រោះនៅតាមភូមិចាម*» និពន្ធដោយ អ៊ីសា ឧស្មាន រៀបរាប់អំពីរឿងរ៉ាវរបស់ប្រជាជនដែលរស់នៅក្នុងរយៈកាលនៃការប៉ះបោរក្នុងភូមិចាមចំនួន២ប្រឆាំងនឹងខ្មែរក្រហមក្នុងខែតុលា ឆ្នាំ១៩៧៥ ។ ២) «*តុលាការខ្មែរក្រហម*» ដែលពិនិត្យផ្ទៀងផ្ទាត់ដោយលោក ចន ឆធីរអារី ទៅលើបញ្ហា ច្បាប់និងនយោបាយជុំវិញបញ្ហាតុលាការនិងឆ្លើយតបទៅនឹងសំណួរសំខាន់ៗស្តីអំពីដំណើរការទទួលខុសត្រូវ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបោះពុម្ពផ្សាយឯកសារបកប្រែជាភាសាខ្មែរស្តីអំពីដំណើរជីវិតរបស់លោករណៈជិត យឹមស៊ុត ដែលមានចំណងថា «*ដំណើរទៅរកសេរីភាព*» ។ ក្រុមការងារវិទ្យុរបស់មជ្ឈមណ្ឌលយើងបានធ្វើការងារជាមួយសាស្ត្រាចារ្យ ហ្វ្រេង ឆក នៃសកលវិទ្យាល័យ ខុនខ័រឌា ក្នុងទីក្រុងម៉ុង-ជ្រៀល អំពីផែនការសម្រាប់ការផ្សព្វផ្សាយក្នុងថ្ងៃអនាគត ។

នៅថ្ងៃទី១៧ ខែកញ្ញា សិស្សនិងនិស្សិតស្ម័គ្រចិត្តដែលមកពីសកលវិទ្យាល័យក្នុងស្រុកនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១៨០នាក់បានចូលរួមគាំទ្រសន្តិភាពមួយនិងដុតទៀនទាមទារឲ្យបញ្ឈប់ការសម្លាប់មនុស្សនៅក្នុងទីក្រុងដាហ្វ័រនៃប្រទេសស៊ូដង់ ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនពីរនាក់ទើបតែវិលត្រឡប់ពីចក្រភពអង់គ្លេសបន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ។ បុគ្គលិកពីររូបទៀតបានវិលត្រឡប់ទៅសហរដ្ឋអាមេរិកវិញដើម្បីបន្តយកសញ្ញាប័ត្រជាន់ខ្ពស់ និងបីនាក់ទៀតកំពុងតែបន្តថ្នាក់អនុបណ្ឌិតនៅឯប្រទេសស៊ុយអែត ហុងកុង និងចក្រភពអង់គ្លេស ។

កាលពីខែកក្កដា មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ញើសៀវភៅសិក្សា «*ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*» ជូនសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងអប់រំនិងរដ្ឋលេខាធិការនៃក្រសួងអប់រំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពផ្សព្វផ្សាយសៀវភៅនេះចំនួន៣.០០០ក្បាលនិងចែកចាយទូទាំងប្រទេសកម្ពុជា បន្ទាប់ពីទទួលបាននូវការអនុម័តពីគណៈកម្មាធិការការងារនៃទីស្តីគណៈរដ្ឋមន្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបជាមួយអង្គការអន្តរវប្បធម៌ចិត្តសង្គមនៃប្រទេសកម្ពុជាដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការសម្រាប់ថ្ងៃអនាគត និងការហ៊ឹកហ៊ឺនក្នុងគម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម ។ មជ្ឈមណ្ឌលបានចំរាញ់យកវិធីសាស្ត្រល្អសម្រាប់រៀបចំកម្រងសំណួរស្តីពីការប៉ះទង្គិចផ្លូវចិត្តនៃសកលវិទ្យាល័យហាដវឺត និងអង្គការអន្តរវប្បធម៌ចិត្តសង្គមបានបណ្តុះបណ្តាលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១៩នាក់អំពីផលប៉ះពាល់នៃហេតុការណ៍ប៉ះទង្គិចផ្លូវចិត្តមកលើអ្នកធ្វើការជាមួយជនរងគ្រោះនិងរបៀបជួយខ្លួនឯង ។ ជាចុងក្រោយ មជ្ឈមណ្ឌលសម្រាប់ជនរងគ្រោះដោយអំពើទារុណកម្មនៅសហរដ្ឋអាមេរិក បានយល់ព្រមជួយបណ្តុះបណ្តាលបុគ្គលិកនៃគម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្មរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាស្តីអំពីការផ្តល់ប្រឹក្សា និងការវាយតម្លៃឬការព្យាបាលសុខភាពផ្លូវចិត្តក្នុងរយៈពេល៤ឆ្នាំខាងមុខនេះ ។ ព័ត៌មានស្តីអំពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផ្សេងៗទៀតសូមរកតាមរយៈគេហទំព័រ www.dccam.org ។ **ឆាំងយុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ប៊ុត ហេង : ប្រធានក្រុមធ្វើឯកសារនៅមន្ទីរស-២១

ប៊ុត ហេង មានស្រុកកំណើតនៅភូមិទួលសាលា ឃុំស្អាងភ្នំ ស្រុក២០ តំបន់២៥ ខេត្តកណ្តាល ។ ហេង ជាប្រធានក្រុមធ្វើឯកសារនៅមន្ទីរសន្តិសុខស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៤ ខែ៥ ឆ្នាំ១៩៧៨ ដោយសារការធ្វើឲ្យឯកសារប្រឡូកប្រឡល់គ្នា ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចេញពីចម្លើយសារភាពរបស់ ហេង ៖

ហេង ធ្លាប់បានសិក្សាត្រឹមតែថ្នាក់ទី១០ នៅសាលាវត្តស្អាងស្រែ ក្នុងខេត្តកណ្តាល ហើយបួសជាសង្ឃនៅវត្តស្អាងស្រែរយៈពេលមួយឆ្នាំទៀតទើបត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយវិញ ។

នៅខែកក្កដា ឆ្នាំ១៩៧២ ហេង បានស្ម័គ្រចិត្តចូលធ្វើជាយុវជនឈ្លបភូមិ តាមការខទ្ទេសនាមរបស់ ខៀវ ឃុន និង ទុយ គីង (ជាប្រធានភូមិស្អាងស្រែ) ។ ពីរខែក្រោយមក ហេង បានផ្លាស់មកធ្វើឈ្លបនៅឃុំស្អាងភ្នំរយៈពេលមួយខែ ហើយក៏ត្រូវមេឃុំបញ្ជូនឲ្យទៅរៀនបច្ចេកទេសយោធានៅតំបន់២៥រយៈពេល២ខែទៀត ។ បន្ទាប់ពីនោះ អង្គការបានជ្រើសរើស ហេង ទៅធ្វើជាយុទ្ធជននៅក្នុងកងវរយអនុសេនាធំ៦៤ ដើម្បីត្រៀមលក្ខណៈទៅវាយខ្មាំងនៅផ្លូវរថភ្លើង ។ ហេង ចាប់ផ្តើមមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយ រុន ព្រោះ រុន ធ្លាប់ស្នាក់នៅផ្ទះរបស់គាត់កាលពីអំឡុងសង្គ្រាមនៅតំបន់១៥ក្នុងឆ្នាំ១៩៧១ ។ ក្រោយពេលដឹងថា ហេង និង ដុន ចូលបម្រើអង្គការខ្មែរក្រហមក្នុងបំណងរំដោះខ្លួនចេញពីបដិវត្តន៍ រុន អប់រំអ្នកទាំងពីរកុំឲ្យទុកចិត្តអង្គការបដិវត្តន៍និងចូលរួមធ្វើសកម្មភាពបំផ្លាញអង្គការជាមួយខ្លួនវិញ ដោយធ្វើជាជនបង្កប់ស៊ីរូងផ្ទៃក្នុងបក្ស ។

នៅខែកញ្ញា ឆ្នាំ១៩៧២ រុន និង សារ៉ែន បានបញ្ចូល ហេង និង ដុន ភ្ជាប់ខ្សែរសេ.អ៊ី.អា ដោយប្រគល់ភារកិច្ចមួយចំនួនទៅអនុវត្ត ៖ ១) កសាងកម្លាំងនៅក្នុងអង្គភាពឲ្យបានច្រើនដើម្បីបង្កប់ខ្លួនថែមទៀត ២) អុកឡុកនៅតាមសមរភូមិនីមួយៗនិងលាក់ការសម្ងាត់ឲ្យបានខ្ពស់ ៣) ទាក់ទងខ្សែរដទៃទៀតដើម្បីធ្វើសកម្មភាពដោយប្រុងប្រយ័ត្ននិងធ្វើតាមលទ្ធភាពជាក់ស្តែង ។

ហេង និង ដុន បានអប់រំ ឃុន ខេង ឲ្យចូលជាសមាជិកសេ.អ៊ី.អាថែមទៀត ។ អ្នកទាំងពីរបានប្រគល់ភារកិច្ចឲ្យ ឃុន ខេង ទៅបំផុសយុទ្ធជនឲ្យរត់ទៅផ្ទះដើម្បីទប់ទល់ផែនការវាយសម្រុកខ្មាំងបំផុសយុទ្ធជនឲ្យខ្លាចសមរភូមិនិងធ្វើពុតជាឈឺ ហើយពន្យារពេលដឹកស្បៀងទៅសមរភូមិ ។

***សកម្មភាពក្នុងឆ្នាំ១៩៧៣***

នៅខែមករា ឆ្នាំ១៩៧៣ កងធំ(កងអនុសេនាធំ៦៤) របស់ ហេង ត្រូវផ្លាស់មកខាងកើតថ្នល់ ព្រោះអង្គការបញ្ចូលកងអនុសេនាធំ៦៤ទៅក្នុងកងធំ៦១ ,កងធំ៦២និងកងធំ៦៣វិញ ។ ហេង និង ខេង ធ្វើការនៅកងធំ៦១ ចំណែក រុន និង ដុន ត្រូវអង្គការបញ្ជូនទៅធ្វើការក្នុងកងស៊ើបការណ៍វរសេនាតូច១១៦ ហើយ សារ៉ែន មកធ្វើជាលេខាអនុសេនាធំ៦៣ ។ បន្ទាប់ពីរៀបចំអង្គភាពសព្វគ្រប់ហើយ ហេង និង ខេង បានភ្ជាប់ខ្សែរសេ.អ៊ី.អាក្នុងកងធំ៦១ជាមួយ យ៉ុន, ដុក, ថន និង ដេង និងធ្វើសកម្មភាពជាបន្តបន្ទាប់ ។ ហេង និងបក្ខពួកថ្មីនេះ បានបំផុសប្រជាជនមិនឲ្យចូលក្នុងក្រុមការងារប្រវាស់ដៃនិងមិនឲ្យកូនចូលធ្វើបដិវត្តន៍ ។

នៅខែមីនា អង្គការត្រៀមវាយសមរភូមិនៅបន្ទាយស្ពានបាក់ ។ ហេង, យ៉ុន និង ដុក បានចាត់តាំងកម្លាំងសេ.អ៊ី.អាឲ្យធ្វើសកម្មភាពតាមខ្សែរត្រៀមបំផុសឲ្យយុទ្ធជនរត់ចោលជួរដោយយកលេសថាខ្មាំងវ៉ៃបកពីក្រោយ ។ ជាលទ្ធផល កងទ័ពរត់ចោលខ្សែរត្រៀមទាំងអស់ ។ ក្រោយពីធ្វើសកម្មភាពនៅសមរភូមិមុខបានរយៈពេលប៉ុន្មានថ្ងៃ អង្គការបានដកកងធំរបស់ ហេង មកសមរភូមិក្រោយវិញ ដើម្បីចូលរួមធ្វើបុណ្យរៀបចំចាត់តាំងជាវរសេនាធំ២៦៧ ។ នៅសមរភូមិក្រោយ សារ៉ែន បានហៅសមាជិកដែលកសាងបានមកប្រជុំរៀបចំខ្សែរធ្វើសកម្មភាព ។ ហេង និង រ៉ែន មាននាទីជាអ្នកដើរបំផុសសកម្មភាព ។ នៅថ្ងៃបុណ្យ

ហេង និង រ៉ន បានត្រឹមតែបំផុសឲ្យមានភាពសេរីនិងច្របូកច្របល់ក្នុងអង្គភាពប៉ុណ្ណោះ ។

ខែមេសា បក្សរៀបចំផែនការវាយយកផ្លូវជាតិលេខ២១ ។ ហេង និងបក្ខពួកបានអូសបន្លាយពេលវេលាដឹកលេណដ្ឋាន ដុត បំផ្លាញផ្ទះប្រជាជនអស់ជាច្រើនខ្នងនិងលួចគោក្របីរបស់ប្រជាជនមកកាប់ហូប ជាពិសេសក្រុមរបស់ ហេង បានធ្វើឲ្យបែកការណ៍ខ្មែរក្រហមរហូតដល់ទាហានលន់នល់ ផ្ទោងគ្រាប់ចូលទីតាំងទ័ព ។ នៅសមរភូមិទួលក្រសាំងវិញ ហេង បានចូលរួមបំផ្លាញគ្រាប់-៦០អស់មួយឡាំងនិងគ្រាប់អ៊ែកែងពីរឡាំង និងគ្រាប់បេ-៤១ អស់១០គ្រាប់ ។ ក្រោយពីធ្វើសកម្មភាពនៅសមរភូមិបាន ៥ថ្ងៃ អង្គការបានដកកម្លាំងពីសមរភូមិទួលក្រសាំងទៅផ្លូវជាតិលេខ២ វិញ ។ យ៉ុន និង ដុក បានហៅខ្មែរចាត់តាំងទាំងអស់មកប្រជុំ ដើម្បីបង្កើនសកម្មភាពសេ.អ៊ី.អា ។ ហេង និងមិត្តភក្តិកសាងបានកម្លាំង សេ.អ៊ី.អា ពីរនាក់ទៀតគឺ ប៊ូរ និង ម៉េង អ៊ី ។

នៅចុងឆ្នាំ១៩៧៣ អង្គការបានវាយមកដល់ស្ពានព្រែកហូរ ។ ហេង បានបន្ទាក់ដំណើររបស់ទ័ព ក្នុងការដឹកលេណដ្ឋាននិងបំផ្លាញកម្លាំងបិដវត្តន៍ធ្វើឲ្យអង្គការពិបាកដោះស្រាយកម្លាំងចូលខ្មែរក្រហម ។

## សកម្មភាពក្នុងឆ្នាំ១៩៧៤

ហេង ត្រូវបានបញ្ចូលជាសមាជិកយុវកកនៅខែកុម្ភៈ ឆ្នាំ ១៩៧៤ និងជាអ្នកស៊ើបការណ៍នៅវរសេនាតូច១១៦ ដូច្នេះ ការទាក់ទងជាមួយខ្មែរសេ.អ៊ី.អាត្រូវផ្អាកមួយរយៈសិន ។ ពីរខែក្រោយមក ហេង ត្រូវបានចាត់តាំងមកធ្វើជាប្រធានក្រុមនៅក្នុងអនុសេនាធំ៦១ ។ ដូច្នេះ ហេង មានឱកាសបានជួបខ្មែរចាស់ៗឡើងវិញ ។

នៅខែមេសា អង្គការបានឡើងវាយនៅសមរភូមិទន្លេបាសាក់ ។ ហេង និងមិត្តភក្តិដែលនៅសមភូមិក្រោយបានធ្វើសកម្មភាពបំផុសបំផុលយុទ្ធជនឲ្យខ្លាចសមរភូមិ ដើរឆ្កាត់ឆ្វែងធ្វើឲ្យយន្តហោះទម្លាក់គ្រាប់បែកចំទីតាំងទ័ពបណ្តាលឲ្យស្លាប់យុទ្ធជនមួយចំនួន ។ បន្ទាប់មក ហេង ត្រូវអង្គការជ្រើសរើសឲ្យមករៀនវគ្គបច្ចេកទេសនៅវត្តចុងកោះ ហើយឆ្លៀតពេលនោះ ហេង កសាងសមាជិកថ្មីពីរនាក់ទៀតគឺឈ្មោះ ឆេង និង ឈុន ។

នៅខែមិថុនា អង្គការបានចាត់តាំងយុវជន១២នាក់ក្នុងមួយវរសេនាតូចទៅរៀនបច្ចេកទេសនៅម្តុំព្រែកតាមេមក្នុងឃុំព្រែកស្តី ស្រុក១៨ ខេត្តកណ្តាល ។ ក្រុមនេះត្រូវបានបែងចែកជាបីក្រុម ហេង ត្រូវអង្គការចាត់តាំងជាប្រធានកងតូចលេខ១ ដែលមាន សោ ជាអនុប្រធាន និង ភន ជាសមាជិក ចំណែក ឆេង ត្រូវបានចាត់តាំងចូលកងតូចលេខ២ និង ឈុន នៅកងតូចលេខ៣ ។ នៅក្នុងវគ្គរៀនសូត្រ ហេង បានស្គាល់គណៈសាលាឈ្មោះ ម៉ាត់ និង ម៉ាន ដែលជាខ្មែរសេ.អ៊ី.អាដែរ ។ ម៉ាន បានខ្ទេសនាម ហេង ឲ្យស្គាល់ខ្មែរសេ.អ៊ី.អាថ្មីមួយចំនួនដើម្បីចូលរួមក្នុងការអនុវត្តផែនការវាយបក្ស ។ ក្រុមរបស់ ម៉ាត់ បានធ្វើសកម្មភាពបាញ់រះក្នុងភូមិ លួចផលដំណាំរបស់ប្រជាជន និងដើរបំភ្លៃមាគ៌ាបក្សដើម្បីឲ្យប្រជាជនវាយតម្លៃកងទ័ពទាំងមូល ។

នៅខែសីហា អង្គការបានជ្រើសរើសខ្មែររបស់ ហេង ចំនួន ៧រូបមាន ៈ ដូ, នួន, អុល, ទឹម, ឈុន, ឆេង និង វ៉ាង បញ្ចូលទៅក្នុងកងសម្រុក ។ ចំណែក ហេង និងអ្នកទៃទៀតត្រូវនៅរៀនបន្ត នៅទីតាំងថ្មីភូមិកំពង់ស្វាយលើ ។ ហេង និង ម៉ាត់ នៅបន្តធ្វើសកម្មភាពអុកឡុកក្នុងភូមិជាបន្តបន្ទាប់ ។

នៅខែតុលា ហេង, ប៉ែត និង ភន ត្រូវអង្គការជ្រើសរើសឲ្យទៅស៊ើបការណ៍នៅសមរភូមិមុខ ហើយបានជួប រុន និង ដុន នៅតាមផ្លូវ ។ ហេង រាយការណ៍ប្រាប់អ្នកទាំងពីរអំពីខ្មែរថ្មីរបស់ខ្លួន ។ នៅខែ១១ អង្គការបានបញ្ជូនក្រុមស៊ើបការណ៍ទៅពិនិត្យបន្ទាយត្រាំត្រុំដើម្បីរៀបផែនការវាយលុក ។ ហេង ធ្វើគ្រប់សកម្មភាពដើម្បីវាយប្រហារបក្ស នៅពេលចុះទៅពិនិត្យមើលសភាពការណ៍ម្តងៗ ហេង ឈរពិនិត្យមើលតែពីចម្ងាយប៉ុណ្ណោះ ហើយរាយការណ៍ថារួចស្រេចអស់ហើយ ។ ពេលផលិតគ្រាប់បែក ហេង និង ភា រុំកៅស៊ូមិនឲ្យតឹងធ្វើឲ្យគ្រាប់នោះបោកទៅមិនផ្ទុះ និងដាក់ខ្មែរឆេះយឺតនិងខ្លីដើម្បីឲ្យឆាប់ផ្ទុះពេលដាក់គីប ។ ហេង និង ភា បានយកគ្រាប់ល្អៗចំនួន៧ គ្រាប់ទៅបោកសាកល្បង ដើម្បីបំភ័ន្តភ្នែកអង្គការថា គ្រាប់នោះមានគុណភាពល្អ ម្យ៉ាងទៀតដើម្បីធ្វើឲ្យបែកការណ៍ដល់ទាហានលន់នល់ ។ ពេលកំពុងរៀបចំក្បួនទ័ព ស្រាប់តែមានយុទ្ធជនម្នាក់ស្រែកភ្ញាក់សំឡេងឮៗធ្វើឲ្យទាហានលន់នល់ បាញ់រះមកបណ្តាលឲ្យកងទ័ពរបួសនិងស្លាប់យ៉ាងច្រើន ។

នៅខែធ្នូ ហេង ត្រូវរបួសជើងនៅសមរភូមិកៀនស្វាយនិងដេកសម្រាកព្យាបាលនៅពេទ្យអស់រយៈពេលមួយខែកន្លះ ។ ពេលចេញពីពេទ្យវិញ ហេង ចូលក្នុងកងនៅត្រើយខាងលិចទន្លេបាសាក់ ។

## សកម្មភាពនៅឆ្នាំ១៩៧៤

នៅខែមករា អង្គការផ្លាស់ទិសដៅទៅវាយនៅសមរភូមិទន្លេមេគង្គ ។ កងអនុសេនាធំ៣២បានចូលប្រយុទ្ធនៅសមរភូមិវត្តពាមរាំង ។ រុន ត្រូវបានចាត់តាំងឲ្យកាន់ទ័ពថ្មើជើង ។ ហេង, ភា, ផុន និង ឆាយ ទៅពិនិត្យបន្ទាយវត្តព្រែកដាច់ដើម្បីរកវិធីសាស្ត្រពន្យារពេលប្រយុទ្ធ ។ ឆ្លៀតឱកាសនោះ ហេង កសាងកម្លាំងថ្មីបានពីរនាក់គឺ ហៃ និង ឡុត ។ បន្ទាប់មក បឿន បានចាត់តាំង ហេង, ហៃ និង ឡុត ឲ្យទៅជួយកងនារីនៅសមរភូមិវត្តព្រែកទន្សាប់ ។ ពេលទៅដល់សមរភូមិកំពង់ចម្លងទល់មុខអ្នកលឿង អង្គការបានដកកម្លាំងពីកងសម្រុកបញ្ចូលក្នុងកងអនុសេនាធំ៣២ដែលមានកម្មាភិបាល៤នាក់ដូចជា ណៃ, ប្រី, ជន និង សា ។ ក្រោយមក អង្គការចាត់តាំងកងអនុសេនាធំ៣២ឲ្យទៅបោះទីតាំងនៅក្នុងព្រៃនៅបន្ទាយខ្ពប ស្ថិតក្នុងភូមិថ្មី ។ តាមការណែនាំរបស់ បឿន, ហេង បានដឹកនាំយុទ្ធជនដើរសម្រុកទៅសមរភូមិមុខធ្វើឲ្យទាហានម៉ារីនរបស់លន់នល់បាញ់រះនិងផ្លោងគ្រាប់មកលើបណ្តាលឲ្យយុទ្ធជនស្លាប់និងរបួសជាច្រើននាក់ ។ ពេលស៊ើបការណ៍ ហេង មិនបានទៅពិនិត្យជាក់ស្តែងនៅតាមខ្សែត្រៀមដូចមុនទេ គឺគ្រាន់តែសួរតាមខ្សែត្រៀមហើយយកមករាយការណ៍បន្តប៉ុណ្ណោះ ។ ហេង ធ្វើដូច្នេះគឺ ដើម្បីទុកឱកាសឲ្យទាហានលន់នល់រត់ឡើងកប៉ាល់ និងពន្យារពេលដើម្បីឲ្យយុទ្ធជនដើរវង្វេងផ្លូវជាន់មីនស្លាប់ និងរបួសមួយចំនួន ។

នៅខែមីនា អង្គការចាត់តាំងកងអនុសេនាធំ៣២វាយសមរភូមិទន្លេបាសាក់ ។ ណៃ និង បឿន បានប្រជុំជាមួយសមាជិកនៅក្នុងព្រៃដើម្បីធ្វើជីវទស្សន៍អំពើសកម្មភាពការងារ និងពង្រីកសកម្មភាពបំផ្លាញបដិវត្តន៍ ។ ហេង, ហៃ, ឡាយ និងសមាជិកដែលមកពីកងពលលេខ១១ត្រូវបានចាត់តាំងឲ្យទៅពិនិត្យនៅបន្ទាយទួលតាប៉ិន ។ ហេង ដឹកនាំយុទ្ធជនដើរស៊ើបការណ៍ និងជាន់មីនផ្ទុះធ្វើឲ្យបែកការណ៍ ហើយនាំគ្នាប្រឡប់មកក្រោយវិញរាយការណ៍ថាស៊ើបការណ៍បានសម្រេច ។ ស្អែកឡើង យុទ្ធជនមួយក្រុមទៀតទៅស៊ើបការណ៍តាមមុខសញ្ញារបស់ ហេង ហើយជាន់មីនផ្ទុះស្លាប់៣នាក់និងរបួសធ្ងន់មួយចំនួន ។ ហេង ក៏មានជំងឺនោមឈាម ហើយទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេល ២ខែ ។

នៅខែឧសភា បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានរំដោះ ហេង បានចេញពីមន្ទីរពេទ្យត្រឡប់ទៅធ្វើការនៅកងរបស់ខ្លួនវិញ ។ បឿន បានណែនាំឲ្យ ហេង និងខ្សែស.អ៊ី.អាធ្វើសកម្មភាពសេរីមិនស្តាប់ការណែនាំរបស់អង្គការ ហើយបាញ់សម្លាប់ប្រជាជនដែលមិនព្រមចាកចេញពីផ្ទះនិងបំផ្លាញសម្ភារនៅតាមផ្ទះចោលទាំងអស់ ។ ក្រោយពីធ្វើសកម្មភាពនៅផ្សារថ្មីបាន៤-៥ថ្ងៃ អង្គការបានចាត់តាំងកងអនុសេនាធំ៣២ឲ្យទៅការពារនៅអគ្គិសនីផ្សារតូច ។ ហេង, ឆាយ, ផុន និង ជន បានរៀបចំគម្រោងធ្វើសកម្មភាពកាត់ផ្តាច់ចរន្តអគ្គិសនីទាំងមូលនិងដឹកនាំយុទ្ធជនឲ្យទៅបង្កទំនាស់ជាមួយកងទ័ពភូមិភាគពិសេសនិងកងទ័ពភូមិភាគឧត្តររហូតដល់ភ្ជង់កាំភ្លើងដាក់គ្នា ។

នៅខែមិថុនា អង្គការបានដកកម្មាភិបាលក្នុងកងអនុសេនាធំ៣២មករៀននៅសាលាគរុកោសល្យ ។ បន្ទាប់ពីរៀនចប់ អង្គការក៏ផ្លាស់កង៣២ឲ្យមកការពារនៅអគ្គិសនីចាក់អង្រែវិញ ។ ហេង បានចូលរួមធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ជាបន្តបន្ទាប់ដូចជាបំផុសទំនាស់រវាងកម្មករនិងកងទ័ព ធ្វើឲ្យខូចស្បែរម៉ាស៊ីនភ្លើងទាំងអស់ អុកឡុកកម្មករមិនឲ្យដេកនិងចុចព្រឺមេភ្លើងឲ្យរលត់ពេញទីក្រុងភ្នំពេញ ។ បន្ទាប់ពីដាច់ចរន្តអគ្គិសនីភ្លាម អង្គការបានចាត់យុទ្ធជនឲ្យដើរឆែកកម្មករនិងពិនិត្យម៉ាស៊ីនភ្លើង ។ ហេង បានអនុវត្តការណែនាំរបស់ បឿន នាំកម្លាំងឆែកឆេរ ដើរសំឡុតកម្មករដោយគ្មានការអនុញ្ញាតដើម្បីធ្វើឲ្យកម្មករមិនពេញចិត្តនឹងមាគ៌ាដឹកនាំរបស់អង្គការបដិវត្តន៍ ។

ក្នុងខែដដែល នួន បានរៀបចំប្រជុំជាមួយខ្សែស.អ៊ី.អា. នៅមន្ទីរ៧៤៣ ហើយ ម៉ាត់ បានលើកផែនការថ្មីសម្រាប់អនុវត្តន៍ដូចតទៅ ៖ ១) បំផុសរបបស៊ីចុកនិងបំផ្លាញអង្ករដែលអង្គការចែកឲ្យ ២) បំផ្លាញរោងចក្រនិងសម្ភារតាមផ្ទះ និង៣) កសាងកម្លាំងថ្មីនិងពង្រឹងកម្លាំងចាស់ ។ ក្រោយពីប្រជុំចប់ពីរបីថ្ងៃ អង្គការបានដក

ផន, ប៊ុន និង ទឹម ទៅធ្វើការនៅមន្ទីរ៤៣(ក) ។ ហេង និង ឆាយ នៅបន្តធ្វើសកម្មភាពបំផ្លាញស្រូវ ដើរកាត់ខ្សែភ្លើងតាមរោងចក្រ និងបំផ្លាញរោងចក្រផ្សេងៗទៀតដូចជា រោងចក្រធ្វើប៉ែល និង រោងចក្រធ្វើស្បែកជើង ។ ក្នុងរយៈពេលធ្វើសកម្មភាព ហេង និង ឆាយ កសាងកម្លាំងបានយុទ្ធជនពីរនាក់គឺ ខ្វិន និង ផុន ។

នៅខែតុលា អង្គការបានបញ្ចូលកងនិរសារទៅក្នុងវរសេនាតូច១៨៣ដើម្បីធ្វើស្រែប្រាំង ។ ក្រុមរបស់ ហេង មិនទាន់ធ្វើសកម្មភាពអប់រំភ្លាមទេគឺនៅក្តាប់ប្រវត្តិរូបរបស់អ្នកទើបមកថ្មីនោះសិន ។ នៅខែ១២ អង្គការដកកងនិរសាររបស់ ហេង មកនៅមន្ទីរ-៤៣(ក)វិញ ។ ហេង មាននាទីក្តាប់សកម្មភាពរបស់កងនិរសារ និងទាក់ទងជាមួយ ជន និង ប៉ូច ដែលធ្វើការក្នុងកងសួរចម្លើយ ។ អង្គការចាត់តាំងកងនិរសារទៅការពារអ្នកទោសនៅផ្ទះមួយខាងលិចជាប់ផ្ទះម៉ាស៊ីនភ្លើង ។ ហេង បានបញ្ជូនកម្លាំងរបស់ខ្លួនឈ្មោះ ចឹក, ចំរើន និង ធុច ឲ្យទៅការពារអ្នកទោស ។ អ្នកទាំងបីធ្វើជាធ្វេសប្រហែសបណ្តោយឲ្យអ្នកទោសចង-ក លោតជីលួច និយាយគ្នានិងរត់រួចចំនួនពីរលើកធ្វើឲ្យបែកការណ៍សម្ងាត់ដល់អង្គការ ។ ឈ្មោះទាំងបីនេះក្រោយមកត្រូវបានបញ្ជូនទៅស្រែ ។ ហេង បានបន្តទាក់ទងជាមួយ ជន, ប៊ុន និង ឈុន ដើម្បីស៊ើបពីសភាពការណ៍នៅក្នុងក្រសួងសន្តិសុខ ហើយបានដឹងថាសភាពការណ៍នៅក្នុងមន្ទីរនេះមានភាពច្របូកច្របល់អាចបង្កលក្ខណៈឲ្យខ្លួនធ្វើសកម្មភាពដោយស្របច្បាប់ ។ ហេង អប់រំបានយុទ្ធជន៣ នាក់ទៀតគឺ ម៉េត, ឃិក និង ហ៊ីង ឲ្យទៅយាមអ្នកទោសនៅអគារខាងក្រោម ។ ប៉ុន្តែដោយខ្លាចអ្នកទាំងបីធ្វើឲ្យបែកការណ៍ ហេង បានដកអ្នកទាំងបីឲ្យទៅយាមនៅជាន់លើវិញ ។

## សកម្មភាពក្នុងឆ្នាំ១៩៧៦

អង្គការបានជ្រើសរើសកងនិរសារទៅការពារនៅថ្ងៃបុណ្យខួបជ័យជម្នះ១៧មេសា ឆ្នាំ១៩៧៦ នៅស្តាតអូឡាំពិក ។ អង្គការបានណែនាំកងនិរសាររបស់ ហេង ថា ការរៀបចំលើកនេះគឺដើម្បីការពារក្នុងពិធីបុណ្យផងនិងដើម្បីចាប់ខ្មាំងនិងតាមដានខ្មាំងទាក់ទងគ្នាផង ។ ហេង បានណែនាំខ្សែរបស់ខ្លួនឲ្យដើរសេរី ។ ក្នុងរយៈពេលបុណ្យ៣យប់៣ថ្ងៃយុទ្ធជនម្នាក់ៗធ្វើសកម្មភាពសេរីគ្មានអ្នកណាស្តាប់អ្នកណាឡើយ ។ នៅថ្ងៃទី១ នី, នួន និង ថុង បំផ្លាញខ្សែវិទ្យុសម្រាប់រាវមីនមួយគ្រឿងខូច និងនាំគ្នាដើររុករើបេះបោចផ្លែឈើនៅពេលសម្រាកហូបបាយ ។ ហេង ក៏បានជួបផុន, ឆាយ និង នួន នៅទីនោះ ហើយបានរាយការណ៍ប្រាប់អំពីសកម្មភាព និងកម្លាំងដែលទើបកសាងបានថ្មីនៅក្នុងក្រុមនិរសារ ។ នួន, ផុន និង ឆាយ បានជំរុញឲ្យ ហេង និង ជន រកវិធីលបបាញ់សម្លាប់ថ្នាក់ដឹកនាំមន្ទីរសន្តិសុខ៣នាក់មាន ណាត, ឌុច និង ហ៊ រ ដើម្បីចាត់តាំងខ្សែស.អ៊ី.អា.របស់ខ្លួនឲ្យកាន់កាប់មន្ទីរនេះជំនួសវិញ ។

ក្រោយពីពិធីបុណ្យបានបញ្ចប់អង្គការបានបែងចែកកងនិរសារជាពីរក្រុមគឺ ក្រុមសួរចម្លើយនិងក្រុមសម្រាប់ជួយធ្វើស្រែ ។ មេក្រុមសួរចម្លើយមានឈ្មោះ ឈុន ជាប្រធាន ចំណែកក្រុមទៅស្រែចែកជាពីរក្រុម គឺក្រុមរបស់ ហេង និង ជន ។ ក្រោយមក ហេង បានផ្លាស់មកធ្វើការនៅអនុសេនាតូច ហើយបានជួប បឿន និង ភា នៅក្នុងកងពល៧០៣ ។ តាមរយៈ បឿន ហេងបានដឹងថាអង្គការកំពុងបោសសម្អាតជនបង្កប់នៅតំបន់២៥ និងកងពល៧០៣ ។

នៅខែមិថុនា អង្គការបានបញ្ជូនកងនៅទីក្រុងភ្នំពេញឲ្យទៅស្រែ ហើយដកក្រុមនិរសារនិងយុទ្ធជនមកពីសាលាបច្ចេកទេសបញ្ចូលក្នុងកងដើមវិញ ។ នៅខែកក្កដា ហេង មកធ្វើស្រូវប្រាំងនៅបឹងទំពុន ។ ហេង, ជន និង ថុង បានធ្វើសកម្មភាពបំផុសយុទ្ធជនឲ្យធ្វើសកម្មភាពបេះបោចដំណាំផ្លែឈើហូបដោយសេរី និងអប់រំយុវជនពីរនាក់ឈ្មោះ ដុន ក្រុមធ្វើឯកសារ និង ផល ជាយុទ្ធជននៅស្រែខាងផ្នែកចាប់ ទៅបំផ្លាញប្រហុកផ្អកអស់៤ពាង ។ នៅក្នុងខែសីហា ហេង និង ជន កសាងកម្លាំងបាន៤នាក់ទៀត ។

ធ្វើស្រែបានរយៈពេលពីរខែ អង្គការដកកងនិរសារត្រឡប់មកភ្នំពេញ និងរៀបចំកងមួយក្រុមឲ្យទៅយាមនៅគុកពិសេស ។ ហេង និង ថុង ត្រូវបានចាត់តាំងមើលការខុសត្រូវម្នាក់មួយក្រុម ចំណែកអ្នកនៅសល់ត្រូវបញ្ជូនទៅធ្វើការនៅក្រុមចាប់ ។ ថ្ងៃមួយពេល ប៊ុន កំពុងសួរចម្លើយ ចាន់ ចក្រី, ហេង និង ថុង នាំគ្នាច្រៀងលេងពេញក្នុងបន្ទប់និងចាក់ចម្រៀងបន្ថែមដើម្បីរំខានដល់ការសួរចម្លើយនិងពន្យារពេលធ្វើឯកសារដែលអង្គការចង់បាន ។

ប្រហែលមួយសប្តាហ៍បន្ទាប់ អង្គការរៀបចំកងដែលទើបមកពីស្រែជាបីផ្នែក ៖ ១) ផ្នែកសួរចម្លើយមាន ស្វួន និង ម៉ាន

ជាអ្នកទទួលខុសត្រូវ ២) ផ្នែកការពារ និង៣) ផ្នែកចាប់ ដែលមាន ផល ជាអ្នកទទួលខុសត្រូវ ។ ក្រុមសួរចម្លើយមានបួននាក់គឺ ម៉ាន, សួន, ជន និង ប៊ូរ ។ ហេង, ម៉ាន, ជន និង ថុង បានពិភាក្សាគ្នារកវិធីបំផ្លាញចម្លើយអ្នកទោស ១) សហការជាមួយផ្នែកទាំងបីដើម្បីយកជយភណ្ឌផ្តល់ឲ្យមកអ្នកសួរ ២) វៃខ្មាំងឲ្យងាប់ដាច់ចម្លើយ ឬវៃឲ្យទុរន់ទុរាកុំឲ្យឆ្លើយកើត និងសរសេរលែងរួច និង ៣) កសាងកម្លាំងឲ្យបានច្រើន ។

នៅពេលសួរចម្លើយ ហេង និង កាក់ បានវាយខ្មាំងមកពីខាងពាណិជ្ជកម្មស្លាប់អស់ម្នាក់ និងធ្វើទារុណកម្មអ្នកទោសផ្សេងទៀតរហូតមិនអាចផ្តល់ចម្លើយបាន ។ ក្រៅពីនេះ ហេង និងក្រុមការងារបានធ្វើសកម្មភាពវាយខ្មាំងសំខាន់ៗ (មកពីមន្ទីរអគ្គការ, កងពល៩២០ និងភូមិភាគឦសាន) ស្លាប់អស់៣នាក់ ហើយបានធ្វើឲ្យខ្មាំងម្នាក់បោកក្បាលសម្លាប់ខ្លួននិងលោតពីលើអគារមកដី ហើយរត់ចេញពីកន្លែងសួរចម្លើយ ។ ហេង ពន្យារពេលសួរចម្លើយខ្មាំងរហូតដល់ជាងពីរខែ និងធ្វើទារុណកម្មខ្មាំងឲ្យឆ្លើយដាក់បងៗ (ថ្នាក់ដឹកនាំ) ។ លើសពីនេះ ហេង បានទាក់ទងយុវជនផ្នែកចាប់ និងផ្នែកការពារឲ្យធ្វើសកម្មភាពអុកឡុករំខានដល់ការងារអង្គការ ជាពិសេសក្នុងពេលអង្គការកំពុងសួរខ្មាំងសំខាន់ៗ ។

អង្គការជ្រើសរើសកងនិរសារឲ្យទៅការពារក្នុងវគ្គសិក្សានៅស្តាត ។ ខ្មែរសេ.អ៊ី.អា.នៅមន្ទីរស-២១ត្រូវបានជ្រើសរើសឲ្យទៅទាំងអស់ ក្នុងនោះមាន ហេង, ជន, ថុង និង ម៉ាន ជាអ្នកទទួលខុសត្រូវ ។ ហេង បានរាយការណ៍ពីសកម្មភាពរបស់ខ្លួនប្រាប់ ប៉េងឡេង និងទទួលផែនការថ្មីៗ ១) វាយនិងរំដោះអ្នកទោសនៅក្នុងគុកឲ្យអស់ ២) ធ្វើឃាត ឌុច, ហ៊ីរ និងដៃជើង និង ៣) បន្តសកម្មភាពអុកឡុកនិងសម្របខ្លួននៅក្នុងស្ថានភាពលំបាកដើម្បីរង់ចាំស្តាប់ពីខ្មែរនៅខាងក្រៅ ។ ម៉ាន ក៏ឯកភាពតាមផែនការទាំងនោះដែរ ហើយថែមទាំងជំរុញឲ្យ ហេង ធ្វើសកម្មភាពអុកឡុកការរៀនសូត្ររបស់បក្សនៅក្នុងស្តាត ។ ហេង និងមិត្តភក្តិឡើងទៅដំបូលស្តាតធ្វើជាដេញព្រាបដើម្បីរំខានអង្គការដែលកំពុងប្រជុំ ។ ក្រោយពីបានទទួលសេចក្តីណែនាំនេះ ម៉ាន និង ហេង បានហៅមេពួកនិងមេក្រុមរបស់ខ្លួនមកប្រជុំផ្សព្វផ្សាយពីខ្លឹមសារណែនាំរបស់ ម៉ាន ។ ជាលទ្ធផល ក្រុមរបស់ខ្លួនបានដើរផ្តាច់ខ្សែមេក្រូធ្វើឲ្យរអាក់រអួលពេលខទ្ទេសនាម ។ សកម្មភាពនេះធ្វើរហូតដល់ថ្ងៃបិទវគ្គសិក្សា ។

ពេលត្រឡប់មកមន្ទីរស-២១វិញ ម៉ាន, ហេង, ជន និង ថុង មកប្រជុំពិភាក្សាគ្នានិងអនុវត្តតាមផែនការរបស់ ប៉េងឡេង ។ នៅខែធ្នូ អង្គការចាត់តាំង ហេង ឲ្យគ្រប់គ្រងក្រុមជំនួស រុន ហើយ រុន បានណែនាំកម្លាំង៥នាក់មកឲ្យ ហេង ដើម្បីអប់រំបន្ត ។ ហេង បានវាយអ្នកទោសស្រ្តីម្នាក់ស្លាប់មុនពេលទទួលបានចម្លើយ ។ ក្នុងខែដដែល ហេង បានបញ្ជាឲ្យ ឆាយ និង គេង វាយអ្នកទោសម្នាក់ដែលព្យាយាមបំបែកក្បាលឲ្យស្លាប់បន្ទាប់ពីលោតសម្លាប់ខ្លួនពីអគារជាន់ទីបីមិនស្លាប់ ។

## សកម្មភាពក្នុងឆ្នាំ១៩៧៧

នៅខែមករា អង្គការបានបែងចែកកងជាក្រុមតូចៗម្តងទៀត ។ ហេង ក៏ដឹកនាំក្រុមធ្វើសកម្មភាពបន្តទៀត ។ រហូតដល់ខែមិថុនា ហេង បានរៀបការជាមួយយុទ្ធនារីម្នាក់នៅមន្ទីរស-២១ ឈ្មោះ រី ធ្វើពេទ្យព្យាបាលអ្នកទោសនារី ហើយបានកូនស្រីមួយ ។ ក្រោយមក រី បានសុំអង្គការដូរទៅធ្វើការនៅកន្លែងមិត្តអ្នកសួរចម្លើយវិញ ដើម្បីងាយស្រួលរាយការណ៍ឲ្យ ហេង ។

អង្គការ រៀបចំក្រុមអ្នកសួរចម្លើយជាបីក្រុម ហេង ទទួលបន្ទុកខាងក្រុមឯកសារដែលមាន ទិត និងក្រុមរបស់ ណាន ខាងផ្ទៀងឯកសារ ហើយ នន ទទួលបន្ទុកខាងក្រុមអង្កៀម ។ បន្ទាប់មក ហេង បានទទួលបញ្ជាឲ្យយក សាន លេខាកងពលមកពីភូមិភាគពាយ័ព្យទៅសួរចម្លើយ ។ ហេង បានបំភ្លៃឯកសារចម្លើយរបស់ សាន ឲ្យទាក់ទងនឹង ទីវ អុល ។ រាល់បញ្ហាដែលកើតឡើងនៅក្នុងក្រុម ហេង មិនដែលប្រជុំដោះស្រាយទេ បណ្តោយឲ្យយុទ្ធជនសេរីពេញក្នុងមន្ទីរ ។ ហេង ធ្វើយ៉ាងនេះគឺដើម្បីឲ្យ ទិត និង ណាន មានកំហឹងនិងទំនាស់ជាមួយខ្លួនដើម្បីឲ្យអង្គការដកអ្នកទាំងពីរចេញ ។

ក្រោយមកអង្គការចាប់បាន ជន ក្នុងពេលធ្វើសម្មភាពអុកឡុក ។ ហេង និង ឈុន ភ័យខ្លាចជាខ្លាំងព្រោះខ្លាច ជន រាយការណ៍រាលដាលដល់ខ្លួន ។ ប៉ុន្តែជាសកម្មភាព ហេង នៅតែបន្តទាក់ទង ប៊ិន និង ថុង នៅផ្នែកសរុបឯកសារឲ្យពង្រីកការសម្ងាត់ និងធ្វើសកម្មភាពតាមការដាក់ស្នែង ។ ក្រៅពីនោះ ហេង ទាក់ទង ដូរ

នៅក្រុមត្រជាក់អំពីផែនការដែលត្រូវធ្វើបន្តទៀត ។

បន្ទាប់មក អង្គការចាត់តាំងក្រុមឯកសារឲ្យទៅរៀបចំផ្ទះលេខ២៣ធ្វើឯកសារ ។ ហេង បាន ចាត់តាំង ឈុន, កាក់ និង ហៀង ធ្វើសកម្មភាពបំផ្លាញឯកសារអស់ជាច្រើនរហូតដល់មិនអាចចាប់ខ្មាំងបាន ។ នៅពេលទំនេរ ហេង តែងទៅជួបប្រពន្ធដើម្បីក្តាប់សភាពការណ៍ខាងផ្នែកពេទ្យផង ។ នៅខែ១០ ហេង បានច្បាប់អនុញ្ញាតឲ្យទៅលេងផ្ទះ ។ ឆ្លៀតពេលត្រឡប់ពីស្រុកកំណើតវិញ ហេង បានប្រាប់ ទ្រី ថា អង្គការបានចាប់ឪពុកខ្លួនធ្វើឲ្យ ទ្រី មានគោលជំហរមិននឹងន ហើយចាប់ផ្តើមបង្កទំនាស់នៅក្នុងក្រុមការពារ ។

នៅខែវិច្ឆិកា ហេង និង ទិត បានទៅរៀនវគ្គនយោបាយនៅស្តាតអូឡាំពិក ។ កាក់ ទទួលខុសត្រូវរួមនៅក្នុងក្រុម ។ នៅទីនោះ ហេង បានជួប បឿន, ឆាយ និង ដុក ពិភាក្សាគ្នាក្នុងការអនុវត្តផែនការពីរ ១) រកវិធីសម្លាប់ក្បាលម៉ាស៊ីនដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដើម្បីចាត់តាំងរដ្ឋអំណាចថ្មី សំខាន់គឺដណ្តើមក្រសួងសន្តិបាលដែលមាន ឌុច និង ហ៊ីរ ជាប្រធាន ២) វាយខ្មាំងឲ្យងាប់ដាច់ចម្លើយដើម្បីកុំឲ្យអង្គការចាប់ខ្សែសេ.អ៊ី.អា.បានតទៅទៀត ។ ក្រោយពីបញ្ចប់វគ្គ ហេង ត្រឡប់មកមន្ទីរស-២១ វិញ ហើយបានទទួលដំណឹងតាមរយៈប្រពន្ធថាអង្គការកំពុងចាប់ខ្សែពេទ្យ១៧ និងអ្នកដែលមានឈ្មោះពាក់ព័ន្ធ ។ មិនយូរប៉ុន្មាន អឿន ត្រូវបានចាប់ខ្លួនពីបទខូចសីលធម៌ជាមួយនារី ម៉េន ។

## សកម្មភាពឆ្នាំ១៩៧៨

នៅខែកុម្ភៈ អង្គការបានចាប់ខ្លួន កាក់ ។ ចំណែក ហេង នៅតែ បន្តធ្វើសកម្មភាពអុកឡុកទៅក្នុងក្រុមធ្វើឯកសារដោយបញ្ចូលយុទ្ធជននៅក្រុមក្តៅចំនួន៣នាក់មាន សេង, ដេន និង ដុន ដើម្បីឲ្យការធ្វើឯកសារច្របូកច្របល់ ។ ក្នុងរយៈពេលពីរ-បីខែនេះ ហេង និងមិត្តភក្តិបានធ្វើឲ្យឯកសារកកស្ទះជាប់រហូត ។ ហេង ចាត់តាំងឲ្យ ឆាយ សួរចម្លើយ រស់ សួន ដែលចាប់មកពីតំបន់២៥និងលួចឯកសារសារភាពចំនួន៣សន្លឹក ដែល សួន បានសរសេរប៉ះពាល់ដល់ខ្សែសេ.អ៊ី.អា ហើយធ្វើជារាយការណ៍ទៅថ្នាក់លើថា បាត់ឯកសារ៣សន្លឹក ។ រយៈពេល៤ថ្ងៃនៅតែរកឯកសារមិនឃើញ ហេង ក៏បានរាយការណ៍ទៅ ហ៊ីរ ថាក្រុមការពារជាអ្នកលួច ។ ដោយឃើញសភាពការណ៍មិនស្រួល ហេង បានចាត់តាំងឲ្យ ឆាយ ដុតឯកសារទាំង៣សន្លឹកនោះចោល ។ ប៉ុន្មានថ្ងៃក្រោយមក ឆាយ ត្រូវអង្គការចាប់ខ្លួន ។ ហេង ព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនយ៉ាងខ្លាំង ហើយបានផ្តែផ្តាំ ទ្រី ឲ្យជួយមើលប្រពន្ធនិងកូនរបស់ខ្លួនផងប្រសិនបើអង្គការចាប់ខ្លួនគាត់ ។

ដោយព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួន ហេង លែងគិតគូរនិងដោះស្រាយបញ្ហាច្របូកច្របល់ឯកសារនិងបញ្ហាស្មុគស្មាញនៅក្នុងក្រុមទៀតហើយ ។ ក្រោយមក ហ៊ីរ បានហៅទាំងអស់គ្នាទៅប្រជុំនៅសាលានិងលើកឡើងពីរឿងបាត់ឯកសារ៣សន្លឹក ។ ហេង ដឹងច្បាស់ថា ហ៊ីរ សង្ស័យមកលើខ្លួន ។ នៅល្ងាច ថ្ងៃទី៤ ខែ៥ ឆ្នាំ១៩៧៨ ហេង ត្រូវអង្គការចាប់ខ្លួន ។

## អំពីក្រុមគ្រួសារ

ឪពុកឈ្មោះ តេង ប៊ុត និងម្តាយឈ្មោះ អំ ដួង និងបងប្អូន៦នាក់ (ប្រុស៥ស្រី១) ។ ក្រោយថ្ងៃរំដោះ១៧មេសា ១៩៧៥ ក្រុមគ្រួសាររបស់ ហេង រស់នៅក្នុងភូមិកំណើតដដែល មានតែ ហេង ម្នាក់ប៉ុណ្ណោះដែលចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។

## ចម្លើយសារភាពនិងការចាប់ខ្លួន

ហេង ត្រូវអង្គការឃុំខ្លួននៅមន្ទីរស-២១ នៅផ្ទះ៣២ បន្ទប់ធំ១ បន្ទប់តូច១៤ និងចាប់ផ្តើមសរសេរចម្លើយសារភាពចាប់ពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៧៨ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៨ ។ នៅក្នុងចម្លើយសារភាព ហេង សរសេរពីប្រវត្តិសកម្មភាពក្បត់របស់ខ្លួន និងឈ្មោះអ្នកពាក់ព័ន្ធចំនួន១១៦នាក់ ។ នៅក្នុងបញ្ជីជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ហេង ត្រូវបានកម្ទេចនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៨ ។

**ណាយ សុផារី**

## ពាក្យស្លោកខ្មែរក្រហម

- **ស្វះស្វែងអនុវត្តន៍កម្មវិធីនយោបាយ និងលក្ខន្តិកៈរបស់ "សម្ព័ន្ធយុវកក"។** (សៀវភៅកំណត់ហេតុលេខ ០៧៧)
- **សម្ព័ន្ធយុវកកៈ សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា។** (កំណត់ហេតុលេខ ០៦៩)

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ឯកឧត្តម ម៉ោញ សាផាន, ស្ទួ ប៊ុនស៊ូ និងបុគ្គលិកស្ម័គ្រចិត្តផ្នែកច្បាប់ នៅក្នុងវគ្គហ្វឹកហ្វឺនផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា



ក្រុមនិស្សិតដែលបានចូលរួមវគ្គហ្វឹកហ្វឺនផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៨៩១ | អៀង សីហា | កម្មករចាស់ | រទេះភ្លើង | ១៦-១២-៧៦ | ២០-៦-៧៧ |
| ២៨៩២ | អួង សុកឆេង (ស្រី) | កូន ចៅ អួង | ឃោសនាការ | ១៦-៦-៧៧ | ២០-៦-៧៧ |
| ២៨៩៣ | អ៊ន់ សៃ ហៅ ខុស (ស្រី) | មើលកុមារ | កសិកម្មរដ្ឋ | ៣-៤-៧៧ | ២០-៦-៧៧ |
| ២៨៩៤ | តូ នឹម | សមាជិក | វរសេនាធំ៣៧៧ | ១៣-៣-៧៧ | ២០-៦-៧៧ |
| ២៨៩៥ | ឃុត ហេង ហៅ ណៃ | លេខា | វរសេនាធំ៣៧៧ | ១៧-២-៧៧ | ២០-៦-៧៧ |
| ២៨៩៦ | ហាប់ ខន | យុទ្ធជន | វរសេនាធំ៣៧៧ | ២៦-៥-៧៧ | ២០-៦-៧៧ |
| ២៨៩៧ | ជុំ ហូ | សេដ្ឋកិច្ច | វរសេនាធំ៣៧៧ | ៧-៣-៧៧ | ២០-៦-៧៧ |
| ២៨៩៨ | ប្រុញ ជឿន | យុទ្ធជន | វរសេនាធំ៣៧៧ | ៦-៣-៧៧ | ២០-៦-៧៧ |
| ២៨៩៩ | ចៅ រ៉ូ | ប្រជាជន | កម្ពុជាក្រោម | ?-?-៧៦ | ២០-៦-៧៧ |
| ២៩០០ | ចៅ ម៉ាត់ ហៅ ដារ៉ា | ប្រជាជន | កម្ពុជាក្រោម | ១២-១២-៧៦ | ២០-៦-៧៧ |
| ២៩០១ | តាំង ខែត ហៅ ខាន់ | ប្រធានកសិកម្ម | ភូមិភាគបស្ចិម | ១៨-១០-៧៦ | ២០-៦-៧៧ |
| ២៩០២ | ទីវ សូផាន ហៅ ជា ហៅ សា | លេខាស្រុក | ភូមិភាគបស្ចិម | ២៤-៣-៧៧ | ២០-៦-៧៧ |
| ២៩០៣ | ឡុង លំហម ហៅ ចាន់ (ស្រី) | ប្រធានសហករណ៍ | ភូមិភាគបស្ចិម | ២៩-៤-៧៧ | ២០-៦-៧៧ |
| ២៩០៤ | ដាំ រើយ ហៅ រ៉ុង | ប្រជាជន | ភូមិភាគពាយ័ព្យ | ២១-៤-៧៧ | ២០-៦-៧៧ |
| ២៩០៥ | កែ សំ | ប្រជាជន | ភូមិភាគពាយ័ព្យ | ១-៦-៧៧ | ២០-៦-៧៧ |
| ២៩០៦ | យង់ ពៅ | ប្រធានសន្តិសុខ | តំបន់១០៦ | ១-៣-៧៧ | ២០-៦-៧៧ |
| ២៩០៧ | ជន ពូ | ប្រជាជន | តំបន់១០៦ | ២-៣-៧៧ | ២០-៦-៧៧ |
| ២៩០៨ | ធីង តូ ហៅ ធា | យុទ្ធជន | តំបន់១០៦ | ៥-៣-៧៧ | ២០-៦-៧៧ |
| ២៩០៩ | ពុំ ឡៃ ហៅ ឡុត | មេក្រុម | តំបន់១០៦ | ៤-៣-៧៧ | ២០-៦-៧៧ |
| ២៩១០ | ម៉ម ឃុត ហៅ កង | ប្រធានឃុំ | តំបន់១០៦ | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩១១ | ញ៉ែក សុក | ប្រធានឃុំ | តំបន់១០៦ | ៥-៣-៧៧ | ២០-៦-៧៧ |
| ២៩១២ | ប៉ា ប៊ុតថា | យុទ្ធជន | តំបន់១០៦ | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩១៣ | សុន ថៃ | មេក្រុម | តំបន់១០៦ | ៤-៣-៧៧ | ២០-៦-៧៧ |
| ២៩១៤ | ភិន ឡុន | យុទ្ធជន | តំបន់១០៦ | ៤-៣-៧៧ | ២០-៦-៧៧ |
| ២៩១៥ | ស៊ិន គង់ ហៅ រិន | ប្រធានកងតូច | តំបន់១០៦ | ៧-៣-៧៧ | ២០-៦-៧៧ |
| ២៩១៦ | ជិប អោក ហៅ អៀង | អនុក្រុម | តំបន់១០៦ | ៦-៣-៧៧ | ២០-៦-៧៧ |
| ២៩១៧ | គីម ឡុង | យុទ្ធជន | តំបន់១០៦ | ៧-៣-៧៧ | ២០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៩១៨ | ធី វ៉ាន់ថុល ហៅ ថុល | យុទ្ធជន | តំបន់១០៦ | ៣-៣-៧៧ | ២០-៦-៧៧ |
| ២៩១៩ | ឆេង មឿន ហៅ សេង | យុទ្ធជន | តំបន់១០៦ | ២៨-១០-៧៦ | ២០-៦-៧៧ |
| ២៩២០ | ជា សុផ | យុទ្ធជន | តំបន់១០៦ | ៧-៣-៧៧ | ២០-៦-៧៧ |
| ២៩២១ | ឃ្វី គង់ ហៅ រុន | មេពួក | តំបន់១០៦ | ៣-៤-៧៧ | ២០-៦-៧៧ |
| ២៩២២ | ហ៊ុយ សួង ហៅ ជឿន (ស្រី) | ប្រធានកាត់ដេរ | តំបន់១០៦ | ៦-៣-៧៧ | ២០-៦-៧៧ |
| ២៩២៣ | សុក ហ៊ាង ហៅ ស៊ីម (ស្រី) | ប្រធានរោងចក្រ | តំបន់១០៦ | ? | ២០-៦-៧៧ |
| ២៩២៤ | សួស ភឹម ហៅ ផាន់ | កម្មករចាស់ | អគ្គិសនីទី១ | ?-១២-៧៥ | ២០-៦-៧៧ |
| ២៩២៥ | ឡុង ប៊ុនគឹម | ក្តាប់កុមារ | ស៊ីងមានជ័យ | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩២៦ | យី គឹមឈន | កម្មករថ្មី | សាធារណការ | ?-៣-៧៧ | ២០-៦-៧៧ |
| ២៩២៧ | អួន សុខូ ហៅ ខំ | សេដ្ឋកិច្ច | សាធារណការ | ១២-៣-៧៧ | ២០-៦-៧៧ |
| ២៩២៨ | អាំង បានហុក | កម្មករថ្មី | សាធារណការ | ១១-៣-៧៧ | ២០-៦-៧៧ |
| ២៩២៩ | ម៉ៅ ស៊ាង | កម្មករចាស់ | អគ្គិសនីទី២ | ១-៣-៧៧ | ២០-៦-៧៧ |
| ២៩៣០ | ខៀវ សៀងថៃ | មេក្រុម | អគ្គិសនីទី១ | ៤២-៤-១៦(?) | ២០-៦-៧៧ |
| ២៩៣១ | អ៊ុម ចំរើន ហៅ ខ្មៅ | ជួសជុលម៉ាស៊ីន | អគ្គិសនីទី២ | ១១-៣-៧៧ | ២០-៦-៧៧ |
| ២៩៣២ | ស៊ិន ស៊ីថាវ | មេក្រុម | អគ្គិសនីទី១ | ១៥-៣-៧៧ | ២០-៦-៧៧ |
| ២៩៣៣ | ម៉ៃ លុន | កម្មករថ្មី | អគ្គិសនីទី១ | ១១-៣-៧៧ | ២០-៦-៧៧ |
| ២៩៣៤ | ម៉ុល ផុរិ | មេក្រុម | សាធារណការ | ១១-៣-៧៧ | ២០-៦-៧៧ |
| ២៩៣៥ | គង់ ប៊ុនធឿន (ស្រី) | មេក្រុម | អគ្គិសនីទី២ | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩៣៦ | ប្រាក់ សាវ៉ុន ហៅ វ៉ុន (ស្រី) | ប្រពន្ធ ម៉ៅ រុន | ស៊ីងមានជ័យ | ១៣-៦-៧៧ | ២០-៦-៧៧ |
| ២៩៣៧ | សុភ័ណ នារី ហៅ ភាព (ស្រី) | ប្រពន្ធ វៀង | ស៊ីងមានជ័យ | ១១-៣-៧៧ | ២០-៦-៧៧ |
| ២៩៣៨ | តាន់ ជន្សាយ (ស្រី) | ម្ចាស់ពេជ្រ | អគ្គិសនីទី១ | ១០-៤-៧៧ | ២០-៦-៧៧ |
| ២៩៣៩ | ហឹម វ៉េន ហៅ អេម (ស្រី) | ពេទ្យ | សាធារណការ | ១៦-៤-៧៧ | ២០-៦-៧៧ |
| ២៩៤០ | ឈុក សុកងួន ហៅ សោម | គណៈដៃ | ដែកំពង់សោម | ១៩-១០-៧៦ | ២០-៦-៧៧ |
| ២៩៤១ | ស្រេង ស្រ៊ាង | ប្រធានកងហា | ដែកំពង់សោម | ១-៦-៧៧ | ២០-៦-៧៧ |
| ២៩៤២ | ចាន់ នឿន ហៅ យឿន | យុទ្ធជន | ដែកំពង់សោម | ១៥-៤-៧៧ | ២០-៦-៧៧ |
| ២៩៤៣ | យ៉ែម សុក | យុទ្ធជន | ដឹកជើងទឹក | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩៤៤ | ឃ្លាំង អ៊ាន ហៅ ចិត្ត | យុទ្ធជន | ដឹកជើងទឹក | ២១-៥-៧៧ | ២០-៦-៧៧ |
| ២៩៤៥ | នន់ លួន ហៅ ចៅ | មេក្រុម | ដឹកជើងទឹក | ២១-៥-៧៧ | ២០-៦-៧៧ |
| ២៩៤៦ | លី សំបាត់ ហៅ ថុល | យុទ្ធជន | ដឹកជើងទឹក | ១៥-៤-៧៧ | ២០-៦-៧៧ |
| ២៩៤៧ | ហង់ ម៉ៅ | យុទ្ធជន | ដឹកជើងទឹក | ១៤-៤-៧៧ | ២០-៦-៧៧ |
| ២៩៤៨ | បាត់ រុន ហៅ ខន | យុទ្ធជន | ដឹកជើងទឹក | ១៤-៤-៧៧ | ២០-៦-៧៧ |

**(នៅមានត)**

# គុកខ្មែរក្រហម

## ខេត្តកំពង់ស្ពឺ

### ស្រុកបសេដ្ឋ

#### ១) គុកសន្តិសុខភូមិខ្ទឹប

មន្ទីរសន្តិសុខភូមិខ្ទឹបត្រូវខ្មែរក្រហមបង្កើតនៅឆ្នាំ១៩៧២ ដោយមានឈ្មោះ ឆែម ជាប្រធានគ្រប់គ្រង ។ ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរសន្តិសុខភូមិខ្ទឹប ភាគច្រើនជាទាហានរបបសាធារណរដ្ឋខ្មែរដែលចាប់បាននៅពេលចាញ់សង្គ្រាម ។ ប្រជាជនស្លូតត្រង់និងព្រះសង្ឃជាច្រើនអង្គក៏ត្រូវឈ្លបចាប់បញ្ជូនខ្លួនមកកាន់មន្ទីរសន្តិសុខនៅភូមិខ្ទឹបដែរ ដោយចោទប្រកាន់ថាបានចូលដៃជើងជាមួយខ្មាំងនិងជាភ្នាក់ងារសេ.អ៊ី.អា. ។ ឈ្លើយសឹកទាំងនេះបានត្រូវនាំយកទៅសម្លាប់នៅទីតាំងមួយចម្ងាយពីមន្ទីរសន្តិសុខភូមិខ្ទឹបប៉ែកខាងលិចប្រហែល១០០ម៉ែត្រ ។

នៅឆ្នាំ១៩៧៥ មន្ទីរសន្តិសុខនេះត្រូវខ្មែរក្រហមបោះបង់ចោល ។ កុយ សៅ អាយុ ៧២ឆ្នាំ និង ចាន់ ឈុំ អាយុ៤៩ឆ្នាំ រស់នៅភូមិខ្ទឹប ឃុំបសេដ្ឋ បាននិយាយប្រាប់ថា ក្រោយឆ្នាំ១៩៧៥មន្ទីរសន្តិសុខភូមិខ្ទឹបត្រូវខ្មែរក្រហមប្រែក្លាយទៅជាទីតាំងសម្លាប់មនុស្សវិញ ។ ជនរងគ្រោះដែលត្រូវកងឈ្លបយកទៅសម្លាប់នៅទីតាំងនោះ ជាប្រជាជនជម្លៀសមកពីទីក្រុងខ្លះ និងប្រជាជនមូលដ្ឋានខ្លះ ។ ប្រជាជនទាំងនេះត្រូវកងឈ្លបយកទៅសម្លាប់នៅកន្លែងជាអតីតមន្ទីរសន្តិសុខភូមិខ្ទឹប ។ ជនរងគ្រោះប្រមាណពី៤០០ទៅ៥០០នាក់ ត្រូវខ្មែរក្រហមសម្លាប់ដាក់ក្នុងរណ្តៅចំនួនពី១០០ទៅ១៥០រណ្តៅ ។

#### ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរសន្តិសុខភូមិខ្ទឹប មានទីតាំងស្ថិតនៅភូមិចម្ការទួល ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ និងមានចម្ងាយប្រហែល ២ គីឡូម៉ែត្រប៉ែកខាងលិចសាលាស្រុកបសេដ្ឋ ។

**ស្ថិតិ** ៖ ជនរងគ្រោះជាប្រជាជនជម្លៀស និងមូលដ្ឋានដែលជាប់ឃុំឃាំងនៅទីតាំងមន្ទីរសន្តិសុខនេះប្រមាណពី៤០០ទៅ៥០០នាក់ ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ដាក់ក្នុងរណ្តៅប្រហែលពី១០០ទៅ១៥០ ។

### ស្រុកច្បារមន

#### ២) មន្ទីរសន្តិសុខវត្តអំពែភ្នំ

មន្ទីរសន្តិសុខវត្តអំពែភ្នំមានទីតាំងស្ថិតនៅក្នុងព្រះវិហារវត្តអំពែភ្នំ ។ ព្រះពុទ្ធប្បដិមាធំត្រូវខ្មែរក្រហមបាញ់ផ្តាច់ព្រះកេស ។ ព្រះភ្នែនរបស់ព្រះអង្គត្រូវកងឈ្លបយកធ្វើជាកន្លែងធ្វើទារុណកម្មនិងសម្លាប់អ្នកទោសក្នុងករណីដែលអ្នកទោសតមាត់ពេលសួរចម្លើយម្តងៗ ។ អ្នកទោសភាគច្រើនដែលកងសន្តិសុខបញ្ជូនមកកាន់ទីតាំងវត្តអំពែភ្នំគឺប្រមូលមកពីតំបន់៥៥ ខេត្តតាកែវនិងអ្នកមូលដ្ឋានខ្លះ ។

ក្រោយថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ព្រះវិហារនេះ បន្សល់ទុកនូវឈាមជិតដាមពាសពេញកម្រាលឥដ្ឋនៅឡើយ ។ ចំណែកលើព្រះភ្នែនព្រះពុទ្ធប្បដិមាវិញ មានសុទ្ធតែឈាមខាប់ដក់នៅខាងក្នុង ។ អ៊ុន ហាក់ អាយុ៧២ឆ្នាំ រស់នៅភូមិអំពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមនបានប្រាប់ថា គាត់ឃើញមានឈាមពាសពេញលើកម្រាលឥដ្ឋក្នុងព្រះវិហារវត្តអំពែភ្នំ ពេលដែលគាត់ចូលទៅដល់ទីនោះមុនគេកាលពីឆ្នាំ១៩៧៩ ។ គំនូរនៅតាមជញ្ជាំងព្រះវិហារត្រូវបានលុបដោយទឹកកំបោរសគ្មានសល់ចន្លោះណាមួយឡើយ ។ ប៉ុន្តែអ្វីដែលចម្លែក គឺស្នាមឈាមក្រហមក្រមៅ ដែលខ្ទាតប្រឡាក់ជាប់ជញ្ជាំង បានជ្រាបចេញប្រគេកប្រគាកពីលើកំបោរសនោះ ។ ចាន់ ម៉ៃ អាយុ៦៥ឆ្នាំ រស់នៅភូមិអំពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមនក៏បានឃើញស្នាមឈាមប្រឡាក់ជញ្ជាំងព្រះវិហារដោយផ្ទាល់ភ្នែកដែរ ពេលដែលគាត់ត្រឡប់មកស្រុកកំណើតវិញនៅឆ្នាំ១៩៧៩ ។ ក្រៅពីឈាមដែលប្រឡាក់ជញ្ជាំង ម៉ៃ បានឃើញសាកសពហើមរលួយបួនប្រាំនាក់ទៀត នៅលើកម្រាលឥដ្ឋក្នុងព្រះវិហារវត្តអំពែភ្នំនេះ ។ ព្រះពុទ្ធប្បដិមាភាគច្រើនត្រូវកងឈ្លបសែងចេញពីព្រះវិហារយកទៅគរវែងចោលក្នុងស្រះទឹកក្បែរនោះ លើកលែងតែរូបប្បដិមាពីរ-បីប៉ុណ្ណោះ ដែលខ្មែរក្រហមទុកសម្រាប់ប្រើជាឧប-

ករណ៍ធ្វើទារុណកម្ម ។ អ្នកទោសដែលជាប់នៅមន្ទីរឃុំឃាំងនេះ គ្មាននរណាម្នាក់បានរួចខ្លួនឡើយ ។

ឆាយ ចេង អាយុ៧០ឆ្នាំ ជាអាចារ្យវត្តអំពែភ្នំ បាននិយាយពីកម្មាភិបាលខ្មែរក្រហមដែលត្រូវអង្គការចាត់តាំងឲ្យមកធ្វើការនៅក្នុងមន្ទីរសន្តិសុខនេះថា អ្នកទាំងនោះសុទ្ធតែជាយុទ្ធជនពិការ ដូចជាកម្មាភិបាលទទួលផ្នែកយាមអ្នកទោស ផ្នែកធ្វើទារុណកម្ម ផ្នែកផលិតថ្នាំ "អាចម៍ទន្សាយ" និងផ្នែកដាំស្ល ជាដើម ។ ចេង បានបន្ថែមថា នៅប៉ែកខាងក្រោយព្រះវិហារប្រមាណ៥០ម៉ែត្រ មានកន្លែងធ្វើទារុណកម្មអ្នកទោសមួយកន្លែងទៀត ។ ខ្មែរក្រហមបានដំដែកគោលបួនដើមជាប់គល់ដើមចាន់យ៉ាំងធំមួយដែលដុះក្នុងទីធ្លាវត្តទុកសម្រាប់ធ្វើទារុណកម្មអ្នកទោស ។

នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមដែលគ្រប់គ្រងនៅវត្តអំពែភ្នំបានរត់ចោលទីតាំងអស់ ។ ព្រះវិហារវត្តអំពែភ្នំ ត្រូវខូចខាតយ៉ាងដំណំ ។ រហូតមកដល់សព្វថ្ងៃនេះ ព្រះពុទ្ធបដិមាដែលខ្មែរក្រហមបំផ្លាញនិងលើកគ្រវែងចោលទៅក្នុងស្រះទឹក ត្រូវប្រជាជនស្រង់យកមកដាក់តម្កល់នៅកន្លែងដើមវិញ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ វត្តអំពែភ្នំស្ថិតនៅក្នុងភូមិអំពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។

**ស្ថិតិ** ៖ ព្រះវិហារវត្តអំពែភ្នំ ត្រូវខ្មែរក្រហមជ្រើសរើសធ្វើជាមន្ទីឃុំឃាំងអ្នកទោស ។ បរិវេណជុំវិញព្រះវិហារត្រូវកងឈ្លបយកធ្វើជាមន្ទីរសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោស ។ ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះបានបន្សល់ទុកស្លាកស្នាមជាច្រើន ដូចជា ឈាមប្រឡាក់ពេញជញ្ជាំងព្រះវិហារ ច្រវាក់ ខ្នោះឃ្នាងនៅពាសពេញគុក និងសាកសពជនរងគ្រោះមួយចំនួន ។ អ្នកទោសត្រូវសម្លាប់ទាំងអស់ បន្ទាប់ពីសួរចម្លើយនិងធ្វើទារុណកម្មលើបល្ល័ង្កព្រះដែលធំជាងគេក្នុងព្រះវិហារ និងនៅក្រោមដើមចាន់ដែលស្ថិតនៅប្រមាណ៥០ម៉ែត្រពីមន្ទីរឃុំឃាំង ។

### ៣) មន្ទីរសន្តិសុខបន្ទាយរោងគោ

បន្ទាយរោងគោជាបន្ទាយទាហានធំជាងគេប្រចាំស្រុកកំពង់ស្ពឺ កាលពីជំនាន់របបសាធារណរដ្ឋខ្មែរ ។ ឧត្តមសេនីយ៍ សុសស្តែន ហ៊្វេរណង់ដែស ជាអ្នកគ្រប់គ្រងនៅបន្ទាយរោងគោនេះ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាយនេះត្រូវខ្មែរក្រហមកាន់កាប់ទាំងស្រុង និងបានបង្កើតមន្ទីរសន្តិសុខមួយនៅកន្លែងនោះ ដើម្បីឃុំឃាំងអ្នកទោសគ្រប់ប្រភេទ ។ គេហដ្ឋានរបស់ឧត្តមសេនីយ៍ សុសស្តែន ហ៊្វេរណង់ដែស និងអគារជាច្រើនទៀតដែលមាននៅក្នុងបរិវេណបន្ទាយរោងគោទាំងមូលត្រូវបានប្រែក្លាយទៅជាមន្ទីរឃុំឃាំង ។ ប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញពីស្រុកនានាជុំវិញ ខេត្តកំពង់ស្ពឺ ពីខេត្តតាកែវ និងពីតំបន់៥៥ បានត្រូវប្រមូលយកមកដាក់ក្នុងមន្ទីរសន្តិសុខនេះ បន្ទាប់ពីអ្នកទាំងនោះចាញ់ល្បិចកលខ្មែរក្រហម ដែលថានឹងប្រគល់មុខតំណែងដូចដើមវិញចំពោះអ្នកដែលហ៊ានសារភាពថាធ្លាប់បានបម្រើការងារក្នុងរបបមុនៗមែន ។ អ្នកទោសខ្លះត្រូវបានសម្លាប់នៅក្នុងបរិវេណមន្ទីរសន្តិសុខបន្ទាយរោងគោ ហើយមួយចំនួនទៀតត្រូវនាំយកទៅសម្លាប់នៅក្នុងភូមិត្រស់សាលា ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ។ កម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងនៅមន្ទីរសន្តិសុខបន្ទាយរោងគោសុទ្ធតែជាអតីតយុទ្ធជនពិការ ។

ក្រោយឆ្នាំ១៩៧៩ បន្ទាយរោងគោត្រូវបានបោសសម្អាតនិងរៀបចំឡើងវិញ ។ ឡុង ជា អាយុ៤៧ឆ្នាំ ជាមេភូមិត្រស់សាលាឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមនបាននិយាយថា ពេលដែលគាត់វិលត្រឡប់មកកាន់ស្រុកកំណើតវិញនៅឆ្នាំ១៩៧៩គាត់ឃើញប្រជាជនជាច្រើនមកជីកគាស់រណ្តៅសាកសពជនរងគ្រោះដើម្បីរកមាសប្រាក់ ។ នៅក្នុងបរិវេណបន្ទាយរោងគោ ដែលមានទំហំប្រមាណមួយរយម៉ែត្របួនជ្រុង គេសង្កេតឃើញថាមានរណ្តៅសាកសពយ៉ាងច្រើនព្រមទាំងឡដុតធ្យូងមួយសម្រាប់ដុតមនុស្ស ។ ឡនោះអាចដុតមនុស្សម្តងៗបាន៣០នាក់ ។ ក្រៅពីរណ្តៅធំៗ នៅមានរណ្តៅតូចៗប្រមាណ៨០រណ្តៅទៀត ស្ថិតនៅពាលវាលពាសកាលពេញដីបន្ទាយរោងគោនេះ ។ សរុបសាកសពជនរងគ្រោះទាំងអស់មានប្រមាណពី២.៤០០នាក់ទៅ៤.០០០នាក់ ។ គំនរឆ្អឹងដែលគាស់កកាយឡើងត្រូវបានដឹកជញ្ជូនទៅកាន់បូជនីយដ្ឋានវត្តអំពែភ្នំ ដើម្បីតម្កល់ទុកជាភស្តុតាង ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ បន្ទាយរោងគោ ស្ថិតនៅទីរួមខេត្តកំពង់ស្ពឺតែម្តង ដែលមានចម្ងាយប្រមាណតែ១គីឡូម៉ែត្រប៉ុណ្ណោះពីសាលាខេត្តកំពង់ស្ពឺ ។ បច្ចុប្បន្នកន្លែងនោះជាស្នងការប៉ូលិសខេត្ត ។

**ស្ថិតិ** ៖ បន្ទាយរោងគោ ជាអតីតបន្ទាយទាហានរបស់របបសាធារណរដ្ឋខ្មែរដែលមានឧត្តមសេនីយ៍ សុសស្តែន ហ៊ែរណង់ដែសជាមេបញ្ជាការ ក្រោយមកបន្ទាយនេះបានប្រែក្លាយទៅជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមវិញ ដែលគ្រប់គ្រងដោយយុទ្ធជនពិការ ។ ជនរងគ្រោះប្រមាណ ពី២.៤០០ទៅ៤.០០០នាក់បានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខបន្ទាយរោងគោនេះ ។ ក្រោយមកត្រូវបានសម្លាប់ចោលនៅក្នុងបរិវេណមន្ទីរ និងនៅក្នុងភូមិត្រស់សាលា ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។

## ស្រុកគងពិសី

### ៤) មន្ទីរសន្តិសុខវត្តឧត្តុង្គមានជ័យ

អតីតសាលាបឋមសិក្សាមួយកន្លែងដែលមានទីតាំងនៅក្នុងបរិវេណវត្តឧត្តុង្គមានជ័យ ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោស ។ កម្មាភិបាលមានវ័យក្មេងដែលជាអ្នកគ្រប់គ្រងអ្នកទោសសុទ្ធតែបញ្ជូនមកពីកន្លែងនានាក្នុងភូមិភាគនិរតី និងពីខេត្តកំពង់ស្ពឺ ។ ម៉ែន ពុំជាអភិបាលរងទី២ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ធ្លាប់ឃើញខ្មែរក្រហមដឹកជញ្ជូនជនរងគ្រោះរៀងរាល់ ១៥ថ្ងៃម្តងពីភូមិភាគនិរតី និងខេត្តកំពង់ស្ពឺឆ្ពោះទៅកាន់មន្ទីរសន្តិសុខវត្តឧត្តុងមានជ័យ ។ ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះភាគច្រើនជាទាហាននិងមន្ត្រីរដ្ឋការជំនាន់របបសាធារណរដ្ឋខ្មែរ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៦ អ្នកទោសទាំងនេះត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ ជាមួយក្រុមគ្រួសារ ។ ខ្មែរក្រហមបានហៅអ្នកទោសតាមលេខរៀង ដែលមានកត់ក្នុងបញ្ជីឲ្យលុតជង្គង់នៅមាត់រណ្តៅរួចវាយចំកញ្ចឹង-កទម្លាក់ទៅក្នុងរណ្តៅតែម្តង ។ នៅឆ្នាំ១៩៧៧ រណ្តៅកប់សាកសពអ្នកទោសទាំងប៉ុន្មានត្រូវខ្មែរក្រហមបញ្ជាឲ្យប្រជាជនគាស់ឡើង ដើម្បីយកឆ្អឹងដុតធ្វើជីដាក់ស្រែ និងដំណាំផ្សេងទៀត ។

នៅឆ្នាំ១៩៧៩ រណ្តៅទាំងអស់នេះត្រូវប្រជាជនចាក់ដីលុបជិតទាំងអស់ ។ អតីតអគារចាស់ៗក្នុងមន្ទីរឃុំឃាំងត្រូវបានជួសជុលឡើងវិញ ។ គណៈកម្មការវត្តនិងពុទ្ធបរិស័ទបានផ្តួចផ្តើមគំនិតសាងសង់អគារសិក្សាមួយថ្មីទៀតពីលើរណ្តៅមួយដែលមានទំហំធំជាងគេ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ វត្តឧត្តុង្គមានជ័យស្ថិតនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

**ស្ថិតិ** ៖ ព្រះវិហារវត្តឧត្តុង្គមានជ័យ និងសាលាបឋមសិក្សាដែលមានទីតាំងនៅក្នុងបរិវេណវត្ត ត្រូវបានជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមកាលពីអំឡុងឆ្នាំ១៩៧៥ ។ អ្នកទោសភាគច្រើនជាទាហាននិងមន្ត្រីរដ្ឋការជំនាន់សាធារណរដ្ឋខ្មែរ ហើយត្រូវបានសម្លាប់ទាំងអស់នៅចុងឆ្នាំ១៩៧៦ ។ នៅឆ្នាំ ១៩៧៧ សាកសពអ្នកទោសត្រូវខ្មែរក្រហមបញ្ជាឲ្យប្រជាជនគាស់យកឆ្អឹងដុតធ្វើជី ។

### ៥) មន្ទីរសន្តិសុខជ្រៃអូរញ៉ោ

ជ្រៃអូរញ៉ោ ជាឈ្មោះភ្នំមួយដែលអ្នកស្រុកអ្នកភូមិនិយមហៅតាំងពីដើមរៀងមក ។ បច្ចុប្បន្នមានព្រះវិហារមួយសង់នៅចំពីលើកំពូលភ្នំ ។ នៅចុងឆ្នាំ១៩៧៦ មន្ទីរសន្តិសុខប្រចាំតំបន់៣៣ ដែលបង្កើតឡើងដោយគណៈភូមិភាគនិរតីឈ្មោះ "ម៉ុក" បាន



វត្តឧត្តុង្គមានជ័យ ភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

លេចរូបរាងឡើងនៅបរិវេណភ្នំជ្រៃអូរញ្ញោ ។ ភ្នំនេះស្ថិតនៅក្នុងឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ បច្ចុប្បន្ននេះ ភ្នំជ្រៃអូរញ្ញោគ្មានបន្សល់ទុកអ្វីដែលជាវត្ថុតាងធំដុំឡើយ ក្រៅពីស្រះទឹកដែលជីកដោយកម្លាំងអ្នកទោស និងអគារបាក់បែកមួយខ្នងទល់មុខសាលាបឋមសិក្សាដែលស្ថិតនៅខាងកើតជើងភ្នំ ។

ក្នុងអំឡុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខនេះដើម្បីអប់រំប្រជាជនដែលធ្លាប់មាននិន្នាការនយោបាយពីសង្គមចាស់ និងអ្នកដែលមិនទាន់ជ្រះស្រឡះចំពោះបដិវត្តន៍ ។ គ្មានប្រជាជន ឬអតីតអ្នកទោសណាម្នាក់បានស្គាល់កម្មាភិបាល ដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខ ជ្រៃអូរញ្ញោច្បាស់លាស់ឡើយ លើកលែងតែ តាខុន (កំបុតដៃម្ខាង) ជាប្រធាន និង តាបែន ជាអនុប្រធានប៉ុណ្ណោះ ព្រោះថា កម្មាភិបាលផ្សេងទៀតសុទ្ធតែផ្លាស់មកពីខេត្តផ្សេងៗ ។ ខៀវ ឡូ បាននិយាយពីកម្មាភិបាល ដែលមកពីខេត្តក្រៅថា "ពួកវា ច្រើននិយាយរដឺនៗ" ។ មាស មាំង ប្រាប់ថា "ភាគច្រើនពួកអាសន្តិសុខនេះច្រើនមកពីខាងដាំសង្កែ ស្រុកថ្ពង ឬកាត់ភ្លុក ស្រុកបសេដ្ឋ" ។



"បដិវត្តន៍កម្ទេច ឬអង្គការកម្ទេច" ជាពាក្យដែលអ្នកទោសនៅមន្ទីរសន្តិសុខជ្រៃអូរញ្ញោ ឮរាល់ថ្ងៃ ហើយជាពាក្យមួយម៉ាត់ដែលធ្វើឲ្យអ្នកសេសសល់ពីស្លាប់មានការឈឺចាប់អស់មួយជីវិត ។ អ៊ឹ ណាប់ បានត្អូញត្អែរប្រាប់ថា "មូលហេតុដែលពួកខ្មែរក្រហមចាប់ខ្ញុំយកទៅដាក់នៅជ្រៃអូរញ្ញោ ព្រោះប្តីរបស់ខ្ញុំត្រូវបដិវត្តន៍កម្ទេច" ។ ប្តីរបស់ ណាប់ ត្រូវខ្មែរក្រហមបញ្ឆោតដោយសរសេរសំបុត្រមកប្រាប់ថា ឲ្យទៅមើលថែរក្សាបងរបស់គាត់ម្នាក់ទៀតដែលជាព្រះសង្ឃរាជ ។ ណាប់ បានលើកស្រង់អត្ថន័យនៅក្នុងសំបុត្រថា "គាត់ (ព្រះសង្ឃ) មានទុក្ខធ្ងន់ណាស់" ។ តាមពិតព្រះសង្ឃរាជនោះត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលតាំងពីឆ្នាំ១៩៧០ម៉្លេះ ។ អស់រយៈយ៉ាងយូរទើប ណាប់ ដឹងថាប្តីរបស់គាត់ស្លាប់បាត់ដោយសារចាញ់ល្បិចកលខ្មែរក្រហម ។ ណាប់ បន្តថា "ពេលបាត់គាត់ខ្ញុំខំដើររកគ្រប់ច្រកល្ហក ទៅសួររហូតដល់ប្រធានភូមិទៀត ទីបំផុតទើបប្រធានភូមិប្រាប់ថា ប្តីខ្ញុំត្រូវបដិវត្តន៍កម្ទេចបាត់ហើយ" ។ ណាប់ បានត្រឹមតែបង្ហូរទឹកភ្នែក ស្ទើរតែរាល់ថ្ងៃ ព្រោះមិនហ៊ានស្តីបន្ទោស ឬទាមទារឲ្យអង្គការសងប្តីសំឡាញ់របស់គាត់មកវិញ ។ ប្រធានភូមិបានហាម ណាប់ មិនឲ្យនិយាយរឿងនេះ ទៅក្រៅទេ ។

មិនមែនមានតែគ្រួសាររបស់ ណាប់ ប៉ុណ្ណោះទេដែលព្រាត់ប្រាសគ្នា គ្រួសារជាច្រើនទៀតក៏មិនខុសគ្នាដែរ ។ ប្រាក់ សារិន ដំទប់លេខ២ឃុំវាល ស្រុកគងពិសី បានពន្យល់ថា "អ្នកទោសដែលមកជាប់នៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញោ សុទ្ធសឹងជាអ្នកមានគ្រួសារត្រូវបដិវត្តន៍កម្ទេច" ។ សារិន បន្តថា "គ្រួសារណាក៏ដោយឲ្យតែមានសាច់ញាតិណាម្នាក់ត្រូវអង្គការយកទៅកម្ទេច សមាជិកគ្រួសារដែលនៅសេសសល់ប្រាកដជាត្រូវខ្មែរក្រហមយកទៅដាក់នៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញោ ឬមន្ទីរសន្តិសុខតំបន់៣៣ទាំងអស់ សូម្បីតែក្មេងតូចៗ ឬចាស់ជរា ដែលដើរមិនរួចក៏ដោយ" ។ ប្រជាជនមិនស្គាល់ឈ្មោះម្នាក់ដែលរស់នៅភូមិព្រៃខ្វង ឃុំវាល បាននិយាយពីការចាប់មនុស្សយកទៅដាក់នៅជ្រៃអូរញ្ញោថា ខ្មែរក្រហមមកចាប់មនុស្សពីសហករណ៍ ឬពីមូលដ្ឋានមិន ដែលភាន់ច្រឡំម្តងណាឡើយ ព្រោះ ពួកគេ (កងឈ្លប ឬប្រធានភូមិប្រធានឃុំ) សុទ្ធតែមានបញ្ជីចាប់ខ្លួនច្បាស់លាស់ ។

ប្តីរបស់ ប្រាក់ គឺ ត្រូវអង្គការយកទៅសម្លាប់ហើយ ក្រោយមកខ្មែរក្រហមបញ្ជាឲ្យកងឈ្លបមកចាប់ខ្លួន គី ទៀត ។ គី បានសម្តែងសកម្មភាពដែលកងឈ្លបមកចាប់គាត់ "ឥឡូវអង្គការឲ្យអ្នកឯងទៅជួបជុំជាមួយប្តីនៅជ្រៃអូរញ្ញោ" ។ គី រំឭករឿងរ៉ាវប្តីរបស់គាត់ដែលត្រូវអង្គការចាប់យកទៅកម្ទេចថា ប្រធានសហករណ៍មកបញ្ឆោតយកទៅសម្លាប់កាលពីខែមករាឆ្នាំ១៩៧៦ ដោយយកលេសថាឲ្យទៅដឹកជញ្ជូនអីវ៉ាន់ ។ គី ដឹងថា ប្តីរបស់គាត់ត្រូវកងឈ្លបសម្លាប់តាំងពីយូរណាស់មកហើយ ប៉ុន្តែគាត់

មិនអាចប្រកែកបាន ។ ទីបំផុត គឺ បានក្លាយជាអ្នកទោសនៅមន្ទីរសន្តិសុខជ្រៃអូរញ្ញាដូច ណាប់ និងអ្នកឯទៀតដែរ ។

នៅខាងក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញា មានគ្រួសារជនរងគ្រោះដោយសារប្តី ឬមេគ្រួសារត្រូវ"បដិវត្តន៍កម្ទេច" និងអ្នកទោសដែលខ្មែរក្រហមចាប់យកមកពីតំបន់២៥ ព្រមទាំងកងទ័ពពីភូមិភាគបូព៌ាទៀតផង ។ អ្នកទោសទាំងអស់ត្រូវកងឈ្លបកម្ទេចចោលដាក់ក្នុងរណ្តៅជាច្រើន ដែលស្ថិតនៅជុំវិញបរិវេណមន្ទីរសន្តិសុខជ្រៃអូរញ្ញា ។

ប្រាក់ សារិន ប្រាប់ថា កាលពីឆ្នាំ១៩៨២ ពេលដែលគាត់នៅជានគរបាលឃុំ គាត់បានរួមដំណើរជាមួយមន្ត្រីថ្នាក់ឃុំនិងស្រុកជាច្រើនរូបចុះទៅគាស់រណ្តៅសាកសពនៅជុំវិញបរិវេណមន្ទីរសន្តិសុខជ្រៃអូរញ្ញានេះ ។ សារិន បានឃើញខោអាវកងទ័ពពណ៌ត្រួយចេករបស់សាកសពរាប់រយនាក់នៅស្រស់ៗនៅឡើយ ។ សារិន និយាយទៀតថាខោអាវទាំងនោះជាឯកសណ្ឋានរបស់កងទ័ពភូមិភាគបូព៌ា ។ ណាប់ បានបញ្ជាក់ថា គាត់ឃើញខ្មែរក្រហមដឹកមនុស្ស៥ ទៅ៦រថយន្តចូលមកកាន់មន្ទីរសន្តិសុខជ្រៃអូរញ្ញា ។ ប៉ុន្តែក្រោយមក គាត់មិនដែលឃើញរថយន្តដឹកអ្នកទោសមកទៀតឡើយ ។ ណាប់ បន្តថា រំលងមួយថ្ងៃ ឬពីរថ្ងៃ គឺមានឡានដឹកមកម្តង ។ ក្រៅពីនេះនៅមាន អ្នកទោសជាប្រជាជនថ្មីច្រើនដែលខ្មែរក្រហមដឹកតាមរថយន្តធំៗមកកាន់មន្ទីរសន្តិសុខជ្រៃអូរញ្ញាដែរ ។ ណាប់ និងអ្នកទោសមូលដ្ឋានខស្បុរាហ៍បានទទួលខោអាវពីកងឈ្លបប្រចាំមន្ទីរសន្តិសុខណាស់ ព្រោះថារៀងរាល់ពេលដែលកងឈ្លបនាំយកអ្នកទោសជាប្រជាជនថ្មីទៅសម្លាប់ កងឈ្លបតែងតែប្រមូលអីវ៉ាន់សម្លៀកបំពាក់របស់អ្នកទោសទាំងអស់មកចែកចាយ ។ អ្នកទោសដែលមិនទាន់ដល់ថ្ងៃស្លាប់ត្រូវធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរ ។ មាស លាភ និយាយទាំងហួសចិត្តថា "បន្ទាប់ពីខ្មែរក្រហមចាប់ ខ្ញុំមកភ្នំជ្រៃអូរញ្ញា ពួកវាបានប្រើខ្ញុំខ្លាំងជាងនៅខាងក្រៅទៅទៀត ។ ខ្ញុំត្រូវពួកវាប្រើឲ្យភ្ជួរស្រែតាំងពីម៉ោង៣ភ្លឺរហូតដល់ម៉ោង១២ថ្ងៃត្រង់ទើបបានឲ្យឈប់ហូបបាយ ។ លុះហូបបាយហើយ ខ្មែរក្រហមប្រើខ្ញុំឲ្យទៅឃ្វាលគោម្នាក់៣នឹមថែមទៀត ហើយម៉ោង៣រសៀលចាប់ភ្ជួរបន្តទៀត ។ អ្នកដែលមិនឃ្វាលគោគឺគេឲ្យទៅកាប់ឆ្ការព្រៃ" ។ លាភ បន្តថា កម្លាំងធ្វើការងារនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញាត្រូវបានបែងចែកជាបីគឺ អ្នកទោសដែលមានកម្លាំងខ្លាំងត្រូវចាត់ចូលក្នុងប្រភេទកម្លាំងទី១ ។ អ្នកបន្ទាប់គឺប្រភេទកម្លាំងទី២ ហើយអ្នកខ្សោយបំផុតដូចយាយៗត្រូវនៅក្នុងប្រភេទកម្លាំងទី៣ ។ ភារកិច្ចតែម្យ៉ាងរបស់ប្រភេទកម្លាំងទី៣ គឺថែរក្សាចៅ ឬមើលក្មេងតូចៗដែលម្តាយត្រូវទៅធ្វើការឆ្ងាយៗ ។ ជួនកាលខ្មែរក្រហមក៏ប្រើឲ្យទៅធ្វើស្រែរែកដីដែរ ។ ប្រាក់ គី ស្ថិតក្នុងប្រភេទកម្លាំងទី២ មានភារកិច្ចដកស្ទូង រែកដី លើកទំនប់ ជីកប្រឡាយ ឬស្រះ ។ កូនតូចរបស់គាត់ត្រូវយកទៅឲ្យយាយៗមើលថែទាំ ។ ពេលល្ងាច ឬយប់ទើបគាត់ទៅយកកូនពីយាយៗមកឲ្យបៅ ។ នៅយប់ខែភ្លឺកងនារីនិងយុវជនត្រូវទៅធ្វើការទាំងយប់តាមផែនការដែលគណៈកងដាក់ចុះ ។ មាស រុំ អាយុ៣៨ឆ្នាំ រស់នៅភូមិព្រៃខ្ទុង ឃុំវាល បាននិយាយថា "ជួនកាលពួកខ្ញុំរែកដីប្រណាំងគ្នាដើម្បីបានហូបឆ្អែត ប៉ុន្តែនៅតែមិនឆ្អែត លើកលែងតែថ្ងៃទី១០ និងទី២០ រៀងរាល់ខែប៉ុណ្ណោះ" ។ ជំទប់ទី២ឃុំវាលបាននិយាយថា ឲ្យតែដល់ថ្ងៃទី១០និងទី២០ ខ្មែរក្រហមមានការបន្ធូរបន្ថយច្រើនសម្រាប់ឲ្យសាច់ញាតិ បងប្អូន ប្តីប្រពន្ធ ដែលនៅក្នុងបរិវេណមន្ទីរសន្តិសុខជួបជុំគ្នា ។

មន្ទីរសន្តិសុខជ្រៃអូរញ្ញាមានសហករណ៍ចំនួន៦ ។ សហករណ៍ទាំងនេះសាងសង់ជារោងវែងៗ ដែលអាចផ្ទុកមនុស្សបានជាច្រើនពាន់នាក់ ប៉ុន្តែអ្នកទាំងនោះសុទ្ធតែត្រូវខ្មែរក្រហមបែងចែកតាមប្រភេទកម្លាំងរួចជាស្រេច ។ នៅតាមសហករណ៍នីមួយៗសុទ្ធតែ មានមន្ទីរពេទ្យមួយសម្រាប់ព្យាបាលជំងឺ ។ ណាប់ ប្រាប់ថាពេទ្យនេះអាចព្យាបាលបានតែប្រភេទជំងឺធ្ងន់ៗប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏មនុស្សស្លាប់នៅតែកើតមានជារៀងរាល់ថ្ងៃដដែលដោយសារតែឈឺអត់ថ្នាំព្យាបាលនិងអត់បាយ ។ អ្នកជិតខាង ណាប់ ម្នាក់ដែលរស់នៅក្នុងមន្ទីរឃុំឃាំងដូចគាត់បានស្លាប់ដោយសារជំងឺហើម ។ អ្នករួមការងារម្នាក់ជាមួយ មាស រុំ បានស្លាប់ដោយសារឃ្លានខ្លាំងពេក ។ រុំ និយាយថា "ខ្ញុំបានឃើញមនុស្សស្លាប់ក្បែរខ្លួនដូចជាឈ្មោះ ថុល ម្នាក់ ឈ្មោះ ម៉ាប់ ម្នាក់ និងម្នាក់ទៀតភ្លេចឈ្មោះ" ។ ទិដ្ឋភាព ប្រាក់ គី ណាប់ និងអ្នកទោសទាំងចាស់ទាំងក្មេងលែងខ្វាចខ្វេច ។ រុំ រំឭកថា "ដំបូងខ្ញុំយំរាល់

យប់ដោយសារភ័យខ្លាចដល់យូរៗទៅធម្មតា បើយប់ណាក៏មានមនុស្សស្លាប់អីចឹងនោះ និងដូចជារស់នៅជាមួយខ្មោចទៅហើយ» ។ រុំ បាននិយាយបន្តពីមូលហេតុដែលនាំឲ្យក្រុមកុមារដូចគ្នាស្លាប់ថា មកពីខ្វះការថែទាំ និងការមិនយកចិត្តទុកដាក់ ។ លាភ បានលើកឧទាហរណ៍ថា នៅពេលដែលក្រុមកុមារវិលត្រឡប់មកពីធ្វើការទាំងហេវហត់វិញ នាំគ្នាចូលដេកទាំងឈឺ រងា និងខ្លួនទទឹកជោកព្រមទាំងគ្មានមុងគ្មានភួយដណ្តប់ផង ។ លុះព្រលឹមឡើងពេលមេកងមកដាស់ឲ្យទៅធ្វើការស្រាប់តែកុមារខ្លះស្លាប់ឡើងរឹងស្តូកទៅហើយ» ។

ប្រធាននិងអនុប្រធានគុកគឺ តាខុន និង តាបែន មិនដែលនិយាយប្រាប់អ្នកទោសពីសភាពការណ៍នយោបាយឡើយ មានតែការប្រជុំការងារម្តងម្កាលប៉ុណ្ណោះ ។ ប៉ុន្តែមានការបញ្ចុះបញ្ចូលផ្នែកមនោគមវិជ្ជាចំពោះកុមារខ្លះដែរ គឺនិយាយបំពាក់បំប៉នកុមារឲ្យខំធ្វើការងារឲ្យស្រឡាញ់អង្គការបដិវត្តន៍ និងឲ្យមានចិត្តដាច់ខាត ។ សារឿន បាន រំឭកពីការបំពាក់បំប៉នមនោគមវិជ្ជារបស់ប្រធានក្រុមកុមារក្នុងអង្គប្រជុំកុមារនៅខាងជើងភ្នំជ្រៃអូរញ៉ោថា «ថ្ងៃមួយ រ៉ា ប្រធានក្រុមខ្ញុំបានប្រជុំណែនាំកុមារយើងឲ្យខំធ្វើការបម្រើអង្គការ ព្រោះយើងជាកូនរបស់អង្គការ ។ កុមារត្រូវតែដាច់ខាតមិនត្រូវស្តាយស្រណោះអាឡោះអាល័យអ៊ីទាំងអស់ ។ ឪពុកម្តាយយើងធ្វើខុសដូច្នេះត្រូវតែស្លាប់ យើងដាច់ខាតត្រូវតែហ៊ានសម្លាប់ឪពុកម្តាយយើង» ។ ពេលនិយាយ ចប់ រ៉ា សួរកុមារក្នុងអង្គប្រជុំថា «មើលមិត្តយើងណាខ្លះហ៊ានសម្លាប់ឪពុកម្តាយ? បើហ៊ានត្រូវលើកដៃ» ។ ពេលនោះទាំងខ្ញុំ ទាំងគេបានលើកដៃទាំងអស់គ្នា» ។

ក្រៅពីនេះ នៅមានការប្រជុំជារៀងរាល់ថ្ងៃជាមួយប្រធានកងហ ប្រធានកងរយ ឬប្រធានក្រុម ជាមួយកូនក្រុមរបស់ខ្លួនដែលជាអ្នកទោសដូចគ្នា ។ ប៉ុន្តែប្រធានកងហ កងរយ ឬប្រធានក្រុមកសាងខ្លួនបានល្អជាងអ្នកដទៃ ។ ណាប់ រំឭកថា «ពួកគេសុទ្ធតែកសាងខ្លួនបានល្អ ទើបបានឡើងជាប្រធាន» ។ ការប្រជុំរបស់ប្រធានក្រុម ប្រធានកងហ កងរយ បានប្រព្រឹត្តទៅជារៀងរាល់ល្ងាចពេលបាយហើយ ។ មាស លាភ បានឲ្យដឹងថា «ការប្រជុំមានរាល់ថ្ងៃក្នុងន័យឲ្យយើង (អ្នកទោស) ខំធ្វើការ» ។ ប្រាក់ គឺ និង អ៊ឹ ណាប់ បានបញ្ជាក់ថានៅពេលប្រជុំម្តងៗពូតែពាក្យថា «ស្លាប់» ជាប់នឹងមាត់ ។ ឧទាហរណ៍ដូចមេកង របស់គាត់តែងនិយាយថា «ឲ្យនាំគ្នាខំធ្វើការប្រយត្ន័ស្លាប់» «កុំឲ្យលួចគេប្រយត្ន័ស្លាប់»...។ ណាប់ បានលើកយកសម្តីរបស់ តាបែន ដែលនិយាយនៅក្នុងប្រជុំថា «ប្រយត្ន័ខ្លួន ព្រោះឥឡូវដល់ពេលចម្រាញ់ហើយ ។ ដូចអង្ករអីចឹងគឺយើងចម្រាញ់យកតែដើមយកតែអាល្អទេ ចំណែកអាចុងមិនយកដាច់ខាតគឺត្រូវវាត់ចោល» ។

ការអត់ឃ្លាន បានធ្វើឲ្យអ្នកទោសនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ៉ោស្លាប់ជាបន្តបន្ទាប់ ។ អ្នកទោសម្នាក់ត្រូវកងឈ្លបវាយរហូតដល់ស្លាប់ ពេលកំពុងភ្ជួររាស់ ដោយសារតែរើសកូនកន្ធែបមួយ ។ មាស រុំ និយាយទៀតថា អ្នកទោសដែលស្លាប់ដោយជំងឺ និងអត់បាយនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ៉ោ មានចំនួនស្ទើរតែស្មើគ្នានឹងអ្នកទោសដែលត្រូវឈ្លបយកទៅសម្លាប់ដែរ ។ ប្រាក់ សារិន ប្រាប់ថា ពេលគាត់ចូលរួមគាស់រណ្តៅសាកសព គាត់សង្កេតឃើញមានលលាដ៍ក្បាលខ្លះផុងប្រេះស្រាំ ឬបែកតែម្តង ។ លលាដ៍ក្បាលរបៀបនេះមានច្រើនណាស់រហូតដល់រាប់រយឯណោះ ។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ អ្នកទោសភាគតិចណាស់ដែលរួចរស់ជីវិតចេញពីគុកជ្រៃអូរញ៉ោ ។ មាស លាភ និងប្អូនស្រីបង្កើត មាស រុំ បានរ៉ាយរ៉ាប់ទាំងអួលដើមកថា ពួកគាត់បានបាត់បង់ម្តាយជាទីស្រឡាញ់នៅពេលដែលអង្គការចាប់ម្តាយនិងកូនពីរនាក់ទៅដាក់នៅគុកជ្រៃអូរញ៉ោ ពីរខែបន្ទាប់ពីចាប់ខ្លួនឪពុកគាត់យកទៅកម្ទេច ។ សុន បានឲ្យដឹងថា ជីវិតកូនស្រីពៅអាយុ៥ឆ្នាំរបស់គាត់ម្នាក់បានស្លាប់យ៉ាងវេទនាបំផុតនៅជ្រៃអូរញ៉ោ ។ នៅឆ្នាំ១៩៧៧ សុន និងមនុស្ស១៧នាក់ផ្សេងទៀតនៅភូមិភ្នំតូច ឃុំសូភី ស្រុកបាទី ខេត្តតាកែវ ត្រូវខ្មែរក្រហមចាប់ខ្លួន ហើយបញ្ជូនតាមរទេះគោពីរគ្រឿងទៅកាន់មន្ទីរសន្តិសុខភ្នំជ្រៃអូរញ៉ោ ។ សុន បានរំឭកពីមូលហេតុដែលគាត់ត្រូវចាប់ខ្លួនតាមការនិយាយប្រាប់របស់ប្រធានភូមិថា «ដោយសារយើងទាំងអស់គ្នាបានរៀបការក្លាយជាប្រពន្ធនិងជាកូនខ្មាំងរបស់អង្គការ» ។ កូនរបស់ គី ប្រាំនាក់បានស្លាប់នៅជ្រៃអូរញ៉ោតែក្នុងរយៈពេលពីរឆ្នាំប៉ុណ្ណោះ ។

ក្នុងបទសម្ភាសន៍របស់លោក ណេត ថៃយ័រ ជាមួយ កាំង ហ្កេច អៀវ ហៅ ឌុច ជា អតីតគណៈមន្ទីរស-២១ ឬគុក ទួលស្លែងបានឲ្យដឹងពីការសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខភ្នំជ្រៃអូរញ៉ោថា «ក្រោមការគ្រប់គ្រងរបស់ តាម៉ុក អ្នកទោសជាច្រើនក្នុងមន្ទីរសន្តិសុខភ្នំជ្រៃអូរញ៉ោត្រូវបានសម្លាប់ដោយគ្មានសួរនាំអ្វីទាំងអស់» ។ ចម្លើយជាសាក្សីបានបញ្ជាក់កាន់តែច្បាស់ថែមទៀតអំពីចំនួនសាកសពដែលគាស់បានក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដោយក្រុមស្រាវជ្រាវនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សារិន ដែលចូលរួមគាស់រណ្តៅសាកសពក្នុងឆ្នាំ១៩៨២ បានបញ្ជាក់ថា «ទីតាំងសម្លាប់មានពីរកន្លែងធំៗគឺក្នុងភូមិព្រះស្តេច និងភូមិព្រៃខ្វង ហើយអ្នកទោសដែលស្លាប់នោះ គឺខ្មែរក្រហមដឹកយកមកពីមន្ទីរសន្តិសុខជ្រៃអូរញ៉ោ» ។

ជនរងគ្រោះរាប់ម៉ឺននាក់បានបាត់បង់ជីវិតនៅមន្ទីរសន្តិសុខភ្នំជ្រៃអូរញ៉ោ ដែលបង្កើតឡើងដោយគណៈភូមិភាគនិរតី ។ ស្ត្រី និងកុមារដែលសល់ពីស្លាប់បានក្លាយជាស្ត្រីមេម៉ាយនិងក្មេងកំព្រា ។ សព្វថ្ងៃ ណាប់ រស់នៅតែម្នាក់ឯង ធ្វើការងារគ្រប់បែបយ៉ាងតាំងពីភ្ជួររាស់ ដកស្ទូង និងការងារក្នុងផ្ទះ ។ ណាប់ រំឭក «ពេលណាធ្វើដំណើរកាត់ភ្នំជ្រៃអូរញ៉ោម្តងៗ ខ្ញុំតែងស្រមៃឃើញមនុស្សម្នាក្នុងសម្លៀកបំពាក់ខ្មៅ រូបរាងស្គមស្គាំង ប្រឹងដើរសំដៅទៅកាន់ការដ្ឋានធ្វើការងារទាំងត្រដាបត្រដួសខ្លះសែងដីខ្លះលីចប... អ្នកខ្លះត្រូវកងឈ្លបចាប់វៃធ្វើបាប និងកាប់សម្លាប់» ។

## ទិន្នន័យសង្ខេប

**ទីតាំង :** ជ្រៃអូរញ៉ោ មានទីតាំងស្ថិតនៅភូមិជើងភ្នំ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

**ស្ថិតិ :** ភ្នំជ្រៃអូរញ៉ោ ជាមន្ទីរសន្តិសុខតំបន់៣៣របស់ខ្មែរក្រហម ។ មន្ទីរនេះត្រូវបានសាងសង់ឡើង នៅឆ្នាំ១៩៧៦ ។ មន្ទីរសន្តិសុខតំបន់៣៣មានសហករណ៍ចំនួន៦ជាចំណុះ ហើយសហករណ៍នីមួយៗសុទ្ធតែមានការបែងចែកកម្លាំងតាមប្រភេទពលកម្ម ។ អ្នកទោសជាច្រើននាក់ត្រូវបានបញ្ជូនមកពីគ្រប់កន្លែងក្នុងខេត្តកំពង់ស្ពឺ និងតាកែវមកដាក់ឃុំឃាំងនៅក្នុងមន្ទីរនេះ ។ អ្នកទោសភាគច្រើនបានស្លាប់ ដោយសារជំងឺ និងគ្មានម្ហូបអាហារគ្រប់គ្រាន់ ។ ចំណែកអ្នកទោសផ្សេងទៀតត្រូវបាននាំយកទៅសម្លាប់នៅភូមិព្រះស្តេចនិងភូមិព្រៃខ្វង ។

**ផេង ពង្សរ៉ាស៊ី**



បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះ នៅវត្តអំពែភ្នំ ខេត្តកំពង់ស្ពឺ

# ចំណោទឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ទំនាក់ទំនង

***(តពីលេខមុន)***

បន្ទាប់ពីអានឯកសារចម្លើយសារភាព បញ្ជីកម្មេចអ្នកទោស និងចំណារប្រហារជីវិតអ្នកទោសក្នុងមន្ទីរអប់រំស្រុកត្រាំកក់ចប់សព្វគ្រប់ ខ្ញុំចាប់ផ្តើមរៀបគម្រោងចុះទៅស្រុកត្រាំកក់ ។ មន្ទីរអប់រំស្រុកត្រាំកក់ ហ៊ុមព័ទ្ធដោយដើមឈើធំៗជាច្រើន ។ នៅចំពីមុខមានស្រះទឹកធំមួយទំហំប្រមាណ៨ ម៉ែត្រ៨ជ្រុង ។ នៅចំកណ្តាលមានបូជនីយដ្ឋានមួយសង់អំពីឈើប្រក់ស្លឹក ចូលទៅខាងក្នុងតាមទ្វារទ្រុឌទ្រោមមួយ នៅចំកណ្តាលមានធ្នើឈើទំហំ៣ម៉ែត្រពេញទៅដោយក្បាលខ្មោច ។ នៅចំហៀង ខាងស្តាំ មានដែករនុក និងច្រវាក់មួយខ្សែយ៉ាងវែងសំយុងចុះមកក្រោម ។

សែន និង ម៉ៅ គឺជាអតីតអ្នកទោសដែលធ្លាប់ជាប់ឃុំឃាំងក្នុងមន្ទីរអប់រំស្រុកត្រាំកក់ ។ បរិវេណមន្ទីរអប់រំស្រុកត្រាំកក់ ដើមឈើនៅខាងក្នុងនិងបរិវេណមន្ទីរទាំងអស់ សុទ្ធតែបង្កប់នូវភាពខ្លោចផ្សាចំពោះពួកគាត់និងអ្នកដែលបានស្លាប់ទៅ ។ សែន ប្រាប់ឲ្យដឹងថា នៅពេលសួរចម្លើយអ្នកទោសត្រូវបាននាំចេញពីបន្ទប់ឃុំឃាំងទៅជ្រុងខាងត្បូង ចំណែកនៅពេលប្រហារជីវិតអ្នកទោសត្រូវនាំចេញទៅជ្រុងខាងកើតឆៀងខាងត្បូង ។ សែន មិនអាចចាំមុខនិងចំនួនអ្នកទោសពេលប្រហារជីវិតម្តងៗឡើយ ប៉ុន្តែ សែន អះអាងថា ណុប ណែម តារាភាពយន្តល្បីម្នាក់ក្នុងរបបសង្គមរាស្ត្រនិយម ដែលមានស្រុកកំណើតនៅស្រុកត្រាំកក់ជាមួយគាត់ និង គាម៉ុក ដែរនោះ ត្រូវបានប្រហារជីវិតនៅក្នុងមន្ទីរអប់រំស្រុកត្រាំកក់នៅចុងឆ្នាំ១៩៧៥ ។ សែន បញ្ជាក់ថា "ពួកដែលបម្រើការងារនៅទីនោះទាំងអស់ សុទ្ធតែជាជនដៃដល់ ។ បើដៃមិនដល់នៅមិនកើតទេ" ។ សែន រៀបរាប់ឈ្មោះជនដៃដល់ដែលគាត់ចាំច្បាស់ចំនួន៦នាក់ គឺ សាំង, ស៊ឹម, ស័ន, ឌុប, ទូច និង អ្នក ។ សាំង, ស៊ឹម, និង ឌុប បដិសេធការចោទប្រកាន់របស់សែន ។ ស៊ឹម រៀបរាប់ពីដំណើរនាំអ្នកទោសនៅមន្ទីរអប់រំស្រុកត្រាំកក់ទៅប្រហារជីវិតតាមការសង្កេតឃើញរបស់គាត់ថា ៖

"ការនាំអ្នកទោសទៅប្រហារជីវិតដំបូងគឺកម្មាភិបាលបើកទ្វាររួចយកដៃខ្ទប់ច្រមុះ ។ បន្ទាប់មកនិយាយ "ឥឡូវបងប្អូនមួយចំនួនត្រូវបានអង្គការដោះលែងបញ្ជូនទៅសហករណ៍វិញ ពេលទៅដល់សហករណ៍ត្រូវធ្វើល្អ កុំទំនាស់គេ លួចដំឡូងគេ" ។ ពេលពួកអ៊ីចឹងអ្នកទោសនាំគ្នាទះដៃលាន់ប្រាវពេញបន្ទប់ ។ រួចហើយកម្មាភិបាលហៅឈ្មោះ ក, ខ, ជ, ង ចេញម្តង៤នាក់ហើយបណ្តើរចេញពីបន្ទប់ ។ ចេញដល់ក្រៅ អ្នកទោសត្រូវបានចងដៃ និងរុំមុខរួចបណ្តើរទៅដល់មាត់រណ្តៅ កម្មាភិបាលនោះប្រាប់អ្នកទោសឲ្យអង្គុយចុះ ហើយវាយកដំបងវាយកួសពីក្រោយ ។ ពេលវាយរួច វាយកដាវវែងមកអារ-ក ទោះស្លាប់ ឬមិនទាន់ស្លាប់ក៏ដោយ វារុញទម្លាក់ចូលរណ្តៅ ហើយកាយដីកប់តែម្តង" ។

ញ៉ វំឭកថា ពេលពួកកម្មាភិបាលមន្ទីរអប់រំ ហៅចំឈ្មោះរបស់ខ្លួន អ្នកទោសខ្សឹបខ្សៀវប្រវាចើបដើរសំដៅទៅមាត់ទ្វារ ។ អ្នកទោសខ្លះមានចិត្តត្រេកអរដោយគិតថាខ្លួនត្រូវបានដោះលែង អ្នកទោសខ្លះទៀតនឹកភ័យដោយគិតថា ខ្លួនត្រូវនាំចេញយកទៅប្រហារជីវិត ។ អ្នកទោសខ្វិនជើងម្នាក់ជាប់ខ្នោះក្បែរ ញ៉ នៅពេលបានឮឈ្មោះរបស់គាត់ភ្លាម អ្នកទោសខ្វិននោះ ខំវារដង លូនដងសំដៅទៅមាត់ទ្វារ ។ ពេលទៅដល់មាត់ទ្វារកម្មាភិបាល២នាក់បានលើកគាត់ដាក់ក្នុងបន្ទីសែងយកទៅទម្លាក់ក្នុងរណ្តៅរួចកប់ចោលតែម្តង ។ ញ៉ អះអាងច្បាស់ថា ការប្រហារជីវិតអ្នកទោសនៅចុងឆ្នាំ១៩៧៨ ម្តងនោះមានចំនួនរហូតទៅដល់១០០នាក់ ។ មនុស្សចាស់ត្រូវវាយទម្លាក់រណ្តៅ តាមការបញ្ជាក់របស់ ញ៉ គឺ "លាន់ឮសូរតែភូសដូចដូងធ្លាក់ពីដើមអ៊ីចឹង" ។ ចំពោះកុមារតូចៗវិញ ខ្មែរក្រហមមិនចាំបាច់ប្រើដាវ កាំបិតចាក់ឡើយ គឺ "វាចាប់

បោកនឹងគល់ឈើ រួចបោះទម្លាក់រណ្តៅតែម្តង» ។

សំណាង ធ្លាប់បានឃើញដាវនិងកាំបិតសម្រាប់ប្រហារជីវិតអ្នកទោស ក្នុងពេលគាត់ដើររកខុសនៅជុំវិញបរិវេណមន្ទីរអប់រំស្រុកត្រាំកក់ ។ សំណាង ពណ៌នាអំពីដាវនិងកាំបិតនោះថា «រលីងឆិល» ដងរលោង និងមុខភ្លឺចាំង ។ សំណាង អះអាងថា ដាវនិងកាំបិតនេះ គឺទុកសម្រាប់ប្រើប្រាស់ប្រហារជីវិត ។ ដាំ អះអាងថា ភារកិច្ចប្រហារជីវិតអ្នកទោស ជាភារកិច្ចប្រចាំថ្ងៃរបស់កម្មាភិបាលមន្ទីរអប់រំដែលត្រូវតែធ្វើ ។ ពេលត្រូវប្រហារជីវិតម្តងៗ គ្មានអ្វីពិបាកឡើយ ដំបូងដោះខ្នោះនាំចេញក្រៅ បណ្តើរយកទៅប្រហារជីវិតតែម្តង ។ ដាំ បញ្ជាក់ថា ការងារនេះច្រើនធ្វើពេលយប់ ។

ម៉ៅ អតីតអ្នកទោសមន្ទីរអប់រំស្រុកត្រាំកក់សង្កេតឃើញថា នៅពេល ភីបាក់ មកមន្ទីរអប់រំស្រុកម្តងៗតែងមានការជប់លៀងផឹកស៊ីសប្បាយតាំងពីព្រលឹមរហូតដល់ល្ងាច ។ ពេលជប់លៀងស៊ីផឹករួច កម្មាភិបាលទាំងនោះសម្រាករហូតដល់ម៉ោង ២-៣រសៀល ទើបចាប់ផ្តើមប្រហារជីវិតអ្នកទោសតែម្តង ។ ដំណើរការប្រហារជីវិតធ្វើឡើងជាលំដាប់លំដោយ គឺដំបូងនាំអ្នកទោសចេញពីបន្ទប់ម្តង២-៣នាក់ទៅទីតាំងរណ្តៅ ។ បន្ទាប់មកឲ្យអ្នកទោសលុតជង្គង់ចុះ ហើយវាយចំពីក្រោយទម្លាក់រណ្តៅនិងអារ-កតែម្តង ។

ដំណើរការប្រហារជីវិតអ្នកទោសនៅក្នុងមន្ទីរអប់រំស្រុកបាទី ក៏មានលក្ខណៈនិងដំណើរការដូចមន្ទីរអប់រំស្រុកត្រាំកក់ដែរ ។ ចក់ ចាប់អារម្មណ៍ថា ពេលមានផែនការប្រហារជីវិតអ្នកទោសម្តងៗ កម្មាភិបាលមន្ទីរអប់រំតែងកាប់ឆ្កែធ្វើការជប់លៀងផឹកស្រាយ៉ាងសប្បាយ ។ មុនការប្រហារជីវិតចាប់ផ្តើមការធ្វើដំណើរចេញចូលពីកន្លែងមួយទៅកន្លែងមួយមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ សូម្បី ចក់ ដែលជាអ្នកទោសមានភារកិច្ចដាំបាយក៏មិនត្រូវបានអនុញ្ញាតដែរ ។ ចក់ បញ្ជាក់សេចក្តីប្រកាសតាមមេក្រុមថា «នៅកន្លែងណានៅកន្លែងនោះ ចូលហើយកុំចេញ ចេញហើយកុំចូល» ។ បន្ទាប់មកដំណើរការប្រហារជីវិតត្រូវចាប់ផ្តើម ។ កម្មាភិបាលមន្ទីរអប់រំបើកមើលសៀវភៅបញ្ជីអ្នកទោស ហើយហៅឈ្មោះអ្នកទោសដែលមានគូសខ្វែងប៊ិចពណ៌ក្រហមឲ្យចេញតាមលេខរៀងម្តង៤-១០នាក់ ។ នៅពេលចេញទៅខាងក្រៅ អ្នកទោសត្រូវចងរុំមុខបណ្តើរសំដៅទៅរណ្តៅ រួចចាក់-កនិងរុញទម្លាក់រណ្តៅកប់ចោលតែម្តង ។ ចក់ បញ្ជាក់ថា ការប្រហារជីវិតចាប់ផ្តើមពីថ្ងៃម៉ោង៣ ជួនកាលរហូតដល់ម៉ោង១២យប់ទើបចប់ ។ ក្នុងពេលសំណេះសំណាលជាមួយ ឈិន អតីតប្រធានស្រុកបាទីពីឆ្នាំ១៩៨០ដល់១៩៨២ ឈិន បានឲ្យដឹងថា បញ្ជីប្រហារជីវិតមានឈ្មោះសរសេរប៊ិចខៀវ និងមានឈ្មោះខ្លះត្រូវខ្វែងដោយប៊ិចក្រហមនិងអក្សរថា «កម្ទេច» ។ ឈិន បានមើលបញ្ជីនោះ ហើយឃើញមានឈ្មោះបងជីដូនមួយរបស់គាត់និងឈ្មោះគាត់ ។ ឈ្មោះបងជីដូនមួយរបស់គាត់មានគូសប៊ិចក្រហម ចំណែកឈ្មោះរបស់គាត់ពុំមានគូសប៊ិចក្រហមឡើយ ។ ហេតុដូចនេះហើយបានជាបងជីដូនមួយរបស់ ឈិន ត្រូវបានប្រហារជីវិតក្នុងអំឡុងឆ្នាំ១៩៧៧នៅក្នុងមន្ទីរអប់រំស្រុកបាទី ។

ដំណើរការនាំអ្នកទោសចេញពីបន្ទប់ឃុំឃាំងយកទៅប្រហារជីវិតដូចខាងលើ ក៏បានកើតឡើងចំពោះអ្នកទោសក្នុងមន្ទីរអប់រំស្រុកលើកដែកដែរ ។ គេង រំឭកថា «ម្តង៧-៨នាក់ ហៅឈ្មោះចេញទៅបាត់រហូត ពេលខ្លះហៅទៅច្រើន ពេលខ្លះហៅទៅតិច ។ ការងារនេះធ្វើតែពេលយប់ប៉ុណ្ណោះ» ។

តាមសម្តីរបស់ ហួយ ថា «ជីវិតអ្នកទោសគឺនៅនឹងចុងក្រចក បើគេចង់យ៉ាងម៉េច គឺស្រេចតែគេថា ។ គ្រាន់តែនាំទៅដល់ក្នុងព្រៃអត់មានសួរច្រើនទេ ហើយក៏មិនប្រើកាំភ្លើងបាញ់នាំតែខាតគ្រាប់ដែរ គឺយកដំបងវាយពីក្រោយចំដើងសក់ងាប់តែម្តង» ។

ការស្លាប់របស់អ្នកទោស មិនមែនកើតឡើងដោយសារតែការនាំទៅប្រហារជីវិតខាងក្រៅបរិវេណមន្ទីរអប់រំស្រុកប៉ុណ្ណោះទេ ។ អ្នកទោសខ្លះ បានស្លាប់ក្នុងបន្ទប់ឃុំឃាំងដោយសារជំងឺ និងគ្រាំគ្រាក្រោយពេលទារុណកម្ម ។ ក្នុងខែកក្កដា ឆ្នាំ១៩៧៧ អ្នកទោសមន្ទីរអប់រំស្រុកត្រាំកក់ ចំនួន២នាក់ឈឺស្លាប់ ។ ចំណែកនៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ចំនួនអ្នកទោសឈឺស្លាប់កើនឡើងរហូតដល់៦នាក់ ។ ស៊ីម អតីតកម្មាភិបាលមន្ទីរអប់រំស្រុកត្រាំកក់ពន្យល់អំពីមូលហេតុនៃការឈឺស្លាប់របស់អ្នកទោសថា «អ្នកទោសអត់បាយ ស្គមគ្រាំគ្រា ដោយសារការវាយធ្វើបាបពេល

ស្លូរចម្លើយនៅពេលថ្ងៃ មានជំងឺ ខ្វះអនាម័យ មូស ចៃខាំរាល់ថ្ងៃ ការបង្អត់អាហារ និងការហេវហត់បាក់កម្លាំងចុះខ្សោយជាប្រចាំ ដូច្នេះរៀងរាល់យប់យ៉ាងតិចក៏មានអ្នកទោស២-៣នាក់ស្លាប់ដែរ ។ សាកសពដែលត្រូវទុកចោលតាំងពីយប់រហូតដល់ល្ងាច រង់ចាំឲ្យអ្នកទោសស្រាលត្រឡប់មកពីធ្វើការវិញ ទើបនាំគ្នាសែងយកទៅដាក់កប់ចោលក្នុងរណ្ដៅ» ។

អ្នកទោសជាប់ខ្នោះក្បែរគ្នាស្លាប់ជាបន្តបន្ទាប់ ធ្វើឲ្យ មៅ មានអារម្មណ៍ភ័យខ្លាច ដេកមិនលក់ស្ទើររាល់យប់ ។ មៅ ពន្យល់ហេតុផលថា បើយប់ត្រូវប្រហារជីវិត គឺភ័យខ្លាចគេត្រូវនាំយកទៅប្រហារជីវិត បើយប់គ្មានការប្រហារជីវិតអ្នកទោសជិតខាងស្រែកឈឺចាប់ទើសភ្លឺយប់ខ្លះមានស្រែករហូតស្លាប់ក៏មាន ។

ក្រៅពីស្ថិតក្នុងសភាពជាអ្នកទោស មៅ គឺជាអាចារ្យខ្មោចហើយ មៅ ត្រូវបានចាត់តាំងជាអ្នកសែងខ្មោចយកទៅកប់ ។ ហេតុការណ៍នេះ ក៏កើតឡើងនៅក្នុងមន្ទីរអប់រំស្រុកលើកដែកដែរ ។ ព្រលឹមថ្ងៃមួយ នៅពេលក្រោកទៅធ្វើការ គេង បានដាស់អ្នកទោសម្នាក់ដែលជាប់ខ្នោះក្បែរជើងគាត់ឲ្យងើបឡើង ប៉ុន្តែគ្មានកម្រើកខ្លួនទាល់តែសោះ ។ ការពិតបុរសម្នាក់ដែលគាត់បានដេកឱបកាលពីយប់នោះ បានស្លាប់បាត់បង់ជីវិតទៅហើយ ។ ដើយ ក៏ធ្លាប់ត្រូវចាត់តាំងឲ្យបំពេញភារកិច្ចសែងខ្មោចអ្នកទោសទៅកប់ដូច គេង ដែរ ។ ដើយ បានឲ្យដឹងថា សាកសពដែលគាត់សែងយកទៅកប់សុទ្ធតែមានសភាពស្គមស្គាំង ។ «មួយអង្រឹងដាក់៣នាក់ សែងទៅដូចជាមិនដឹងធ្ងន់ឡើយ» ។

ឈន់ អតីតអ្នកទោសមន្ទីរអប់រំស្រុកកណ្ដាលស្ទឹង អះអាងថា អ្នកទោសឈឺស្លាប់ក្នុងបន្ទប់ឃុំឃាំងយ៉ាងតិចពី៨ទៅ១០នាក់ក្នុងមួយថ្ងៃ ។ ទោះបីតួលេខនៃការស្លាប់ដោយជំងឺដែលអះអាងដោយអតីតអ្នកទោសនិងកម្មាភិបាលខាងលើមានលក្ខណៈខ្ពស់បន្តិចក៏ដោយក៏វាជាការបញ្ជាក់អំពីហេតុការណ៍ពិតដែលកើតឡើងនៅក្នុងមន្ទីរអប់រំស្រុកនៅទូទាំងភូមិភាគនិរតីទាំងមូល ។

**ទំនាក់ទំនងមន្ទីរអប់រំស្រុកនិងតំបន់**

បន្ទាប់ពីការចាប់ខ្លួន ខ្មាំងរបស់អង្គការត្រូវបញ្ជូនខ្លួនទៅឃុំឃាំងនិងសួរចម្លើយនៅមន្ទីរអប់រំស្រុក ។ ចម្លើយសារភាពរបស់អ្នកទោសត្រូវប្រធានមន្ទីរអប់រំស្រុកផ្ញើជូនគណៈតំបន់ពិនិត្យនិងសម្រេច ។ ជាក់ស្ដែងមានឯកសារមួយចុះកាលបរិច្ឆេទថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៧ ។ នៅក្នុងឯកសារនេះ សមមិត្ត អាន់ បានផ្ញើចម្លើយសារភាពរបស់អ្នកទោស៣នាក់ ដែលមានឈ្មោះ ១) អ៊ុន លី អាយុ៤៣ឆ្នាំ ២) ស៊ីន យ៉ាង អាយុ៥០ឆ្នាំ និង៣) ឈ្មោះ ចាន់ សឿន អាយុ២៣ឆ្នាំ ជូនសមមិត្ត ប្រាក់ លេខាតំបន់១៣ពិនិត្យនិងសម្រេច ។ មួយសប្ដាហ៍ បន្ទាប់មកគណៈតំបន់សម្រេចឲ្យប្រហារជីវិតខ្មាំងទាំង៣ខាងលើ ។ ក្នុងសេចក្ដីរាយការណ៍អំពីចម្លើយសារភាពរបស់ខ្មាំងចុះកាលបរិច្ឆេទមួយផ្សេងទៀត រួមមានឈ្មោះអ្នកទោសចំនួន៣នាក់ ។ «១) យឹង គាន អាយុ២៨ឆ្នាំ ប្រពន្ធឈ្មោះ ស៊ុន លឹមហេង កំណើតនៅភូមិតាកែវ ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ២) អ៊ុល ហៀង អាយុ៣៧ឆ្នាំ ប្រពន្ធឈ្មោះ លិន លឹម ស្រុកកំណើតនៅភូមិប្រជុំ ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ៣) វ៉ាល់ ជា អាយុ៣៨ឆ្នាំ ប្រពន្ធ ឈ្មោះ ជុន សូវ៉ាន កំណើតនៅភូមិគោករវាង ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ។ អាទាំង៣នាក់នេះជារដ្ឋការមានបណ្ដាស័ក្តិ ដែលទិសអង្គការត្រូវប្រមូលយកមក» ។ អ្នកទោសទាំង៣នេះ ត្រូវគណៈតំបន់សម្រេច


ឆ្អឹងនិងលលាដ៍សាកសពជនរងគ្រោះនៃរបបខ្មែរក្រហម

ឲ្យប្រហារជីវិតនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ ។ ឌុច ជាអ្នកវាយអង្គុលីលេខចម្លងចេញអំពីចម្លើយសារភាពរបស់អ្នកទោស ហើយប្រធានមន្ទីរអប់រំជាអ្នកចារលើឯកសារនោះ ។ ឌុច បញ្ជាក់ថា ឯកសារដែលគាត់បានវាយជាអង្គុលីលេខទាំងអស់ពិតជាត្រូវបានផ្ញើជូនថ្នាក់លើ ប៉ុន្តែគាត់មិនដឹងថាផ្ញើទៅណាឡើយ ។ ឌុច បញ្ជាក់ថា “ខ្ញុំដឹងដោយសារពេលវាយអង្គុលីលេខរួច អាន់តែងរៀបចំឯកសារទាំងនោះយកចេញទៅ ។ ប៉ុន្តែខ្ញុំមិនដឹងយកទៅឲ្យអ្នកណាឡើយ” ។

តេង អតីតអ្នកទោសមន្ទីរអប់រំស្រុកលើកដែកអះអាងអំពីការផ្ញើចម្លើយសារភាពរបស់អ្នកទោសទៅឲ្យថ្នាក់លើដូច ឌុច ដែរ ។ តេង ពុំបានដឹងច្បាស់ថា ថ្នាក់លើនោះនៅទីណា និងជានរណាពិតប្រាកដឡើយ ។


អ្នកស្រុកចង្អុលបង្ហាញពីស្នាកស្នាមដែលបន្សល់ទុក ពីរបបកម្ពុជាប្រជាធិបតេយ្យ

អ្នកទោសដែលបានឆ្លើយសារ-ភាពអំពីទោសកំហុសក្បត់បដិវត្តរបស់ខ្លួនជូនអង្គការភាគច្រើនត្រូវគណៈតំបន់សម្រេចឲ្យប្រហារជីវិត ។ ក្នុងចម្លើយសារភាពរបស់អ្នកទោសមួយចំនួនបង្ហាញអំពីទំនាក់ទំនងពាក់ព័ន្ធខ្សែសង្វាក់ខ្មាំងនិងមានឋានៈខ្ពស់ក្នុងរបបលន់នល់ ទៅមន្ទីរសន្តិសុខតំបន់ដើម្បីឃុំឃាំងនិងសួរចម្លើយបន្ត។ សឿន ចូវ ហៅ ចៅ អាយុ ៨៩ឆ្នាំ ខ្មែរកម្ពុជាក្រោម ស័ក្តិ៥ គឺជាប្អូនរបស់អតីតទេសាភិបាលធនាគារជាតិ ឈ្មោះ សឺន សាន ត្រូវបានសមមិត្ត ឃុន គណៈមន្ទីរស្រុកកោះធំ បញ្ជូនពីមន្ទីរអប់រំស្រុកកោះធំទៅមន្ទីរសន្តិសុខតំបន់២៥ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៥ ។ អ្នកទោសម្នាក់ទៀតឈ្មោះ សុង ក៏ត្រូវបានបញ្ជូនពីមន្ទីរអប់រំស្រុកកោះធំទៅមន្ទីរសន្តិសុខតំបន់២៥ដែរ ។ សុង រៀបរាប់ដំណើរការបញ្ជូនខ្លួនគាត់ពីមន្ទីរអប់រំស្រុកកោះធំទៅមន្ទីរសន្តិសុខតំបន់២៥ថា “ដំបូងពួកគ្នាខ្ញុំ ជាងម្ភៃនាក់ត្រូវបានគេហៅឡើងទូកនាំចេញពីមន្ទីរឃុំទៅមន្ទីរអប់រំស្រុកកោះធំ ។ ពួកយើងជាប់ឃុំឃាំងនៅទីនោះ ៤-៥ថ្ងៃ ស្រាប់តែមានបញ្ជាឲ្យពួកខ្ញុំទាំងអស់ ចុះទូកទៅមន្ទីរសន្តិសុខតំបន់២៥ទៀត ។ តាមខ្ញុំចាំកាលនោះ ពួកយើងជិះទូកដែលមានលេខ១០៨ ។ អង្គុយជាពីរជួរ ជើងជាប់ខ្នោះទល់មុខគ្នា” ។ អ្នកទោសចំនួន៤នាក់ ក្នុងស្រុកលើកដែក ឈ្មោះ សែន, ហួរ, អ៊ុត និង យិន ត្រូវសមមិត្ត លន គណៈស្រុកលើកដែកបញ្ជូនខ្លួនពីមន្ទីរអប់រំស្រុកលើកដែក ទៅមន្ទីរសន្តិសុខតំបន់២៥ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៧៦ ។ សមមិត្ត លន បានសរសេរបញ្ជាក់ក្នុងលិខិតមួយផ្ញើជូនប្រធានមន្ទីរសន្តិសុខតំបន់ថា ក្រៅពីអ្នកទោសទាំង៤ខាងលើ នៅមានពីរនាក់ទៀតដែលគាត់កំពុង “ចាត់វិធានការរកបន្តទៀត ។ ដោយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់កម្ទេចខ្មាំង” ។

ដំណើរការបញ្ជូនអ្នកទោសពីមន្ទីរអប់រំស្រុកលើកដែកទៅមន្ទីរសន្តិសុខតំបន់២៥ ក៏មិនខុសពីដំណើរការបញ្ជូនអ្នកទោសពីមន្ទីរអប់រំស្រុកកោះធំដែរ ។ ការបញ្ជូនអ្នកទោសធ្វើឡើងតាមរយៈទូកធំមួយ ។ តេង អតីតអ្នកទោសមន្ទីរអប់រំស្រុកលើកដែកបញ្ជាក់អំពីដំណើរការនេះថា “អ្នកទោសត្រូវនាំចេញពីបន្ទប់ឃុំឃាំងចងដៃរួចបណ្តើរចុះទូក ។ ទូកនោះធំប្រហែលជាអាចផ្ទុកមនុស្សបាន៥០នាក់” ។ ដើយ អះអាងថា អ្នកទោសដែលត្រូវបញ្ជូនចេញហើយឡើងទូកទាំងនោះភាគច្រើន ជាអតីតទាហាន ប៉ូលិសរបប លន់ នល់ និងយុវជនខ្មែរក្រហម ដែលត្រូវចោទថាក្បត់ ។ នៅពេលមកដល់កោះថ្មី អ្នកទោសត្រូវដោះខ្នោះចេញពីទូក ហើយបណ្តើរឡើងទៅលើកោះសំដៅទៅបន្ទប់ឃុំឃាំងតែម្តង ។ ប៉ាន បញ្ជាក់ថា អ្នកទោសត្រូវនាំមកពីគ្រប់ស្រុកក្នុង

តំបន់២៥ ។ ប៉ាន ចាំច្បាស់ថា ទូកសម្រាប់ដឹកអ្នកទោសចូលមកមន្ទីរសន្តិសុខតំបន់មានដាក់លេខសម្គាល់០៨ ។

នៅពេលពិនិត្យចម្លើយសារភាពរបស់អ្នកទោសរួច គណៈតំបន់ចារនឹងបញ្ជូនកំណត់ហេតុទាំងអស់ទៅឲ្យប្រធានមន្ទីរអប់រំស្រុក និងគណៈស្រុក ដើម្បីអនុវត្ត ។ នៅពេលទទួលបានបញ្ជាពីគណៈតំបន់ឲ្យប្រហារជីវិតអ្នកទោស ប្រធានមន្ទីរអប់រំស្រុក និងគណៈស្រុកជ្រើសរើសថ្ងៃកំណត់មួយ ដើម្បីអនុវត្តតាមសេចក្តីសម្រេចរបស់គណៈតំបន់ ។ ចក់ អតីតអ្នកទោសម្នាក់ក្នុងវត្តកកោះ ស្រុកបាទី អះអាងថា កម្មាភិបាលមន្ទីរអប់រំស្រុកបាទីតែងតែរៀបចំតុ កៅអីជាមុន ដើម្បីទទួលគណៈស្រុកបាទី សមមិត្តនារី ជឹម និងសមមិត្ត ឆន ពីរនាក់ប្តីប្រពន្ធ ដែលតែងតែនៅជាប់ជាមួយប្រធាននិងអនុប្រធានមន្ទីរអប់រំស្រុកបាទីក្នុងពេលប្រហារជីវិតអ្នកទោសម្តងៗ ។ ចក់ ប្រាប់ថា វត្តមានរបស់កម្មាភិបាលថ្នាក់លើនៅក្នុងពេលប្រហារជីវិតគឺដើម្បីអង្គុយកៅអីផ្ទៀងមើលឈ្មោះណាដែលមានសញ្ញាខ្វែងពណ៌ក្រហមតាមបញ្ជីនិងដើរចុះដើរឡើងមើលនាយអាយតែប៉ុណ្ណោះ ។ ជនដៃដល់ប្រហារជីវិតអ្នកទោសនោះគឺ កម្មាភិបាលមន្ទីរអប់រំស្រុក ។

វត្តមានរបស់កម្មាភិបាលដែលជាគណៈស្រុកមាន ភី បាក់, តាជឹម, តាសាន នៅក្នុងមន្ទីរអប់រំស្រុកត្រាំកក់ ស្រុកបាទី និងស្រុកទ្រាំង នៅក្នុងយុទ្ធនាការប្រហារជីវិតអ្នកទោសអាចបង្ហាញថា គណៈស្រុកទាំងនេះ បានទទួលបញ្ជាពីលេខាតំបន់ឲ្យចូលរួមប្រហារជីវិតអ្នកទោសក្នុងមន្ទីរអប់រំស្រុកក្នុងស្រុកដែលស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់ខ្លួន ។

ចំពោះមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ការប្រហារជីវិតខ្មាំងរបស់អង្គការ គឺជាវិធានការដោះស្រាយទំនាស់សំខាន់ទីមួយ ។ វិធានការរបស់អង្គការគឺ ប្រហារជីវិតអ្នកទោសដែលបានសួរចម្លើយរួច ។ ការប្រហារជីវិតខ្មាំងរបស់អង្គការជាការសម្រេចរបស់គណៈមជ្ឈិមបក្ស ដោយប្រគល់សិទ្ធិឲ្យលេខាបក្សភូមិភាគ ហើយតាមរយៈលេខាភូមិភាគ គណៈតំបន់ជាអ្នកទទួលខុសត្រូវក្នុងការសម្រេចប្រហារជីវិតខ្មាំងក្នុងមន្ទីរអប់រំស្រុក ។

**តារាងបង្ហាញដំណើរការនៃមន្ទីរសន្តិសុខតំបន់**

**មន្ទីរអប់រំស្រុក**

១) ឃុំឃាំង និងសួរចម្លើយអ្នកទោស ។

២) ផ្ញើរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសជូនគណៈតំបន់ ។

៣) បញ្ជូនអ្នកទោសទៅមន្ទីរសន្តិសុខតំបន់ ។

**តំបន់**

១) សម្រេចឲ្យចាប់ខ្លួនអ្នកទោសក្នុងក្របខ័ណ្ឌតំបន់ ។

២) ពិនិត្យរបាយការណ៍ និងចម្លើយសារភាពរបស់អ្នកទោសផ្ញើមកពីមន្ទីរអប់រំស្រុកនិងចេញបញ្ជាឲ្យប្រធានមន្ទីរអប់រំស្រុក ប្រហារជីវិតអ្នកទោស ។

**មន្ទីរសន្តិសុខតំបន់**

១) ចាប់ខ្លួន ឃុំឃាំង និងសួរចម្លើយអ្នកទោស ។

២) ទទួលយកអ្នកទោសដែលបញ្ជូនមកពីមន្ទីរអប់រំស្រុក ។

៣) បញ្ជូនអ្នកទោសទៅមន្ទីរស-២១ ។

៤) ផ្ញើរបាយការណ៍ និងចម្លើយសារភាពរបស់អ្នកទោសតំបន់ជូនអង្គការភូមិភាគ ។

**មន្ទីរសន្តិសុខតំបន់**

មន្ទីរសន្តិសុខតំបន់ក្នុងភូមិភាគនិរតីមាន៣ គឺមន្ទីរសន្តិសុខតំបន់២៥ មន្ទីរសន្តិសុខតំបន់៣៥ និងមន្ទីរសន្តិសុខតំបន់៣៣ ។ មន្ទីរសន្តិសុខតំបន់២៥ហៅ "មន្ទីរ១៥" ស្ថិតក្នុងឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល ។ មុនខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខតំបន់២៥មានទីតាំងនៅភូមិលេខ១ ឃុំពោធិ៍បាន ស្រុកកោះធំ ដែលមានសមមិត្តជ័យ សួន ហៅ សែន ជាលេខាតំបន់ និងសមមិត្តគេង ជាប្រធានមន្ទីរសន្តិសុខតំបន់២៥ ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខតំបន់២៥ បានផ្លាស់ទីតាំងទៅនៅលើកោះថ្មីក្នុងស្រុកស្អាង ដែលគ្រប់គ្រងដោយសមមិត្តសោម ជា និងសមមិត្ត មាវ៉ា ។ វត្តកោះថ្មី ក្លាយជាមន្ទីរឃុំឃាំងអ្នកទោសបុរស សាលារៀនបឋមសិក្សាកោះថ្មីក្លាយជាមន្ទីរឃុំឃាំងអ្នកទោសស្ត្រី ចំណែកផ្ទះនៅខាងត្បូងវិហារក្លាយជាមន្ទីរឃុំឃាំងយុទ្ធជនខ្មែរក្រហម ។ ទីតាំងសួរចម្លើយស្ថិតនៅខាងលិច ចំណែកទីតាំងប្រហារជីវិតនិងកន្លែងកប់សាកសពអ្នកទោសស្ថិតនៅខាងកើតវិហារ ។

មន្ទីរសន្តិសុខតំបន់៣៥ស្ថិតក្នុងស្រុកទ្រាំងខេត្តកំពត ។ មន្ទីរ

សន្តិសុខតំបន់៣៥ ជាអតីតពន្ធនាគារ ខេត្តកំពត ក្នុងរបបសង្គមរាស្ត្រនិយមដឹកនាំដោយសម្តេច សីហនុ និងរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ។ មន្ទីរសន្តិសុខតំបន់៣៥ ស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានមន្ទីរសន្តិសុខតំបន់ឈ្មោះ ណយ និងសមមិត្ត សំ ប៊ិត ជាលេខាតំបន់៣៥ ។ មន្ទីរឃុំឃាំងមាន២បន្ទប់ និងបន្ទប់សួរចម្លើយមួយ ។ បន្ទាប់ពីសួរចម្លើយចប់សព្វគ្រប់អ្នកទោសត្រូវដឹកចេញទាំងឡានៗ ទៅប្រហារជីវិតនៅជើងភ្នំបូកគោ ។

មន្ទីរសន្តិសុខតំបន់៣៣ ស្ថិតក្នុងភូមិជើងភ្នំ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ មន្ទីរនេះ ត្រូវបានប្រជាជនមូលដ្ឋានហៅថា «គុកជ្រៃអូញ៉ៅ» ។ មន្ទីរសន្តិសុខតំបន់៣៣ ស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានមន្ទីរសន្តិសុខតំបន់ឈ្មោះ បែន អនុប្រធានឈ្មោះ ខុន និងលេខាតំបន់ឈ្មោះ ចុង ។ អ្នកទោសត្រូវរស់នៅជា៦សហករណ៍ ៖ មានសហករណ៍វ័យចាស់ មេម៉ាយមានកូន មេម៉ាយអត់កូន យុវជន យុវនារី និងកុមារ ។ អ្នកទោសត្រូវធ្វើការធ្ងន់និង ពេលសម្រាកតិចតួចបំផុត ។ អ្នកទោសដែលរកឃើញថា បានប្រព្រឹត្តកំហុសដោយការលួច ឬធ្វើការមិនពេញដៃពេញជើងត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងក្នុងវត្តចំប៉ា ។ អ្នកទោសក្នុងមន្ទីរសន្តិសុខនេះត្រូវយកទៅប្រហារជីវិតនៅភូមិព្រះស្តេច និងភូមិព្រៃខ្នុង ។

## អ្នកទោសមន្ទីរសន្តិសុខតំបន់

វត្តមានអ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់កើតឡើងដោយសារមូលហេតុពីរ ៖ ទី១) ការចាប់ខ្លួនរបស់កងទ័ពនិងកម្មាភិបាលមន្ទីរសន្តិសុខតំបន់ និងទី២) ត្រូវបញ្ជូនបន្តមកពីមន្ទីរអប់រំស្រុក ។ អ្នកទោសដែលត្រូវចាប់ខ្លួនដោយកម្មាភិបាលមន្ទីរសន្តិសុខតំបន់ភាគច្រើនជាអតីតកម្មាភិបាលបម្រើការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលកម្មាភិបាលដឹកនាំរបស់ខ្លួនត្រូវបានចោទប្រកាន់ថា ប្រឆាំងនឹងអង្គការ ក្រៅពីនោះ គឺជាអតីតទាហានប៉ូលិសរបប លន់ នល់ ប្រជាជនជាប់និន្នាការនិងប្រជាជនដែលត្រូវបានចោទប្រកាន់ថាខ្មាំងផ្ទៃក្នុង ។ ហេតុផលនៃការចាប់ខ្លួនមាន៣សំខាន់ៗ ៖ ទី១) កម្មាភិបាលដឹកនាំរបស់ខ្លួនត្រូវចោទថាក្បត់និងត្រូវចាប់ខ្លួន ទី២) ជាប់ឈ្មោះក្នុងចម្លើយសារភាពខ្មាំង និងទី៣) រងនូវការចោទប្រកាន់ថា បានប៉ុនប៉ងធ្វើ ឬបានធ្វើសកម្មភាពក្បត់នឹងអង្គការ ។

នៅចុងឆ្នាំ១៩៧៥ កម្មាភិបាលនិងប្រជាជនក្នុងតំបន់២៥រាប់រយនាក់ត្រូវបានចាប់ខ្លួនក្នុងព្រឹត្តិការណ៍បោសសម្អាតខ្មាំងផ្ទៃក្នុងរបស់បក្ស ។ មូលហេតុនៃការចាប់ខ្លួននេះ កើតឡើងបន្ទាប់ពីលេខាតំបន់២៥ឈ្មោះជ័យ សួន ហៅ សែន និងកម្មាភិបាលដឹកនាំជាច្រើនទៀតដូចជា សុខ ប៊ុតចំរើន គណៈតំបន់២៥ ហួត សេ ប្រធានសន្តិសុខតំបន់២៥ សុខ មេបញ្ជាការតំបន់២៥ ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១នៅអំឡុងខែវិច្ឆិកា ពីបទបង្កើតបក្ស «ពលករកម្ពុជា» ដើម្បីប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជាដែលដឹកនាំដោយ ប៉ុល ពត ។ ជ័យ សួន គឺជាអតីតជនបដិវត្តមានអាយុស្របាលនឹង ប៉ុល ពត ហើយចេញមុខធ្វើសកម្មភាពប្រឆាំងជាចំហតាំងពីទសវត្សរ៍៥០ម្ល៉េះ ។ ជ័យ សួន ត្រូវបានចាប់ដាក់គុកដោយរាជការសម្តេចសីហនុនៅឆ្នាំ១៩៦២ ។ បន្ទាប់ពីត្រូវបានដោះលែងពីគុកនៅឆ្នាំ១៩៧០ ជ័យ សួន ចាប់ផ្តើមបម្រើខ្មែរក្រហម ការចូលរួមបម្រើបដិវត្តន៍នៅក្នុងព្រៃម៉ាកគីនិងបន្តបម្រើខ្មែរក្រហមរហូតដល់ពេលត្រូវអង្គការចាប់ខ្លួន ។

ក្នុងរបាយការណ៍កំណត់ហេតុនៃអង្គប្រជុំលេខា អនុលេខាកងពល និងវរសេនាធំឯករាជថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ សមមិត្ត សុន សេន បានបញ្ជាក់អំពីសភាពការណ៍ខ្មាំងជូនអង្គប្រជុំថា ការចាប់ខ្លួនយុទ្ធជនក្នុងតំបន់២៥មកទល់ពេលនេះមានចំនួនជិត២០០នាក់ ។ ការចាប់ខ្លួននេះកើតឡើងដោយសារយុទ្ធជនទាំងនេះជាខ្មាំងជាប់ពាក់ព័ន្ធជាមួយ ចាន់ ចក្រី ដែលបានរៀបចំផែនការបះបោរប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ។ មួយខែកន្លះក្រោយមកគឺនៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៦ ដដែលសមមិត្ត សុន សេន រំឭកអំពីលទ្ធផលនៃការកម្ទេចខ្មាំងក្បត់បដិវត្តន៍ និងដាក់ផែនការបន្តថា «យើងមើលឃើញច្បាស់ពីទំនាស់ហើយ ។ ខ្សែមេៗយើងវាយកម្ទេចជាមូលដ្ឋានហើយ តែដៃជើងវានៅមានបន្តទៀត» ។ ស៊ុយ ផល និង មៅ ជាដៃជើងរបស់ខ្មាំងអង្គការ ដែលសមមិត្ត សុន សេន បន្តតាមរកក្នុងចំណោមដៃជើងរបស់ខ្មាំងដែលសមមិត្ត សុន សេន ចាត់ទុកថា បានចូលរួមក្នុងចលនាក្បត់

នឹងអង្គការ ។ តាមរយៈចម្លើយសារភាពរបស់អ្នកទោសពីម្នាក់ទៅម្នាក់ ខ្មាំងរបស់អង្គការកាន់តែកើនចំនួនឡើង ។ ក្នុងចម្លើយសារភាពរបស់គាត់ ស៊ុយ ផល ឆ្លើយសារភាពអំពីទោសកំហុសរបស់គាត់ ដែលនាំឲ្យមានការចាប់ខ្លួនថា ដោយសារគាត់មានបំណងរត់ទៅប្រទេសវៀតណាម ហើយបំណងនៃការរត់នេះ គឺដោយសារខ្សែក្សត់ជាមួយគាត់ត្រូវបែកមុខ និងត្រូវចាប់ខ្លួនជាបន្តបន្ទាប់ ។ ខ្សែក្សត់របស់ ស៊ុយ ផល ត្រូវអង្គការចាប់ខ្លួនមុន ស៊ុយ ផល មានចំនួន២០នាក់ ហើយឈ្មោះដែលជាប់ក្នុងចម្លើយសារភាពរបស់ ស៊ុយ ផល ក្នុងផែនការធ្វើរដ្ឋប្រហារផ្តួលរំលំអង្គការមានចំនួន៩១នាក់ ក្នុងនោះ៦២នាក់ជាអ្នករៀបចំផែនការ និង២៩នាក់ ជាអ្នកគាំទ្រ ។ អតីត និរសាររបស់ នួនសួន ហៅ ជ័យ ម្នាក់ឈ្មោះ ម៉ៅ ត្រូវចាប់ខ្លួនក្នុងពេលយុទ្ធនាការចាប់ខ្លួនរបស់ នួនសន ហៅ ជ័យ ដែរ ។ ម៉ៅ ត្រូវសមមិត្ត ម៉េត ចាប់និងបញ្ជូនទៅឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខតំបន់២៥ ។ ម៉ៅ រៀបរាប់ថា «ពេលតាជ័យ ត្រូវចាប់ខ្លួន ពេលនោះខ្ញុំក៏ត្រូវ ម៉េត មកចាប់យកទៅដែរ ។ ម៉េត ដឹកខ្ញុំតាមម៉ូតូពីភូមិមកដល់ស្រុកស្អាងត្រើយខាងលិចកោះថ្មី បន្ទាប់មកហៅខ្ញុំចុះទូកឆ្លងទៅកោះថ្មី ។ ពេលឡើងទៅដល់កោះថ្មីភ្លាម កម្មាភិបាលមន្ទីរសន្តិសុខតំបន់២៥ ចាប់ខ្ញុំចងស្លាបសេក ឃ្លុំមុខខ្ញុំជាប់រួចនាំចូលក្នុងបន្ទប់ឃុំឃាំងកោះថ្មីតែម្តង ។ ពេលទៅដល់ទីនោះ ខ្ញុំឃើញគុកចំនួន៣ធំៗ នៅក្នុងវិហារមួយនិងសាលាពីរ ។ នៅក្នុងវិហារ គឺគុកសម្រាប់ដាក់អ្នកទោសធ្ងន់ ។ ចំណែក សាលាសម្រាប់ដាក់អ្នកទោសស្រាល អ្នកទោសស្ត្រីនិងកូនក្មេង ។ ពេលទៅដល់ដំបូង ខ្ញុំជាប់ឃុំនៅក្នុងវិហារ ។ វិហារនោះបិទទ្វារចាក់សោជិតងងឹតឈឹង ។ ក្រោយមកទើបខ្ញុំមើលឃើញនៅក្នុងនោះមានខ្នោះវែងៗចំនួន៣ខ្សែ ។ ក្នុងមួយខ្សែមានអ្នកទោស ពី២០ទៅ៣០នាក់» ។ ផននិងយុទ្ធជនចំនួន២៤នាក់ក្នុងកងពល១៧០ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៦ ដោយសារយុទ្ធជនទាំងនោះស្ថិតក្រោមបញ្ជារបស់ ចាន់ ចក្រី ។ យុទ្ធជនក្នុងកងពលលេខ១៧០ចំនួន២៥នាក់ត្រូវបានចាប់ខ្លួន ប៉ុន្តែបើតាម ផន ដឹងពីកម្មាភិបាលមន្ទីរសន្តិសុខតំបន់២៥ ចំនួនកងទ័ពក្នុងភូមិភាគបូព៌ា និងកងពល១៧០របស់ ចាន់ ចក្រី ដែលត្រូវបានចាប់ខ្លួនសរុបទាំងអស់មានចំនួនរាប់ពាន់នាក់ ។


អគារបាក់បែកបន្សល់ទុកពីរបបខ្មែរក្រហម ក្នុងខេត្តតាកែវ

មូលហេតុនៃការចាប់ខ្លួនរបស់ ហាក់ ក្នុងឆ្នាំ១៩៧៦ មានលក្ខណៈប្លែកពីការចាប់ខ្លួនអតីតកងទ័ពនិងកម្មាភិបាលតំបន់២៥បន្តិច ។ ក្រៅពីហេតុផលជាអតីតទាហានរបប លន់ នល់ ហេតុផលមួយផ្សេងទៀត គឺដោយសារ ហាក់ បានវាយកូនបង្កើតរបស់គាត់ ។ ហាក់ ប្រាប់ឲ្យដឹងថា គាត់វាយកូនរបស់គាត់ ដោយសារកូនគាត់ដែលបញ្ជូនទៅមណ្ឌលកុមារនោះ ចេះតែរត់ត្រឡប់មកផ្ទះវិញ ធ្វើឲ្យប្រធានក្រុមមណ្ឌលកុមារ ស្តីបន្ទោសគាត់ថា មិនចេះស្តីប្រដៅកូន ។ ហាក់ តូចចិត្តនឹងការស្តីបន្ទោសរបស់ប្រធានមណ្ឌលកុមារ ក៏យករំពាត់វាយកូនគាត់តែម្តង ។ ករណីចាប់ខ្លួនរបស់កងទ័ពដែលបម្រើក្នុងបដិវត្តន៍ខ្មែរ-ក្រហមនៅក្នុងតំបន់៣៥ មិនមែនដោយសារមូលហេតុមានការពាក់ព័ន្ធនឹង ចាន់ ចក្រី ឬ នង សួន ហៅ ជ័យ ឡើយ ។ លី ជាអតីតយុទ្ធជនវរសេនាតូចលេខ១២២ការពារដែនសមុទ្រ ។ នៅខែ១២ ឆ្នាំ១៩៧៥ លី ត្រូវបានចាប់ខ្លួនបញ្ជូនទៅឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់៣៥ ពីបទចោទប្រកាន់ថា មានផែនការបះបោររត់ទៅប្រទេសវៀតណាម ។ លី បានដឹងឮច្រើនអំពីអ្នកទោសដែលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់៣៥ជាមួយគាត់ ព្រោះបន្ទាប់ពីជាប់ឃុំឃាំងក្នុងគុកងងឹតរយៈពេលមួយខែកន្លះ ឆ្លងកាត់ការធ្វើទារុណកម្ម ការសួរចម្លើយ៣ដង គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើ

ចបបន្តិ និងដាំដំណាំវិញ ។ លី បញ្ជាក់ប្រាប់ថា អ្នកទោសត្រូវបានបញ្ជូនមកពីគ្រប់ស្រុកទូទាំងតំបន់៣៥ ដែលមានចំនួនប្រមាណ ៨០០នាក់ ក្នុងនោះមានកម្មាភិបាល កងទ័ពខ្មែរក្រហម អតីតទាហាន ប៉ូលិស របបលន់នល់ ជនជាតិ ចាម ប្រជាជន១៧ មេសា និងប្រជាជនមូលដ្ឋានមួយចំនួន ។ អ្នកទោសជាប់គុកងងឹតដេកផ្ទាល់នឹងស៊ីម៉ងត៍ ជើងទាំងពីរជាប់ខ្នោះ ។ គុកធំមានច្រើនជួរ មួយជួរមានអ្នកទោសចំនួន៤០នាក់ ។ អ្នកទោសជាប់ខ្នោះកងរនុកវែង ត្រូវបន្ទោរបង់ដាក់ក្នុងឡាំងគ្រាប់នៅក្បែរខ្លួន» ។

ម៉ឹង តេង បានឲ្យដឹងថា ក្រៅអំពីកងទ័ព មហាជនបំពេញមុខងារក្នុងក្របខ័ណ្ឌតំបន់ ប្រជាជនមួយចំនួនដែលត្រូវបានចោទប្រកាន់ថា ជាប់និន្នាការនិងជាខ្សាំងដែលមានពាក់ព័ន្ធជាខ្សែសង្វាក់ខ្សាំងរបស់អង្គការក៏ត្រូវបានចាប់ខ្លួនមកឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខតំបន់ដែរ ។ ម៉ឹង តេង បញ្ជាក់ថា រយៈពេលដែលគាត់គ្រប់គ្រងមន្ទីរសន្តិសុខតំបន់២៥ គាត់បានទទួលផែនការពីបក្សតាមរយៈលេខាតំបន់២៥ឲ្យប្រមូលអ្នកមានបណ្តាស័ក្តិ..... ប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញដើម្បីបញ្ជូនទៅមន្ទីរសន្តិសុខធ្វើសំណុំរឿងនិងកម្ទេច ។

សុង និង ឆុក ជាបងប្អូនបង្កើតនិងជាអតីតប៉ូលិសរបប លន់នល់ ។ សុង និង ឆុក ត្រូវបានជម្លៀសពីភ្នំពេញមកដល់ស្រុកកំណើតនៅស្រុកកោះធំ ។ បន្ទាប់ពីទៅដល់ភូមិបានមួយខែ សុង និង ឆុក និងអ្នកស្រុក២៥នាក់ទៀតត្រូវបានចាប់ខ្លួនពីបទចោទប្រកាន់ថា បានបម្រើក្នុងទាហានរបបលន់នល់ ហើយបើកយន្តហោះមកទម្លាក់គ្រាប់បែកក្នុងស្រុកកោះធំក្នុងសង្គ្រាមនៅមុនឆ្នាំ១៩៧៥ ។ សុង រៀបរាប់ថាជំបូងគណៈឃុំឈ្មោះ ស្រួច ហៅទៅឲ្យចូលរួមប្រជុំនៅមន្ទីរឃុំ ។ បន្ទាប់ ពីប្រជុំរួច សុង និង ប្រជាជនទាំងអស់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនតាមទូកលេខ០៨ទៅមន្ទីរសន្តិសុខតំបន់២៥ ។ សុង អះអាងថា គាត់បានដឹងរឿងរ៉ាវច្រើននៅមន្ទីរសន្តិសុខតំបន់២៥ ដោយសារគាត់ជាប់គុកនៅទីនោះរយៈពេលមួយខែបន្ទាប់មក ត្រូវក្លាយជាអ្នកទោសស្រាលធ្វើការក្នុងមន្ទីរសន្តិសុខនេះវិញ ។ សុង រៀបរាប់ពីទិដ្ឋភាពនិងព្រឹត្តិការណ៍ដែលគាត់បានឃើញផ្ទាល់ភ្នែកថា ៖ «អ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់២៥ បែងចែកដាក់ក្នុងបន្ទប់ឃុំឃាំង៣ផ្សេងៗគ្នា អ្នកទោសប្រុសចំនួនពីរបន្ទប់ និងអ្នកទោសស្ត្រីចំនួនមួយបន្ទប់ ។ អ្នកទោសធ្ងន់ជាប់ឃុំឃាំងក្នុងបន្ទប់ងងឹត ទោសល្មមស្ថិតក្នុងបន្ទប់ភ្លឺ និងអ្នកទោសស្ត្រីនិងកូនក្មេងដែលជាប្រពន្ធកូនរបស់អ្នកទោស ។ ក្នុងមួយបន្ទប់មានអ្នកទោសជាង៥០នាក់ ។ នៅក្នុងបន្ទប់ឃុំឃាំងអ្នកទោសស្ត្រី មានស្ត្រីម្នាក់ឈ្មោះ ប្រាយ ឈឺពោះឆ្លងទន្លេ ហើយបានស្រែកឲ្យរកអ្នកទោសស្ត្រីគ្នាឯងជួយ ។ អ្នកទោសស្ត្រីម្នាក់បានស្រែកសុំទឹកពីអ្នកយាមទ្វារថា «មានមិត្តយើងឈឺពោះឆ្លងទន្លេឲ្យសុំទឹកមួយផ្តិល» ។ ពេលនោះអ្នកយាមនោះក៏ហុចទឹកឲ្យមួយផ្តិល ។ ទារកនោះកើតបានប៉ុន្មានម៉ោងក្រោយមកក៏ស្លាប់ទៅ» ។

ថៃ ត្រូវចាប់ខ្លួនដាក់ឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់២៥ ក្រោមការចោទប្រកាន់ថា ជាភ្នាក់ងារចារកិច្ចរបស់ លន់ នល់ ដែលបានបង្កប់ខ្លួននៅភូមិព្រែកផ្អាវ ឃុំកំពង់កុង ស្រុកកោះធំ ។ ចំណែក ហួរ និងប្រជាជនចំនួន៤០នាក់ទៀត ត្រូវបានចាប់ខ្លួនក្នុងពេលជាមួយគ្នា គឺនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៧៦ ពីបទចោទប្រកាន់ដូចគ្នា «មានផែនការក្បត់អង្គការ មានបំណងរត់គេចទៅប្រទេសវៀតណាម» ។

ចំណែក ឡោះ និង តូច វិញត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់៣៥ ពីបទចោទប្រកាន់ដូច ហួរ និងប្រជា-


ប្រជាជននិងព្រះសង្ឃកំពុងប្រមូលអដ្ឋិធាតុជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងខេត្តតាកែវ

ជន៤០នាក់នៅតំបន់២៥ដែរ ។ ឡោះ និង តូច ត្រូវចាប់ខ្លួនដោយសារត្រូវបានចោទប្រកាន់ថា ចង់ប្រឆាំងបះបោរនឹងអង្គការ និងចង់រត់ទៅប្រទេសវៀតណាម ។ ឡោះ និង តូច បានឲ្យដឹងថា ក្រោយការចាប់ខ្លួន ឃុំឃាំង និងសួរចម្លើយអ្នកទោសត្រូវបានឃុំឃាំងបន្ទប់ដាច់ពីគ្នា២ គឺអ្នកទោសធ្ងន់និងអ្នកទោសស្រាល ។ អ្នកទោសធ្ងន់ ជាប់គុកងងឹត ជាប់ខ្នោះទាំងដៃទាំងជើង ហើយមិនត្រូវបានអនុញ្ញាតឲ្យចេញក្រៅឡើយ សូម្បីពេលបន្ទោរបង់ ។

អ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់មាន២ប្រភេទ គឺអ្នកទោសស្រាលនិងអ្នកទោសធ្ងន់ ។ អ្នកទោសស្រាលជាប់ឃុំឃាំងក្នុងបន្ទប់ ដែលមានពន្លឺថ្ងៃចេញចូលនិងត្រូវដាក់ខ្នោះជើង ។ អ្នកទោសស្រាលត្រូវប្រើឲ្យធ្វើការងារផ្សេងៗ ជាពិសេសការងារកសិកម្មបម្រើដល់ដំណើរការរបស់មន្ទីរសន្តិសុខ ។ អ្នកទោសស្រាលជាអ្នកទោសដែលបានឆ្លងកាត់សភាពជាអ្នកទោសធ្ងន់ ឆ្លងកាត់ការសួរចម្លើយ ប៉ុន្តែមិនទាន់ត្រូវបានសម្រេចប្រហារជីវិត ។ ចំណែកអ្នកទោសធ្ងន់ត្រូវដាក់ឃុំឃាំងក្នុងបន្ទប់ងងឹតនិងជាប់ខ្នោះដៃនិងជើង ។ អ្នកទោសធ្ងន់ក្នុងមន្ទីរសន្តិសុខតំបន់ដែលលេខាតំបន់និងភូមិភាគយល់ថា មានជាប់ពាក់ព័ន្ធជាខ្សែសង្វាក់ប្រឆាំងនឹងអង្គការត្រូវបញ្ជូនបន្តទៅមន្ទីរសន្តិសុខមជ្ឈិមហៅមន្ទីរស-២១ ។

**របបអាហារ**

អាហាររបស់អ្នកទោសមន្ទីរសន្តិសុខតំបន់ មានពីរពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់និងពេលល្ងាច ។ អ្នកទោសទទួលបានរបបអាហារពេលថ្ងៃនៅម៉ោង១១ ឬ ១១ : ៣០នាទី និងពេលល្ងាចនៅម៉ោង៥ ។ របបអាហារទាំង២ពេលនោះមានបបររាវលាយត្រកួន ត្រកៀត គល់ចេក និង ម្សៅជ្រៃ ។

ប៉ាន អតីតកម្មាភិបាលមន្ទីរសន្តិសុខតំបន់២៥ រៀបរាប់ថា អ្នកទោសមានរបបអាហារថ្ងៃត្រង់មួយពេលនិងល្ងាចមួយពេល ។ ប៉ាន បញ្ជាក់ថា មានអ្នកទោសពីរបីនាក់ត្រូវបានចាត់តាំងការងារដាំបាយនិងដួសបាយជាអ្នកបំពេញការងារនេះ ប៉ុន្តែរបបត្រូវកំណត់ឲ្យជាស្រេចគឺបបរពីរបីវែក សម្រាប់អ្នកទោសម្នាក់ ។ វឿន កម្មាភិបាលការពារអ្នកទោសបានឲ្យដឹងថា របបកំណត់សម្រាប់អ្នកទោស"ហូបមិនគ្រប់គ្រាន់ទេ វេទនាណាស់" ។ សុង អ្នកទោសមន្ទីរសន្តិសុខតំបន់២៥ រៀបរាប់ថា គាត់និងអ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់២៥ ពិតជាទទួលបានបបរមួយវែកលាយគល់ចេកម្សៅជ្រៃ រាល់ថ្ងៃមែន ។ អ្នកទោសអាចហូបបានតែពីរពេលគត់ ហើយនៅពេលយប់ហេវប្បូចង់ផឹកទឹកក៏ពួកគាត់ផឹកមិនបានដែរ ។ ហាក់ បញ្ជាក់ថា ប្រដាប់ប្រដាហូបចុករបស់អ្នកទោស មានចានដែកម្នាក់មួយចំណែកស្លាបព្រាវិញ គឺគ្រាប់ស្វាយចិតជាពីរសម្រាប់ដួសហូប ។ ស្ថានភាពហូបចុកនិងរបបអាហាររបស់អ្នកទោសមន្ទីរសន្តិសុខតំបន់២៥ តាមការប្រៀបធៀបរបស់ ហាក់ គឺរបបអាហាររបស់"សត្វជ្រូក" ។ របបអាហារពេលនោះធ្វើឲ្យអ្នកទោសដើរមិនរួច ម្នាក់ៗត្រូវវារប្រវេប្រវា ។ សុង រៀបរាប់ថា "អ្នកទោសរញ៉េរញ៉ៃ ខ្យល់បក់ខ្វាំងដួល" ។ អ្នកទោសមន្ទីរសន្តិសុខតំបន់២៥ម្នាក់ទៀតឈ្មោះ ម៉ៅ រអ៊ីវទាំថា គាត់បានហូបបបររាវលាយម្សៅជ្រៃ និងពេលខ្លះមានតែកន្ទក់ ដូច្នេះហើយបានមកទល់សព្វថ្ងៃ សុខភាពនៅតែមានលក្ខណៈមិនស្រួលឡើយ ។

បបរលាយដំឡូង គឺជារបបអាហារស្ទើរប្រចាំថ្ងៃរបស់អ្នកទោសមន្ទីរសន្តិសុខតំបន់៣៥ ។ អ្នកទោសទទួលបានបបរមួយកូនចានចង្កឹះលាយដំឡូងនិងអំបិល ។ អ្នកទោសធ្ងន់ទទួលបានរបបបបរលាយនឹងដំឡូងមួយពេលក្នុងមួយថ្ងៃ ចំណែកអ្នកទោសស្រាលវិញ អាចទទួលបានពីរពេលក្នុងមួយថ្ងៃ ។ លី ពន្យល់មូលហេតុនៃរបបអាហារខុសគ្នារបស់អ្នកទោសថា អ្នកទោសស្រាលអាចជួយធ្វើការក្នុងមន្ទីរសន្តិសុខបាន ។ ចំណែកអ្នកទោសធ្ងន់វិញ កម្មាភិបាលមន្ទីរសន្តិសុខប្រាប់ថា "ពួកគ្មានបានប្រយោជន៍" ។ របបអាហារបបររាវមួយកូនចានចង្កឹះរាល់ថ្ងៃធ្វើឲ្យក្រពះរបស់ ដី ឡោះ ជួបប្រទះបញ្ហាយ៉ាងធ្ងន់ធ្ងរ ។ ក្រពះរបស់គាត់ពេលនោះ "លែងដំណើរការ" ។ បន្ទាប់ពីត្រូវបានដោះលែងពីមន្ទីរសន្តិសុខ ដី ឡោះ បានចំណាយពេលយ៉ាងយូរទើបអាចហូបបាយនិងសម្ល ធម្មតាបាន ។ ដី ឡោះ ត្អូញត្អែរពីសុខភាពទ្រុឌទ្រោមរបស់គាត់ដែលបន្សល់ពីរបបកម្ពុជាប្រជាធិបតេយ្យថា "ឥឡូវនេះសុខភាពខ្ញុំនៅតែមិនល្អ ព្រោះពេលជាប់គុកវាឲ្យយើងហុតទឹកបបរមួយកូនចានដ៏រ ក្នុងមួយថ្ងៃបន្ទាប់ពីបានរួចខ្លួនមកយើងនៅតែមិនអាចហូបអ្វីបានដដែល បើហូបមិនយូរប៉ុន្មានទេ ត្រូវចេញមកវិញភ្លាម ព្រោះក្រពះវាមិនធ្វើការ ។ ខ្ញុំចំណាយពេលរាប់ខែទើបអាចហូបបានបន្តិចៗឡើងវិញ" ។ **(នៅមានត)** **អៀ ម៉េងទ្រី**

# ដំណើរទស្សនកិច្ចលើកទី៧របស់ប្រជាជនមកកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅខែសីហានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចលើកទីប្រាំពីរ ដោយបានអញ្ជើញប្រជាជនឲ្យមកទស្សនាអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការខ្មែរក្រហម) ។ ជាទូទៅក្នុងដំណើរទស្សនកិច្ចនីមួយៗ ប្រជាជនដែលមកពីតាមបណ្ដាខេត្តទាំងអស់នៅទូទាំងប្រទេស បានអញ្ជើញទៅទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បូជនីយដ្ឋានវាលពិឃាតជើងឯក និងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លើកនេះ ដោយសារផ្លូវទៅកាន់បូជនីយដ្ឋានវាលពិឃាតជើងឯកត្រូវទឹកជំនន់កាត់ផ្ដាច់ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំជូនប្រជាជនឲ្យមកទស្សនាតែសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនិងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប៉ុណ្ណោះ ។

នៅក្នុងដំណើរទស្សនកិច្ចលើកទីប្រាំពីរនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនចំនួន ៥១០ នាក់ មកពីខេត្តចំនួន៨ រួមមាន : ខេត្តកណ្ដាល កំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពត កំពង់ស្ពឺ និងក្រចេះ ។ ក្នុងចំណោមនោះ ក៏មានបងប្អូនជនជាតិចាមនិងដូនជីចូលរួមដែរ ។ ដូចគ្នានឹងដំណើរទស្សនកិច្ចលើកមុនៗ ក្រៅពីដើរទស្សនាកន្លែងទាំងពីរខាងលើប្រជាជនបានចូលរួមស្ដាប់ការបកស្រាយច្បាប់និងការពន្យល់អំពីដំណើរការនិងការប្រព្រឹត្តទៅនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីសមាជិកសភា មន្ត្រីតុលាការ និងអ្នកជំនាញការច្បាប់ ។

ប្រជាជនដែលបានចូលរួមទាំងអស់បានសម្ដែងនូវការសប្បាយរីករាយ ដោយបានឃើញការបង្កើតឡើងតុលាការមួយដែលមានកម្រិតស្ដង់ដារអន្ដរជាតិផ្ទាល់ភ្នែក ដើម្បីស្វែងរកយុត្តិធម៌ជូនគាត់ ។ ជាងនេះទៅទៀត ប្រជាជនកាន់តែយល់ច្បាស់អំពីច្បាប់និងដំណើរការកាត់សេចក្ដីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនដែលបានអញ្ជើញមកទាំងអស់នឹងនាំនាំពត៌មានដែលខ្លួនទទួលបានក្នុងដំណើរទស្សនកិច្ចលើកនេះ ទៅចែកជូនបងប្អូននិងអ្នកជិតខាងដែលមិនបានអញ្ជើញមក ។

**ប៊ាន ពីរ័ន**



ប្រជាជនចូលរួមស្ដាប់ការស្រាយបំភ្លឺរបស់ក្រុមអ្នកច្បាប់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២



ប្រជាជនកំពុងសម្លឹងមើលរូបភាពទារុណកម្មនៅមន្ទីរស-២១



ប្រជាជនចូលរួមស្ដាប់និងសួរសំណួរទៅកាន់មន្ត្រីតុលាការខ្មែរក្រហម

# ខ្មាំងបដិវត្តន៍ ៖ ទោស និង ទណ្ឌកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនប្រមាណពីរលាននាក់បានស្លាប់ដោយការអត់អាហារ ការធ្វើការហួសកម្លាំង ជំងឺគ្មានថ្នាំព្យាបាល និងការសម្លាប់ ។ ក្នុងចំណោមអ្នកស្លាប់ប្រមាណពីរលាននាក់ ប្រវត្តិវិទូ បែន ឃៀរនិន ធ្វើការសន្និដ្ឋានថាប្រជាជនប្រហែលប្រាំសែននាក់ស្លាប់ដោយការសម្លាប់ ដោយការចោទពីបទក្បត់ជាតិ ក្បត់បដិវត្តន៍ និងបានប្រព្រឹត្តអំពើផ្សេងៗទៀត ដែលខ្មែរក្រហមយល់ថាជាអំពើឧក្រិដ្ឋប្រឆាំងនឹងរដ្ឋ ហើយដែលត្រូវតែកម្ទេចចោលជាដាច់ខាតដើម្បីរក្សាសន្តិសុខសង្គមនិងសុវត្ថិភាពបដិវត្តន៍ ។ ក្នុងចំណោមនេះជនរងគ្រោះមួយម៉ឺនបួនពាន់នាក់ត្រូវបានចាប់ខ្លួនបញ្ជូននិងសម្លាប់នៅមន្ទីរស-២១ (គុកទួលស្លែង) ។*

*នៅក្នុងរយៈកាលជិតបួនឆ្នាំនៃរបបនេះ ក្រៅពីរដ្ឋធម្មនុញ្ញដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ គ្មានច្បាប់ណាផ្សេងទៀតត្រូវបានបង្កើតនិងអនុម័តឲ្យប្រើប្រាស់ក្នុងប្រទេសកម្ពុជាប្រជាធិបតេយ្យក្នុងនាមជាប្រជាជាតិមួយនោះទេ ។ សូម្បីតែសភាតំណាងប្រជាជនកម្ពុជា ដែលជាអង្គការបង្កើតច្បាប់តែមួយគត់បានជួបប្រជុំគ្នាតែម្តងគត់ គឺពីថ្ងៃទី១១ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ។ម្យ៉ាងវិញទៀតរដ្ឋធម្មនុញ្ញដែលមានតែ២១មាត្រានោះត្រូវបានបង្កើតឡើងដើម្បីឲ្យអន្តរជាតិមើលឃើញថា កម្ពុជាប្រជាធិបតេយ្យជាប្រទេសឯករាជ្យនិងអធិបតេយ្យ ដែលមានរដ្ឋធម្មនុញ្ញមានការគោរពច្បាប់ និងមានការបែងចែកអំណាចច្បាស់លាស់ គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិនិងអំណាចតុលាការ ។ រដ្ឋធម្មនុញ្ញមិនមានចែងអ្វីទាំងអស់ទាក់ទងនឹងវត្តមានតួនាទី និងករណីយកិច្ចរបស់បក្សកុម្មុយនិស្តកម្ពុជា ទោះបីជាបក្សបានដើរតួនាទីគ្រប់គ្រងទាំងស្រុងទៅលើរដ្ឋកម្ពុជាប្រជាធិបតេយ្យក៏ដោយ ។*

*រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមិនបានចែងឲ្យច្បាស់លាស់អំពីតួនាទីនៃអំណាចតុលាការកម្រិតនៃទោសនិងទណ្ឌកម្មទេ ។ មាត្រា៩នៃរដ្ឋធម្មនុញ្ញបានចែងថា ៖ "តុលាការជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន...." ។ ផ្ទុយទៅវិញ មិនមានរចនាសម្ព័ន្ធតុលាការណាមួយត្រូវបានបង្កើតឡើងទេ ។ អង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជាបានជ្រើសតាំងគណៈកម្មាធិការតុលាការមួយដែលមាន កង ចាប ជាប្រធាន ។ ប៉ុន្តែគណៈកម្មាធិការនេះមិនមានដំណើរការអ្វីទាំងអស់ ហើយក៏មិនមានតុលាការខេត្តក្រុងណាមួយត្រូវបានបង្កើតឡើងសម្រាប់តំណាងឲ្យយុត្តិធម៌របស់ប្រជាជននិងស្វែងរកយុត្តិធម៌ឲ្យប្រជាជន ដូចដែលបានអះអាងក្នុងរដ្ឋធម្មនុញ្ញនោះទេ ។ អ្នកស្រាវជ្រាវជាន់ខ្ពស់ ស៊ីវ ហេឌ័រ បានអះអាងថា ការកាត់ទោសត្រូវបានអនុវត្តដោយប្រធានសហករណ៍ គណៈស្រុក គណៈតំបន់ ឬគណៈភូមិភាគ ដែលទទួលបញ្ជាតាមឋានានុក្រមពីការកំណត់របស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ដែលជាអង្គការតែមួយគត់មានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ និងការកំណត់មាគ៌ានយោបាយរបស់ជាតិ ។ ការកាត់ទោសភាគច្រើនត្រូវបានធ្វើឡើងដោយសម្ងាត់ក្រោមលេសថា "អង្គការស្នើឲ្យទៅរៀនសូត្រឬទៅប្រជុំ" ។*

*ប៉ុល ពត មើលឃើញប្រជាជនទូទាំងប្រទេស សូម្បីតែកសិករក្រដែលបក្សទុកចិត្តជាងគេនោះ ថានៅមានឥទ្ធិពលបរទេសនិងឥទ្ធិពលអាក្រក់ពីសង្គមចាស់នៅឡើយ ។ ប្រការនេះជារឿងដ៏ស្មុគស្មាញ និងពិបាកដោះស្រាយបំផុតសម្រាប់បក្សដែលចង់កសាងសង្គមកម្ពុជាបរិសុទ្ធមួយ ។ ម្យ៉ាងទៀត ប៉ុល ពត យល់ឃើញថា មនុស្សមួយចំនួនរួមទាំងកម្មាភិបាលជាន់ខ្ពស់របស់គាត់ផង បាននិងកំពុងរៀបចំផែនការក្បត់ដើម្បីផ្តួលរំលំរដ្ឋាភិបាលទើបបង្កើតថ្មី ដែលមានរូបគាត់ផ្ទាល់ជានាយករដ្ឋមន្ត្រី ។ នៅក្នុងសៀវភៅ "សត្រូវបងប្អូនឯង" ណាយ៉ាន់ ចាន់ដា បានបញ្ជាក់ថា មានផែនការសម្លាប់ ប៉ុល ពត ដោយដាក់ថ្នាំបំពុលនៅក្នុង*

អាហារប្រចាំថ្ងៃរបស់គាត់ ។ ប៉ុន្តែ ប៉ុល ពត អាចរួចផុតពីគ្រោះថ្នាក់នេះ ដោយសារកងការពាររបស់គាត់ភ្លក់អាហារទាំងនេះមុន ហើយត្រូវពុលស្លាប់ភ្លាមៗ ។ អ្នកស្រាវជ្រាវរូបនេះបានអះអាងបន្ថែមថា នេះជាមូលហេតុចម្បងមួយដែល ប៉ុល ពត លាលែងពីតំណែងនាយករដ្ឋមន្ត្រីនៅខែកញ្ញា ឆ្នាំ១៩៧៦ ហើយ នួន ជា ដែលជាអនុលេខាបក្ស ត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រីបណ្តោះអាសន្ន ។ បន្ទាប់ពីការលាលែងពីតំណែងនេះភ្លាម ការចាប់ខ្លួនថ្នាក់ដឹកនាំជាន់ខ្ពស់ កម្មាភិបាល និងមេបញ្ជាការទ័ពមួយចំនួនទៀតត្រូវបានធ្វើឡើង ។ អ្នកទាំងនេះត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ដើម្បីសួរចម្លើយស្វែងរកចាប់ខ្លួនបក្ខពួកក្បត់ផ្សេងៗទៀត ហើយមនុស្សជាច្រើនត្រូវបានចាប់ខ្លួនបញ្ជូនចូលមន្ទីរនេះជាបន្តបន្ទាប់ ។

ប្រជាជនរាប់សែននាក់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋផ្សេងៗ ហើយត្រូវទទួលទោសប្រហារជីវិត ទោះជារដ្ឋធម្មនុញ្ញមិនបានចែងពីទោសប្រហារជីវិតក៏ដោយ ។ មាត្រា១០នៃរដ្ឋធម្មនុញ្ញបានចែងពីបទល្មើសពីរប្រភេទ "ចំពោះប្រភេទសកម្មភាពប្រឆាំងនិងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយមានគ្រោះថ្នាក់ដល់រដ្ឋ ប្រជាជន ត្រូវផ្តន្ទាទោសខ្ពស់បំផុត ។ ចំពោះបទល្មើសក្រៅពីប្រភេទខាងលើ ត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន" ។ តើទោសខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាទោសអ្វី? តើកំហុសកម្រិតណាដែលត្រូវកំណត់ថាជាទោសប្រហារជីវិត? តើការកាត់ទោសប្រព្រឹត្តទៅតាមនីតិវិធីបែបណាខ្លះ? ដើម្បីបកស្រាយនូវសំណួរទាំងនេះ ខ្ញុំសូមធ្វើការវិភាគពីទោសនិងទណ្ឌកម្មទៅតាមប្រភេទអ្នកដែលខ្មែរក្រហមចោទថាជាខ្មាំង ជាជនក្បត់ជាតិ ឬជាជនក្បត់បដិវត្តន៍ ដូចខាងក្រោម ៖

## បទល្មើសប្រឆាំងបដិវត្តន៍និងរដ្ឋ

ការកាត់ទោសប្រហារជីវិតស្ទើរតែក្លាយទៅជាបទដ្ឋានទូទៅមួយសម្រាប់យកមកអនុវត្តនៅក្នុងដំណើរការនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យទៅហើយ ។ ការប្រហារជីវិតនេះកើតមានឡើងចំពោះប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈនិងគ្រប់និន្នាការនយោបាយទាំងអស់ ។ អ្នកដែលត្រូវបានសម្លាប់ក្រោមបទល្មើសទាំងនេះរួមមាន ៖

***អតីតអ្នករដ្ឋការនិងទាហានរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ*** ៖ មុនជ័យជម្នះ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានប្រកាសប្រហារជីវិតថ្នាក់ដឹកនាំជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរតែប្រាំពីររូបប៉ុណ្ណោះ រួមមានប្រធានាធិបតី លន់ នល់, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ, លោកនាយករដ្ឋមន្ត្រី ឡុង បូរ៉េត, ចេង ហេង, អ៊ិន តាំ, សឺន ង៉ុកថាញ់ និងរដ្ឋមន្ត្រីក្រសួងការពារជាតិឧត្តមសេនីយ៍ សូស្តែន ហ្វេណង់ដែស ដែលខ្មែរក្រហមហៅថាជា"មហាជនក្បត់" ។ ប៉ុន្តែ បន្ទាប់ពីទទួលបានជ័យជម្នះភ្លាម ខ្មែរក្រហមបានសម្លាប់អតីតមន្ត្រីជាន់ខ្ពស់រដ្ឋបាលស៊ីវិល នាយទាហាន និងពលទាហានរាប់ពាន់នាក់ ។ នៅក្នុងអត្ថបទ "រដ្ឋប្រហារទម្លាក់លោកសេនាប្រមុខ លន់ នល់" របស់លោក ឆាំង សុង ដែលជារដ្ឋមន្ត្រីក្រសួងព័ត៌មាននិងឃោសនាការនៃរបបសាធារណរដ្ឋខ្មែរបានបញ្ជាក់ថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពអាវខ្មៅខ្មែរក្រហមបានសម្លាប់ឧត្តមសេនីយ៍ លន់ ណុន ប្អូនប្រុសលោកសេនាប្រមុខ លន់ នល់ ហើយកាត់ក្បាលយកទៅចងព្យួរនៅក្បែរផ្សារថ្មីដើម្បីឲ្យប្រជាជនមើល ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានចូលទៅជ្រកកោននៅក្នុងស្ថានទូតបារាំងជាមួយជនបរទេសប្រហែល៦០០នាក់និងជនជាតិខ្មែរជាង១០០នាក់ផ្សេងទៀត ។ ខ្មែរក្រហមបានបញ្ជាឲ្យជនជាតិខ្មែរទាំងអស់ចាកចេញពីបរិវេណស្ថានទូតហើយបញ្ជូនអ្នកទាំងនេះទៅជនបទដូចអ្នកឯទៀតដែរ ។ ព្រះអង្គម្ចាស់ សិរិមតៈ ត្រូវខ្មែរក្រហមប្រហារជីវិតភ្លាមៗនៅក្បែរស្ថានទូត ។ លោកនាយករដ្ឋមន្ត្រី ឡុង បូរ៉េត ត្រូវកងទ័ពខ្មែរក្រហមព័ទ្ធចាប់បាននៅក្នុងបរិវេណពហុកីឡដ្ឋានអូឡាំពិក នៅពេលដែលលោកឡើងជិះឧទ្ធម្ភាគចក្រជាមួយមន្ត្រីជាន់ខ្ពស់ដទៃទៀតរួមទាំងឧត្តមសេនីយ៍ សាក់ ស៊ុតសាខន ប៉ុន្តែលោកបានចុះមកវិញ ដោយសារតែឧទ្ធម្ភាគចក្រនៅសល់តែមួយកន្លែងសម្រាប់លោក និងមិនអាចមានកន្លែងថែមសម្រាប់ឲ្យប្រពន្ធកូននិងបងប្អូនរបស់លោកចំនួនដប់បួននាក់ទៀត ។

ក្រៅពីការប្រហារជីវិតមេដឹកនាំទាំងបីនេះ មន្ត្រីជាន់ខ្ពស់និងនាយទាហានផ្សេងៗទៀតដែលរត់ទៅក្រៅប្រទេសមិនទាន់ក៏ត្រូវបានសម្លាប់នៅថ្ងៃនោះដែរ ។ ខ្មែរក្រហមបានដាក់របាំង

ការពារតាមផ្លូវ ដើម្បីស្វែងរកចាប់ខ្លួនទាហាន លន់ នល់ ។ យោង តាមឯកសារនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បក្សកុម្មុយនិស្តកម្ពុជាបានដាក់ផែនការឲ្យកងទ័ពភូមិភាគទាំងអស់ ឆែកឆេរតាមគ្រប់ច្រកចេញពីភ្នំពេញ "ភូមិភាគនីមួយៗត្រូវរៀបចំកន្លែងឆែកឆេរហើយមានភារកិច្ច (១) សង្កេតឆែកឆេររកជនក្បត់ គឺអ្នកទទួលតំណែងធំៗ (២) ទាហានសាធារណរដ្ឋខ្មែរ លន់ នល់ (៣) ពួកគិញ (៤) អ្នកដែលរត់ចេញពីបក្សមកចូលនឹង លន់ នល់" ។ ទោះជាឯកសារនេះមិនបានបញ្ជាក់ថាខ្មែរក្រហមមានផែនការសម្លាប់ទាហាន លន់ នល់ ក៏ដោយ ក៏ប្រជាជនជម្លៀសជាច្រើនបានឃើញឬបានជួបហេតុការណ៍នេះដោយផ្ទាល់ ។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបសម្ភាសន៍ជាមួយ ស្រី ហោះ សង្វារ ហៅសង្ហា ពីរឿងរ៉ាវឪពុករបស់គាត់ដែលជាអតីតមេបញ្ជាការរងយុទ្ធភូមិភាគពិសេសក្នុងរបបសាធារណរដ្ឋខ្មែរ ។ សង្ហា បានរៀបរាប់ថា ខ្មែរក្រហមបានប្រកាសតាមវិទ្យុជាតិឲ្យឧត្តមសេនីយ៍និងមន្ត្រីជាន់ខ្ពស់ទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ មកជួបជុំគ្នានៅក្រសួងឃោសនាការដើម្បីចរចាសន្តិភាពនិងរៀបចំទទួលសម្តេចព្រះនរោត្តម សីហនុ ។ ឪពុករបស់ សង្ហា ឈ្មោះ ស្រី យ៉ា ក៏បានទៅចូលរួមនៅទីនោះដែរ ។ ហេតុការណ៍នេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងសៀវភៅ "រដ្ឋប្រហារទម្លាក់លោកសេនាប្រមុខ លន់ នល់" ។ នៅក្នុងចំណោមមន្ត្រីដែលទៅចូលរួមតាមការប្រកាសទាំងនោះ រួមមានឧត្តមសេនីយ៍យ៉ាងតិច៣០នាក់ ដូចជាឧត្តមសេនីយ៍ ឈឹម ឈួន ឧត្តមសេនីយ៍ យ៉ុង យក់ហង់ ឧត្តមសេនីយ៍ ម៉ី ស៊ីចន ឧត្តមនាវី វង់ សារិនឌី ។ល ។ បន្ទាប់ពីប្រមូលប្រវត្តិរូបបានគ្រប់គ្នាហើយ ខ្មែរក្រហមបានអញ្ជើញមន្ត្រីនិងឧត្តមសេនីយ៍ទាំងនោះឡើងលើរថយន្តឆ្ពោះទៅម៉ុំអង់តែនវិទ្យុស្ទឹងមានជ័យហើយសម្លាប់ចោលទាំងអស់ ។

ការកាត់ទោសប្រហារជីវិតដោយគ្មានការវិនិច្ឆ័យឲ្យបានត្រឹមត្រូវនេះ មិនមែនកើតមានឡើងតែនៅក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះទេ នៅតំបន់ផ្សេងៗទៀតទូទាំងប្រទេសក៏មានហេតុការណ៍ដូចៗគ្នាកើតឡើងដែរ ។ នៅក្នុងសៀវភៅ "ក្រឡេកមើលក្រោយវិញនៃរឿងដ៏សែនខ្លោចផ្សាមួយ" លោក អុង ថុងហឿង បានសរសេររៀបរាប់ពីព្រឹត្តិការណ៍ដ៏ព្រៃផ្សៃមួយដែលកើតមានឡើងនៅក្នុងខេត្តបាត់ដំបង ។ ខ្មែរក្រហមបានប្រើវិធីសាស្ត្របោកបញ្ឆោតតែមួយក្នុងការសម្លាប់មន្ត្រី នាយទាហាន និងពលទាហានបម្រើការនៅខេត្តបាត់ដំបង ។ នៅពេលចូលកាន់កាប់បានក្រុងបាត់ដំបងភ្លាម ខ្មែរក្រហមបានប្រកាសឲ្យអតីតនាយទាហាននិងពលទាហានគ្រប់ជាន់ថ្នាក់ទាំងអស់ស្លៀកពាក់ឯកសណ្ឋានទៅតាមឋានន្តរស័ក្តិរបស់ខ្លួនដើម្បីទៅទទួលសម្តេចឪ ។ ខ្មែរក្រហមបានយកឡានជាច្រើន គ្រឿងមកដឹកទាហានទាំងអស់នោះទៅកាន់ព្រៃមួយដែលមានកងទ័ពខ្មែរក្រហមពួនចាំនៅជុំវិញនោះជាស្រេច ។ ទៅដល់ទីនោះ ភ្លាមមេខ្មែរក្រហមម្នាក់បានបញ្ជាឲ្យអតីតទាហានទាំងអស់នោះចុះពីលើឡាន ។ កងទ័ពខ្មែរក្រហមដែលពួនទីនោះបានបាញ់ស្រោចមកលើអ្នកទាំងនេះ ។ មានមនុស្សតិចតួចណាស់ដែលអាចរត់រួចពីវាលពិឃាតនេះ ។

ព្រឹត្តិការណ៍នេះសបញ្ជាក់ឲ្យឃើញថា មន្ត្រី នាយទាហាននិងពលទាហានរបស់របបសាធារណរដ្ឋខ្មែរទាំងអស់ត្រូវបានខ្មែរក្រហមចាត់ទុកថាជាជនក្បត់ជាតិ និងជាសត្រូវទីមួយរបស់ខ្លួន ។ ខ្មែរក្រហមយល់ថា អ្នកទាំងអស់នេះលែងមានប្រយោជន៍អ្វីទៀតហើយសម្រាប់ការកសាងជាតិតទៅអនាគត ហើយជាជនដែលមានគ្រោះថ្នាក់បំផុតចំពោះផែនការបដិវត្តន៍របស់ខ្លួន ។ មិនតែប៉ុណ្ណោះ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញនិងតំបន់ទាំងឡាយណាដែលជាអតីតតំបន់គ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់ថាជាជនឃុបឃិតនឹងជនក្បត់ ហើយត្រូវបានចាត់ទុកថាជា "ប្រជាជនថ្មី" ដែលគ្មានសិទ្ធិអ្វីទាំងអស់នៅក្នុងសង្គមក្នុងនាមជាប្រជាជននៃប្រជាជាតិមួយ ។ ទោះជាយ៉ាងនេះក្តី អតីតអ្នករដ្ឋការ និងនាយទាហានជាច្រើននាក់បានព្យាយាមលាក់អត្តសញ្ញាណរបស់ខ្លួន ហើយអាចរួចរស់ជីវិតបានមួយពេលឬរួចរស់ជីវិតរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**ភ្នាក់ងារសម្ងាត់របស់បរទេស** ៖ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាតែងតែមានការព្រួយបារម្ភជានិច្ចចំពោះការជ្រៀតជ្រែកពីសំណាក់បរទេស ពិសេសការឈ្លានពានពីសំណាក់ប្រទេសជិតខាងគឺប្រទេសវៀតណាមនិងប្រទេសថៃ ។ តាមរយៈបទពិសោធន៍ពីរបបមុនៗ មេដឹកនាំទាំងនេះមើលឃើញថា ប្រទេសកម្ពុជា

មិនដែលមានឯករាជ្យពេញបរិបូណ៌ទេ ហើយថាប្រជាជនកម្ពុជា ជាពិសេស ប្រជាជនក្រីក្រនៅតំបន់ជនបទតែងតែទទួលរងគ្រោះ ដោយសារតែមេដឹកនាំមួយក្តាប់តូចដែលព្រមទទួលយកឥទ្ធិពលរបស់បរទេសរហូតធ្វើឲ្យប្រទេសក្លាយទៅជារណបរបស់បរទេសទៀតផង ។ ហេតុដូចនេះហើយ ខ្មែរក្រហមមើលឃើញប្រជាជនមួយចំនួនថាជាភ្នាក់ងារសម្ងាត់សេ.អ៊ី.អារបស់អាមេរិក ភ្នាក់ងារសម្ងាត់កា.ហ្សេ.បេ.របស់សូវៀត និងភ្នាក់ងារសម្ងាត់របស់វៀតណាម ។ ប្រជាជន១៧មេសាគឺអ្នកដែលជម្លៀសពីភ្នំពេញនិងទីប្រជុំជននានាត្រូវបានសង្ស័យថា ជាភ្នាក់ងារសម្ងាត់របស់បរទេស ហើយមួយចំនួនត្រូវបានចោទប្រកាន់ដោយច្រឡំ និងត្រូវប្រហារជីវិតទៀតផង ។

ប៉ុល ពត និងមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាដទៃទៀត យល់ឃើញថា កម្ពុជាគឺជាចំណុចក្តៅមួយដែលប្រទេសមហាអំណាចមួយចំនួនដូចជាសហរដ្ឋអាមេរិក សហភាពសូវៀត និងចិន រួមទាំងប្រទេសជិតខាងដូចជា វៀតណាម និង ថៃ ចង់បានបំផុត ដើម្បីពង្រីកឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក៏ដូចនៅលើពិភពលោក ។ សាស្ត្រាចារ្យ ដេវីដ ឆេនល័រ បានស្រាវជ្រាវឃើញឯកសារមួយចំនួននៅមន្ទីរស-២១ ដែលបានបង្ហាញឲ្យឃើញពីការប្រមើលមើលរបស់បក្សកុម្មុយនិស្តកម្ពុជាដែលនៅខែមីនា ឆ្នាំ១៩៧៦ បក្សមើលឃើញថា វៀតណាមបានសហការជាមួយប្រទេសថៃនិងសហរដ្ឋអាមេរិកក្នុងគោលបំណងកម្ទេចកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបក្សពលករដាណឺម៉ាក នៅខែកក្កដា ឆ្នាំ១៩៧៨


ការធ្វើទារុណកម្មនៅគុកធំ ខេត្តសៀមរាប
គំនូរដោយៈ ស៊ី រិទ្ធី (អតីតអ្នកទោសនៅគុកធំ)

នួន ជា បានធ្វើការចោទប្រកាន់ត្រង់ៗថា ក្រុមសេ.អ៊ី.អា និងក្រុមកា.ហ្សេ.បេ បានប្រកួតប្រជែងគ្នាដើម្បីកាន់កាប់កម្ពុជាប្រជាធិបតេយ្យ ។ បក្សកុម្មុយនិស្តកម្ពុជាយល់ឃើញថាការវាយប្រហាររបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យមិនមែនជាការសងសឹកចំពោះទង្វើរបស់កម្ពុជាប្រជាធិបតេយ្យដែលបានវាយចូលទឹកដីវៀតណាម ហើយសម្លាប់ជនស៊ីវិលវៀតណាមអស់រាប់រយនាក់ទេ ប៉ុន្តែជាមហិច្ឆតារបស់ កា.ហ្សេ.បេ និងវៀតណាមទៅវិញ ។ នៅក្នុងសេចក្តីថ្លែងការណ៍នេះ បក្សកុម្មុយនិស្តកម្ពុជាក៏បានចោទប្រកាន់ពីការប៉ុនប៉ងរបស់សេ.អ៊ី.អា អាមេរិក ដែលបានធ្វើប្រតិបត្តិការនៅតាមព្រំដែនថៃ ។ ដំហរបែបនេះធ្វើឲ្យមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាកើតជំងឺសង្ស័យកាន់តែច្រើនឡើងៗទៅលើកម្មាភិបាលបក្សរបស់ខ្លួនដែលនាំដល់ការចាប់ខ្លួននិងសម្លាប់យ៉ាងច្រើននៅទូទាំងប្រទេស ។

មនុស្សមួយចំនួនទៀតដែលត្រូវជាប់ចោទថាជាគិញសម្ងាត់របស់បរទេសគឺនិស្សិតដែលបានចេញទៅរៀននៅបរទេសដូចជាអតីតសហភាពសូវៀត បារាំង កាណាដា អាមេរិក និងមន្ត្រីទូតដែលចេញទៅបំពេញបេសកកម្មក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥ នៅប្រទេសមួយចំនួន ដែលទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងដែលបង្កើតឡើងនៅទីក្រុងប៉េកាំងក្នុងឆ្នាំ១៩៧០ ។ ក្រោយជ័យជម្នះឆ្នាំ១៩៧៥ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស បានបញ្ជាឲ្យប្រធានបេសកកម្មការទូតទាំងអស់របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាវិលត្រឡប់ចូលមកក្នុងប្រទេសវិញ ដើម្បីសិក្សាផ្នែកព័ត៌មានរយៈពេលបីបួនសប្តាហ៍ ។ មន្ត្រីទូតទាំងនេះបានត្រឡប់ចូលមកក្នុងប្រទេសវិញនៅខែធ្នូ ឆ្នាំ១៩៧៥ ។ បណ្តានិស្សិតដែលចេញទៅសិក្សានៅបរទេសក៏ត្រូវបានអំពាវនាវឲ្យចូលមកក្នុងប្រទេស ក្រោមលេសថាចូលមកជួយកសាងប្រទេសដែលខ្ទេចខ្ទាំដោយសង្គ្រាម និងកំពុងខ្វះអ្នកបច្ចេកទេស ។

យោងតាមចម្លើយសារភាពរបស់និស្សិតនិងមន្ត្រីទូតមួយចំនួន ដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១បន្ទាប់ពីវិលត្រឡប់មកដល់កម្ពុជាភ្លាម និស្សិតនិងមន្ត្រីទូតនៅបរទេសទាំងអស់មិនបានដឹងថាមានអ្វីកំពុងកើតមានឡើងនៅក្នុងប្រទេស

ទេ ដោយសារតែប្រព័ន្ធទូរគមនាគមន៍ត្រូវបានកាត់ផ្តាច់ទាំងស្រុង ។ ប្រកតែមួយគត់ដែលអាចទាក់ទងមកកម្ពុជាបានគឺតាមរយៈស្ថានទូតកម្ពុជាប្រចាំប្រទេសចិន ដែលស្ថិតក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹងរបស់ខ្មែរក្រហម ។ ដំណឹងពីភាពមិនប្រក្រតីមួយចំនួនបានលេចឮទៅក្រៅប្រទេសតាមរយៈជនភៀសខ្លួន ។ ទោះជាយ៉ាងនេះក្តី ជនជាតិខ្មែរនៅបរទេសមិនសូវខ្វល់ខ្វាយនឹងព័ត៌មានទាំងនេះឡើយ ដោយយល់ឃើញថាប្រទេសដែលទើបតែងើបពីសង្គ្រាមតែងតែមានហេតុការណ៍ហិង្សាមួយចំនួនមិនអាចជៀសបាន ។ ម្យ៉ាងទៀត អ្នកទាំងនេះមិនជឿថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាដែលធ្លាប់រស់នៅរៀនសូត្ររួមសុខរួមទុក្ខជាមួយគ្នានៅបរទេស និងសុទ្ធតែជាអ្នករៀនសូត្រចេះដឹងជ្រៅជ្រះនឹងធ្វើទុក្ខទោសឬកាប់សម្លាប់អ្នកចេះដឹងដូចគ្នាឡើយ ។

បក្សកុម្មុយនិស្តកម្ពុជាកសាងប្រទេសដោយយកកសិករនិងកម្មករជាធំ ដែលបក្សយល់ថាជាមនុស្សស្អាតស្អំនិងគួរជាទីទុកចិត្ត ។ បក្សមិនប្រើមនុស្សដែលធ្លាប់រស់នៅរៀនសូត្រ និងទទួលឥទ្ធិពលពីបរទេសឡើយ ទោះបីជាការពិតមេដឹកនាំបក្សមួយចំនួនទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិតពីបរទេសក៏ដោយ ។ ពេលត្រឡប់ចូលមកក្នុងប្រទេសភ្លាម និស្សិតនិងមន្ត្រីទូតទាំងអស់ត្រូវបានប្រមូលផ្តុំនៅសាលាបឹងត្របែក និងសាលាបច្ចេកទេសដើម្បីទទួលការអប់រំមួយរយៈសិន ។ ផ្ទុយពីការរំពឹងទុក ដែលថាខ្លួននឹងបានចូលបម្រើការតាមក្រសួងមន្ទីរនានានៅទីក្រុងភ្នំពេញ និស្សិតទាំងនេះត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែចម្ការនៅតាមជនបទដាច់ស្រយាល ។ យោងតាមចម្លើយសារភាពរបស់ ហួត សម្បត្តិ អគ្គទូតនិងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមួយចំនួនដែលត្រឡប់ចូលមកក្នុងប្រទេសវិញ ដូចជា ចាន់ យូរ៉ាន់, សារិន ឆាក, អ៊ិន សុភាព, និងព្រះអង្គម្ចាស់ នរោត្តម ភូរិស្សរ៉ា ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើពលកម្មដូចជា សង់ផ្ទះ កាប់ដីដាំដំណាំ ប្រឡេះគ្រាប់ពោតហាល ស្ងោរពោត និងចិញ្ចឹមត្រី ។ នៅចុងបញ្ចប់ ហួត សម្បត្តិ ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ក្រោមបទឧក្រិដ្ឋចូលរួមជាមួយសេ.អ៊ី.អាក្បត់នឹងបដិវត្តន៍ ។ ចម្លើយសារភាពខ្លះមានរៀបរាប់ពីប្រវត្តិសកម្មភាពក្បត់ចូលសេ.អ៊ី.អា ឬកា.ហ្សេ.បេ និងមានរាយនាមនិស្សិតដែលធ្លាប់ទៅរៀនសូត្រនៅបរទេសជាមួយគ្នា ។ និស្សិតមួយចំនួនដែលខិតខំធ្វើពុតជាមនុស្សល្ងង់ខ្លៅនិងលាក់អត្តសញ្ញាណរបស់ខ្លួនជាយូរមកហើយ ត្រូវអង្គការចាប់បញ្ជូនមកមន្ទីរស-២១ ដោយសារតែខ្លួនជាប់ក្នុងបញ្ជីសេ.អ៊ី.អា ឬកា.ហ្សេ.បេ ។

ជនជាតិខ្មែរនៅកម្ពុជាក្រោមមួយចំនួន ដែលតូចចិត្តចំពោះការរើសអើងនិងការធ្វើទុក្ខបុកម្នេញពីសំណាក់រដ្ឋាភិបាលវៀតណាម បានរត់ភៀសខ្លួនចូលមកកម្ពុជាប្រជាធិបតេយ្យក្នុងគោលដៅរួមកម្លាំងជាមួយខ្មែរក្រហម ដើម្បីរំដោះទឹកដីកម្ពុជាក្រោមពីការគ្រប់គ្រងរបស់វៀតណាម ។ ទោះជាខ្មែរនៅកម្ពុជាក្រោមទាំងនេះមានដើមកំណើតជាជនជាតិខ្មែរក្តី សម្រាប់ខ្មែរក្រហម អ្នកទាំងនេះបានរស់នៅក្រោមការត្រួតត្រានិងទទួលឥទ្ធិពលមនោគមវិជ្ជារបស់វៀតណាម ដែលខ្មែរក្រហមចាត់ទុកជា“សត្រូវស្ទូពូជ” ។ ដូច្នេះ ខ្មែរកម្ពុជាក្រោមទាំងអស់ មិនទទួលបានការទុកចិត្តពីបក្ស ហើយថែមទាំងចោទថាជាគិញសម្ងាត់របស់វៀតណាមទៀត ។ អ្នកដែលត្រូវបានរកឃើញថា មកពីកម្ពុជាក្រោមទាំងអស់ត្រូវបានចាប់ដាក់គុកនិងទទួលរងនូវការកាប់សម្លាប់ស្ទើរគ្មានសល់ ។ ហង់រី ឡូកា បញ្ជាក់ថា ខ្មែរក្រោមមួយចំនួនដែលភៀសខ្លួនចូលមកកម្ពុជាប្រជាធិបតេយ្យ តាមខេត្តតាកែវត្រូវកងទ័ពភូមិភាគចាប់ដាក់គុកក្នុងស្រុកត្រាំកក់ក្នុងភូមិភាគនិរតីដែលមាន តាម៉ុកជាលេខា ។

ជនជាតិខ្មែរមួយចំនួនផ្សេងទៀតនៅភូមិភាគបូព៌ា មិនត្រឹមតែត្រូវបានចោទប្រកាន់ថាជាគិញសម្ងាត់របស់វៀតណាមប៉ុណ្ណោះទេ ថែមទាំងត្រូវបានចោទប្រកាន់ជាចំហដោយមជ្ឈិមបក្សថាចូលដៃចូលជើងជាមួយវៀតណាមដើម្បីបំផ្លាញកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនមួយភាគធំក្នុងភូមិភាគបូព៌ា ត្រូវបានមជ្ឈិមបក្សកំណត់ថាជាមនុស្ស “ក្បាលយួនខ្លួនខ្មែរ” ដែលមានន័យស្មើជនក្បត់ជាតិនិងដែលត្រូវតែកម្ទេចចោលជាដាច់ខាត ។

កត្តាទាំងអស់ខាងលើនេះធ្វើឲ្យមជ្ឈិមបក្សកើតការសង្ស័យទៅលើប្រជាជនស្ទើរគ្រប់រូប ហើយទីបំផុតសូម្បីតែកម្មាភិបាលរបស់បក្សក៏ត្រូវជាប់ចោទពីបទចូលរួមសកម្មភាពរបស់សេ.អ៊ី.អា កា.ហ្សេ.បេ ឬគិញសម្ងាត់របស់បរទេសដទៃទៀតដែរ ។ មជ្ឈិមបក្សបានបញ្ជាឲ្យចាប់ខ្លួនសមាជិកជាន់ខ្ពស់បក្សមួយចំនួន ដែល

បក្សសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងសកម្មភាពទាំងអស់នេះ ។ ក្នុងនោះ កុយ ធួន ដែលជាអតីតលេខាភូមិភាគឧត្តរនិងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវជាប់ចោទថាជាភ្នាក់ងារសេ.អ៊ី.អារបស់អាមេរិក ហើយត្រូវបានបញ្ជូននិងសម្លាប់នៅមន្ទីរស-២១ ។ អ្នកនៅក្រោមបង្គាប់របស់ កុយ ធួន ដូចជា ទីវ អុល, ភោគ ឆាយ និងកម្មាភិបាលក្រសួងពាណិជ្ជកម្មមួយចំនួនទៀតត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ។ ទីបំផុតបញ្ចប់ ភូមិភាគឧត្តរទាំងមូលត្រូវបានធ្វើវិសុទ្ធកម្មក្រោមបញ្ជារបស់មជ្ឈិមបក្ស ។

***សមាជិកបក្សដែលត្រូវបានចោទថាជាជនក្បត់*** ៖ ចាប់ពីចុងឆ្នាំ១៩៧៦ ការស្វែងរកចាប់ខ្លួននិងការធ្វើវិសុទ្ធកម្មបានរាលដាលដល់កម្មាភិបាលបក្ស ហើយនៅទីបំផុតមេដឹកនាំជាន់ខ្ពស់បក្សមួយចំនួនក៏ត្រូវបានសម្លាប់ពីបទចោទប្រកាន់ថាក្បត់ជាតិនិងចូលដៃចូលជើងជាមួយបរទេសក្នុងការបំផ្លាញកម្ពុជាប្រជាធិបតេយ្យ ។ ក្រៅពីភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក និងភូមិភាគកណ្ដាលដឹកនាំដោយ កែ ពក ថ្នាក់ដឹកនាំភូមិភាគនិងថ្នាក់ដឹកនាំតំបន់ផ្សេងទៀត រួមទាំងកម្មាភិបាលនៅតាមភូមិភាគនិងតំបន់ត្រូវបានផ្លាស់ប្ដូរជាញឹកញាប់ ។ អ្នកដែលបានផ្លាស់ចេញត្រូវជាប់ចោទពីបទឧក្រិដ្ឋផ្សេងៗ ។ អ្នកខ្លះត្រូវបានសម្លាប់នៅនឹងកន្លែង ហើយមេដឹកនាំធំៗត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខមជ្ឈិមស-២១ដើម្បីសួរចម្លើយស្វែងរកបក្សពួកក្បត់បន្ថែមទៀត ។

យោងតាមចម្លើយសារភាពរាប់សែនសន្លឹកបន្សល់ទុកនៅមន្ទីរស-២១ អ្នកទោស ភាគច្រើនបានសារភាពថា បានចូលដៃចូលជើងជាមួយខ្មាំង រិះគន់នយោបាយដឹកនាំរបស់បក្ស និងធ្វើសកម្មភាពផ្សេងៗដើម្បីបំផ្លាញបដិវត្តន៍ ។ ទោះជាយ៉ាងនេះក្ដីចម្លើយសារភាពភាគច្រើនជាចម្លើយមិនពិត ព្រោះអ្នកទោសបានឆ្លើយនូវអ្វីដែលខ្លួនអាចនឹកឃើញ ដើម្បីឲ្យស្របទៅតាមការចង់បានរបស់អ្នកសួរចម្លើយ ធ្វើយ៉ាងណាឲ្យតែបានរួចផុតពីទារុណកម្មហួសវិស័យ ។ នៅក្នុងសៀវភៅ«សំឡេងពីមន្ទីរស-២១» សាស្ត្រាចារ្យ ដេវីដ ឆេនល័រ បានអះអាងថា អ្នកសួរចម្លើយបានប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីចម្រាញ់យកចម្លើយមួយដែលធ្វើឲ្យថ្នាក់លើពេញចិត្ត ដែលប្រការនេះគឺជាគោលការណ៍មួយរបស់មជ្ឈិមបក្សក្នុងការធ្វើយុត្តិកម្មនៃការកាត់ទោសប្រហារជីវិតអ្នកទោសទាំងអស់នោះ ។ ដោយមិនអាចទ្រាំទ្រនឹងទារុណកម្មយ៉ាងធ្ងន់ធ្ងរអ្នកទោសជាច្រើន ជាពិសេសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានសរសេរចម្លើយសារភាពរាប់រយសន្លឹកដែលរៀបរាប់ពីសកម្មភាពរបស់ខ្លួនតាំងពីតូច ជាពិសេសសកម្មភាពក្បត់រហូតដល់ថ្ងៃចាប់ខ្លួន ។ ចុងក្រោយនៃចម្លើយសារភាពមានរាយនាមបក្សពួកក្បត់ជាច្រើន ដែលក្រោយមកអ្នកដែលមានឈ្មោះក្នុងបញ្ជីទាំងប៉ុន្មានបានក្លាយទៅជាជនក្បត់ជាតិនិងក្បត់បដិវត្តន៍ដោយស្វ័យប្រវត្តិ ហើយមួយចំនួនត្រូវអង្គការរកឃើញនិងត្រូវបានចាប់បញ្ជូនទៅមន្ទីរស-២១ និងត្រូវទទួលទោសប្រហារជីវិតដូចអ្នកមុនៗដែរ ។ នៅក្នុងចម្លើយសារភាពរាប់រយទំព័រ មានចម្លើយរបស់ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មាននិងឃោសនាការ កុយ ធួន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាអតីតលេខាភូមិភាគឧត្តរ ជូ ជេត លេខាភូមិភាគបស្ចិម ណៃ សារ៉ាន់ លេខាភូមិភាគឦសាន ។ល ។

នៅក្នុងចម្លើយសារភាពផ្សេងៗទៀតដែលមានកម្រាស់ពីពីរទៅដប់ទំព័រ អ្នកទោសបានរៀបរាប់ពីសកម្មភាពក្បត់ដែលមិនគួរឲ្យជឿ ។ ទោះបីជាសកម្មភាពទាំងនោះពិតជាត្រូវបានប្រព្រឹត្តឡើងក្ដី ក៏នៅលើពិភពលោកនេះមិនដែលមានប្រទេសណាមួយបង្កើតច្បាប់កាត់ទោសប្រហារជីវិតចំពោះកំហុសបែបនេះឡើយ ។ ចម្លើយសារភាពផ្ដេសផ្ដាសទាំងនោះរួមមានបំផុសយុវជនឲ្យខ្ជាចខ្ជាំងចូលរួមលួចដំឡូងយកមកស្ងោរហូប បង្ហូរទឹកចេញពីសន្ទូងអស់មួយហិកតា បំផ្លាញសំណាប បំផុសយុទ្ធជនពីរនាក់ឲ្យរត់ទៅផ្ទះ បំផ្លាញសម្ភារ ដើរស៊ីដឹកសេរី ប្រយុទ្ធធ្វើស្រែមិនបាន បំផ្លាញជ្រូកប្រជាជនអស់បីក្បាល លួចគោប្រជាជនយកមកកាប់ស៊ី ពុតធ្វើឈឺ បំផុសកម្មករកុំឲ្យខំធ្វើការ លែងគោឲ្យស៊ីស្រូវ បំផុសយុវជនឲ្យបំផ្លាញចានម្ដងបន្តិចៗដើម្បីបំផ្លាញបដិវត្តន៍ ។ ប្រសិនបើទង្វើទាំងអស់នេះត្រូវប្រព្រឹត្តមែន តើអំពើទាំងនេះអាចធ្វើឲ្យបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ ដែលមេដឹកនាំខ្មែរក្រហមអះអាងថាខ្លាំងក្លា ភ្លឺស្វាងជាងបដិវត្តន៍ចិននិងបដិវត្តន៍វៀតណាមទៅទៀតនោះ ដួលរលំបានដែរឬទេ? ក្រៅពីចម្លើយទាំងនេះ អ្នកទោសក៏បានឆ្លើយពីទោសកំហុសដទៃទៀតដែលខ្លួនបានធ្វើដូចជាប្រមូលកម្លាំងវាយបដិវត្តន៍ បំផុស

ចលនាខ្មែរសេរី ពង្រីកកម្លាំងក្បត់ កសាងកម្លាំងបន្តប់ស៊ីរូងផ្ទៃក្នុងជួរបដិវត្តន៍ បំផុសប្រជាជនឲ្យស្អប់បដិវត្តន៍ កសាងកម្លាំង សេ.អ៊ី.អា កម្ទេចផលដំណាំសហករណ៍ ប្រមូលសម្ភារត្រៀមផែនការវាយបក្ស វាយប្រហារមាគ៌ាបក្សជាដើម ។ ទាំងអស់នេះគឺជាទោសឧក្រិដ្ឋធ្ងន់បំផុតសម្រាប់ខ្មែរក្រហមដែលបណ្តាលឲ្យមានការសម្លាប់រង្គាលនៅទូទាំងប្រទេស ។

ការវាយប្រហារឬការរិះគន់ចំពោះមាគ៌ាដឹកនាំ ឬគោលនយោបាយរបស់បក្សបាននាំទៅដល់វិសុទ្ធកម្មដ៏សាហាវឃោរឃៅនៅភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ និងជាពិសេសភូមិភាគបូព៌ា ។ ណាយ៉ាន់ ចាន់ដា បានអះអាងថា ថ្នាក់ដឹកនាំភូមិភាគបានទិតៀននយោបាយឆ្វេងជ្រុលហួសហេតុនិងនយោបាយផ្សងព្រេងរបស់ ប៉ុល ពត ដែលចង់សម្រេចឲ្យបានលទ្ធិសង្គមនិយមក្នុងរយៈពេលដ៏ខ្លី ។ មេដឹកនាំភូមិភាគទាំងនេះក៏មិនពេញចិត្តចំពោះគោលនយោបាយរបស់បក្សក្នុងការដាក់ការកៀបសង្កត់ ការរើសអើងប្រឆាំងនឹងប្រជាជនថ្មី (ឬប្រជាជន១៧មេសា) ។ ជាពិសេសអ្នកទាំងនេះបានទិតៀននយោបាយព្រហើនហួសមាឌរបស់បក្សក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសវៀតណាមដែលជាប្រទេសជិតខាងមួយមានកម្លាំងខ្លាំងជាងកម្ពុជាប្រជាធិបតេយ្យទាំងចំនួនប្រជាជន សេដ្ឋកិច្ច នយោបាយ និងយោធា ។ កត្តាទាំងអស់នេះបានធ្វើឲ្យមជ្ឈិមបក្សបញ្ជូនទ័ពពីភូមិភាគនិរតីមកវាយប្រហារភូមិភាគបូព៌ានិងភូមិភាគពាយ័ព្យ ។ ជាលទ្ធផល ប្រជាជនប្រហែលមួយសែននាក់នៅភូមិភាគបូព៌ាត្រូវបានសម្លាប់យ៉ាងរង្គាលក្នុងរយៈពេលមួយដ៏ខ្លី ។

ព្រឹត្តិការណ៍កាប់សម្លាប់នេះបានធ្វើឲ្យកម្មាភិបាលបក្សភូមិភាគបូព៌ាមួយចំនួនធំភៀសខ្លួនទៅព្រំដែនវៀតណាមដើម្បីគេចពីសេចក្តីស្លាប់ ហើយអ្នកទាំងនេះទទួលបានការគាំពារពីសំណាក់រដ្ឋាភិបាលវៀតណាមទៀតផង ។ ការណ៍នេះបានធ្វើឲ្យមជ្ឈិមបក្សចោទប្រកាន់ដោយចំហថា កម្មាភិបាលនិងប្រជាជនក្នុងភូមិភាគបូព៌ាគឺជាពួក "ក្បាលយួនខ្លួនខ្មែរ" ដែលបក្សចាត់ទុកថាជាអំពើមហាក្បត់ជាតិមួយយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចលើកលែងទោសឲ្យបាន ។ នៅក្នុងសៀវភៅ "របប ប៉ុល ពត" ប្រវត្តិវិទូ បែន គៀរនិន បញ្ជាក់ថា នៅក្នុងសភាពការណ៍បែបនេះ សោ ភឹម លេខាភូមិភាគបូព៌ានិងជាមនុស្សដែលមាននិន្នាការទៅរកវៀតណាម ហើយដែលធ្លាប់ស្នាក់នៅរៀនសូត្រនៅវៀតណាមតាំងពីទសវត្សឆ្នាំ១៩៤០មកមានគោលជំហរមិនទាន់ច្បាស់លាស់នៅឡើយ ។ នៅពេលនោះ មជ្ឈិមបក្សបានកោះហៅ សោ ភឹម ទៅចូលរួមប្រជុំនៅភ្នំពេញដែលជាលេសមួយដើម្បីសម្លាប់មេដឹកនាំរូបនេះ បន្ទាប់ពីវិលត្រឡប់មកពីព្យាបាលរោគនៅប្រទេសចិន ។ កម្មាភិបាលថ្នាក់ក្រោមជាច្រើនបានឲ្យយោបល់កុំឲ្យ សោ ភឹម ទៅប្រជុំ ។ ប៉ុន្តែ សោ ភឹម ដែលជាកម្មាភិបាល ជើងចាស់របស់បក្សមិនជឿថា ប៉ុល ពត នឹងកម្ចាត់គាត់ចេញពីបក្សនោះទេ ។ បែន គៀរនិន បានជួបសម្ភាសផ្ទាល់ជាមួយកម្មាភិបាលជាន់ខ្ពស់ ភូមិភាគបូព៌ា ដែលនៅជាប់ជាមួយ សោ ភឹម ហើយដែលបានអះអាងបន្ថែមថា សោ ភឹម បានបញ្ជូននិរសារម្នាក់ឲ្យទៅផ្តល់ដំណឹងដល់មជ្ឈិមបក្សពីការមកដល់របស់ខ្លួន ។ និរសាររូបនេះ បានបាត់ខ្លួន



មិនឃើញត្រឡប់មកវិញ ។ នៅទីបំផុត សោ ភឹម ត្រូវកងទ័ពមជ្ឈិមបាញ់ឲ្យរបួសក្នុងខណៈពេលធ្វើដំណើរមកដល់មុំអរិយក្សត្រ ។ សោ ភឹម និងកងការពារជាច្រើននាក់ទៀតបានរត់បកក្រោយវិញ ប៉ុន្តែត្រូវឡោមព័ទ្ធដោយកងទ័ពមជ្ឈិម ។ ដោយអស់សង្ឃឹមនៅក្នុងជីវិតបដិវត្តន៍របស់ខ្លួន សោ ភឹម បានផ្តែផ្តាំកម្មាភិបាលដែលនៅសេសសល់ទាំងប៉ុន្មានឲ្យរត់ទៅមុនគាត់ ហើយដឹកនាំទ័ពទៅចុះចូលជាមួយវៀតណាម ដើម្បីធ្វើការតស៊ូប្រឆាំងនឹង ប៉ុល ពត វិញ ។ សោ ភឹម បានដកកាំភ្លើងខ្លីបាញ់សម្លាប់ខ្លួនឯង ។ ជីវិតបដិវត្តន៍ជិត៤០ឆ្នាំត្រូវបានបញ្ចប់ ។

ការទិតៀនឬការនិយាយ អាក្រក់ពីបក្សគឺជារឿងមួយដែលមិនអាចទទួលយកបានជា ដាច់ខាត និងជាអំពើក្បត់បក្ស ក្បត់បដិវត្តន៍និងក្បត់ជាតិ ។ សម្រាប់មេដឹកនាំខ្មែរក្រហមអង្គការមិនដែលប្រព្រឹត្តកំហុស ហើយមិនដែលសម្រេចចិត្តខុសទាល់តែសោះ ។ ណាយាន់ ចាន់ដា បានដកស្រង់អត្ថបទ របស់ ស៊ីវ ហេឌ័រ ដែលបាន អះអាងថា “សម្រាប់ ប៉ុល ពត និងមេដឹកនាំជិតស្និទ្ធរបស់គាត់ មួយក្តាប់តូច ការចោទប្រកាន់ពីអំពើក្បត់គឺជាមធ្យោបាយងាយស្រួលមួយ ដើម្បីគេចចេញពីការពិភាក្សាតទល់គ្នាខាងផ្នែកនយោបាយដែលក្នុងនោះ អ្នកដែលជំទាស់នឹង ប៉ុល ពត មិនប្រាកដថា មានប្រៀបលើគាត់ឡើយ ហើយមុខជានឹងបង្កឲ្យមានភាពបាក់បែកគ្នាក្នុងបក្ស” ។ ជាទស្សីករណ៍ ហ៊ូ យន់ ដែលបានជំទាស់នឹងនយោបាយ បំបាត់ផ្សារ បំបាត់សាលារៀន បំបាត់សាសនា និងការជម្លៀស ប្រជាជនចេញពីទីក្រុង បានបាត់ខ្លួនតាំងពីពេលដែលខ្មែរក្រហមទើបទទួលបានជ័យជម្នះភ្លាមៗម្ល៉េះ ។ អ្នកស្រាវជ្រាវភាគច្រើនបានសន្និដ្ឋានថា ហ៊ូ យន់ ត្រូវបានសម្លាប់ក្រោមបញ្ជាពីមជ្ឈិមបក្ស ដោយសារតែគំនិតប្រឆាំងរបស់គាត់ ។

ជាទូទៅ ការសម្លាប់កម្មា ភិបាលបក្សខ្លួនឯងមានលក្ខណៈខុសគ្នាពីការប្រហារជីវិតអ្នករដ្ឋការ និងទាហានរបស់របបសាធារណរដ្ឋខ្មែរ ។ ផ្ទុយពីអ្នករដ្ឋការរបបចាស់ ដែលត្រូវបានសម្លាប់ភ្លាមៗនៅនឹងកន្លែងនៅពេលអត្តសញ្ញាណរបស់ខ្លួនត្រូវបានរកឃើញ ។ កម្មាភិបាលនិងកងទ័ពខ្មែរក្រហមដែលជាប់ចោទពីបទល្មើសផ្សេងៗជាទូទៅត្រូវឆ្លងកាត់ការសម្លាប់ដែលមានលក្ខណៈជាប្រព័ន្ធមួយរួមមាន ការចាប់ខ្លួន ការឃុំឃាំង ការសួរចម្លើយ ទារុណកម្ម និងការសម្លាប់ ។

ការធ្វើទារុណកម្មនិងការដាក់ទោសទណ្ឌមានលក្ខណៈឃោរឃៅបំផុត ។ ដើម្បីចម្រាញ់យកចម្លើយដែលខ្លួនចង់បានអ្នកសួរចម្លើយបានប្រើវិធីសាស្ត្រសាហាវព្រៃផ្សៃផ្សេងៗ ដូចជាបង្ខំឲ្យអ្នកទោសដេកហាលថ្ងៃច្រើនម៉ោង វាយខ្លួនប្រាណនឹងដំបងឬស្នូកកាំភ្លើង ឆក់ខ្សែភ្លើង ឬចងជើងព្យួរឡើងលើក្បាលចុះក្រោមពេញមួយថ្ងៃ ។ វិធីសាស្ត្រសាហាវជាងនេះត្រូវអ្នកស្រាវជ្រាវរកឃើញថាបានយកមកអនុវត្តនៅក្នុងមន្ទីរសន្តិសុខថ្នាក់មជ្ឈិម ឬហៅថាមន្ទីរស-២១(គុកទួលស្លែង) ដែលមាន ឌុច ជាប្រធានមន្ទីរ ហើយដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងការពារជាតិដែលមាន សុន សេន ជារដ្ឋមន្ត្រី ។ ទណ្ឌកម្មទាំងនោះរួមមានដកក្រចក ចាក់អាល់កុលពីលើ ដាក់ដៃចូលទៅក្នុងទ្រុងក្អែប ប្រកក្បាលចូលក្នុងថង់ប្លាស្ទិកធ្វើឲ្យថប់ដង្ហើម បង្ខំឲ្យស៊ីលាមកឬផឹកទឹកនោម ឬបង្ខំឲ្យសំពះតុកៅអី ឬរូបឆ្កែ ។

បន្ទាប់ពីទទួលរងទារុណកម្មខាងលើ អ្នកទោសនឹងត្រូវបាន












កាត់ទោសប្រហារជីវិតដោយគ្មានការជំនុំជម្រះក្ដីអ្វីបន្តិចឡើយ ។ អ្នកទោសនឹងត្រូវដឹកតាមឡានទៅកាន់វាលពិឃាត ហើយត្រូវបានវាយសម្លាប់ត្រង់ផ្នែកខាងក្រោយនៃក្បាលជាមួយនឹងដងចបជីបង ស្នូកកាំភ្លើង ឬខ្នងពូថៅ ។ អ្នកទោសខ្លះត្រូវបាញ់សម្លាប់ជាក្រុម ហើយកប់ក្នុងរណ្ដៅសាកសពរួមដែលជួនកាលមានចំនួនច្រើនជាងមួយរយនាក់ ។ វិធីសាស្ត្រនេះបានផ្ដល់រំលំសសរទ្រូងជាតិអស់ជាច្រើន ដែលបានបើកឱកាសឲ្យវៀតណាមប្រើពេលតែពីរសប្ដាហ៍ប៉ុណ្ណោះក្នុងការផ្ដួលរំលំកម្ពុជាប្រជាធិបតេយ្យ ។

### ទោសកំហុសផ្សេងៗ

មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដូចជា ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន និង ខៀវ សំផន សុទ្ធតែជាអ្នកធ្លាប់បានរៀនសូត្រនិងទទួលបានសញ្ញាប័ត្រខ្ពង់ខ្ពស់ពីបរទេស ។ អ្នកទាំងនេះយល់ឃើញថាខ្លួនបានលះបង់ជីវិតឯកជន ហើយរត់ចូលព្រៃធ្វើបដិវត្តន៍ ដោយសង្ឃឹមថាខ្លួននឹងអាចរំដោះប្រទេសជាតិនិងប្រជាជនចេញពីអំពើអយុត្តិធម៌ទាំងឡាយដែលកើតមានក្នុងសង្គមខ្មែរអស់រាប់សតវត្សរ៍មកហើយ ។ ហង់រី ឡូកាបានអះអាងថា មេដឹកនាំទាំងនេះរំពឹងថាប្រជាជនកម្ពុជាទូទាំងប្រទេសនឹងលះបង់សេចក្ដីសុខនិងជីវភាពឯកជនដូចដែលខ្លួនបានធ្វើដើម្បីចូលរួមក្នុងចលនាបដិវត្តន៍ដែរ ។ មេដឹកនាំខ្មែរក្រហមយល់ឃើញថា ការរួបរួមកម្លាំងគ្នាជាធ្លុងមួយពីសំណាក់ប្រជាជនគ្រប់ស្រទាប់វណ្ណៈគឺរស់នៅរួមគ្នា ហូបរួម ប្រើប្រាស់រួម ធ្វើការរួម ដែលខ្មែរក្រហមឲ្យឈ្មោះថា "សមូហភាវូបនីយកម្ម" ជាវិធីតែមួយគត់ដែលអាចវាយដណ្ដើមយក "យុត្តិធម៌និងសមភាព" ក្នុងសង្គមជូនជាតិនិងប្រជាជនកម្ពុជាវិញ ។ ប្រសិនបើមើលសំបកក្រៅមនុស្សគ្រប់រូបទោះជាអ្នកមិនបានរៀនសូត្រជ្រៅជ្រះក៏នឹងយល់ស្របថា នេះគឺជាគំនិតប្រកបដោយគតិបណ្ឌិតនិងពោរពេញទៅដោយមនសិការស្នេហាជាតិខ្ពស់បំផុត ។ ប៉ុន្តែនេះគ្រាន់តែជាគំនិតស្រមើស្រមៃនិយមជ្រុលហួសហេតុប៉ុណ្ណោះ ។ ជាងនេះទៅទៀត គ្រឿងផ្សំដែលមេដឹកនាំខ្មែរក្រហមជ្រើសរើសក្នុងការផ្សំឲ្យចេញជាធាតុ"សមូហភាវូបនីយកម្ម"គឺ ពោរពេញទៅដោយភាពលីងដូរចត់និងសាហាវយង់ឃ្នង់ ដែលមនុស្សជាតិមិនអាចទទួលយកបាន ។

ប្រជាជនទាំងឡាយណាដែលបញ្ចេញកាយវិការផ្ទុយនឹងការកំណត់របស់អង្គការត្រូវបានចោទថាជាខ្មាំង ហើយជាទូទៅត្រូវបានសម្លាប់ ឬយ៉ាងហោចណាស់ក៏ត្រូវបានបញ្ជូនទៅជំរំអប់រំកែប្រែ ដែលនៅទីនោះប្រជាជនត្រូវទទួលរងនូវការធ្វើទុក្ខបុកម្នេញ ឬទារុណកម្មធ្ងន់ធ្ងរ ។ សកម្មភាពគ្រប់បែបយ៉ាងទោះបីជាធ្វើឡើងដោយចេតនាក្ដី ដោយអចេតនាក្ដី ឬធ្វើឡើងដោយបន្ទំចិត្តក្ដីគឺត្រូវមានទោសទាំងអស់ ។ តាំ ម៉ាន ជនជាតិចាមរស់នៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ត្រូវខ្មែរក្រហមវាយនឹងឫស្សីរហូតមានស្នាកស្នាមជាប់ក្បាលដល់សព្វថ្ងៃ ។ ទោសកំហុសរបស់ ម៉ាន គឺដោយសារតែគាត់ដេកមមើហើយ ស្រែកថា "កាប់ៗៗ" ដែលជាពាក្យមួយបង្ហាញពីការបះបោរប្រឆាំងនឹងខ្មែរក្រហម ព្រោះថានៅពេលនោះ ជនជាតិចាមក្នុងឃុំស្វាយឃ្លាំងបានបះបោរប្រឆាំងនឹងខ្មែរក្រហម ។ ជនជាតិចាមជាច្រើនត្រូវបានសម្លាប់នៅនឹងកន្លែង ហើយមួយចំនួនទៀតត្រូវបានចាប់ដាក់មន្ទីរឃុំឃាំង ។ ម៉ាន ក៏ត្រូវជាប់ក្នុងមន្ទីរឃុំឃាំងដែរ ដោយគាត់មានជាប់ពាក់ព័ន្ធនឹងសកម្មភាពបះបោរនេះ ។

នៅក្នុងការប្រកបការងារប្រចាំថ្ងៃជូនបដិវត្តន៍ អ្នកដែលអង្គការមើលឃើញថាមានគុណវិបត្តិច្រើននឹងត្រូវចាត់ទុកថាជាខ្មាំង ។ អង្គការយល់ឃើញថាជនប្រភេទនេះលែងមានប្រយោជន៍អ្វីសម្រាប់បដិវត្តន៍ទៀតហើយៗត្រូវតែកម្ទេចចោលដើម្បីជាគំរូដល់ជនដទៃទៀត ក្រោមពាក្យស្លោកមួយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ។ អ្វីដែលខ្មែរក្រហមចាត់ទុកថាជាគុណវិបត្តិមានដូចជា លួចដាំបាយ ឬស្ងោរដំឡូងហូបជាឯកជនដោយមិនចែកចាយជាមួយសមូហភាព ឬលួចបេះបោចដំណាំដែលខ្លួនបានដាំនៅក្បែរផ្ទះ ។ ដោយមិនអាចទ្រាំទ្របាននឹងការងារធ្ងន់ៗប្រចាំថ្ងៃជាមួយនឹងរបបអាហារដ៏តិចតួច ប្រជាជនភាគច្រើនបានឆ្លៀតស្វែងរកបេះបោចស្លឹកឈើព្រៃ ឬចាប់សត្វល្អិតដូចជាកន្ធាត កណ្ដុរ ខ្យង ឬ ពស់ មកធ្វើជាអាហារបន្ថែម ។ អ្នកខ្លះទៀតលួចបេះដំណាំក្បែរផ្ទះនៅពេលយប់ដោយប្រថុយនឹងគ្រោះថ្នាក់បំផុត ព្រោះថាទង្វើបែបនេះត្រូវបានចាត់ទុកថាក្បត់សមូហភាពដែលអាចទទួលរងទណ្ឌកម្មធ្ងន់ធ្ងរឬចាប់ដាក់គុក ។ នៅក្នុងសៀវភៅ "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" លឿង អ៊ុង បានរៀបរាប់

ពីទារុណកម្មដែលបងប្រុសរបស់គាត់ឈ្មោះ គីម ត្រូវខ្មែរក្រហមវាយរហូតដល់បែកឈាមពេញខ្លួន ដោយសារ គីម បានលួចកាច់ពោតនៅពេលយប់យកមកធ្វើជាអាហារបន្ថែមសម្រាប់គ្រួសារ ហើយត្រូវកងឈ្លបខ្មែរក្រហមចាប់បាន។ គីម ត្រូវបានកងឈ្លបដោះលែងឲ្យមកផ្ទះវិញ បន្ទាប់ពីទទួលទារុណកម្មយ៉ាងដំណំ។

អ្នកជំងឺបណ្តាលមកពីការធ្វើការហួសកម្លាំងឬហូបមិនគ្រប់គ្រាន់ ត្រូវបានអង្គការចោទថា ជាមនុស្សមានពុត ឬឈឺសតិអារម្មណ៍។ ប្រជាជនគ្រប់រូបស្ទើរតែគ្មានសិទ្ធិឈឺ។ អ្នកជំងឺត្រូវបានចាត់ទុកថាជាមនុស្សអសកម្មចំពោះបដិវត្តន៍ ហើយមានតែមនុស្សធ្វើការមិនចេះនឿយហត់និងមិនចេះត្អូញត្អែរទេទើបមានប្រយោជន៍សម្រាប់អង្គការ ដូចដែល ហង់រី ឡូកា បានកត់ត្រាពាក្យស្លោកខ្មែរក្រហមមួយចំនួនដែលរិះគន់ចំពោះអ្នកជំងឺថា *“គាត់ហ្នឹងឈឺជំងឺសន្តមចាស់ ទាល់តែដាក់ថ្នាំលេនីន។ ដេកផ្សំផ្តួលរមួលផ្សំគ្រេច ឈឺតិចៗថាឈឺខ្លាំង ពួកមិត្តឯងទុកក៏មិនចំណេញ ដកចេញក៏មិនខាត” “គ្រុនញាក់គ្រុនញ័រ គ្រុនត្រាក់ទ័រគ្រុនឡាន គ្រុនបាយបាន គ្រុនខ្វល់ដើល គ្រុនសតិអារម្មណ៍”*។

អ្នកជំងឺមួយចំនួនទទួលបានការអនុញ្ញាតឲ្យសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។ ប៉ុន្តែជាទូទៅឪពុកម្តាយឬបងប្អូនមិនត្រូវបានអនុញ្ញាតឲ្យទៅថែរក្សាអ្នកជំងឺនៅមន្ទីរពេទ្យទេព្រោះជាការចំណាយពេលឥតប្រយោជន៍។ ខ្មែរក្រហមនិយាយថា *“មិត្តមិនបាច់ទៅមើលអ្នកជំងឺទេ ពីព្រោះមិត្តមិនមែនជាគ្រូពេទ្យ ហើយក៏មិនមែនជាវេជ្ជបណ្ឌិតដែរ...” “អ្នកមានជំងឺមិនចាំបាច់ស៊ីទេ ពីព្រោះជំងឺវាធ្វើឲ្យបាត់ការស្រេកឃ្លាន ឯការអត់អាហារបណ្តាលឲ្យជាសះស្បើយ”*។

## សេចក្តីសន្និដ្ឋាន

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស្ទើរគ្រប់រូបរស់នៅក្នុងឋានៈជាជនសង្ស័យដែលមានទណ្ឌភាពជាប់ខ្លួន ហើយដែលអាចត្រូវអង្គការយកទៅកាត់ទោសនៅថ្ងៃណាមួយដោយមិនដឹងខ្លួន។ ប្រជាជនថ្មីក្លាយជាអ្នកទោសដោយស្វ័យប្រវត្តិ។ ខ្មែរក្រហមនិយាយថា មានតែក្មេងទើបតែកើតទេ ទើបមានភាពបរិសុទ្ធគ្រប់គ្រាន់សម្រាប់បដិវត្តន៍និងប្រទេសជាតិ។ ជនទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធជាមួយរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ គឺជាខ្មាំង។ ជនជាតិភាគតិចដែលមិនព្រមប្តូររបៀបរបបរស់នៅតាមប្រពៃណីនិងជំនឿសាសនារបស់ខ្លួន ត្រូវបានចាត់ទុកជាខ្មាំង ហើយអ្នកដែលមានទំនោរទៅរកលោកសេរី អ្នកសីហនុនិយម និងអ្នកដែលខ្មែរក្រហមសង្ស័យថាជាតិញសម្ងាត់របស់បរទេស ក៏ជាខ្មាំងរបស់បដិវត្តន៍ដែរ។ អ្នកដែលប្រឆាំងនឹងបន្ទាត់នយោបាយ ឬសម្តែងកាយវិការមិនពេញចិត្តចំពោះគោលនយោបាយរបស់អង្គការត្រូវបានចោទថាជាខ្មាំង។ នៅទីបំផុត ប្រជាជនរួមទាំងថ្នាក់ដឹកនាំនិងកម្មាភិបាលខ្មែរក្រហមមួយចំនួនផង បានក្លាយជាអ្នកទោសរបស់អង្គការ ហើយត្រូវទទួលទណ្ឌកម្មតាមរូបភាពនៃការឃុំខ្លួន ការសម្លាប់ ការបង្ខំឲ្យធ្វើការជាទម្ងន់ ការដកហូតនូវសិទ្ធិសេរីភាព ការដាក់ប្រជាជនទូទាំងប្រទេសឲ្យទៅជាទាសករ។ល។ មេដឹកនាំខ្មែរក្រហមយល់ឃើញថា វិធានការទាំងនេះគឺជាវិធីតែមួយគត់ដើម្បីរក្សាសន្តិសុខនិងស្ថិរភាពនៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ និងធ្វើឲ្យមានប្រក្រតីភាពនៃដំណើរការបដិវត្តន៍និងដំណើរការកសាងជាតិរបស់ខ្លួន។

ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតបានធ្វើការបកស្រាយប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ពីអតីតកាលជាមួយនឹងគំនិតជ្រុលនិយមហួសហេតុរបស់ខ្លួន។ ជាងនេះទៅទៀត មេដឹកនាំខ្មែរក្រហមបានបដិសេធរួចជាស្រេចអំពីហេតុផលទាំងឡាយដែលនាំដល់ការកើតមានឡើងនូវព្រឹត្តិការណ៍ទាំងអស់នោះ ហើយបានសម្រួចចិត្តរបស់ខ្លួនទៅលើហេតុផលតែមួយគត់ គឺការជិះជាន់កេងប្រវ័ញ្ចរបស់អ្នកមានអំណាចមកលើប្រជាជនក្រីក្រ និងទង្វើខុសឆ្គងរបស់មេដឹកនាំដែលធ្វើឲ្យប្រទេសជាតិធ្លាក់ក្រោមការគ្រប់គ្រងរបស់បរទេស និងបាត់បង់អស់នូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី កិត្តិយសនិងកិត្យានុភាពជាតិ។ ប្រសិនបើរបបកម្ពុជាប្រជាធិបតេយ្យបន្តកាន់អំណាចតទៅទៀត ប្រជាជនគ្រប់រូបនឹងក្លាយជាអ្នកទោសរបស់អង្គការ ហើយនៅទីបំផុតមានតែ ប៉ុល ពត និងមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមួយចំនួនតូចប៉ុណ្ណោះដែលជាមនុស្សស្អាតស្អំ ជាអ្នកស្នេហាជាតិដ៏បរិសុទ្ធនិងជាជនបដិវត្តន៍ដ៏ត្រឹមត្រូវនៅកម្ពុជា។

**ឌី ខាំបូលី**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

**ថាច់ គីម**

***អតីតជាអ្នកបើកបររទេះភ្លើង***

***(រាជាយស្ម័យយានកម្ពុជា)***

*ពៅ ភិរុន គឺជាស្ត្រីមេម៉ាយដែលបានរស់រានជីវិតពីរបបខ្មែរក្រហម ។ ប្តីរបស់ ភិរុន ឈ្មោះ ថាច់ គីម ជាអតីតអ្នកបើករទេះភ្លើងក្នុងរបប លន់ នល់ ។ គីម ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ដោយសារមិត្តភក្តិ២នាក់បានចោទប្រកាន់ថាជាប់ខ្សែសេ.អ៊ី.អា ។ ពាក់ព័ន្ធនឹងការចោទប្រកាន់នេះ ភិរុន បានអះអាងថា ប្តីរបស់គាត់មិនបានធ្វើសេ.អ៊ី.អាដូចការចោទប្រកាន់ទេ ។ រុនបានរៀបរាប់ពីប្រវត្តិរឿងរ៉ាវនេះថា ÷*

*"ប្តីខ្ញុំជាមនុស្សស្លូតត្រង់ ខស្សរាហ៍ព្យាយាមក្នុងកិច្ចការងារ និងជាមនុស្សដែលគោរពចាស់ទុំ ។ គាត់គឺជាកូនប្រុសច្បងក្នុងចំណោមបងប្អូន៩នាក់ ។ គាត់មានកម្ពស់ខ្ពស់ល្មមនិងមានសម្បុរសណ្តែកបាយ ។ កូនប្រុសរបស់ខ្ញុំមានសម្បុរ និងមុខមាត់ដូចគាត់ណាស់ ។ ម្តាយក្មេកខ្ញុំស្លាប់ចោលប្តីខ្ញុំតាំងពីអាយុ១១ឆ្នាំ ។ ក្រោយមកឪពុកក្មេកខ្ញុំបានរៀបការប្រពន្ធម្នាក់ទៀត ។ ដោយ-សារប្តីខ្ញុំមិនចង់ជំពាក់គុណម្តាយចុង គាត់សម្រេចចិត្តមកស្នាក់នៅជាមួយឪពុកធំដើម្បីរៀនសូត្រនៅវត្តលង្កា ។ គាត់ស្វែងរកប្រាក់មកផ្គត់ផ្គង់ការសិក្សាដោយខ្លួនឯង ដោយឆ្លៀតពេលទំនេរពីសាលារៀនទៅលក់នំបុ័ងនិងធ្វើជាកម្មករសំណង់ ។*

*ពេលរៀនចប់ថ្នាក់ទី១ ប្តីខ្ញុំប្រឡងចូលរៀនខាងផ្នែកពាណិជ្ជសាស្ត្រ ។ បន្ទាប់មករៀនផ្នែកសិកម្ម ។ ដោយសារជីវភាពមានការខ្វះខាត ប្តីខ្ញុំរៀនមុខវិជ្ជាទាំងពីរនេះមិនទាន់ចប់ទេ ។ ក្រោយមកឪពុកធំរបស់គាត់បានណែនាំឲ្យគាត់ចូលធ្វើការនៅផ្នែករទេះភ្លើងនៅខេត្តបាត់-ដំបង ។ គាត់រៀនបណ្តើរនិងធ្វើការងារបណ្តើរអស់រយៈពេល៣ឆ្នាំទើបបានចូលធ្វើពេញសិទ្ធិ ។ ពេលរៀនចប់បានមួយរយៈខ្លី គាត់បានឲ្យសាច់ញាតិរបស់គាត់ចូលស្តីដណ្តឹងខ្ញុំ ។ យើងទាំងពីរនាក់ជាអ្នកជិតខាងគ្នា ។ សាច់ញាតិរបស់គាត់ចូលចិត្តខ្ញុំណាស់ ។ ខ្ញុំគឺជាកូនស្រីទោលនៅក្នុងគ្រួសារ ។ ឪពុកម្តាយរបស់ខ្ញុំក៏បានសួរខ្ញុំអំពីការស្តីដណ្តឹងនេះដែរ ប៉ុន្តែនៅសម័យនោះការសម្រេចចិត្តរបស់កូនស្រីគឺស្ថិតលើឪពុកម្តាយជាអ្នកសម្រេច ។ ពិធីរៀបការរបស់យើងប្រព្រឹត្តឡើងយ៉ាងអធិកអធម ដោយមានភ្ញៀវមកចូលរួមកុះករ ។ កាលនោះខ្ញុំរៀនបានដល់ថ្នាក់ទី៣ ហើយខ្ញុំប្រឡងចូលធ្វើពេទ្យ ប៉ុន្តែប្តីរបស់ខ្ញុំមិនអនុញ្ញាត គាត់ឲ្យខ្ញុំធ្វើជាមេផ្ទះ ។ ខ្ញុំមិនជំទាស់ចំពោះការសម្រេចចិត្តរបស់គាត់ទេ ព្រោះពេលខ្ញុំនៅជាមួយឪពុកម្តាយខ្ញុំត្រូវស្តាប់តាមគាត់ទាំងពីរ ។ ដូច្នេះពេលខ្ញុំរៀបការហើយ ខ្ញុំត្រូវតែតាមប្តីខ្ញុំ ។*

*ក្រោយពេលរៀបការ យើងផ្លាស់មករស់នៅទីក្រុងភ្នំពេញជាមួយម្តាយធំដែលជាស្ត្រីមេម៉ាយនៅគីឡូលេខ៦ ។ ប្តីខ្ញុំបើករទេះភ្លើងពីភ្នំពេញទៅកំពត-កំពង់សោមដឹកអ្នកដំណើរនិងទំនិញដូចជាស៊ីម៉ង់ត៍និងស្រូវអង្ករជាដើម ។ ដោយខ្ញុំនៅទំនេរ ខ្ញុំចង់ជួយរកប្រាក់ផ្គត់ផ្គង់ជីវភាព ខ្ញុំបានសម្រេចចិត្តទៅរៀន*



*ថាច់ គីម និង ពៅ ភិរុន ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ ឆ្នាំ១៩៦៧*

កាត់ដេរ ។ ប្តីខ្ញុំមិនបានជំទាស់នឹងការងារនេះឡើយ ព្រោះគាត់គិតថា ការងារកាត់ដេរអាចធ្វើនៅផ្ទះបាន ។ ខ្ញុំរៀនកាត់ដេរអស់រយៈពេល១ឆ្នាំ ។ ក្រោយពេលបញ្ចប់វគ្គ ខ្ញុំបានទទួលសញ្ញាប័ត្រពីក្រសួងអប់រំ ហើយមានការលើកទឹកចិត្តឲ្យទៅកម្សាន្តនៅទឹកឈូរ ។ ក្រោយមកខ្ញុំបានបើកហាងកាត់ដេរសម្លៀកបំពាក់នៅផ្ទះ ហើយខ្ញុំក៏មានពេលមើលថែផ្ទះសម្បែងនិងក្រុមគ្រួសារដែរ ។

នៅឆ្នាំ១៩៧០ យើងបានផ្លាស់ទៅរស់នៅខេត្តបាត់ដំបងវិញ ព្រោះប្តីរបស់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅទីនោះ ។ គាត់បើករទេះភ្លើងទៅ-មកភ្នំពេញនិងបាត់ដំបង ។ ក្រៅពីដឹកជញ្ជូនអ្នកដំណើរ គាត់ដឹកស្រូវពីបាត់ដំបងមកភ្នំពេញ ។ នៅបាត់ដំបងរដ្ឋបានចែកដីឲ្យយើងសង់ផ្ទះនៅរួមគ្នាជាមួយកម្មកររទេះភ្លើងនៅក្បែរស្ថានីយរថភ្លើង ។ ជីវភាពរបស់យើងគ្រប់គ្រាន់ល្មម ព្រោះខ្ញុំមានកូនតែមួយនៅក្នុងបន្ទុក ហើយខ្ញុំដេរសម្លៀកបំពាក់នៅផ្ទះគ្រាន់ទទួលបានប្រាក់ចំណូលបន្ថែម ។ ប្តីខ្ញុំធ្វើការនៅផ្នែករទេះ-ភ្លើងមិនដែលជួបប្រទះនូវគ្រោះថ្នាក់អ្វីឡើយ ប៉ុន្តែមិត្តភក្តិរបស់គាត់ម្នាក់បានស្លាប់បាត់បង់ជីវិត ដោយសារផ្ទុះមីននៅតាមផ្លូវនៅខេត្តកំពង់ឆ្នាំង ។



ថាច់ គឹម និង ពៅ ភិរុន ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ ឆ្នាំ១៩៦៧

នៅឆ្នាំ១៩៧៥ ប្រជាជននាំគ្នារត់មករស់នៅក្នុងទីរួមខេត្ត ព្រោះតំបន់ដែលនៅឆ្ងាយពីទីរួមខេត្តបាត់ដំបងត្រូវកងទ័ពរំដោះគ្រប់គ្រង ។ អ្នកខ្លះមកសុំសង់កូនខ្ទមនៅមុខផ្ទះរបស់យើងដើម្បីស្នាក់នៅជាបណ្តោះអាសន្ន ។ នៅពេលដែលប្រជាជនជម្លៀសចេញពីភ្នំពេញ យើងក៏ត្រូវអង្គការជម្លៀសចេញពីផ្ទះទៅរស់នៅក្នុងទីរួមខេត្តដែរ ហើយផ្ទះរបស់យើងត្រូវទុកឲ្យប្រជាជនជម្លៀស ។ ខ្ញុំដឹងថាការជម្លៀសនេះ គឺអង្គការមិនចង់ឲ្យមានកម្មសិទ្ធិសួនតួ ហើយត្រូវជម្រុះឲ្យអស់នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ យើងយកតែរបស់របរមានតម្លៃបន្តិចបន្តួចទៅជាប់ខ្លួនប៉ុណ្ណោះ ។ គ្រួសារខ្ញុំមានកង់មួយគ្រឿងនិងរបស់របរប្រើប្រាស់នៅក្នុងផ្ទះមួយចំនួន ។ យើងបានលះបង់ទ្រព្យសម្បត្តិរបស់យើងឲ្យទៅអង្គការទាំងអស់ ។ យើងរស់នៅពឹងផ្អែកលើសហករណ៍ផ្តល់ឲ្យទាំងម្ហូបអាហារនិងរបស់របរប្រើប្រាស់ ។ គ្រួសារខ្ញុំរស់នៅជួបជុំគ្នា ប៉ុន្តែពេលថ្ងៃយើងចេញទៅធ្វើការរៀងៗខ្លួន ។ ប្តីខ្ញុំត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅស្ថានីយរទេះភ្លើងដដែលនិងឲ្យគាត់ជួយបង្ហាត់ពីរបៀបបើកនិងបច្ចេកទេសជួសជុលគ្រឿងម៉ាស៊ីនដល់កម្មករទៀតផង ។ ពេលខ្លះប្តីខ្ញុំត្រូវចាត់តាំងឲ្យបើករទេះភ្លើងមកភ្នំពេញ ។ ចំណែកខ្ញុំត្រូវអង្គការចាត់តាំងឲ្យកាត់ដេរសម្លៀកបំពាក់នៅក្នុងសហករណ៍ ។ ក្រណាត់ដែលយើងដេរគឺជាប្រភេទក្រណាត់តេតារ៉ុននិងក្រណាត់ទេសឯកពណ៌ខ្មៅ ។ កាលពីជំនាន់នោះ យើងមិនអាចស្លៀកពាក់ពណ៌ឆើតឆាយបានទេ ខោអាវពណ៌ត្រូវជ្រលក់ឲ្យខ្មៅទាំងអស់ ហើយកាត់សក់ឲ្យខ្លីត្រឹម-ក គ្រប់ៗគ្នា ។ គ្មាននរណាម្នាក់ហ៊ានប្រកែកតវ៉ាចំពោះគោលការណ៍នេះឡើយ ។ ខ្ញុំបានប្តូរឈ្មោះពី ពៅ ភិរុន ទៅជា ពៅ សារុន ចំណែកកូនប្រុសខ្ញុំប្តូរពី គឹម រតនៈ ទៅជា គឹម សារុបវិញ ។ មូលហេតុដែលយើងប្តូរឈ្មោះ ព្រោះឈ្មោះរបស់យើងដូចជា ឈ្មោះត្រកូលអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ហើយយើងខ្លាចអង្គការយល់ច្រឡំថាយើងគឺជាអ្នកមាន ។ ចំណែកប្តីខ្ញុំគាត់មិនប្តូរឈ្មោះទេគាត់យល់ថាឈ្មោះគាត់សាមញ្ញ ។

មួយឆ្នាំក្រោយមក អង្គការបានបំបែកខ្ញុំនិងកូនចេញពីប្តី ។ អង្គការចាត់តាំងឲ្យខ្ញុំទៅធ្វើចម្ការនៅភូមិវត្តកណ្តឹង ដាំត្រសក់ ស្ពៃ និងត្រឡាច ។ រយៈពេល១ខែទើបខ្ញុំត្រូវបានអនុញ្ញាតឲ្យទៅជួបប្តីបាន១យប់ ។ យើងមិនអាចធ្វើដំណើរដោយសេរីបានទេ ។ នៅទីនោះសម្បូរស្រូវ ប៉ុន្តែយើងហូបមិនបានគ្រប់គ្រាន់ឡើយ ។

ពេលខ្លះយើងហូបបបរនិងពេលខ្លះទៀតហូបបាយ ។ បន្លែ ឬផ្លែឈើដែលយើងដាំនៅបរិវេណផ្ទះរបស់យើងក៏មិនអាចបេះហូបបានដែរ ។ យើងត្រូវយករបស់ទាំងនោះទៅដាក់ក្នុងសហ-ករណ៍រួម ។

នៅឆ្នាំ១៩៧៧ ខ្ញុំធ្លាក់ខ្លួនឈឺទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យភូមិ ។ មិត្តភក្តិប្តីខ្ញុំម្នាក់បានទៅប្រាប់ខ្ញុំនៅមន្ទីរពេទ្យថាប្តីរបស់ខ្ញុំនឹងត្រូវអង្គការផ្លាស់ទៅធ្វើការនៅភ្នំពេញឬពេជនិលជាមួយកម្មកររទេះភ្លើងចំនួន៤៧នាក់ទៀត ។ ឮដូច្នេះខ្ញុំក៏ប្រញាប់ទៅជួបគាត់មុន ។ ខ្ញុំនិងកូនបានទៅជួបគាត់នៅមុខរទេះភ្លើងដែលបម្រុងនឹងចេញដំណើរ ។ ខ្ញុំនិងគាត់ឈរនិយាយគ្នាពីចម្ងាយ ។ គាត់បានផ្តាំផ្ញើខ្ញុំឲ្យមើលថែរក្សាខ្លួននិងកូន ហើយប្រសិនបើគាត់ទៅបាន៤-៥ថ្ងៃ គាត់នឹងផ្ញើដំណឹងមកខ្ញុំ ប៉ុន្តែបើបាត់ដំណឹងយូរមានន័យថាគាត់ស្លាប់ហើយ ។ យើងយំទាំងអស់គ្នា ។ គាត់បានផ្តាំទៀតថា គាត់បានសរសេរកូនសំបុត្រមួយច្បាប់ទុកឲ្យខ្ញុំនៅលើក្បាលគ្រែនៅផ្ទះ ។ មុនពេលគាត់ចាកចេញពីខ្ញុំ គាត់បានហុចរូបថតរបស់គាត់មួយសន្លឹកទៀតដែលមានបិទរូបរបស់ខ្ញុំនៅក្បែររូបគាត់ ។ គាត់ប្រាប់ថា គាត់មិនត្រូវការទុករូបនេះទេ ព្រោះគាត់ទៅហើយ ។ រទេះភ្លើងបាននាំយកប្តីរបស់ខ្ញុំទៅដោយមិនដឹងថាពេលណានាំប្តីរបស់ខ្ញុំត្រឡប់មកវិញទេ ។ ពេលនោះមានតែខ្ញុំនិងកូនប៉ុណ្ណោះដែលមានឱកាសបានទៅជួបមុខប្តីជាលើកចុងក្រោយ ។



“ផលបុណ្យដែលសាងល្អគង់តែនឹងជួយយើង បើអូនអាចលែបានទៅផ្ទះចុះកុំគិតពីបង បើលែមិនបានទេ យកតែកូនទៅឲ្យម៉ែ ។ អីវ៉ាន់ណា សំខាន់ចាំយកទៅតាមខ្លួនដើម្បីឲ្យស្រួលទៅផ្ទះ ។ បើបងទៅបាន៤-៥ថ្ងៃ ចាំបងឲ្យដំណឹងជាក្រោយ ។ បងនឹករឭកជានិច្ច ។ ពីបង បើអាយុមិនអស់មិនស្លាប់ ។ ចំពោះអូន” ។

ចំណែកប្រពន្ធកម្មករផ្សេងទៀត ដែលមានផ្ទះនៅឆ្ងាយពីស្ថានីយមិនបានដឹងថាប្តីត្រូវផ្លាស់ទៅធ្វើការនៅកន្លែងផ្សេងឡើយ ។ ពេលមកដល់ផ្ទះវិញខ្ញុំក៏យកកូនសំបុត្រនោះ មកអាន ÷

“ផលបុណ្យដែលសាងល្អគង់តែនឹងជួយយើង បើអូនអាចលែបានទៅផ្ទះចុះកុំគិតពីបង បើឡើមិនបានទេយកតែកូនទៅឲ្យម៉ែ ។ អីវ៉ាន់ណាសំខាន់ចាំយកទៅតាមខ្លួនដើម្បីឲ្យស្រួលទៅផ្ទះ ។ បើបងទៅបាន៤-៥ថ្ងៃចាំបងឲ្យដំណឹងជាក្រោយ ។ បងនឹករឭកជានិច្ច ។ ពីបង បើអាយុមិនអស់មិនស្លាប់ ។ ចំពោះអូន” ។

ចាប់តាំងពីពេលនោះមកខ្ញុំចេះតែរង់ចាំប្តីខ្ញុំត្រឡប់មកវិញជារៀងរាល់ថ្ងៃ ។ ចំណែកកូនរបស់ខ្ញុំចេះតែសួររកប៉ាៗ ។ ខ្ញុំកុហកវាម្តងហើយម្តងទៀត ។ ពេលខ្ញុំអានសំបុត្រនេះម្តងៗ ទឹកភ្នែករបស់ខ្ញុំស្រក់មកដោយមិនដឹងខ្លួន ។ ខ្ញុំនឹកស្រណោះប្តីខ្ញុំដែលធ្លាប់រស់នៅជួបជុំគ្នា ។ ខ្ញុំលួចសួរដំណឹងពីអ្នកនៅក្នុងសហករណ៍ ប៉ុន្តែនៅតែមិនបានលទ្ធផលអ្វីទាំងអស់ ។ ពាក្យពេចន៍ដែលគាត់ផ្តាំផ្ញើខ្ញុំ ខ្ញុំគិតថាគាត់ប្រហែលជាដឹងខ្លួនថា គាត់នឹងគ្មានជីវិតរស់ត្រឡប់មករកខ្ញុំនិងកូនវិញទេ ព្រោះអង្គការប្រាប់ថាផ្លាស់ទៅធ្វើការកន្លែងថ្មី ។ អ្នកដែលធ្វើដំណើរទៅជាមួយគាត់ទាំងប៉ុន្មានគ្មានអ្នកណាបានត្រឡប់មកវិញឡើយ ។ ក្រោយមកខ្ញុំបានដឹងដំណឹងពីប្អូនថ្លៃស្រីរបស់ខ្ញុំថា នៅពេលរទេះភ្លើងទៅដល់ខេត្តពោធិសាត់ ប្តីខ្ញុំបានផ្ញើសំបុត្រមួយទុកឲ្យវាដែរ ហើយវាប្រាប់ថាបងប្រុសរបស់វាធ្វើដំណើរទៅភ្នំពេញហើយ ។

៥ខែក្រោយមក អង្គការបានប្រមូលប្រពន្ធកម្មកររទេះភ្លើងទាំងអស់ទៅភ្នំពេញ ដោយប្រាប់ថា នាំទៅជួបជុំប្តី ។ ខ្ញុំជិះរថភ្លើងបានមកដល់ស្ថានីយភ្នំពេញ ប៉ុន្តែកូនប្រុសរបស់ខ្ញុំមិនព្រមចុះពីរថភ្លើងទេ វានិយាយថា ចាំប៉ាមកទទួលសិន ។ ខ្ញុំក៏កុហកវាថា ប៉ាកូនចាំនៅឯផ្ទះបាយ ទើបកូនខ្ញុំព្រមចុះពីរថភ្លើង ។ បន្ទាប់មកអង្គការបញ្ជូនខ្ញុំនិងកូនឲ្យទៅរស់នៅជាមួយប្រជាជនមូលដ្ឋាននៅភូមិតាឡីស្ថិតនៅជាយទីក្រុងភ្នំពេញ ។ ដំបូងឡើយខ្ញុំរស់នៅជាមួយកូន ប៉ុន្តែមួយរយៈក្រោយមកកូនរបស់ខ្ញុំត្រូវអង្គកាបញ្ជូនទៅធ្វើការនៅកងកុមារ ។ ចំណែកខ្ញុំធ្វើការនៅក្នុងសហករណ៍ជាមួយ

យុវនារី ស្ទូងស្រូវ ដកសំណាប និងច្រូតស្រូវ ។ ពេលខ្ញុំលួចបេះបានផ្លែឈើ ខ្ញុំឆ្លៀតយកទៅឲ្យកូន ប៉ុន្តែកូនខ្ញុំមិនហ៊ានទទួលរបស់ទាំងនោះ ព្រោះវាខ្លាចមេកងឃើញ ។ ខ្ញុំតែងតែចូលរួមប្រជុំជាញឹកញាប់ជាមួយប្រជាជននៅក្នុងសហករណ៍អំពីបញ្ហាកម្មសិទ្ធិសួនតួជាមួយកូន ។ មានពេលមួយអង្គការឲ្យកូនរបស់ខ្ញុំទៅជញ្ជូនកណ្តាប់នៅពេលយប់ ។ ដោយសារកូនខ្ញុំងងុយដេកខ្លាំងពេកវាដេកលក់នៅក្នុងចំបើង ហើយគោដើរជាន់ជើងវាស្ទើរបាក់ឆ្អឹង ។ ខ្ញុំទៅមើលកូននៅមន្ទីរកុមារ ។ ពេលខ្ញុំឃើញកូនធ្វើឲ្យខ្ញុំនឹកស្រណោះខ្លួនឯងដែលមិនអាចរស់នៅជួបជុំកូននិងប្តី ។ រាល់ពេលខ្ញុំចុះទៅធ្វើការម្តងៗ ភ្នែករបស់ខ្ញុំសម្លឹងរកមើលគ្រប់ទីកន្លែង និងលួចសួរដំណឹងពីអ្នកធ្វើការនៅទីនោះ ក្រែងបានដឹងដំណឹងពីគាត់ខ្លះ ។ មួយរយៈក្រោយមក អង្គការបានយករថយន្តប្រមាណ១០គ្រឿង មកដឹកកុមារឲ្យទៅធ្វើការនៅតាមមន្ទីរៗផ្សេង ។ កូនរបស់ខ្ញុំ ត្រូវអង្គការបញ្ជូនទៅធ្វើការនៅកងកុមារស៊ីងមានជ័យ ។ កុមារទាំងអស់ត្រូវចុះពីលើឡាន ប៉ុន្តែកូនខ្ញុំនិងកុមារម្នាក់ទៀតឈ្មោះជនាញ ក្រាញនៀលមិនព្រមចុះពីឡានទេ ព្រោះវាខ្លាចផ្ទះថ្មខ្ពស់ៗ ។ អ្នកបើកឡានក៏បញ្ជូនកូនខ្ញុំនិងកុមារម្នាក់នោះមកសហករណ៍វិញ ចំណែកកុមារដែលដឹកទៅទីក្រុងទាំងប៉ុន្មានមិនឃើញវិលត្រឡប់មកកងវិញឡើយ ។


ថាច់ គីម និង ពៅ ភិរុន ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ ឆ្នាំ១៩៦៧

ក្រោយពេលច្រូតស្រូវហើយ អង្គការអនុញ្ញាតឲ្យខ្ញុំទៅរស់នៅជាមួយកូននៅស្វាគូ ។ ខ្ញុំនិងកូនលែងបែកគ្នាទៀតហើយ ប៉ុន្តែការហូបចុកនៅទីនោះមានការខ្វះខាតខ្លាំងណាស់ ។ យើងហូបបបររាវជាមួយទឹកត្រី និងពេលខ្លះហូបលាយជាមួយពោតឬដំឡូង ហើយធ្វើការទាំងថ្ងៃទាំងយប់ស្ទើរតែរកពេលសម្រាកគ្មាន ។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំបានឮស្គរគ្រាប់ផ្លោងនិងកាំភ្លើងច្បាំងគ្នា ។ មនុស្សជាច្រើនផ្អើលឈូឆរចាកចេញពីសហករណ៍ ។ កម្មាភិបាលខ្មែរក្រហមបានកៀរយើងឲ្យរត់ចូលព្រៃទៅទិសខាងលិច ។ ខ្ញុំពកូនដើរឆ្ពោះទៅទិសខាងលិច តាមការដឹកនាំរបស់ខ្មែរក្រហម ។ យើងរស់នៅនៅក្នុងព្រៃគ្មានទីជម្រកនិងខ្វះខាតម្ហូបអាហារ ។ ប្រជាជនខ្លះសម្រាលកូននៅតាមផ្លូវ និងគ្មានថ្នាំសង្កូវព្យាបាល ។ អ្នកខ្លះត្រូវស្លាប់ដោយសារពស់ចឹកនិងអត់អាហារ ។ កូនរបស់ខ្ញុំស្រែកយំទាររកអាហារ ខ្ញុំគ្មានអ្វីឲ្យកូនទេ គឺមានតែឡើងបេះផ្លែឈើនៅក្នុងព្រៃឲ្យវាហូបដើម្បីបំពេញការស្រេកឃ្លាន ។

ដោយសារកងទ័ពវៀតណាមបេះតែដេញជាបន្តបន្ទាប់ យើងធ្វើដំណើរភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយទៀតជាមួយកម្មាភិបាលខ្មែរក្រហម ។ យើងបានទៅដល់ភូមិអង្គ ។ ខ្មែរក្រហមបានប្រមូលប្រជាជនជម្លៀសឲ្យរស់នៅដាច់ដោយឡែកពីអ្នកមូលដ្ឋាន និងកេណ្ឌប្រជាជនជម្លៀសនិងគ្រួសារកម្មាភិបាលប្រមាណ២០ គ្រួសារបម្រុងយកទៅសម្លាប់ ។ គ្រួសារខ្ញុំក៏មានឈ្មោះដែរ ប៉ុន្តែយើងបានរួចជីវិតដោយសារគោឈឺជើងមិនអាចធ្វើដំណើរទៅមុខបានដូនពេលនោះកងទ័ពវៀតណាមបានដេញមកទាន់ និងរំដោះយើងឲ្យចេញផុតពីក្នុងព្រៃ ។

យើងបានមកដល់វត្តទេពប្រណម្យប្រមាណ៣-៤ថ្ងៃ ។ នៅទីនោះមានការប្រកាសឲ្យអ្នកមានចំណេះដឹងចូលធ្វើការនៅតាមមន្ទីរក្រសួងវិញ ។ ខ្ញុំក៏ចុះឈ្មោះដែរ ប៉ុន្តែបែរជាសម្រេចចិត្តមិនទៅធ្វើការវិញ ដោយសារខ្ញុំខ្លាចមានបញ្ហាដូចឆ្នាំ១៩៧៥ទៀត ។ ខ្ញុំនិងកូនបានធ្វើដំណើរមកស្រុកកំណើតនៅឯខេត្ត

 

បាត់ដំបង ។ កូនរបស់ខ្ញុំនៅតែសួររកប៉ា ហើយខ្ញុំចេះតែកុហកវា ជាបន្តបន្ទាប់ថា ពេលណាយើងទៅដល់ផ្ទះយើងនឹងបានជួបប៉ា ។ កូនខ្ញុំគ្រុនក្តៅ ហើយបានកង់ទំពវៀតណាមឲ្យថ្នាំលេបទើបបានជាសះស្បើយ ។ ខ្ញុំបានមកដល់ផ្ទះវិញនៅចុងឆ្នាំ១៩៧៩ ។ ពេលទៅដល់ផ្ទះសាច់ញាតិរបស់ខ្ញុំចេញមកទទួលខ្ញុំគ្រប់គ្នា ប៉ុន្តែមិនឃើញប្តីខ្ញុំឡើយ ។ ខ្ញុំព្យាយាមស្វែងរកគាត់តាមរយៈញាតិមិត្តបងប្អូននិងស្តាប់តាមវិទ្យុដែរ ប៉ុន្តែនៅតែមិនបានទទួលព័ត៌មានអំពីគាត់សោះ ។ ខ្ញុំគ្មានសង្ឃឹមថាគាត់នៅរស់ទេ ។ ប្រសិនបើគាត់នៅរស់មែន គាត់ប្រាដកជាវិលមករកខ្ញុំនិងកូនហើយ ។ ខ្ញុំបានធ្វើបុណ្យឧទ្ទិសកុសលទៅឲ្យគាត់ ហើយឧស្សាហ៍ទៅវត្តសូត្រធម៌ដើម្បីឲ្យចិត្តរបស់ខ្ញុំឈប់គិតពីគាត់ ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់សាច់ញាតិអស់៩នាក់ ។

នៅឆ្នាំ២០០៦នេះខ្ញុំបានទទួលប្រវត្តិរូបរបស់គាត់មួយសន្លឹកពីក្រុមអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ តាមរយៈប្រវត្តិរូបនិងឯកសារ ខ្ញុំបានដឹងថា ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួននិងបញ្ជូនមកគុកទួលស្លែងដោយសារមិត្តភក្តិរបស់គាត់ពីរនាក់ឆ្លើយដាក់ថា គាត់ជាសេ.អ៊ី.អា ។ មិត្តម្នាក់ឈ្មោះ គីរី ផល្លា ដែលខ្ញុំធ្លាប់ដឹងថា គាត់ជាអតីតអនុប្រធាននៅស្ថានីយរទេះភ្លើង និងម្នាក់ទៀតឈ្មោះ ឱម សឹក អតីតជាងជួសជុលរទេះភ្លើង ។

ភិរុន ខឹងយ៉ាងខ្លាំងចំពោះអ្នកដែលបានចោទប្រកាន់ប្តីរបស់គាត់ថាជា សេ.អ៊ី.អា ។ ភិរុន បានបញ្ជាក់ថា នៅក្នុងសម័យខ្មែរក្រហម បើអ្នកណាចោទប្រកាន់ថាយ៉ាងម៉េច គឺខ្មែរក្រហមជឿទាំងអស់ គ្មាននរណាអាចតវ៉ាបានទេ ហើយក៏គ្មានតុលាការកាត់សេចក្តីរកខុសរកត្រូវដែរ ។

ភិរុន ពេញចិត្តចំពោះតុលាការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាតិសហការគ្នាដោយមានការជួយជ្រោមជ្រែងពីមជ្ឈមណ្ឌលឯកសារកម្ពុជាផង ។ ភិរុន សង្ឃឹមថា តុលាការនេះនឹងអាចផ្តល់យុត្តិធម៌ឲ្យប្តីរបស់គាត់និងកាត់សេចក្តីយ៉ាងសុក្រឹតចំពោះអ្នកដែលបានប្រព្រឹត្តខុស ។ ភិរុន សូមអំពាវនាវឲ្យតុលាការធ្វើការកាត់ទោសឲ្យបានត្រឹមត្រូវនិងរកមុខរកឃាតករឲ្យឃើញទាំងមេដឹកនាំខ្មែរក្រហមមួយចំនួនដែលស្លាប់បាត់បង់ជីវិតនិងមេដឹកនាំដែលនៅរស់ ។


ថាច់ កឹម, ពៅ ភិរុន និងកូនប្រុស កឹម រតនៈ
ខេត្តបាត់ដំបង ថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៧៣


ថាច់ ប្រាជ្ញ ឪពុក
ថាច់ កឹម ឆ្នាំ១៩៧២


ថាច់ សាន ប្អូនប្រុស
ថាច់ កឹម ឆ្នាំ១៩៧២


ថាច់ យឹង ប្អូនស្រី
ថាច់ កឹម ឆ្នាំ១៩៧៤


ថាច់ កឹម ខេត្តបាត់ដំបង ឆ្នាំ១៩៧៣

 

ភិរុន បានបង្ហាញរូបថតនិងសំបុត្រដែលប្ដីរបស់គាត់ប្រគល់ឲ្យនៅថ្ងៃឡើងរថភ្លើង ។ ក្រៅពីនេះ ភិរុន បានរក្សាទុករូបថតក្រុមគ្រួសាររបស់គាត់ជាច្រើនសន្លឹកទៀត ដែលនៅក្នុងនោះមានរូបមួយសន្លឹក គឺជារូបដែលគាត់ទាំងពីរនិងកូនថតជុំគ្នានៅហាងទាន់សម័យក្នុងខេត្តបាត់ដំបងកាលពីឆ្នាំ១៩៧៣ ។ រូបថតប្ដីរបស់គាត់មួយចំនួនទៀតថតនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០-១៩៧០ និងរូបថតអាពាហ៍ពិពាហ៍ ក្នុងឆ្នាំ១៩៦៧ និងរូបថតរបស់ កឹម ថតជាមួយសាច់ញាតិនិងមិត្តភក្តិរបស់គាត់ ។

នៅក្នុងប្រវត្តិរូបរបស់ ថាច់ កឹម បានកត់ត្រាថា ÷ ថាច់ កឹម អាយុ៣៧ឆ្នាំ ប្រពន្ធឈ្មោះ ពៅ សារុន និងមានកូនប្រុសម្នាក់ មានស្រុកកំណើតនៅឃុំមោងឫស្សី ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ មុនឆ្នាំ១៩៧៥ ធ្វើជាកម្មកររទេះភ្លើង ។ នៅក្នុងរបបខ្មែរក្រហមធ្វើជាកម្មករ ។ ឃាត់ខ្លួននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ នៅផ្ទះ "ជ" បន្ទប់ធំ០៥ បន្ទប់តូច១៥ នៅខេត្តបាត់ដំបង ។ នៅខាងលើប្រវត្តិរូបរបស់ ថាច់ កឹម សរសេរថា "ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង" និងនៅខាងស្ដាំដៃនៃប្រវត្តិរូបមានបិទរូបថតរបស់ ថាច់ កឹម មួយសន្លឹក ។ នៅក្នុងឯកសារមួយសន្លឹកទៀតបានបញ្ជាក់ថា ÷ អោម សឹក អតីតអ្នកជួសជុលម៉ាស៊ីន រទេះភ្លើងបានឆ្លើយដាក់ ថាច់ កឹម ថាបានចូលបម្រើសេ.អ៊ី.អានៅឆ្នាំ១៩៦៨ ។ នៅចន្លោះឆ្នាំ១៩៧៤-១៩៧៥ កឹម បានទទួលផែនការពី គិរី ផល្លា និង ទូច កឹមសួ អំពីសកម្មភាពប្រឆាំងបដិវត្តន៍ ។

**ប៊ុន ពីច័ន**

# ដំណឹងសួររកឪពុកឈ្មោះ អ៊ុម សំអុល

នាងខ្ញុំឈ្មោះ មន្ថា (ហៅក្រញាញ់ កើតឆ្នាំ១៩៦៨) និងប្អូនប្រុសឈ្មោះ សាមឿន (ហៅ វ៉ៃម៉ុង កើតឆ្នាំ១៩៧០) សព្វថ្ងៃរស់នៅប្រទេសបែលហ្ស៊ិក សូមសួររកឪពុកឈ្មោះ អ៊ុម សំអុល (នាមដើម អ៊ុក មួយ អាយុ៦៨ឆ្នាំ) មានស្រុកកំណើតនៅរការកោង ។ ឪពុករបស់នាងខ្ញុំជាជនភៀសខ្លួនម្នាក់ ហើយដែលត្រូវបានចេញទៅប្រទេសទី៣នៅក្នុងឆ្នាំ១៩៨០-៨១បន្ទាប់ពីគាត់បានធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ ឃែរ (CARE) នៅមន្ទីរថ្លឹងកុមារសង្កាត់ទី១៨នៃជំរំជនភៀសខ្លួនខាវអ៊ីដាងប្រទេសថៃ ម្ដាយឈ្មោះ សុខា (ឈ្មោះថ្មី គឹម សុម៉ាលី) បានបែកចេញពីឪពុកខ្ញុំទៅធ្វើការនៅជំរំថ្មីជាប្រធានមន្ទីរវះកាត់ជនពិការនៅអង្គការមនុស្សធម៌អាល្លឺម៉ង់មួយ ។ កាលរស់នៅប្រទេសកម្ពុជា គាត់ទាំងពីររស់នៅខេត្តបាត់ដំបង ធ្វើការនៅរោងចក្រផ្នែកជួសជុលម៉ាស៊ីន ។

ប្រសិនបើអស់លោក លោកស្រី មាមីងពូ បានស្គាល់ឬជួបលោក អ៊ុម សំអុល រស់នៅប្រទេសណាសូមមេត្តាជួយផ្ដល់ព័ត៌មានមកនាងខ្ញុំតាម អ៊ីម៉ែល ផ្ញើលិខិត ឬទូរស័ព្ទមកយើងខ្ញុំតាមអាសយដ្ឋានខាងក្រោមនេះ ។ សូមអរគុណ ។

*Mme Montha Kim,145Rue Neuve, B-1640 Rhode-st-Gene`se(Belgique)*

*Tel: 00 33 2 381 0527; email: kimanfrov@yahoo.fr or fb663380@skynet.be*



មន្ថា និងប្អូនប្រុស សាមឿន
នៅជំរុំខាវអ៊ីដាង



មន្ថា និងប្អូនប្រុស សាមឿន
នៅជំរុំខាវអ៊ីដាង



សុខា ម្ដាយរបស់ មន្ថា
នៅជំរុំខាវអ៊ីដាង

# សូមគោរពជូនចៅក្រមជាតិ និងអន្តរជាតិ

*ផ្ញើនៅដំដែក, ថ្ងៃពុធ ទី២៦ ខែកក្កដា ឆ្នាំ២០០៦*

តាមរយៈអង្គការសង្គមស៊ីវិលនានាប្រចាំខេត្តសៀមរាប មានជាអាទិ៍ៈ អាដហុក លីកាដូ និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

ខ្ញុំបាទឈ្មោះ អ៊ុង ថន អាយុ៦៤ នៅភូមិបុស្ស ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ជាអតីតកងទ័ពរំដោះជាតិកម្ពុជា ខ្មែរអង្គភាពវៀតណាមឆ្នាំ១៩៧០ សមរភូមិពាយ័ព្យនៃកងវរសេនាតូច J-31 ភូមិភាគ២០៣ (កងពលរបស់វៀតណាម) ប្រតិបត្តិការសឹកខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ បាត់ដំបង និងពោធិសាត់ មួយភាគ ។ បច្ចុប្បន្នជាសាស្ត្រាចារ្យបម្រើការនៅវិទ្យាល័យដំដែក ស្រុកសូត្រនិគម ខេត្តសៀមរាប ។

**កម្មវត្ថុ** ៖ សំណើសុំចូលរួមធ្វើជាសាក្សីក្នុងអង្គសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានជាអាទិ៍ ៖ ខៀវ សំផន និង អៀង សារី ។

លោកចៅក្រមជាតិ និងអន្តរជាតិជាទីស្នេហា

មុននឹងឈានទៅដល់ការចោទប្រកាន់ទៅលើពួកមេដឹកនាំខ្មែរក្រហមប្រល័យពូជសាសន៍នេះ ខ្ញុំបាទសូមអនុញ្ញាតលើកពីសភាពការណ៍ក្រោយថ្ងៃរដ្ឋប្រហារ១៨មីនា ឆ្នាំ១៩៧០ ជូនអង្គសវនាការដូចខាងក្រោម ៖

ក្រោយថ្ងៃរដ្ឋប្រហារ១៨មីនា ឆ្នាំ១៩៧០ សម្តេចឪព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានផ្ញើព្រះរាជសារតាមរយៈវិទ្យុប៉េកាំងដល់ជនរួមជាតិ ៖ សូមឲ្យកូនចៅទាំងអស់មាន មន្ត្រីរាជការ ប៉ូលិស ទាហាន សិស្ស និងនិស្សិត ព្រមទាំងប្រជារាស្ត្ររត់ចូលព្រៃម៉ាគី ដើម្បីចូលរួមក្នុងចលនារណសិរ្សសេរីកាបង្រួបបង្រួមជាតិ *Front Uni National De Libération* ធ្វើការតស៊ូផ្តួលរំលំរបប លន់ នល់ ។

រណសិរ្សពេលនោះចែកចេញជា៣ភូមិភាគគឺ ៖

១) ភូមិភាគបូព៌ាដឹកនាំដោយលោក ខៀវ សំផន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ឯកងពល វៀតណាមគឺ២០១ ។

២) ភូមិភាគពាយ័ព្យដឹកនាំដោយលោក ហ៊ូ យន់ (ស្លាប់) ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកងពលវៀតណាមគឺ២០៣ ខ្មែរក្រហមភូមិភាគ៣០២ ។

៣) ភូមិភាគនិរតីដឹកនាំដោយលោក ហ៊ូ នឹម (ស្លាប់) ជារដ្ឋមន្ត្រីក្រសួងឃោសនាការ ឯកងពលរបស់វៀតណាមគឺ២០២ ។

សម្តេច ព្រះនរោត្តម សីហនុ ជាប្រធានរណសិរ្សបង្រួបបង្រួមជាតិ

សម្តេច ប៉ែន នុត (ស្លាប់) ជារដ្ឋមន្ត្រីទី១

អៀង សារី ជាបេសកជនពិសេស

**ការបែងចែកសមរភូមិប្រយុទ្ធចែកចេញជាពីរសមរភូមិគឺ**

១) សមរភូមិមុខ

កងទ័ពស្រួច ៖ កងទ័ពស្មគ្រចិត្តវៀតណាម ហៅថា យៀកកុង រួមជាមួយកងទ័ពខ្មែរហៅថា ខ្មែរអង្គភាព (l'entité Khmer) មានតួនាទី និងភារកិច្ចវាយផ្តួលរំលំរបប លន់ នល់ គ្រប់សមរភូមិទូទាំងប្រទេសដើម្បីរំដោះទឹកដីនិងប្រជារាស្ត្រ ។

២) សមរភូមិក្រោយ

ខ្មែរក្រហមរួមជាមួយប្រជារាស្ត្រខ្មែរមានជាអាទិ៍ ៖ កសិករ សិស្ស និងនិស្សិត មានតួនាទី និងភារកិច្ចអប់រំ តែងតាំងរដ្ឋអំណាច ភូមិ ឃុំ ស្រុក ខេត្ត និងជ្រើសរើសទ័ពនៅក្នុងតំបន់ណាដែលកងទ័ពស្រួចវាយរំដោះបានពី លន់ នល់ ។

**អំពីផែនការកាប់សម្លាប់របស់ពួកខ្មែរក្រហមចែកចេញជាពីរគឺ**

១) ការកាប់សម្លាប់ប្រជារាស្ត្រខ្មែរនៅក្នុងតំបន់រំដោះគឺក្រោយ ថ្ងៃរដ្ឋប្រហារ១៨ មីនា ឆ្នាំ១៩៧០

ក) ខេត្តសៀមរាប

ចុងឆ្នាំ១៩៧០ ចាប់លោក ចាន់ ជុល មេបញ្ជាការកងទ័ពខ្មែរក្រហម (សមរភូមិវត្តស្វាយ) ដោយខ្មែរក្រហមឈ្មោះ ព្រំ សារឿន ជាលេខាស្រុក-ស្រុកសូទ្រនិគម ។

ឆ្នាំ១៩៧១ ចាប់ពួកខ្មែរ-ស (K.G.B) ដែលគាំទ្រដោយ

កងទ័ពវៀតណាមមានឈ្មោះ ហ៊ុយ វឿន នៅវត្តលលៃ ពួកខ្មែរ-សនេះបះបោរប្រឆាំងនឹងខ្មែរក្រហម

ចាប់លោកមេឃុំ សឹត់ នៅឃុំចាន់សរ និងព្រះសង្ឃព្រះនាម សាមទ្រី ប្រគល់ឲ្យគណៈស្រុកឈ្មោះ សាយ ដា និងឈ្មោះ វ៉ាន់ យកទៅសម្លាប់ ។

អ្នកដែលចាប់ក្រុមខ្មែរសនេះគឺ មេបញ្ជាការកងទ័ពវៀតណាមឈ្មោះ វឿង ប្រធាន នយោបាយវរសេនាតូច J-31 ភូមិភាគ២០៣ សមរភូមិស្វាយ័ត និងតំបន់អង្គរវត្ត ។

សម្លាប់ក្រុមខ្មែរភាគខាងជើងឈ្មោះលោក លាវ កែវមុនី ។

ឆ្នាំ១៩៧២ នៅពេលដែលកងទ័ពស្ម័គ្រចិត្តវៀតណាមធ្វើមាតុភូមិនិវត្តន៍ វៀតណាម បានប្រគល់កងទ័ពខ្មែរគឺខ្មែរអង្គភាព នៅភូមិព្រះដាក់ ស្រុកបន្ទាយស្រី ក៏ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ ។

១) ខេត្តកំពង់ធំ

ឆ្នាំ១៩៧១ វៀតណាមឈ្មោះ វឿង មេបញ្ជាការវរសេនាតូច J-31 ភូមិភាគ២០៣ បានដឹកនាំកងទ័ពវៀតណាមពីរវរសេនាតូច គឺវរសេនាតូច J-31 និង K-20 ចាប់ លោក អៀង ហឿន និងលោក រិន ជាអតីតអ្នករួមប្រយុទ្ធជាមួយកងទ័ពវៀតណាម ដោយចោទថា មេក្រុមខ្មែរ-ស នៅស្រុកស្ទោង ខេត្តកំពង់ធំ ក៏ប្រគល់ឲ្យទៅពួកខ្មែរក្រហមដែរ ហើយក៏ត្រូវពួកខ្មែរក្រហមសម្លាប់ទាំងអស់ ។

នៅឆ្នាំ១៩៧២ ចាប់ក្រុមលោក យុត ឧត្តម ជាមេបញ្ជាការកងទ័ពខ្មែរនៅសមរភូមិជុំវិញទីរួមខេត្តកំពង់ធំ ក៏ត្រូវពួកខ្មែរក្រហមសម្លាប់ដែរ ។

២) ការសម្លាប់ប្រជារាស្ត្រខ្មែរ : ព្រះសង្ឃ អ្នករដ្ឋការ ទាហាន ស៊ីវិល និងនិស្សិត នៅក្នុងតំបន់ទីរួមខេត្ត និងក្រុងនានា ក្រោយថ្ងៃ ១៧មេសា ឆ្នាំ១៩៧៥ (តំបន់ លន់ នល់ គ្រប់គ្រង) ។

## ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ១៧មេសា ១៩៧៥

ក្រោយថ្ងៃជ័យជម្នះ ពួកខ្មែរក្រហមបានជម្លៀសប្រជាជន មន្ត្រីរាជការ ទាហាន លន់ នល់ ប៉ូលិស រដ្ឋការនានា ព្រះសង្ឃ សិស្ស និងនិស្សិត ឲ្យចេញពីទីក្រុងនានា និងទីរួមខេត្តទូទាំងប្រទេសទៅរស់នៅក្នុងតំបន់រំដោះ ដោយពួកខ្មែរក្រហមបានចាត់តាំងប្រជាជនមូលដ្ឋាន (ប្រជាជនចាស់) តាមដានរាល់សកម្មភាពប្រជាជនថ្មី ។

## អំពីការកាប់សម្លាប់ក្រោយថ្ងៃ១៧មេសា១៩៧៥របស់ពួកខ្មែរក្រហម

ពួកវាចាត់តាំងប្រជាជនចាស់ឲ្យឃ្លាំមើលរាល់សកម្មភាពរបស់ប្រជាជនថ្មីទាំងអស់ ការនិយាយស្តី ការសារបង្កបង្កើនផលសីលធម៌បុរស-នារី និងវិន័យការងារ ។ល ។

ទាហាន ប៉ូលិស និងរដ្ឋការ ត្រូវពួកខ្មែរក្រហមសម្លាប់ទាំងអស់ ។

ព្រះសង្ឃ សិស្ស និងនិស្សិត ក៏ត្រូវពួកវាសម្លាប់ដែរ ។

អ្នកមានទ្រព្យសម្បត្តិផ្សេងៗ ។

ប្រជាជនចាស់និងថ្មីក៏ត្រូវពួកវាយកទៅសម្លាប់ ។

សមមិត្តរួមអាជីពជាមួយគ្នាក៏ត្រូវពួកវាសម្លាប់ទាំងអស់ ដោយវាចោទថា ជាពួកសេរីនិយម ។

## សំណួរពាក់ព័ន្ធ

១) ពាក់ព័ន្ធទៅមេដឹកនាំខ្មែរក្រហម ខៀវ សំផន និង អៀង សារី

ក) ហេតុអ្វីបានជាពួកបរិវាររបស់អស់លោកចាប់អ្នកស្នេហាជាតិ និងប្រជាជននៅក្នុងតំបន់រំដោះ ក្រោយថ្ងៃរដ្ឋប្រហារ ១៨ មីនា ១៩៧០ យកទៅសម្លាប់?

ខ) ក្រោយថ្ងៃរដ្ឋប្រហារ ១៨ មីនា ១៩៧០ ពួកខ្មែរក្រហមរំដោះបានសមរភូមិណាខ្លះ?

គ) តើការចាត់តាំងប្រជាជនចាស់ឲ្យតាមដានរាល់សកម្មភាពប្រជាជនថ្មីក្នុងគោលបំណងបែបណា?

ឃ) តើក្រុមខ្មែរស (K.G.B) អ្នកណាបង្កើត? អ្នកណាចាប់? អ្នកណាសម្លាប់? មូលហេតុអ្វីបានក្រុមខ្មែរ-សកើតឡើងក្នុងតំបន់រំដោះ?

ក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ពួកខ្មែរក្រហមបានឡើងដឹកនាំ និងគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង ហេតុអ្វីបានជាចាប់ប្រជាជនទាំងចាស់ទាំងថ្មីយកទៅសម្លាប់ តើគេទាំងនោះខុសអ្វី?

ហេតុអ្វីបានជាមកចាប់ខ្មែរអង្គភាពវៀតណាម (L'entité Khmer-Vietnam) ខ្មែរភាគខាងជើង និងអ្នកគស្សិរួមអាជីព ជាមួយ

ខ្មែរក្រហមយកទៅសម្លាប់? តើអ្នកទាំងអស់នោះមានកំហុសអ្វីខ្លះ?

២) ពាក់ព័ន្ធនិងរាជរដ្ឋាភិបាល

ហេតុអ្វីបានជាអង្គសវនាការជំនុំជម្រះក្តីពួកមេដឹកនាំខ្មែរក្រហមកាត់ក្តីគិតត្រឹមពីឆ្នាំ១៩៧៥-១៩៧៩? ចំពោះប្រជាពលរដ្ឋ និងអ្នកស្នេហាជាតិដែលស្លាប់ដោយស្នាដៃពួកខ្មែរក្រហម និងកងទ័ពវៀតណាមវាសម្លាប់ដែរ ក្រោយថ្ងៃរដ្ឋប្រហារ ១៨ មីនា ១៩៧០ ម្តេចក៏មិនជំនុំជម្រះ កាត់ក្តីផង តើចាត់ទុកព្រឹត្តិការនោះយ៉ាងណា? យើងខ្ញុំជួសមុខឲ្យជនរងគ្រោះ សូមធ្វើការតវ៉ាដោយទទូច ទាមទារឲ្យអង្គសវនាការជំនុំជម្រះក្តីនេះ គឺកាត់ក្តីពីឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧៨ផង ទើបមានតម្លាភាព និងសច្ចយុត្តិធម៌ ។

៣) ពាក់ព័ន្ធនិងកងទ័ពវៀតណាម

នៅឆ្នាំ១៩៧១ ក្នុងតំបន់រំដោះ កងទ័ពវៀតណាមជាអ្នកជួយឧបត្ថម្ភ និងគាំទ្រពួកខ្មែរសដែលមានឈ្មោះ ហ៊ុយ រឿន ជាមេចលនាខ្មែរស នៅតំបន់អង្គរវត្តឲ្យធ្វើសកម្មភាពប្រឆាំងនឹងពួកខ្មែរក្រហម ហើយទីបំផុត កងទ័ពវៀតណាមបែរជាចាប់ក្រុមខ្មែរសនេះយកទៅអោយពួកខ្មែរក្រហមយកទៅសម្លាប់ទៅវិញ គឺចាប់នៅវត្តលលៃ ចាន់សរ ដំដែក កំពង់ក្តី និងស្ទោង ដោយមេបញ្ជាការកងទ័ពវៀតណាម ឈ្មោះ រឿង ប្រធាននយោបាយវរៈសេនាតូច J-13 កងពល២០៣ ក្រោមបញ្ជាការរបស់បាបាង និងបាលាវ ។

ទង្វើទាំងអស់នេះ តើវៀតណាមមានគោលបំណងបែបណាមកលើប្រជាជាតិខ្មែរ?

៤) ពាក់ព័ន្ធទៅនឹងប្រទេសជាមហាអំណាច

សហរដ្ឋអាមេរិកគាំទ្រ លន់ នល់ ។ សហភាពសូវៀតគាំទ្រកងទ័ពវៀតណាម និងចិនប្រជាមានិតគាំទ្រខ្មែរក្រហម ។ ដូច្នេះទំហំនៃការបាត់បង់អាយុជីវិតរាស្ត្រខ្មែរ ទ្រព្យសម្បត្តិជាតិ និងទ្រព្យសម្បត្តិរាស្ត្រ តើមហាអំណាចខាងលើនេះត្រូវមានកំហុសដែរឬទេ? បើមានកំហុស តើសាលាក្តីនេះ ត្រូវជំនុំជម្រះយ៉ាងម៉េច? បើមិនមានកំហុស តើបណ្តាលមកពីមូលហេតុអ្វី?

សំណូមពរ ៖ ក្នុងនាមខ្ញុំបាទជួសមុខឲ្យជនរងគ្រោះសូមលោកចៅក្រមមេត្តាជួយធ្វើអន្តរាគមន៍ឲ្យរូបខ្ញុំបាទផ្ទាល់ចូលគាល់សម្តេចឪ ព្រោះព្រះអង្គជាព្រះប្រធានរណសិរ្សសេរីកាជាតិកម្ពុជានាទសវត្សរ៍ឆ្នាំ៧០ ឲ្យបានមុនការបើកអង្គសវនាការជំនុំជម្រះក្តីពួកដឹកនាំខ្មែរក្រហម ដើម្បីរាយការណ៍ពីសភាពការណ៍ក្រោយថ្ងៃរដ្ឋប្រហារ ១៨មីនា ១៩៧០ និងក្រោយថ្ងៃជ័យជម្នះ ១៧មេសា ១៩៧៥ ថ្វាយព្រះអង្គឲ្យទ្រង់ជ្រាបសេចក្តី ។

សូមលោកចៅក្រមជាតិ និងអន្តរជាតិ ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**អ៊ុំ ថន**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# នយោបាយអតីតកាលរបស់ទីតាំងប្រល័យពូជសាសន៍នៅរ៉្វាន់ដា

## សេចក្ដីផ្ដើម

អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាឆ្នាំ១៩៩៤ត្រូវបានមកវិភាគតាមទស្សនវិស័យយល់ឃើញផ្សេងៗគ្នានិងទស្សនៈផ្សេងៗ គ្នាជាច្រើនទៀតនៃអ្នកដែលប្រព្រឹត្ត ។ ប្រវត្តិវិទូបាននឹងកំពុងពិនិត្យរកឫសគល់នៃការបែងចែកជាតិពន្ធុនៅប្រទេសរ៉្វាន់ដាក្នុងសម័យអាណានិគមនិយម ។ នរវិទូ បាននឹងកំពុងតែវិភាគតក្កភាពជានិមិត្តសញ្ញានៃទម្រង់អំពើហិង្សាដែលប្រព្រឹត្តទៅលើជនស៊ីវិលស្លូតត្រង់ ខណៈដែលអ្នកប្រាជ្ញខ្លះទៀតកំពុងសំឡឹងមើលពីតួនាទីរបស់រដ្ឋអំណាចនៅក្នុងអំពើប្រល័យពូជសាសន៍ដោយការគោរពចំពោះរដ្ឋអំណាចដែលបង្ហាញនូវចរិតលក្ខណៈនៃវប្បធម៌នយោបាយរបស់ប្រទេសរ៉្វាន់ដា ។ ជំពូកនេះរកឃើញទិដ្ឋភាពមួយក្រោយអំពើប្រល័យពូជសាសន៍ដែលពុំត្រូវបានទទួលការចាប់អារម្មណ៍ច្រើននោះ គឺជោគវាសនានៃបូជនីយដ្ឋានប្រល័យពូជសាសន៍ដែលជាទីតាំងភូមិសាស្ត្រ ដែលមនុស្សជាច្រើនក្រុមត្រូវបានសម្លាប់យ៉ាងរង្គាល ។ ដោយមានការដៅជាចំណុចនៅលើដែនទី និងដោយមានទំនាក់ទំនងទៅនឹងការកសាងសង្គមនិងនយោបាយទីតាំងប្រល័យពូជសាសន៍មិនត្រឹមតែបានរំឭកនូវរឿងរ៉ាវដែលបានកើតឡើងក្នុងអំឡុងនៃអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ តែថែមទាំងឆ្លុះបញ្ចាំងពីរបៀបវារៈនយោបាយបច្ចុប្បន្ននៃប្រទេសរ៉្វាន់ដាថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិទៀតផង ។ ចាប់តាំងពីឆ្នាំ១៩៩៤ ប្រជាជនរ៉្វាន់ដាសម្រេចចិត្តប្រែក្លាយទីតាំងសម្លាប់រង្គាលឲ្យមានសភាពដូចមុន ដូចជាសាលារៀន មន្ទីរពេទ្យ ឬទីសក្ការបូជា ។ ប្រជាជនរ៉្វាន់ដាត្រូវតែសម្រេចចិត្តថាតើត្រូវបញ្ចុះសាកសព ឬទុកអដ្ឋិធាតុរបស់ជនរងគ្រោះសម្រាប់បង្ហាញជាសាធារណៈដែរឬយ៉ាងណាដើម្បីឲ្យមានភាពងាយស្រួលចងចាំរបៀបដែលជនរងគ្រោះស្លាប់ ។ ប្រជាជនរ៉្វាន់ដាត្រូវគិតពិចារណាពីបំណងប្រាថ្នានិងអត្ថប្រយោជន៍របស់ជនរងគ្រោះនិងអ្នករស់រានមានជីវិតពីការប្រល័យពូជសាសន៍ដូចគ្នានឹងបំណងប្រាថ្នានិងអត្ថប្រយោជន៍របស់ជនដៃដល់ដែលជាប់ចោទ ព្រមទាំងរដ្ឋាភិបាល ដែលកំពុងតែដោះស្រាយសមាជិកជាន់ខ្ពស់តាមគោលនយោបាយរបស់ខ្លួន ។ សហគមន៍អន្តរជាតិក៏ចូលរួមនៅក្នុងដំណើរការនេះផងដែរ ។ តុលាការអន្តរជាតិ មានបំណងប្រើប្រាស់អដ្ឋិធាតុជនរងគ្រោះដែលប្រមូលមកពីទីតាំងសម្លាប់ធ្វើជាភស្តុតាងជាក់ស្ដែង ។ ភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនាប្រទេសរ៉្វាន់ដាក្រោយការប្រល័យពូជសាសន៍ ចង់ឃើញផ្ទាល់ភ្នែកនូវព្រឹត្តិការណ៍ដ៏រន្ធត់ដែលបានកើតឡើងនៅទីនោះ ដោយទស្សនានូវអដ្ឋិធាតុជាក់ស្ដែងដោយអំពើហិង្សាឆ្នាំ១៩៩៤ ។ អ្នកដែលមានបំណងចង់ឲ្យពិភពលោកស្វែងយល់អំពីទំហំនៃសោកនាដកម្មនៅក្នុងប្រទេសដ៏តូចមួយនេះ ចង់ឲ្យមានការថែរក្សាអដ្ឋិធាតុរបស់ជនរងគ្រោះដោយការសម្លាប់ដើម្បីបង្ហាញរឿងរ៉ាវដែលជនរងគ្រោះបានជួបប្រទះ ។

ដូចនេះ ទាំងអត្ថិភាពនៃទីតាំងប្រល័យពូជសាសន៍និងគោលបំណងនៃការប្រើប្រាស់ទីតាំងនេះបន្ទាប់ពីការបញ្ចប់នៃរបបប្រល័យពូជសាសន៍មិនច្បាស់លាស់ ឬមិនទាន់បានកំណត់នៅឡើយទេ ។ ការកំណត់ទិសដៅនៃវត្ថុបំណងនិងអត្ថប្រយោជន៍នឹងផ្ដល់សារសំខាន់តាមរយៈការប្រើប្រាស់ទីតាំងប្រល័យពូជសាសន៍ទាំងនេះ ហើយជោគវាសនានៃទីតាំងនេះនឹងទុកសម្រាប់ឲ្យក្មេងជំនាន់ក្រោយៗធ្វើការវាយតម្លៃ ប្រសិនបើសង្គមក្រោយការប្រល័យពូជសាសន៍ផ្សេងៗទៀតជាម៉ែត្រសម្រាប់វាស់វែងវត្ថុបំណងនិងអត្ថប្រយោជន៍ ។ អស់រយៈពេលជាង២៥ឆ្នាំបន្ទាប់ពីអំពើប្រល័យពូជសាសន៍បានកើតឡើងនៅក្នុងប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥-១៩៧៩ ប្រជាជនកម្ពុជានៅតែពិភាក្សាអំពីការចាត់វិធានការសមស្របដោយសំអាងទៅលើអដ្ឋិធាតុជាក់ស្ដែងដែលសេសសល់ពីការប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## បរិបទនៃប្រវត្តិសាស្ត្រនិងនយោបាយ

ប្រទេសរ៉្វាន់ដាមានទីតាំងស្ថិតក្នុងតំបន់ដែលសម្បូរដោយបឹងធំៗក្នុងទ្វីបអាហ្វ្រិកកណ្ដាល ។ ប្រទេសរ៉្វាន់ដាជាប្រទេសដ៏តូច

មួយដែលហ៊ុមព័ទ្ធដោយផ្ទៃក្រឡាប្រហែល ២៦.០០០គីឡូម៉ែត្រការ៉េ (១០.០០០ម៉ាយការ៉េ) (ដែលមានទំហំប្រហែលរដ្ឋម៉ារីឡេនរបស់សហរដ្ឋអាមេរិក) ។ សេដ្ឋកិច្ចរបស់ប្រទេសរ៉្វាន់ដាពឹងផ្អែកទៅលើការនាំចេញកាហ្វេ វិស័យទេសចរណ៍ និងជំនួយបរទេស ។ ប្រជាជនរ៉្វាន់ដាភាគច្រើនប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែចម្ការ ពីព្រោះសេដ្ឋកិច្ចរបស់ប្រទេសនេះក្រខ្សត់ខ្លាំងណាស់ ។ ដូចគ្នានឹងប្រទេសប៊ូរុនឌីដែលជាប្រទេសជិតខាងរបស់ខ្លួន រ៉្វាន់ដាធ្លាប់ស្ថិតនៅក្រោមអាណានិគមនៃប្រទេសបែលហ្ស៊ិក ហើយទទួលបានឯករាជ្យមកវិញនៅក្នុងឆ្នាំ១៩៦០ ។ ប្រជាជនរ៉្វាន់ដាបែងចែកជាបីក្រុមជនជាតិគឺ ហ៊ូទូ (Hutu) ទុតស៊ី (Tutsi) និងត្វា (Twa) ។ ក្រុមទាំងបីនេះនិយាយភាសាតែមួយ មានវប្បធម៌ដូចគ្នា និងកាន់សាសនារ៉ូម៉ាំងកាតូលិក ។

រយៈបីខែនៅក្នុងឆ្នាំ១៩៩៤ សង្គមរ៉្វាន់ដាបានឆ្លងកាត់នូវអំពើយ៉ាងព្រៃផ្សៃមួយក្នុងចំណោមអំពើព្រៃផ្សៃជាច្រើនដែលបានប្រល័យជីវិតមនុស្សដ៏ច្រើនដែលមិនធ្លាប់មាននៅក្នុងសតវត្សរ៍ទី២០ ។ នៅក្នុងប្រទេសមួយដែលមានប្រជាជនប្រហែល៧លាននាក់ ប្រជាជនប្រមាណពី៥សែនទៅ១លាននាក់ត្រូវបានសម្លាប់ ។ ការសម្លាប់នេះត្រូវបានរៀបចំនិងប្រព្រឹត្តឡើងមុនខែមេសា ឆ្នាំ១៩៩៤ ដោយមានសន្ទុះយ៉ាងលឿនគួរឲ្យតក់ស្លុត និង មានលទ្ធផលល្អថែមទៀត ។ ពួកអ្នកដែលបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍ គឺជាក្រុមអ្នកនយោបាយនិងអ្នកកាន់អំណាចជ្រុលនិយមមួយក្រុមតូចដែលជិតនឹងរបបនៃអតីតប្រធានាធិបតីរ៉្វាន់ដា ជូវេណល់ ហាប៊ីយ៉ារីម៉ាណា (Juvenal Hybyarimana) ។ ឧក្រិដ្ឋជនទាំងនេះសុទ្ធតែជាទាហាន កងជីវពល និងប្រជាជនទូទាំងប្រទេសរ៉្វាន់ដាសព្វថ្ងៃ ។ ទិសដៅសំខាន់ គឺជនជាតិភាគតិចទុតស៊ី អ្នកប្រកាន់នយោបាយកណ្តាលដែលបង្កការគំរាមកំហែងដល់មនោគមវិជ្ជារបស់ពួកជ្រុលនិយម ឬអ្នកទាំងឡាយដែលប្រឆាំងមិនចូលរួមនឹងការសម្លាប់ ។ បីភាគបួននៃក្រុមភាគតិចទុតស៊ីដែលរស់នៅរ៉្វាន់ដានៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ ត្រូវបានសម្លាប់ ។ ជនជាតិហ៊ូទូ ត្វា និងប្រជាជានដែលមិនមែនជាជនជាតិរ៉្វាន់ដារាប់ពាន់រាប់ម៉ឺនក៏ត្រូវបានសម្លាប់ផងដែរ ។

អំពើប្រល័យពូជសាសន៍ បានបញ្ចប់ក្នុងខែកក្កដា ឆ្នាំ១៩៩៤ នៅពេលកងទ័ពខុទ្ទាមនៃរណសិរ្សស្នេហាជាតិរ៉្វាន់ដាបានផ្តួលរំលំរដ្ឋាភិបាលរបស់លោកប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា និងបង្ខំឲ្យកងទ័ពរ៉្វាន់ដា កងយោធា និងប្រជាជនស៊ីវិលរ៉្វាន់ដារត់ឆ្លងកាត់តាមព្រំដែនចូលទៅក្នុងប្រទេសហ្សាអៀរ ។ ក្រុមខុទ្ទាមមានសមាសភាពសំខាន់សុទ្ធតែជាកុមារ ដែលភាគច្រើនជាកូនរបស់ជនភៀសខ្លួនទុតស៊ី ដែលបាននិរទេសទៅរស់នៅបរទេសអស់រយៈពេល៣៥ឆ្នាំ ។ ភ្លាមៗនោះ ក្រុមខុទ្ទាមបានបង្កើតរដ្ឋាភិបាលថ្មីមួយ និងចាប់ផ្តើមកសាងប្រទេសជាតិឡើងវិញ ដោយការពារទឹកដីពីការវាយលុកដោយកងទ័ពរ៉្វាន់ដា ដែលត្រូវបានបណ្តេញចេញពីអំណាច និងដោះស្រាយលទ្ធផលក្រោយអំពើហិង្សាដែលបានរាលដាលពាសពេញប្រទេស ។

ការខិតខំប្រឹងប្រែងក្នុងការបង្កើតឲ្យមានការកាត់ទោសនេះ បានចាប់ផ្តើមភ្លាមៗដោយរួមសហការជាមួយអង្គការសហប្រជាជាតិបង្កើតតុលាការពិសេសមួយនៅក្នុងទីក្រុងអារូស្សានៃប្រទេសតង់ហ្សានី ដើម្បីកាត់ទោសក្រុមអ្នកដែលបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា ។ ស្របពេលជាមួយគ្នានោះដែរ រដ្ឋាភិបាលថ្មីនៃប្រទេសរ៉្វាន់ដាបានចាប់ផ្តើមធ្វើការចាប់ខ្លួនឧក្រិដ្ឋជនថ្នាក់ទាបយកមកជំនុំជម្រះទោសនៅក្នុងតុលាការរ៉្វាន់ដា ។ តុលាការពិសេសរបស់អង្គការសហប្រជាជាតិក្នុងទីក្រុងអារូស្សា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស រ៉្វាន់ដា (ICTR) មានភាពយឺតយ៉ាវក្នុងការចោទប្រកាន់ចាប់ខ្លួន កាត់ទោស និងវិនិច្ឆ័យទោស ដោយមានចុងចោទតែ១២នាក់ប៉ុណ្ណោះ បានបង្ហាញខ្លួននៅមុខអង្គជំនុំជម្រះក្នុងចន្លោះ ឆ្នាំ១៩៩៤ និងឆ្នាំ២០០១ ។

មតិខ្លះអះអាងថា អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាបានកើតឡើងយូរមកហើយតាំងពីមុនឆ្នាំ១៩៩៤ម្ល៉េះ ។ ការជជីករកអត្តសញ្ញាណ ការបណ្តេញចេញ និងការបំបាត់លក្ខណៈជាមនុស្សនូវសមាជិកនៃក្រុមភាគតិចទុតស៊ី គឺជាការវិលត្រឡប់ទៅរកចុងបញ្ចប់នៃសម័យអាណានិគម ។ ការធ្វើទុក្ខបុកម្នេញសិស្សនិងសាស្ត្រាចារ្យទុតស៊ីនិងអ្នកជិតនឹងព្រះមហាក្សត្របានចាប់ផ្តើមនៅឆ្នាំ១៩៥៩ ជាមួយនឹងព្រឹត្តិការណ៍នៃអំពើហិង្សាដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៦៤, ឆ្នាំ១៩៧៣ និងពេញ

ពាក់កណ្ដាលទីមួយនៃទសវត្សរ៍ឆ្នាំ១៩៩០ ។ ប្រៀបដូចភ្នំភ្លើងព្រួសផ្សែងមុននឹង"ដុំភ្លើងដ៏ធំមួយ"ផ្ទុះឡើង ។ ការប៉ុនប៉ងសម្លាប់និងការសម្លាប់រង្គាលនៅទសវត្សរ៍ឆ្នាំ១៩៥០ ឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ គឺជាបន្ទុះភ្នំភ្លើងតូចៗប្រៀបដូចព្រឹត្តិការណ៍នៅចន្លោះខែមេសា និងខែកក្កដា ឆ្នាំ១៩៩៤ដែរ ។ អំពើហិង្សាឆ្នាំ១៩៩៤ បានផ្លាស់ប្ដូរមុខមាត់ថ្មីសង្គមរ៉្វាន់ដាជារៀងរហូតដោយបន្សល់ទុកនូវស្លាកស្នាមជាប់ជានិច្ចទៅលើស្ថាប័នសង្គមនយោបាយ និងសេដ្ឋកិច្ច ហើយបង្កើតឲ្យមានទីតាំងប្រល័យពូជសាសន៍ ដែលជាគំនិតសំខាន់នៅក្នុងជំពូកនេះ ។

## ការអភិរក្ស ការចងចាំ និងការប្រមូលឯកសារ ទ្រឹស្ដីនិងនិយមន័យ

សោកនាដកម្មនៃអំពើប្រល័យពូជសាសន៍គឺពិបាកនឹងស្វែងយល់អំពីចំណេននិងវិសាលភាពនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ការសម្លាប់ផុតពូជនូវក្រុមមនុស្ស (ដែលត្រូវបានកំណត់ថាជាជនជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាដែលមានចែងក្នុងអនុសញ្ញាប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៨) មិនត្រឹមតែជាទង្វើដែលព្រៃផ្សៃប៉ុណ្ណោះទេ ថែមទាំងមានមហិច្ឆិតាផង ។ ក្នុងការស្វែងយល់អំពីទុក្ខសោកបែបនេះ ជំហានដំបូងត្រូវជជីករកមូលហេតុដែលរដ្ឋាភិបាលចាត់ទុកអំពើប្រល័យពូជសាសន៍ជាដំណោះស្រាយដែលអាចទទួលយកបាន ឬមានប្រសិទ្ធភាព ។ ជំហានទីពីរ គឺត្រូវបង្ហាញឲ្យឃើញថា ពិតជាមានយន្តការដ៏គួររន្ធត់នៃការសម្លាប់ជាទ្រង់ទ្រាយធំ ។ ពីទីកន្លែងខស្ទួនពុលនៃការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅកាន់វាលពិឃាតនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា វាជាព័ត៌មានស្ដីពីការសម្លាប់រង្គាលដែលគាំទ្រដោយរដ្ឋដែលតំណាងឲ្យសភាវៈអាក្រក់របស់អំពើប្រល័យពូជសាសន៍ ។ ទិដ្ឋភាពទាំងបីនៃទីតាំងជាក់ស្ដែង អណ្ដូងនិងរណ្ដៅសាកសព ព្រមទាំងក្លិននិងរូបរាងអដ្ឋិធាតុជនរងគ្រោះ បង្កើតជាទីតាំងដែលអំពើប្រល័យពូជសាសន៍កើតឡើងដោយរំឭកថា អំពើប្រល័យពូជសាសន៍ជាវត្ថុបុរាណនៃសង្គមមនុស្សមិនមែនគ្រោះធម្មជាតិនោះទេ ។ ទីតាំងប្រល័យពូជសាសន៍អាចនឹងប្រើប្រាស់ជាទីកន្លែងដែលឆ្លុះបញ្ចាំងនូវការពិតនៃអ្វីដែលបុគ្គលទាំងឡាយនៃសង្គមមួយប្រព្រឹត្តទៅលើប្រជាជនរបស់ខ្លួន ។

ប្រទេសរ៉្វាន់ដាមានទីតាំងប្រល័យពូជសាសន៍ជាច្រើនរាប់មិនអស់ ដែលទីកន្លែងខ្លះត្រូវបានគេស្គាល់និងទីកន្លែងខ្លះទៀតមិនត្រូវបានគេស្គាល់ ។ ពលរដ្ឋរ៉្វាន់ដានឹងគាស់រណ្ដៅសាកសពសាងសង់ជាបូជនីយដ្ឋាន និងបញ្ចុះអដ្ឋិធាតុជនរងគ្រោះឡើងវិញក្នុងរយៈពេលជាច្រើនឆ្នាំនាពេលខាងមុខ ។ ទោះបីជាយ៉ាងណាក៏ដោយ អំពើហិង្សាដ៏ល្វីល្វាញជាច្រើនដែលកើតឡើងក្នុងរយៈកាលនៃអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាត្រូវបានកត់ត្រាក្នុងឯកសាររួចទៅហើយ រណ្ដៅសាកសពត្រូវបានជីកគាស់ឡើង ហើយទីតាំងសម្លាប់ក៏ត្រូវបានកត់ត្រាទុកនៅលើផែនទីធ្វើជាវត្ថុតាងផងដែរ ។ ទីតាំងទាំងនេះមានសារសំខាន់ណាស់ មិនមែនសម្រាប់តែក្រុមគ្រួសាររបស់សាកសពនោះទេ ថែមទាំងសម្រាប់ក្រុមអ្នកនយោបាយ អ្នកស្រាវជ្រាវ មេដឹកនាំសាសនា និងក្រុមបុគ្គលិកជំនួយដែលកំពុងតែដោះស្រាយតម្រូវការចាំបាច់របស់ប្រទេសដែលបំផ្លិចបំផ្លាញដោយការប៉ុនប៉ងជិតបានសម្រេចនូវចំណុចនៃផែនការ"ដំណោះស្រាយចុងក្រោយ" ។

ក្នុងការរុករកនូវបញ្ហានិងការពិភាក្សាជុំវិញទីតាំងប្រល័យពូជសាសន៍នៅរ៉្វាន់ដាឆ្នាំ២០០០ ខ្ញុំសង្កេតឃើញមានសកម្មភាពដែលមានទំនាក់ទំនងគ្នាផ្សេងៗគ្នាចំនួនបីស្ដីពីទីតាំងប្រល័យពូជសាសន៍នេះ ÷ ១) ការអភិរក្សនិងការរៀបចំឡើងវិញឆ្អឹងសពជនរងគ្រោះនិងទម្រង់នៃអដ្ឋិធាតុ ២) ការរំឭកនិងការធ្វើបុណ្យខួបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ និង៣) ការប្រមូលឯកសារនិងការស្រាវជ្រាវអំពីព្រឹត្តិការណ៍ដែលកើតឡើង ។ ទោះបីជាសកម្មភាពទាំងបីនេះជាកិច្ចការដែលបំពេញគ្នា ឬជាសកម្មភាពដែលវិវត្តទៅមុខក៏ដោយ តាមការអនុវត្តជាក់ស្ដែង សកម្មភាពទាំងនេះកើតឡើងត្រួតគ្នា និងជួយឬធ្វើឲ្យអន្តរាយគ្នាទៅវិញទៅមក ។ មុននឹងពិភាក្សាសកម្មភាពទាំងបីនេះនៅក្នុងបរិបទរ៉្វាន់ដា ខ្ញុំសូមអនុញ្ញាតធ្វើការកំណត់និយមន័យមួយចំនួនដែលខ្ញុំអាចកំណត់ភាពខុសប្លែកគ្នារវាងសកម្មភាពទាំងបីនេះ ។

**ការអភិរក្ស** មានន័យថាការបញ្ឈប់ដំណើរវិវត្តនៃធម្មជាតិនិងការរក្សាអ្វីមួយឲ្យនៅក្នុងសភាពដដែល ។ ទាក់ទិននឹងការអភិរក្សដដែល គឺការរៀបចំឡើងវិញដែលសកម្មភាពក្នុងការ

ផ្លាស់ប្តូរជាចាំបាច់ ត្រឡប់ទៅរកសភាពដើមដែលអាចរក្សាទុកបានដោយមិនកំណត់ ។ វាមិនច្បាស់លាស់ថាតើការប្រើងប្រែងក្នុងការអភិរក្សឬរៀបចំឡើងវិញ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រអាចសន្មតទីតាំងពិតនិងជាក់ស្តែងបានដែរឬយ៉ាងណា ។ គេតែងបញ្ជាក់ឬយល់ថា អ្វីមួយអាចថែរក្សាទុកបានអាស្រ័យនឹងលក្ខខណ្ឌការកំណត់បរិច្ឆេទនិងពេលវេលាច្បាស់លាស់ ។ ដោយយោងតាមលទ្ធផលក្រោយអំពើប្រល័យពូជសាសន៍ ការអភិរក្សទីតាំងប្រល័យពូជសាសន៍ មានន័យថាការសម្រេចចិត្តទៅលើអ្វីដែលត្រូវអភិរក្ស (អដ្ឋិធាតុ អគារ អាវុធ ឬឯកសារ) និងត្រូវតាមពេលវេលាក្នុងប្រវត្តិសាស្ត្រ ។

តាមការអនុវត្តនិងការសិក្សា ការអភិរក្សទីតាំងប្រល័យពូជសាសន៍ជាចំណុចប្រសព្វនៃការអភិរក្ស ឬការរៀបចំឡើងវិញនូវប្រវត្តិសាស្ត្រ និងនរវិទ្យាខាងកោសល្យវិច័យ ។ ដោយជាទីតាំងឧក្រិដ្ឋកម្មអន្តរជាតិ ទីតាំងប្រល័យពូជសាសន៍នេះមានភ័ស្តុតាងសំខាន់ៗពីអដ្ឋិធាតុជនរងគ្រោះជាក់ស្តែងរហូតដល់អំពើហិង្សាដែលអាចប្រើប្រាស់ក្នុងការកំណត់កាលបរិច្ឆេទនិងពេលវេលានៃឧក្រិដ្ឋកម្ម និងក្នុងការស្វែងរកឧក្រិដ្ឋជន ។ អ្នកជំនាញខាងកោសល្យវិច័យ ប្រើប្រាស់វិធីសាស្ត្រផ្សេងៗដែលអាចប្រមែប្រមូល និងវិភាគសណ្ឋានដី សរសៃឈាម ឬសាច់ដុំ ឆ្អឹងសក់ ។ល ។ ដើម្បីពិចារណាអង្គហេតុពិតអំពីព្រឹត្តិការណ៍នេះ ។

ម្យ៉ាងទៀត ការអភិរក្សនិងការរៀបចំឡើងវិញទីតាំងប្រល័យពូជសាសន៍ក៏មានវត្ថុបំណងអប់រំអ្នកដែលមិនបានឆ្លងកាត់ព្រឹត្តិការណ៍នោះបានយល់ដឹងឲ្យបានច្បាស់អំពីរឿងរ៉ាវដែលបានកើតឡើងដោយប្រើប្រាស់អដ្ឋិធាតុជនរងគ្រោះជាក់ស្តែងនៃសម័យកាលនោះ ។ ការអភិរក្សបែបនេះពុំសូវមានប្រិតប្រៀនដូចការអភិរក្សសម្រាប់បម្រើឲ្យគោលបំណងផ្លូវច្បាប់ ក៏ប៉ុន្តែការអភិរក្សបែបនេះពឹងផ្អែកទាំងស្រុងលើស្លាកស្នាមនៅលើរូបរាងកាយនិងភាពជាក់ស្តែង ។ ជាងនេះទៀត អ្នកជំនាញខាងអភិរក្សប្រវត្តិសាស្ត្រព្រួយបារម្ភអំពីការរៀបចំឡើងវិញនូវភាពជាក់ស្តែងនៃរឿងរ៉ាវដែលកើតឡើងក្នុងទីកន្លែងណាមួយ ក្នុងខណៈដែលក្រុមអ្នកជំនាញទាំងនេះកំពុងស្វះស្វែងរកឲ្យមានការអភិរក្សទីតាំងប្រល័យពូជសាសន៍នោះសម្រាប់បំណងថ្ងៃអនាគត ។ សកម្មភាពទាំងពីរនេះ មានវិធីសាស្ត្រគោលបំណងនិងប្រវត្តិសាស្ត្រផ្សេងៗគ្នា ហើយត្រៀមខ្លួនជាស្រេចក្នុងការដោះស្រាយការរំលោភសិទ្ធិមនុស្សនៅលើពិភពលោកអស់រយៈពេលជាច្រើនទសវត្សរ៍ ។ ពីការគាំពារនិងការអភិរក្សទីកន្លែងសម្ងាប់នៃប្រវត្តិសាស្ត្ររបស់ជនជាតិដើមអាមេរិកនៅអាមេរិកខាងជើងរហូតដល់ការជីកគាស់រណ្តៅសាកសពនៅអតីតប្រទេសយូហ្គោស្លាវី ការអភិរក្ស និងការធ្វើកោសល្យវិច័យ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងស្ថានភាពដែលងាយនឹងប្រេះស្រាំនយោបាយ និងស្ថានភាពយុត្តិសាស្ត្រច្បាប់ ។


ឯកសារដែលសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យនៅមន្ទីរ ស-២១

សកម្មភាពទីពីរ គឺការរំឭកនិងការធ្វើខួបរំឭកដែលជាសកម្មភាពដែលមានទំនាក់ទំនងគ្នា ។ នៅក្នុងការរំឭកដល់សោក-នាដកម្មមួយ តែងតែមានអារម្មណ៍ដក់ជាប់គោរព

ចំពោះជនរងគ្រោះ និងធ្វើឲ្យអ្នកដទៃដឹង និងចងចាំរឿងរ៉ាវដែលបានកើតឡើងចំពោះអ្នកទាំងនោះ ។ ពិធីរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ អាចប្រព្រឹត្តទៅជាសាធារណៈនិងរួមគ្នា ឬជាឯកជននិងបុគ្គល ។ ជាក់ស្តែង ការរៀបចំពិធីរំឭកនេះសំដៅការប្រារព្ធទិវាដែលចងចាំព្រឹត្តិការណ៍ពិសេសមួយ ឬក្រុមជនរងគ្រោះ ឬការសាងសង់ជាបូជនីយដ្ឋាន ឬការសាងសង់ជាសារមន្ទីរ ឬការសរសេរជាសាច់រឿង និពន្ធបទចម្រៀង ឬការដាក់តាំងផ្ទាំងគំនូរ ។ ការរៀបចំពិធីរំឭកនេះក៏អាចបញ្ចូលគ្នា ជាមួយនឹងការអភិរក្សដើម្បីបង្ហាញពីហេតុការណ៍ដែលបានកើតឡើងក្នុងអតីតកាលតាមរយៈការថែរក្សាទុកវត្ថុតាងមួយចំនួនឲ្យនៅដដែល ក្នុងខណៈដែលវត្ថុតាងមួយចំនួនផ្សេងទៀតមានការផ្លាស់ប្តូរនូវលក្ខណៈដើម ។ ការរៀបចំពិធីរំឭកវិញ្ញាណក្ខន្ធពុំមានគោលបំណងសំដៅយកផ្នែកច្បាប់ ឬផ្នែកស្រាវជ្រាវនោះទេ ក៏ប៉ុន្តែវាជាកាយវិការខាងនយោបាយមួយដែលបង្ហាញពីសាមគ្គីភាពជាមួយជនរងគ្រោះ ។ ការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ក៏ជាការបង្ហាញដ៏សំខាន់អំពីការឆ្លើយតបខាងសាសនានិងសីលធម៌របស់ប្រជាជនទៅនឹងការបាត់បង់ ។

ការប្រមូលឯកសារនិងការស្រាវជ្រាវគឺជាសកម្មភាពទីបីដែលជាញឹកញាប់កើតឡើងក្រោយការប្រល័យពូជសាសន៍ ។ ការប្រមូលឯកសារដែលជាការប្រឹងប្រែងក្នុងការបង្កើតនូវរឿងរ៉ាវដែលអាចជឿទុកចិត្តបាននៃព្រឹត្តិការណ៍ដោយផ្អែកលើប្រភពព័ត៌មានទីមួយ អាចបម្រើឲ្យគោលបំណងរបស់អ្នកច្បាប់ អ្នកស្រាវជ្រាវ ឬអ្នកនយោបាយ ប៉ុន្តែមិនអាចជួយកាត់បន្ថយភាពសោកសៅនិងមិនអាចជួយសម្រួលដល់ការកាន់មរណទុក្ខតាមវិធីនៃការរៀបចំរំឭកវិញ្ញាណក្ខន្ធនោះទេ ។ ជាទូទៅ គម្រោងប្រមូលឯកសារដែលបង្កើតដោយអ្នកស្រាវជ្រាវជាន់ខ្ពស់មានទិសដៅស្វែងរកអង្គហេតុពិតនៃព្រឹត្តិការណ៍ ឬរយៈកាលនៃព្រឹត្តិការណ៍នោះដើម្បីយកមកធ្វើការសិក្សាវិភាគនិងចងក្រងទុកសម្រាប់ក្មេងជំនាន់ក្មេងក្រោយ ។

អំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤ នៅរ៉្វាន់ដាជំរុញឲ្យពលរដ្ឋរ៉្វាន់ដាចូលរួមក្នុងសកម្មភាពទាំងបីនេះ គឺការអភិរក្ស ការរំឭកវិញ្ញាណក្ខន្ធ និងការប្រមូលឯកសារ ។ នៅខែសីហា ឆ្នាំ ២០០០ ខ្ញុំមានបំណងកំណត់អ្វីដែលពលរដ្ឋរ៉្វាន់ដាបានធ្វើទាក់ទិននឹងទីតាំងប្រល័យពូជសាសន៍ដោយយោងតាមគំនិតនៃសកម្មភាពទាំងបីខាងលើ ។ ខ្ញុំបានជួបសម្ភាសន៍ជាមួយតំណាងដែលមកពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ផ្នែកស្រាវជ្រាវ និងប្រជាជនដែលពាក់ព័ន្ធក្នុងសកម្មភាពទាំងនេះតាមកម្រិតនិងក្នុងហេតុផលផ្សេងៗគ្នា ។ ក្នុងករណីជាច្រើនសកម្មភាពទាំងនេះកើតឡើងត្រួតគ្នា ។ ចំណែកទីតាំងប្រល័យពូជសាសន៍មូរ៉ាមប៊ី ក្នុងខេត្តហ្គីកុងហ្គោរ៉ូនេះវិញ កិច្ចខិតខំប្រឹងប្រែងអភិរក្សដែលទទួលបាននូវការជួយឧបត្ថម្ភជាឯកជនមួយរួមបញ្ចូលជាមួយនឹងបំណងប្រាថ្នាចង់បានរបស់សហគមន៍ក្នុងតំបន់ឲ្យមានការរៀបចំពិធីរំឭកដល់វិញ្ញាណក្ខន្ធជនរងគ្រោះចំនួន៥ម៉ឺននាក់ ។ ក្នុងខេត្តឃីហ្កាលីនោះវិញ រដ្ឋា-ភិបាលចាប់អារម្មណ៍នឹងការស្ថាបនាបូជនីយដ្ឋាននិងសារមន្ទីរប្រល័យពូជសាសន៍ដែលអាចបង្រៀនពិភពលោកអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសរ៉្វាន់ដានិងរំឭកដល់ពលរដ្ឋរ៉្វាន់ដា ផ្ទាល់អំពីអតីតកាលដែលពលរដ្ឋរ៉្វាន់ដា មិនគួរឲ្យកើតមានឡើងម្តងទៀត ។ នៅសកលវិទ្យាល័យជាតិក្នុងខេត្តប៊ូថា ក្រុមអ្នកស្រាវជ្រាវជាន់ខ្ពស់សង្ឃឹមថានឹងបង្កើតនូវមជ្ឈមណ្ឌលឯកសារមួយ ដែលនឹងជំរុញឲ្យមានការស្រាវជ្រាវទៅលើអំពើប្រល័យពូជសាសន៍ និងការអភិរក្សនូវឯកសារសំខាន់ៗដែលសេសសល់ពីសម័យកាលនោះ ។

ការថែរក្សាទីតាំងប្រល័យពូជសាសន៍គឺមានទំនាក់ទំនងនឹងការរំឭកអដ្ឋិធាតុជនរងគ្រោះនិងការប្រមូលឯកសារ ។ នៅក្នុងប្រទេសរ៉្វាន់ដាបច្ចុប្បន្ន សកម្មភាពទាំងបីនេះមិនទទួលបាននូវការពេញនិយមរបស់ប្រជាជនរ៉្វាន់ដានោះទេ ដោយសារតែការថែរក្សានិងការរៀបចំទីតាំងប្រល័យពូជសាសន៍ឡើងវិញ ពុំត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ និងត្រូវចំណាយថវិកាអស់ជាច្រើន ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយរួមបញ្ចូលជាមួយនឹងការរំឭកអដ្ឋិធាតុជនរងគ្រោះនិងការប្រមូលឯកសារ ការថែរក្សាទីតាំងប្រល័យពូជសាសន៍ទទួលបាននូវការគាំទ្រយ៉ាងច្រើនពីសំណាក់ពលរដ្ឋរ៉្វាន់ដានិងទទួលបានការឧបត្ថម្ភពីបុគ្គល និងស្ថាប័នជាច្រើន ។ **(នៅមានត)**

**ស៊ូហ្សាន អ៊ី យុក**

# ក្មេងជំនាន់ក្រោយនិងការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

តើកូនចៅខ្មែរជំនាន់ក្រោយគួរទទួលបានការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀនដែរឬទេ? ចាប់តាំងពីឆ្នាំ២០០២រហូតមកទល់នឹងបច្ចុប្បន្ននេះ អត្ថបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមិនទាន់ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលានៅឡើយទេ ។ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងរួមមួយទេនោះ កូនចៅខ្មែរជំនាន់នេះនិងជំនាន់ក្រោយនឹងបានយល់ដឹងតិចតួចបំផុតអំពីប្រវត្តិសាស្ត្រដ៏ជូចត់នៃប្រទេសរបស់ខ្លួន ។ កូនខ្មែរដែលកើតក្រោយរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់គួរតែទទួលបានការបង្ហាត់បង្រៀននៅតាមសាលាអំពីមូលហេតុនិងលទ្ធផលនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ធ្វើដូច្នេះ អ្នកទាំងអស់នេះនឹងមិនប្រព្រឹត្តកំហុសដដែលនេះជាថ្មីម្តងទៀត ហើយថែមទាំងអាចជួយអ្នកទាំងនេះក្នុងការស្វែងរកអនាគតភ្លឺស្វាងមួយទៀតផង ។

ការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យគឺជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការទប់ស្កាត់ការកើតមានឡើងនូវអំពើប្រល័យពូជសាសន៍និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដទៃទៀតនាពេលអនាគត ហើយថែមទាំងជួយជំរុញដល់ដំណើរការផ្សះផ្សារវាងជនរងគ្រោះនិងជនដៃដល់ទៀតផង ។ រយៈពេលជិត៣០ឆ្នាំហើយចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនខ្មែរភាគច្រើនបានលាក់ទុកបទពិសោធន៍ឈឺចាប់ទាំងឡាយដែលខ្លួនបានជួបប្រទះក្នុងរយៈកាលនៃរបបនេះ ដោយមួយចំនួនមិនចង់និយាយ ហើយមួយចំនួនទៀតមិនមានឱកាសក្នុងការនិយាយ ។ ឪពុកម្តាយមួយចំនួនដែលបានរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានត្អូញត្អែរថាកូនៗរបស់ខ្លួនមិនជឿថា អំពើឃោរឃៅបែបនេះបានកើតមានឡើងក្នុងប្រទេសកម្ពុជានោះទេ ។

ជារៀងរាល់ឆ្នាំក្នុងពិធីបុណ្យចូលឆ្នាំនិងបុណ្យភ្ជុំបិណ្ឌម្តងៗ ខ្ញុំនិងភរិយាតែងតែយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅឯទីវត្តអារាមដើម្បីរំឭកដល់វិញ្ញាណក្ខន្ធឪពុកម្តាយនិងបងពីរនាក់របស់ខ្ញុំដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ កូនប្រុសខ្ញុំដែលមានអាយុទើបបាន៥ឆ្នាំបានសួរខ្ញុំថាខ្ញុំ តើខ្ញុំនិយាយអ្វីខ្លះនៅពេលខ្ញុំនិងភរិយាខ្ញុំប្រគេនចង្ហាន់ដល់ព្រះសង្ឃនិងអុជធូបបន់ស្រន់ម្តងៗ ។ ខ្ញុំបានប្រាប់កូនខ្ញុំថា ប៉ាកំពុងនឹកដល់វិញ្ញាណក្ខន្ធជីដូនជីតានិងអ៊ំៗរបស់កូនដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ ក្នុងខណៈនោះ កូនប្រុសខ្ញុំហាក់មានទឹកមុខឆ្ងល់ ហើយបានសួរខ្ញុំទៀតថា “ហេតុអ្វីបានជាគាត់ត្រូវយកទៅសម្លាប់? តើខ្មែរក្រហមជាអ្វី?” ពាក្យសំណួរនេះភ្លាមខ្ញុំមានការភ្ញាក់ផ្អើលនិងនឹកអាណិតដល់កូនប្រុសខ្ញុំខ្លោចចិត្ត ។ ជាងនេះទៅទៀតកូនប្រុសរបស់ខ្ញុំបាននិយាយទៀតថា នៅពេលគេធំឡើងគេនឹងធ្វើជាប៉ូលិស ហើយគេនឹងមានកាំភ្លើងដើម្បីបាញ់ពួកខ្មែរក្រហមដែលបានសម្លាប់លោកតា លោកយាយនិងអ៊ំៗរបស់គេ ។ នេះគឺជាសម្តីក្មេងប្រុសម្នាក់ ដែលជាកូនរបស់ជនរងគ្រោះម្នាក់ដែលនៅរស់រានមានជីវិត និងជាចៅនិងក្មួយរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ ក្រោយពីបានឮកូនប្រុសរបស់ខ្ញុំនិយាយដូច្នេះ ខ្ញុំមានការរន្ធត់ក្នុងចិត្តយ៉ាងខ្លាំង ហើយគិតក្នុងចិត្តថា តើយើងត្រូវធ្វើយ៉ាងណាដើម្បីស្រាយបំភ្លឺពីបញ្ហានេះដល់ក្មេងជំនាន់ក្រោយឲ្យបានយល់អំពីរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហម ។

នេះជាសញ្ញាមួយបង្ហាញថា អំពើប្រល័យពូជសាសន៍នៅតែបន្តយាយីដល់អនាគតនៃប្រទេសកម្ពុជាយើង ។ ការបង្ហាត់បង្រៀនអំពីព្រឹត្តិការណ៍ទាំងមូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យអាចជួយសម្រាលការឈឺចាប់របស់អ្នកដែលនៅរស់រានមានជីវិតដោយផ្តល់ឱកាសឲ្យគាត់រៀបរាប់អំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់ប្រាប់កូនចៅរបស់គាត់ ។ ដូច្នេះ ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងបង្កើតឲ្យមានការពិភាក្សាលើប្រធានបទនេះ ដែលជាមូលដ្ឋានមួយដ៏សំខាន់សម្រាប់សិស្សក្នុងការជជែកពិភាក្សានូវអ្វីដែលខ្លួនបានរៀននៅសាលា ជាមួយឪពុកម្តាយនិងបងប្អូនដែលធ្លាប់ឆ្លងកាត់របបនោះផ្ទាល់ ។

វត្តមាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការខ្មែរក្រហម) បានបង្ហាញឲ្យឃើញថា ការសិក្សាពីប្រវត្តិសាស្ត្រ

កម្ពុជាប្រជាធិបតេយ្យកាន់តែមានសារសំខាន់ខ្លាំងថែមទៀត ។ សិស្សានុសិស្សទាំងអស់ត្រូវតែទទួលបាននូវការបង្ហាត់បង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យពួកគេអាចចូលរួមក្នុងដំណើរការតុលាការ ហើយសង្ឃឹមថានឹងជួយពង្រឹងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។ លុះត្រាតែប្រជាជនដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទើបប្រជាជនមានមូលដ្ឋានដើម្បីចូលរួមក្នុងដំណើរការនៃការកាត់សេចក្តី និងឈានទៅដល់ការពិភាក្សាពីបញ្ហាយុត្តិធម៌ ។

វាគឺជារឿងដ៏គ្រោះថ្នាក់បំផុត ដែលការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបន្តអវត្តមានពីកម្មវិធីសិក្សារបស់សាលា ហើយកូនចៅខ្មែរជំនាន់ក្រោយអាចនឹងជួបប្រទះនូវអំពើប្រល័យពូជសាសន៍ជាថ្មីម្តងទៀត ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាអត្ថបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងត្រូវបានដាក់បញ្ចូលទៅក្នុងវិធីសិក្សា ។ កូនចៅខ្មែរជំនាន់ក្រោយត្រូវតែទទួលបានឱកាសសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការនាំកម្ពុជាឆ្ពោះទៅវិបុលភាពនាពេលអនាគត ។

**រស់ សំពៅ**

# ព័ត៌មានបន្ថែមអំពី អៀង សារី


អៀង សារី ឆ្នាំ១៩៧៩

អៀង សារី មានស្រុកកំណើតនៅភូមិហ័រឡាក់B ឃុំលឿងហ័រ ស្រុកចូវថាញ់ ខេត្តត្រាវិញ ។ ផ្ទះកំណើតរបស់ អៀង សារី សង់ពីថ្មផ្ទាល់ដីដំបូលប្រក់ស៊ីប្រូស៊ីម៉ង់ត៍ ។ បច្ចុប្បន្នផ្ទះនេះ ក្មួយស្រីរបស់ អៀង សារី កំពុងរស់នៅ ។

យើងបានជួបក្មួយប្រុសរបស់ អៀង សារី ឈ្មោះ ថាច់ វុត្ថា និងក្មួយប្រសាឈ្មោះ ហ៊ី (ថាច់ វុត្ថា និងប្រពន្ធ ហ៊ីម ត្រូវជាកូន របស់បងស្រី អៀង សារី) ។ វុត្ថា បានឲ្យដឹងថា ឪពុករបស់ អៀង សារី ឈ្មោះ គឹម រៀម ជាជនជាតិខ្មែរកម្ពុជាក្រោម និងម្តាយ ឈ្មោះ ច្រិន ធិ ឡូយ (Tran Thi Loi) ជនជាតិចិនដែលរត់មកពីស្រុកចិនតាំងពីតូចៗជាមួយឪពុកម្តាយ ។

អៀង សារី មានបងប្អូន៣នាក់ ។ បងទី១ឈ្មោះ គឹម ចូវ ភេទប្រុស នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ មានឋានៈជាប្រធានផ្សារអូរឫស្សី ។ នៅអំឡុងទសវត្សរ៍ឆ្នាំ៨០ ចូវ និងក្រុមគ្រួសារបានភៀសខ្លួនទៅរស់នៅរដ្ឋហ្វរីដា សហរដ្ឋអាមេរិក ។ បងទី២ឈ្មោះ គឹម ធី កូវ ភេទស្រី មានប្តីឈ្មោះ ថាច់ សុង (បច្ចុប្បន្នស្លាប់ទាំងពីរនាក់ប្តីប្រពន្ធ) ។ កូវ មានកូន៧នាក់ កូនម្នាក់ស្លាប់ដោយសារជំងឺ កូន៣នាក់ រស់នៅប្រទេសកម្ពុជា និង៣នាក់ទៀតរស់នៅភូមិកំណើត ។

អៀង សារី ជាកូនពៅ ដែលមានឈ្មោះ កំណើតថា គឹម ស៊្រី ។ អៀង សារី បានមករស់ស្រុកខ្មែរតាំងពីកុមារភាព ។ អៀង សារី ធ្លាប់បានទៅលេងស្រុកកំណើតម្តង មុនពេលទៅសិក្សានៅប្រទេសបារាំង ។ ពេលនោះ ថាច់ សុង បានលក់ស្រូវ២០០ ថាំងដើម្បីយកថវិកាមកជួយឧបត្ថម្ភ និងជូនដំណើរ អៀង សារី ទៅរៀននៅប្រទេសបារាំង ។

ឪពុករបស់ អៀង សារី ក្រោយមកមានជំងឺ ហើយពិការភ្នែកមួយចំហៀង ។ ដោយក្តីនឹករឭកចំពោះកូន ម្តាយរបស់ អៀង សារី តែងតែសួរនាំអំពីសុខទុក្ខ អៀង សារី ជានិច្ច ។ ប៉ុន្តែ អៀង សារី មិនដែលប្រាប់ពីសុខទុក្ខរបស់ខ្លួន ឬទៅលេងស្រុកកំណើតសោះឡើយ ។

វុត្ថា បានឲ្យដឹងថា នៅអំឡុងឆ្នាំ១៩៧៦ រដ្ឋាភិបាលវៀតណាមបានទៅលេងនិងនាំយកទឹកដោះគោ តែស្ករ ទៅជូនឪពុកម្តាយរបស់ អៀង សារី បាន៥-៦ដងដែរ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៧បន្តមក រដ្ឋាភិបាលវៀតណាមមិនដែលទៅសួរសុខទុក្ខនិងឧបត្ថម្ភទឹកដោះគោតែស្ករទៀតឡើយ ។

**ឡុង ដានី**

# ទូតឡាវ : ជាមនុស្សដំបូងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃជ័យជម្នះរបស់កងទ័ពកម្ពុជា ក្រោមការដឹកនាំរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានផ្តួលរំលំរបបខ្មែរក្រហមនិងរំដោះប្រជាពលរដ្ឋឲ្យរួចផុតពីរបបប្រល័យពូជសាសន៍។ រដ្ឋធានីភ្នំពេញ ក៏ដូចជាខេត្តនានានៅទូទាំងប្រទេសត្រូវបានរំដោះជាស្ថាពរ ។

ព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បន្ទាប់ពីស្នូរគ្រាប់កាំភ្លើង តូច ធំ លែងឮបាញ់តគ្នា កងទ័ពកម្ពុជាបានទទួលបទបញ្ជាពីអគ្គបញ្ជាការជាន់ខ្ពស់ ឲ្យបើកយុទ្ធនាការបោសសម្អាតត្រួតពិនិត្យសមរភូមិប្រយុទ្ធដោយសហការជាមួយកងទ័ពវៀតណាម ។ រថក្រោះតេ៥៤ រថយន្តផ្ទុកយោធានិងកងទ័ពថ្មើរជើងដើរល្បាតផែកនេរពាសពេញទីក្រុងភ្នំពេញ ។ ក្បួនល្បាតដើរមកដល់អគារមួយខ្នងមានសភាពស្អាតល្អនិងស្ងាត់ជ្រងំ ទំនងជាស្ថានទូតប្រទេសណាមួយ មេបញ្ជាការកងល្បាតបានឲ្យយោធាបើកទ្វារចូលទៅពិនិត្យអគារនោះភ្លាម ប៉ុន្តែនៅជុំវិញអគារពុំឃើញមានមនុស្សឃើញតែរថយន្ត១គ្រឿងចតក្នុងបន្ទប់ល្វែងដាក់ឡានបិទជិតនិងចាក់សោ ដែលមើលឃើញតាមជញ្ជាំងចម្រឹងលួសសំណាញ់ដែក ។ បន្ទាប់ពីស្តាប់របាយការណ៍របស់កូនទាហានរាយការណ៍ថាគ្មានមនុស្សនៅក្នុងអគារនេះទេ ប៉ុន្តែហាក់ដូចជា មានមនុស្សពួនសម្ងំនៅក្នុងអគារ មេបញ្ជាការនោះសង្ស័យថាប្រហែលជាស្ថានទូតប្រទេសណាមួយហើយ ។ មិនអស់ចិត្ត មេបញ្ជាការក៏បាននាំកូនទាហានមួយក្រុមចូលទៅក្នុងអគារជាលើកទី២ ហើយប្រកាសតាមមីក្រូថា «យើងជាកងទ័ពកម្ពុជារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាមករំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីរបបខ្មែរក្រហម ប៉ុល ពត» ។

មួយសន្ទុះក្រោយមក ទ្វារបន្ទប់អគារដែលចាក់សោត្រូវបានបើកចំហ ហើយលេចចេញបុរសម្នាក់និងសហការី៤នាក់និយាយជាភាសាខ្មែរយ៉ាងច្បាស់ ព្រមទាំងលើកទង់ជាតិមួយបង្ហាញលោកមេបញ្ជាការថា ÷ «យើងខ្ញុំទាំងអស់គ្នាជាកម្មាភិបាលស្ថានទូតឡាវប្រចាំនៅកម្ពុជា ។ ពេលនោះមេបញ្ជាការបានចាប់ដៃកម្មាភិបាលទូតឡាវដោយក្តីរំភើបរីករាយ រួចក៏បានរាយការណ៍ជូនអគ្គបញ្ជាការជាន់ខ្ពស់កងទ័ពកម្ពុជា ប្រហែល១៥នាទីក្រោយមកមេបញ្ជាការកងទ័ពកម្ពុជានិងវៀតណាម បានធ្វើដំណើរមកដល់ស្ថានទូតឡាវ ហើយលោកឯកអគ្គរដ្ឋទូតឡាវបានជម្រាបជូនមេបញ្ជាការជាន់ខ្ពស់កងទ័ពកម្ពុជា និងកងទ័ពវៀតណាមថា ÷ «ខ្ញុំឈ្មោះ ខាំផាន់ វិឡាចិត ជាឯកអគ្គរដ្ឋទូតឡាវ លេខាទូតខ្ញុំម្នាក់និងកម្មាភិបាលបម្រើការងារក្នុងស្ថានទូតចំនួន៣នាក់» ។ លោកក៏បានជម្រាបជូនទៀតថា : មុនថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ មន្ត្រីស្ថានទូតទាំងអស់គ្នានាំគ្នាលាក់ខ្លួននៅក្នុងបន្ទប់អគារជាន់ក្រោមដី ដោយមុនថ្ងៃជ័យជម្នះ៧មករាប្រហែល១សប្តាហ៍ ឮស្នូរតែគ្រាប់កាំភ្លើង ធំ-តូច ផ្ទុះឡើង ចរន្តអគ្គិសនីត្រូវកាត់ផ្តាច់ រាល់ទំនាក់ទំនងជាមួយក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យត្រូវកាត់ផ្តាច់ទាំងស្រុង ។

ក្រោយពីសំណេះសំណាលអស់មួយរយៈពេលខ្លី មេបញ្ជាការកងទ័ពកម្ពុជានិងមេបញ្ជាការកងទ័ពវៀតណាមបានបង្ហូតទង់ជាតិឡាវដែលមានសញ្ញារង្វង់លោកខែពេញបូរមីឡើង ។ ទន្ទឹមនឹងនោះដែរ ភាគីកម្ពុជានិងវៀតណាមបានចាត់តាំងទាហានកម្ពុជានិងវៀតណាមមួយក្រុមការពារសន្តិសុខសណ្តាប់ធ្នាប់ និងយាមការពារបរិវេណស្ថានទូតឡាវដើម្បីធានាសុវត្ថិភាព ។

ក្រសួងការបរទេសកម្ពុជាបានបញ្ជូនម៉ូតូមួយគ្រឿងដែលជារបស់ជ័យភណ្ឌ សម្រាប់ការពាររថយន្តស្ថានទូតឡាវក្នុងពេលទំនាក់ទំនងជាមួយក្រសួងការបរទេសកម្ពុជា ។ ទន្ទឹមនេះដែរ អគ្គបញ្ជាការកងទ័ពជាន់ខ្ពស់កម្ពុជានិងវៀតណាម បានផ្ញើសារទូរលេខមួយច្បាប់ជូនមជ្ឈិមបក្សឡាវដោយឆ្លងកាត់ ទីក្រុងហូជីមិញ និងទីក្រុងហាណូយ ដើម្បីឲ្យបានជ្រាបអំពីដោគវាសនារបស់ឯកអគ្គរដ្ឋទូតឡាវ និងកម្មាភិបាលស្ថានទូតទាំងអស់ដែលនៅមានជីវិតនៅឡើយប្រកបដោយការយកចិត្តទុកដាក់ពីសំណាក់កងទ័ពកម្ពុជានិងវៀតណាម ។

នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ!របស់ឯកអគ្គរដ្ឋទូតឡាវ

ព្រមទាំងសហការីដែលជាមនុស្សដំបូងត្រូវជាប់គាំងនៅក្នុងស្ថានទូត របស់ខ្លួនមុនថ្ងៃទី៧មករា និងដែលបានសម្តែងចេញនូវទឹកចិត្ត ក្លាហានបួរផ្តាច់ខ្ពស់ ក្នុងការលះបង់អាយុជីវិតធ្វើពលិកម្មដើម្បី តួនាទីជាអ្នកការទូតដ៏ល្អកម្ររកបាន និងជាកុលបុត្រដ៏ឆ្នើមនៃ ទឹកដីឡាវសាវរបស់បក្សប្រជាជនបដិវត្តន៍ឡាវ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨០ខ្ញុំ (ភូ គឹមមឿ) អ្នកបកប្រែ ភាសាខ្មែរនៅវិទ្យុជាតិឡាវនៅរដ្ឋធានីវៀងចន្ទ ក្រសួងឃោសនាការ ព័ត៌មាននិងវប្បធម៌ឡាវ ត្រូវបានចាត់តាំងឲ្យមកបកប្រែភាសា ជូនគណៈប្រតិភូឡាវជាថ្មីម្តងទៀត នៅឱកាសប្រារព្ធខួបថ្ងៃទី២ ធ្នូ នៃថ្ងៃបង្កើតខួបកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅសាលមហោស្រពចតុមុខ ។ ក្នុងអំឡុងឆ្នាំ១៩៨០ គណៈប្រតិភូ ឡាវដែលបានមកបំពេញទស្សនកិច្ចរួមមាន ៖

- ◆សិល្បៈមជ្ឈិមរបស់ឡាវ
- ◆សិល្បៈនៃកងទ័ពរបស់ឡាវ
- ◆ក្រុមសៀករបស់ឡាវនិងគណៈប្រតិភូផ្សេងៗទៀត ។ល ។

បានមកសម្តែងបម្រើទស្សនិកជនប្រជាជនគ្រប់ស្រទាប់វណ្ណៈ មន្ត្រីរាជការ យោធា នគរបាល ដើម្បីជាការផ្តល់នូវកម្លាំងចិត្ត ចំពោះទស្សនិកជននៅរាជធានីភ្នំពេញ និងបន្តធ្វើដំណើរតាម រថយន្តទៅសម្តែងជូនប្រជាពលរដ្ឋនៅខេត្តបាត់ដំបងនិងខេត្ត សៀមរាបតាមសំណូមពររបស់រដ្ឋាភិបាលកម្ពុជា ដោយឆ្លងកាត់ នូវកំណាត់ផ្លូវដ៏សែនលំបាកក្នុងដំណាក់កាលប្រទេសកម្ពុជាទើប ឆ្លងកាត់ពីរបបខ្មែរក្រហម ។ ប្រជាជនទូទាំងប្រទេសនៅជួបបញ្ហា ការលំបាក កង្វះខាតសព្វសារពើ និងពុំទាន់បោះពុម្ពក្រដាស ប្រាក់សម្រាប់ចាយនៅឡើយ ។ រាល់ការចាយវាយដោះដូរទំនិញ សព្វសារពើ សម្រាប់ជីវភាពប្រចាំថ្ងៃ គឺយកបន្លែដូរអង្ករ យក មាសដែលនៅសេសសល់ពីការប្រមូលរបស់អង្គការខ្មែរក្រហម មកកាត់ជាចំណិតតូចៗ ដូរអង្ករហូប ដូរយកជាសម្លៀកបំពាក់ ។ ទំនិញទាំងនោះគឺនាំចូលតាមច្រកពីព្រំដែនប្រទេសថៃ និងប្រទេស ឡាវរាល់ការទិញដូរគឺគិតជាមាសសុទ្ធ ។

ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ បក្សនិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវបានរួមចំណែក ឧបត្ថម្ភគាំទ្រដល់រដ្ឋាភិបាលកម្ពុជាដូចជា ៖

- ◆ជួយម៉ាស៊ីនដេរចំនួន៩០០គ្រឿង
- ◆ក្រណាត់ស៊ីប៉ាលីរាប់ម៉ឺនម៉ែត្រ
- ◆អំបោះហុងរាប់ពាន់ដុំនិងគ្រឿងបន្លាស់ម៉ាស៊ីន មួយចំនួន ដែលមានលោក ប៊ូ ឡាំ តំណាងអគ្គភាពមន្ទីរកាត់ដេរ ។ បច្ចុប្បន្ន លោក ប៊ូ ឡាំ មានតួនាទីជាអភិបាលរងខេត្តរតនគិរី ។

កងទ័ពកម្ពុជាបានទទួលយកសម្ភារទាំងអស់នេះពីក្រសួង ការពារជាតិឡាវតាមជើងយន្តហោះក្រុមហ៊ុនអាកាសចរឡាវ វៀងចន្ទ-ភ្នំពេញ ។

បន្ទាប់ពីរកឃើញកម្មាភិបាលស្ថានទូតឡាវរួចមក ចំណង ទាក់ទងការទូតកាន់តែត្រូវបានបង្កើនយ៉ាងជិតស្និទ្ធរវាងឡាវ- កម្ពុជា ។ មជ្ឈិមបក្សនិងក្រសួងការបរទេសឡាវបានធ្វើលិខិត ជម្រាបជូនមជ្ឈិមបក្សនិងក្រសួងការបរទេសកម្ពុជា ស្នើសុំឲ្យ លោកឯកអគ្គរដ្ឋទូតឡាវ ខាំដាន់ វិឡាចិត មកវៀងសាកសួរ ជួបជុំគ្រួសារ និងធ្វើសេចក្តីរាយការណ៍ជូនមជ្ឈិមបក្សនិងក្រសួង ការបរទេសឡាវ ស្តីពីមូលហេតុអ្វីបានជាកម្មាភិបាលស្ថានទូតឡាវ ពុំបានវិលត្រឡប់មកកាន់មាតុភូមិ? ព្រោះថាពីរសប្តាហ៍មុនថ្ងៃ រំដោះទូទាំងប្រទេស ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ បានអញ្ជើញស្ថានទូតទាំងអស់នៅកម្ពុជា មកប្រជុំនៅក្រសួងការ បរទេស ។ អ្នកនាំពាក្យក្រសួងការបទេសបានបញ្ជាក់ប្រាប់ស្ថានទូត បានជ្រាបថា ៖ សភាពការណ៍រួមនៅកម្ពុជាមានសន្តិសុខនិង ស្ថានភាពនយោបាយជាប្រក្រតី ។

ប៉ុន្តែស្រាប់តែក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ប្រាប់ឲ្យស្ថានទូតប្រទេសនានា ដកថយទៅកាន់ព្រំដែនប្រទេស ថៃ ទៅតាមផ្លូវបាត់ដំបង ប៉ោយប៉ែត ឲ្យបានមុនថ្ងៃរំដោះមួយ សប្តាហ៍ ។

មុនពេលធ្វើដំណើរទៅកាន់រដ្ឋធានីវៀងចន្ទ អ្នកយកការ សារព័ត៌មានអន្តរជាតិបានសុំការអនុញ្ញាតពីក្រសួងការបរទេស កម្ពុជាជួបសម្ភាសន៍ជាមួយឯកអគ្គរដ្ឋទូតឡាវ អំពីជោគវាសនា របស់លោកនិងកម្មាភិបាលស្ថានទូតឡាវដែលបានស្ថិតក្នុងរបប ខ្មែរក្រហម ដែលកងទ័ពកម្ពុជាបានរកឃើញនៅក្នុងស្ថានទូតឡាវ ប្រចាំនៅទីក្រុងភ្នំពេញនៅព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៩ ។

**អំពីបទសម្ភាសន៍ ៖**

សំណួរទី១ៈ ហេតុដូចម្ដេចបានជាស្ថានទូតនានាត្រូវភៀសខ្លួនទៅថៃ មុនថ្ងៃ៧មករា ឆ្នាំ១៩៧៩ ហើយដោយមូលហេតុអ្វីបានជានៅសល់តែកម្មាភិបាលស្ថានទូតឡាវដែលពុំអាចភៀសខ្លួនទៅកាន់ព្រំដែនថៃ? (សំណួររបស់អ្នកយកសារព័ត៌មានជាតិនិងអន្តរជាតិ)

**មូលហេតុដូចខាងក្រោម ៖**

នៅក្នុងអំឡុងខែកញ្ញា ឆ្នាំ១៩៧៨ដល់ដើមឆ្នាំ១៩៧៩ ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យបានអញ្ជើញស្ថានទូតនៅកម្ពុជាទាំងអស់មកប្រជុំនៅក្រសួងការបរទេសស្ដាប់សេចក្ដីប្រកាសព័ត៌មានរបស់អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យបានបកស្រាយអំពីស្ថានភាពនយោបាយនៅកម្ពុជាថាៈ បច្ចុប្បន្នកងទ័ពវៀតណាមជាច្រើនកងពលបានបញ្ជូនកម្លាំងកងទ័ពឈ្លានពានវាយប្រហារកម្ទេចបំផ្លាញអាយុជីវិតប្រជាជននៅតំបន់ជាយដែន រំលោភបូរណភាពទឹកដីកម្ពុជាយ៉ាងខុសច្បាប់ កងទ័ពកម្ពុជាបានវាយតបជាមួយកម្លាំងកងទ័ពឈ្លានពានរបស់វៀតណាម ហើយបានកម្ទេចនិងសម្លាប់ចាប់ជាឈ្លើយសឹកមួយចំនួន ។



ការថ្លែងសុន្ទរកថារបស់ឯកអគ្គរដ្ឋទូតឡាវនៅក្នុងរប…ម្ពុជាប្រជាធិបតេយ្យ

នៅក្នុងនាមប្រទេសមួយបំពេញការងារទូតនៅកម្ពុជា ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ បានហាមប្រាមមិនឲ្យស្ថានទូតនានាមានសិទ្ធិសេរីភាពក្នុងការធ្វើដំណើរទៅណាមកណាតាមចិត្តចង់ទៅឡើយ គ្មានសិទ្ធិទាក់ទងតាមប្រព័ន្ធទូរស័ព្ទរវាងស្ថានទូតមួយទៅស្ថានទូតមួយទៀត ។ ផ្លូវត្រូវធ្វើដំណើរពីស្ថានទូតមកក្រសួងការបរទេសត្រូវបានកំណត់ច្បាស់ ចំពោះអ្នកបើកបររថយន្តស្ថានទូតបរទេសនីមួយៗត្រូវបានក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យជាអ្នកកំណត់ផ្ដល់ឲ្យ ។

ចំពោះគ្រឿងឧបភោគបរិភោគរបស់ស្ថានទូតនានាត្រូវបានក្រសួងការបរទេសជាអ្នកចែកចាយក្នុងការទូទាត់រវាងស្ថានទូតជាមួយក្រសួងការបរទេស ផ្នែកផ្គត់ផ្គង់គ្រឿងឧបភោគ ។ ជីវិតអ្នកការទូត ឡាវដែលជាតំណាងប្រទេសមួយប្រចាំការនៅរដ្ឋធានីភ្នំពេញនៅក្នុងរបបខ្មែរក្រហមស្ថិតនៅក្នុងទីក្រុងមួយដ៏ល្អ ដែលល្បីល្បាញនៅអាស៊ីអាគ្នេយ៍ មានភាពស្ងាត់ជ្រងំ មានផ្ទះគ្មានមនុស្សនៅ មានផ្លូវគ្មានមនុស្សដើរ រថយន្តដែលខូច យកទៅបិទតាមច្រកផ្លូវតូចៗចេញចូល ។

ក្នុងដំណើរឆ្ពោះទៅវៀង សាកសួរសុខទុក្ខគ្រួសារនៅទីក្រុងវៀងចន្ទ និងរាយការណ៍ជូនមជ្ឈិមបក្សឡាវអំពីសភាពការណ៍ដែលទូតឡាវពុំបានភៀសខ្លួនចេញមុនថ្ងៃរំដោះនោះ ក៏ដូចជាប្រសាសន៍របស់លោក ខាំផាន់ វិឡាចិត តបបទសម្ភាសន៍ជាមួយអ្នកយកព័ត៌មានជាតិ និងអន្តរជាតិនៅភ្នំពេញដូច្នេះដែរ ។

ខ្ញុំបាទចាំច្បាស់ថា នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៩ មជ្ឈិមបក្សឡាវបានអនុញ្ញាតឲ្យលោក ខាំផាន់ វិឡាចិត ធ្វើបឋកថាមួយនៅសាលានយោបាយទ្រឹស្ដី ណង បន រដ្ឋធានីវៀងចន្ទ ដោយមានការចូលរួមស្ដាប់ពីមជ្ឈិមបក្សឡាវ រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ប្រធាន អនុប្រធាន អគ្គនាយកដ្ឋាន អភិបាលខេត្ត អភិបាលក្រុងទូទាំងប្រទេស ។

លោក ខាំផាន់ វិឡាចិត ជាអ្នកការទូតដែលមានចំណេះដឹងខ្ពង់ខ្ពស់ទាំងភាសាជាតិ អន្តរជាតិ ពិសេសភាសាខ្មែរ លោកធ្លាប់បួសជាសង្ឃនិងបន្តការសិក្សានៅវត្តឧណ្ណាលោមរយៈពេល៥-៦ឆ្នាំ ។ នៅឆ្នាំ១៩៥០ លោក ចេះសរសេរ ចេះអាន និយាយ

ភាសាខ្មែរយ៉ាងក្បោះក្បាយ ។ លោកមានដើមកំណើតនៅទីរួមខេត្ត លួងព្រះបាងប្រទេសឡាវ ។ ក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ ១៩៧៩ មជ្ឈិមបក្សឡាវបានបញ្ជូនលោកទៅបំពេញការងារជាឯកអគ្គរដ្ឋទូតឡាវប្រចាំនៅកម្ពុជារហូតដល់ឆ្នាំ១៩៨២ ។

២៧ឆ្នាំបានកន្លងផុតទៅជីវិតរបស់លោក ខាំផាន់ វិឡាចិត បានទទួលមរណភាពក៏ពិតមែន ប៉ុន្តែនៅមានប្រជាជនកម្ពុជា មន្ត្រីរាជការ និងប្រជាពលរដ្ឋមួយចំនួនធ្លាប់ស្គាល់ជិតដិត រាក់ទាក់ស្និទ្ធស្នាល ក្នុងពេលដែលលោកបំពេញបេសកកម្មការទូតនៅកម្ពុជា ។

នៅពេលថ្មីៗនេះ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្របានឆ្លុះបញ្ចាំងយ៉ាងច្បាស់ ក្នុងពិធីផឹកទឹកសម្បថសច្ចាប្រណិធានរបស់ចៅក្រមជាតិ អន្តរជាតិ និងសហចៅក្រមនៅមុខព្រះភក្ត្រព្រះបាទ សម្តេចព្រះនរោត្តម អតីតព្រះមហាក្សត្រកម្ពុជានៅព្រះបរមរាជវាំង កាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ កន្លងទៅនេះគឺ ៈ

ដើម្បីជាកិច្ចចាប់ផ្តើមដំណើរនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក៏ដូចជាការផ្តល់វិភាគទានដល់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិតែងតាំងចៅក្រមជាតិ អន្តរជាតិ និងបុគ្គលិកមានកម្រិតខ្ពស់ព្រមទាំងផ្តល់វិភាគទានផ្សេងៗទៀត ។

ដើម្បីចាប់ផ្តើមកាត់ទោសមេដឹកនាំខ្មែរក្រហម ក្រោយពេលបង្កើតអង្គជំនុំជម្រះវិសាមញ្ញ កាត់ក្តីតាមផ្លូវច្បាប់ និងមានលក្ខណៈប្រវត្តិសាស្ត្រគួរជាទីពេញចិត្ត នាពេលឆាប់ៗខាងមុខនេះគឺជាការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះដែលស្លាប់ និងអ្នកដែលរស់រានមានជីវិត អាចទទួលយកបាននូវភាពយុត្តិធម៌ និងសច្ចធម៌ថែមទៀតផង នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

ខ្ញុំបាទជាម្ចាស់អត្ថបទ សូមឧទ្ទិសនូវកម្រងអត្ថបទដែលសរសេររឿងពិតនិងជាបណ្តាំឯកសាររបស់លោកអគ្គរដ្ឋ ទូតឡាវ ខាំផាន់ វិឡាចិត មុនពេលលោកទទួលអនិច្ចកម្មក្នុងជន្មាយុ៧២ ឆ្នាំដោយរោគចាស់ជរា ក្នុងពលិកម្មដ៏ថ្លៃថ្លាសម្រាប់ប្រទេសជាតិមាតុភូមិនៃទឹកដីឡាងសាងនៃប្រទេសឡាវ ។ សូមឲ្យវិញ្ញាណក្ខន្ធរបស់លោកបានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

**ភូ គីមមឿ**

**អភិបាលរងស្រុកអូរជុំខេត្តរតនៈគិរី**

# លិខិតរបស់លោក ភូ គីមមឿ

លោក ឆាំង យុ និពន្ធនាយកទូទៅនៃទស្សនាវដ្តីមជ្ឈមណ្ឌលឯកសារស្វែងរកការពិត ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកនាយកដែលបានចុះផ្សាយអត្ថបទរបស់ខ្ញុំនៅក្នុងទំព័រ ទស្សនាវដ្តីនៃមជ្ឈមណ្ឌលស្វែងរកការពិតលេខ៧៨ ខែឧសភា ឆ្នាំ២០០៦ ។

ទន្ទឹមនឹងនេះ ឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជានិងលេខាទូតប្រចាំនៅកម្ពុជា និងលេខាទូតឡាវបានទូរស័ព្ទថ្លែងអំណរគុណខ្ញុំបាទដែលជាម្ចាស់អត្ថបទសរសេរបានល្អ ហើយបានសំណូមពរខ្ញុំសរសេរអត្ថបទបន្តទៀតនៅក្នុងរឿងរ៉ាវដែលឯកអគ្គរដ្ឋទូតឡាវប្រចាំនៅទីក្រុងភ្នំពេញ ដែលស្ថិតនៅក្នុងរបបខ្មែរក្រហមរហូតមុនថ្ងៃ៧មករា ឆ្នាំ១៩៧៩ ហើយកងទ័ពកម្ពុជានិងកងទ័ពវៀតណាមរកឃើញនៅអាគារស្ថានទូតនៅព្រឹកថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៩ ។

ដើម្បីតបស្នងគុណនិងសំណូមពររបស់ឯកអគ្គរដ្ឋទូតឡាវ ខ្ញុំបាទក៏ព្យាយាមសរសេររឿងពិតមួយនេះជូនមជ្ឈមណ្ឌលឯកសារស្វែងរកការពិត ។ សូមលោកនាយកជួយទំនាក់ទំនងស្ថានទូតឡាវដើម្បីយករូបភាពរបស់លោកអគ្គរដ្ឋទូតឡាវក្នុងសម័យនោះចុះក្នុងទំព័រអត្ថបទនេះផង រូបគាត់និងកម្មាភិបាលស្ថានទូតក៏ជាប់ជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមនេះដែរ ។

សូមលោកនាយកមេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពស់ខ្ពស់អំពីខ្ញុំ ។ **ភូ គីមមឿ**

# អ្នកដែលឃ្លាតឆ្ងាយ

ខ្ញុំនៅចាំបានថាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺជាព្រឹត្តិការណ៍មួយដ៏សាហាវដែលកងទ័ពអាវខ្មៅបង់ក្រមា ប្រដាប់ដោយអាវុធគ្រប់ធុន គ្រប់ដៃ វាយចូលទីក្រុងភ្នំពេញនិងបណ្តេញមនុស្សឲ្យចាកចេញចោលលំនៅដ្ឋាន ផ្ទះសម្បែង ទ្រព្យសម្បត្តិ ដើម្បីឲ្យទៅរស់នៅទីជនបទដាច់ស្រយាល ។

រយៈពេលជាង៣ឆ្នាំប្រជាជនទ្រាំរស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងវេទនា ដែលរួមទាំងខ្ញុំម្នាក់ដែរ ។ រៀងរាល់យប់ខ្ញុំតែងស្រមៃឃើញនូវសកម្មភាពទាំងឡាយ ដែលខ្ញុំនិងប្រជាពលរដ្ឋដទៃទៀត ហាក់ដូចជាកំពុងធ្វើពលកម្មនៅវាលស្រែ និងរែកដីនៅឡើយ ។ម្យ៉ាងទៀត ពេលខ្ញុំបានចំណីហូបឆ្ងាញ់ៗធ្វើឲ្យខ្ញុំនឹកឃើញដល់ពេលខ្ញុំហុតទឹកបបរជាមួយទឹកប្រហុក ឬអំបិល ។ ពេលឈឺគ្មានថ្នាំលេបពេលស្លាប់បានត្រឹមតែរុំនឹងកន្ទេលរហែកសែងប្រដឹសសបុស្សរីយកទៅកប់ក្នុងព្រៃប៉ុណ្ណោះ ។

នាងខ្ញុំឈ្មោះ ឈិត ធារី ហៅ ពុធ ធារី សព្វថ្ងៃនេះខ្ញុំមានអាយុ៤០ឆ្នាំហើយ ។ ខ្ញុំមានបងប្អូន៥នាក់ ។ មុនឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅទីក្រុងភ្នំពេញនិងរៀននៅសាលាវត្តកោះ ។

មុនឆ្នាំ១៩៧០ ប៉ាខ្ញុំជាមន្ត្រីរាជវាំង ម្តាយខ្ញុំជាជាងកាត់ដេរនិងជាអ្នកម៉ៅការដេរសម្លៀកបំពាក់ឲ្យមន្ត្រីនៅក្នុងវាំង ។ ក្រោយរដ្ឋប្រហារថ្ងៃ១៨មីនាឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំបានផ្លាស់ប្តូរទីលំនៅពីខាងលិចវិមានឯករាជ្យមករស់នៅក្រោយមន្ទីរពេទ្យមុនីវង្សវិញ គឺនៅខាងត្បូងបន្ទាយរបស់ទ័ពអាកាស ។ ពេលនោះប៉ាខ្ញុំក៏បានប្តូរការងារពីមន្ត្រីវាំងមកធ្វើការនៅក្នុងក្រសួងយុត្តិធម៌វិញ ។ ប៉ាខ្ញុំឈ្មោះ ឈិត ចាន់ណារិទ្ធី (ហៅញ៉ុក) ម្តាយខ្ញុំ ឈ្មោះ អ៊ុយ សុខុម ។ កងទ័ព ឈុតខ្មៅបានជម្លៀសក្រុមគ្រួសារខ្ញុំឲ្យចាកចេញពីភ្នំពេញឲ្យទៅរស់នៅភូមិមួយឆ្ងាយដាច់ស្រយាលជាប់ព្រំដែនវៀតណាម ភូមិនោះឈ្មោះភូមិអន្ទាំ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម ។ ពេលទៅដល់ស្រុកនោះអ្វីៗក្នុងជីវិតខ្ញុំបានផ្លាស់ប្តូរទាំងអស់ ដៃរបស់ខ្ញុំធ្លាប់តែកាន់ប៊ិចសរសេរអក្សរ ឥឡូវបែរជា កាន់ចប បង្គី ដើរកើបអាចម៍គោទៅវិញ ។



ឈិត ចាន់ណារិទ្ធី ក្នុងឆ្នាំ១៩៦៧
(ឪពុករបស់ ពុធ ធារី)

ដំបូងខ្ញុំខ្លើមរអើមខ្លាំងណាស់ ខ្ញុំត្រូវប្រធានកងកុមារវាយខ្ញុំមួយបន្ទះឫស្សី យ៉ាងដំណំបណ្តាលឲ្យខ្ញុំធ្លាក់ខ្លួនឈឺអស់រយៈពេល៣ថ្ងៃ ។ កាលណោះប្រសិនបើនរណាម្នាក់ឈឺយូរថ្ងៃនឹងមានបញ្ហា ហើយមេកងនឹងហៅទៅប្រជុំរកមូលហេតុដែលឈឺ ។ ព្រលឹងស្រាងៗឡើង សំឡេងជួងក្នុងភូមិបានបន្លឺឡើងដើម្បីដាស់មនុស្សម្នាឲ្យក្រោកទៅធ្វើពលកម្មមុនពេលចេញទៅស្រែចម្ការ ពួកយើងត្រូវឈរតម្រង់ជាជួរដើម្បីច្រៀងបទគោរពទង់បក្សមួយចប់ ដែលមានចំណងជើងថា«ឈាមក្រហមច្រាល» បន្ទាប់មកមេកងសន្តិសុខហៅឈ្មោះម្តងម្នាក់ៗដើម្បីរាប់ចំនួនបើបាត់អ្នកណាម្នាក់ មេកងនឹងទៅតាមរកមើលដល់ផ្ទះឬក៏ថា«ទុកមិនចំណេញ ដកចេញមិនខាត» ដោយនាំអ្នកនោះចូលព្រៃហើយសម្លាប់ចោលតែម្តង ។ ពួកយើងគាស់គល់ឈើរានដីធ្វើស្រែចម្ការទាំងក្នុងពោះគ្មានអាហារមួយគ្រាប់ពេលស្រេកទឹកយើងត្រូវរត់ទៅរកទឹកថ្លុក-ត្រពាំងដោយខ្លួនឯង ។ ពេលសម្រាកថ្ងៃត្រង់មេកង បានចែករបបបបររាវកក្លុកឲ្យហូប ពួកយើងក៏បានបេះបន្លែស្លឹកឈើយកមកហូបជាមួយដើម្បីឲ្យឆ្អែត ។ សម្រាកហូបបបរថ្ងៃត្រង់រួច យើងត្រូវចុះទៅធ្វើការបន្តទៀត រហូតដល់ម៉ោង៨-៩យប់ទើបបានសម្រាក ។

ពេលយប់ពួកយើងមិនហ៊ាននិយាយរកគ្នាទេព្រោះកងឈ្លបដើរយកការណ៍តាមផ្ទះរាល់យប់ ប្រសិនបើយើងនិយាយអ្វីឲ្យប៉ះពាល់ដល់អង្គការនោះ ព្រឹកឡើងមុខតែត្រូវកងឈ្លបហៅទៅរៀនសូត្រហើយៗ បើហៅទៅហើយគ្មានថ្ងៃវិលត្រឡប់មកជួបជុំ

គ្រួសារកូនចៅវិញទេ ដូចជាប៉ារបស់ខ្ញុំអ៊ីចឹង ។

នៅថ្ងៃដែលមេកងឈ្មោះ ផាន មកហៅប៉ារបស់ខ្ញុំទៅរៀនសូត្រ ម្តាយខ្ញុំស្លុតចិត្តយ៉ាងខ្លាំង គាត់យំអង្វរមិត្ត ផាន ប៉ុន្តែមិត្ត ផាន ប្រាប់ម្តាយខ្ញុំថា "សូមមិត្តបងកុំព្រួយអី ខំធ្វើការនៅក្នុងភូមិឲ្យបានល្អទៅ" ។ ប៉ាខ្ញុំត្រូវអង្គការយកទៅរៀនសូត្ររហូតបាត់ខ្លួនដល់សព្វថ្ងៃ ។

នៅឆ្នាំ១៩៧៧ ម្តាយខ្ញុំបានទទួលដំណឹងពីការដ្ឋានលើកទំនប់ថា បងប្រុសខ្ញុំដែលរែកដីនៅទំនប់ (ថ្នុកជ្រៅ) និងមិត្តភក្តិរបស់គាត់៧នាក់ទៀត ត្រូវសន្តិសុខចងបណ្តើរទាំងខ្សែយកទៅ ដោយចោទថានិយាយស្តីនៅប្រកាន់របបសក្តិភូមិ-នាយទុន ។ ចាប់ពីពេលនោះមក បងខ្ញុំក៏បាត់ខ្លួនដូចជាប៉ាខ្ញុំអ៊ីចឹងដែរ ពួកយើងលែងបានជួបមុខគ្នាជារៀងរហូត ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ ពេលវៀតណាមវាយប្រយុទ្ធតាមព្រំដែន ពេលនោះក៏មានការជម្លៀសប្រជាជនម្តងទៀត ប្រជាជនចាស់ថ្មីដែលត្រូវរត់ចេញពីភូមិចូលព្រៃ ខ្លះត្រូវស្លាប់ដោយគ្រាប់បែកដែលយន្តហោះវៀតណាមទម្លាក់ ។ គ្រាប់ផ្លោងបានធ្លាក់ក្បែរខ្លួនខ្ញុំ មនុស្សជាច្រើននាក់បានស្លាប់ ឯរូបខ្ញុំត្រូវអម្បែងបៀមនៅជើង ខ្ញុំត្រូវបានពេទ្យយោធាម្នាក់ជួយឆ្កឹះអម្បែងគ្រាប់និងព្យាបាលនៅក្នុងព្រៃ ។

ក្រោយថ្ងៃជ័យជម្នះ ៧មករា ១៩៧៩ ខ្ញុំបានជួបម្តាយខ្ញុំតាមផ្លូវ ពួកយើងក៏នាំគ្នាដើរត្រឡប់មកភ្នំពេញវិញដល់អរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ។

មកដល់ស្រុកកំណើត ម្តាយខ្ញុំក៏ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ នៅឆ្នាំ១៩៨៥ម្តាយខ្ញុំក៏ទទួលមរណភាពទៅដោយពាំនាំនូវភាពហ្មងសៅរាប់មិនអស់ទៅជាមួយបន្សល់ទុកឲ្យពួកខ្ញុំនៅកំព្រាអនាថា ។

ការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលជាង៣ឆ្នាំបានបន្សល់ទុកនូវអនុស្សាវរីយ៍ដ៏ជូរចត់ចំពោះខ្ញុំ ។ របបនេះបានធ្វើឲ្យពលរដ្ឋទាំងអស់ជួបនូវការនិរាសព្រាត់ប្រាសប្រទេសជាតិរងនូវវិនាសកម្មដ៏ធ្ងន់ធ្ងរ បន្សល់នូវក្មេងកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងវិបត្តិផ្លូវចិត្តឲ្យពលរដ្ឋខ្មែរទាំងអស់ ។

សរុបមក របបនេះបានរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ។ រូបខ្ញុំដែលជាជនរងគ្រោះម្នាក់នឹងចូលរួមស្រាយបំភ្លឺនៅក្នុងសវនាការកាត់ទោសខ្មែរក្រហមអំពីព្រឹត្តិការណ៍ទាំងឡាយដែលខ្ញុំបានឃើញនិងជួបប្រទះប្រសិនបើតុលាការត្រូវការរូបខ្ញុំ ។ អ្វីៗដែលដក់ជាប់ក្នុងអារម្មណ៍ និងមិនអាចបំភ្លេចបាននោះគឺភាពរន្ធត់ពិសេសជាងនេះគឺ"អ្នកដែលឃាតឆ្ងាយ"ពីខ្ញុំ ។

លិខិតនេះ នាងខ្ញុំសូមផ្ញើជូនមជ្ឈមណ្ឌលឯកសារកម្ពុជា សូមលោកនាយកមជ្ឈមណ្ឌលមេត្តាជួយចុះផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិតឲ្យនាងខ្ញុំផង ព្រោះនេះគឺជីវប្រវត្តពិតរបស់នាងខ្ញុំហើយក៏ជាឆន្ទៈរបស់នាងខ្ញុំក្នុងការចូលរួមចំណែកស្វែងរកការពិត ។

បច្ចុប្បន្ន នាងខ្ញុំមានទីលំនៅនៅភូមិស្លាបតាអោន ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**ពុធ ធាវី**

# ពាក្យស្លោកខ្មែរក្រហម

- **ផ្នែកឱ្យរឹងមាំលើវណ្ណៈអធន សាមគ្គីយ៉ាងជិតស្និទ្ធជាមួយកម្លាំងប្រជាជាតិធាំងមូល មកខាងបដិវត្តន៍ឯកោ ខ្មាំងសត្រូវមួយក្តាប់តូចជាអតិបរមា!**
- **ក្តាប់ជាប់ និងអនុវត្តឱ្យល្អ ផែនការបង្កើនចំនួនប្រជាជននឹងឱ្យបានច្រើនជាអតិបរមាពី១៥-២០លាននាក់ក្នុង ១០-១៥ឆ្នាំខាងមុខនេះ។** *(សៀវភៅកំណត់ហេតុលេខ០៧៦)*

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: dccam@online.com.kh

Home page: www.dccam.org

# ដំណឹងស្វែងរកបងស្រី និងបងថ្លៃ



អ៊ុន ណារ៉េត

នាងខ្ញុំឈ្មោះ អ៊ុន ណារ៉េត អាយុ៤៥ រស់នៅភូមិរទាំង ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ សូមស្វែងរកបងស្រីឈ្មោះ អ៊ុន យ៉ន និងប្តីរបស់គាត់ឈ្មោះ សូ សឿង ។ នៅឆ្នាំ១៩៧៣ អ៊ុន យ៉ន ប្តី និងកូនទាំងពីររបស់គាត់ឈ្មោះ ធីតា ហៅតុប(ស្រី) និងឈ្មោះ ម៉ាប់(ប្រុស) រស់នៅខេត្តកំពង់ស្ពឺ ។ សូ សឿង ជាទាហានច័ន្ទរង្សីក្នុងខេត្តកំពង់ស្ពឺ ។ អ៊ុន យ៉ន មានរូបរាងទាបទ្រនាប់ ខ្មៅស្រអែម ហើយមេដៃទាំងពីររបស់គាត់ខ្វីដែលកាលណោះគាត់អាយុប្រហែល៤០ឆ្នាំ ។ ចំណែក សូ សឿង រូបរាងខ្ពស់សម្បុរជ្រះ ។ គ្រួសារនេះបានបាត់ខ្លួនចាប់ពីឆ្នាំ១៩៧៣រហូតមកដល់សព្វថ្ងៃ ។

បើបងប្អូនបានស្គាល់ឈ្មោះនិងភិនភាគខាងលើនេះ សូមជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខៈ ០១១ ៦២៧ ៣៣៧ ។ សូមអរគុណ ។

# ដំណឹងស្វែងរកបងប្រុស ភុង សុរិន

ខ្ញុំបាទឈ្មោះ ភុង សុខនឿន អាយុ២៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រឡា ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ស៊ីង ភុង ម្តាយឈ្មោះ ជុំ សៀក ។ ខ្ញុំបាទមានបងប្អូនទាំងអស់បីនាក់ ប្រុសទាំងបី ៖

១) ភុង សុខណា, ២) ភុង សុរិន, ៣) ភុង សុខនឿន ។

ខ្ញុំបាទបានបែកបងប្រុសទី២ឈ្មោះ ភុង សុរិន នៅពេលដែលគាត់ត្រូវបានជម្លៀសទៅភូមិអន្លួញដី ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដែលនៅពេលនោះកងទ័ពខ្មែរក្រហមបានកៀរយកបងប្រុសទៅមិនដឹងទៅដល់ទីណា ។ មកទល់សព្វថ្ងៃបងប្រុសមានអាយុប្រហែល៣២ឆ្នាំ ។

ប្រសិនបើ បងប្រុសបានឃើញសេចក្តីប្រកាសនេះសូមមករកប្អូននៅស្រុកកំណើត ឬបងប្អូនបានស្គាល់ឈ្មោះនេះសូមផ្តល់ដំណឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# ដំណឹងស្វែងរកក្រុមគ្រួសារ

ខ្ញុំបាទឈ្មោះ ជា វណ្ណៈ ជាគ្រូបង្រៀននៅសាលាបឋមសិក្សារមូល ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ សព្វថ្ងៃខ្ញុំបាទរស់នៅភូមិអំពិល ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ជាទីលំនៅដែលឪពុកខ្ញុំបានទិញកាលពីឆ្នាំ១៩៧០ ។ សូមស្វែងរកឪពុកម្តាយ និងបងប្អូន៧នាក់ទៀតដែលមានឈ្មោះដូចខាងក្រោមនេះ ៖

១) ឪពុកឈ្មោះ ឡាយ យូ អាយុប្រហែល៧៤ឆ្នាំ, ២) ម្តាយឈ្មោះ ឡាយ ជី, ៣) ឡាយ យូវ៉ាន់ឌី, ៤) ឡាយ សុរិប្រាសិទ្ធិ, ៥) ឡាយ មុន្នីធីរិទ្ធិ, ៦) ឡាយ សុគន្ធា, ៧) ឡាយ សុជាតា, ៨) ឡាយ សុភាព ។

មុនឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំបាទរស់នៅទីក្រុងភ្នំពេញ ។ ឪពុកជាអតីតទាហានជំនាន់បារាំង ទាហានរបបសម្តេច និងទាហានលន់ នល់ ។ នៅពេលបែកឆ្នាំ១៩៧៥ ឪពុកម្តាយនិងបងប្អូនទាំង៧នាក់របស់ខ្ញុំជម្លៀសទៅខេត្តតាកែវដោយមានបំណងត្រឡប់ទៅស្រុកកំណើតនៅកម្ពុជាក្រោមវិញ ។ តាំងពីពេលនោះមកបាត់ដំណឹងមិនដឹងថាអ្នកទាំងអស់នៅរស់ឬស្លាប់ឡើយ ។ ហេតុដូច្នេះ បើបងប្អូនណា ស្គាល់ឈ្មោះខាងលើ សូមមេត្តាជួយផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ចូលរួមឃ្លាំមើលដំណើរការកាត់ទោស
# មេដឹកនាំខ្មែរក្រហម

## ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើទស្សនកិច្ចនៅវាលពិឃាតបឹងជើងឯក



អគាររដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ



មេឃុំធ្វើទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា



មេឃុំក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ



ជនរងគ្រោះក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ

- ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ចាប់ដំណើរការនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦។
- ដំណើរការទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ជារៀងរាល់ថ្ងៃអង្គារ៍ក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ នៅក្នុងឆ្នាំ២០០៦។ មកទល់នឹងខែតុលានេះ មានប្រជាជន៥០០០នាក់រួចមកហើយដែលបានចូលរួម។
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាករកម្ពុជាមានទីតាំងនៅតាមផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ទំនាក់ទំនងជាមួយមន្ត្រីផ្នែកកិច្ចការសាធារណៈ ទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ ព័ត៌មានបន្ថែមសូមមើលគេហទំព័រ www.cambodia.gov.kh/krt ឬ www.eccc.gov.kh។
- មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ វិថីព្រះសីហនុ (ខាងកើតវិមានឯករាជ្យ) ប្រអប់សំបុត្រ១១១០ ទំនាក់ទំនងជាមួយលោក វ៉ាន់ថាន់ ពៅដារ៉ា ទូរស័ព្ទលេខ ០១២ ៨៤៦ ៥២៦ ព័ត៌មានបន្ថែម សូមមើលគេហទំព័រ www.dccam.org។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 81, September 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.